

ឯកសារគម្ពីព្រះត្រៃបិដកស្កាននេះ
ត្រូវបានថតចេញពី ច្បាប់គម្ពីរព្រះត្រៃបិដកជប៉ុន ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះ ចាប់ពីភាគ៥១ ដល់ ភាគ១១០
ត្រូវបានរៀបចំធ្វើឡើងដោយ គេហទំព័រ៥000ឆ្នាំ បូជា
ចំពោះព្រះពុទ្ធសាសនា សម្រាប់ជាធម្មទាន ។

ផ្តល់សៀវភៅគម្ពីរព្រះត្រៃបិដកសម្រាប់ការងារ
ដោយ ឧបាសិកា កាំង ហ្គិចណៃ ។

គ្រប់គ្រងគម្រោង (ទូទៅ និងផ្នែកបច្ចេកទេស)
ដោយ ឧបាសក ស្រុង-ចាន់ណា ។

ត្រួតពិនិត្យឡើងវិញ
ដោយ ចន-ស្រីស្រស់ ។

ថតស្កានដោយ
ប្អូនប្រុស ម៉ាន់ សាវ៉េត

www.5000-years.org

ក្រោមការឧបត្ថម្ភយ៉ាងច្រើនលើសលុបពីៈ

- ឧបាសិកា កាំង ហ៊ុចណៃ (ភ្នំពេញ)
- ឧបាសក ជុត លីស្រុង និង ឧបាសិកា លី សុខា ព្រមទាំងបុត្រ (ភ្នំពេញ)
- ឧបាសក សរ ចន និង ឧបាសិកា អ៊ូច សាវឿង ព្រមទាំងបុត្រ (បាត់ដំបង)
- ឧបាសក ជា ស៊ុវត្ថានា និងឧបាសិកា ឃុន សូនីម៉ា ព្រមទាំងបុត្រី ជា សុមេធាធីតា (ស.រ.អ)
- លោក ជឹម-ជា និងលោកស្រី រតនី ស្រីមុំ (ភ្នំពេញ)
- ឧបាសក ផេង យឿន (កូរ៉េ)
- លោក ស៊ុក ចាន់សេរី (បន្ទាយមានជ័យ)
- ឧបាសិកា យ៉ា វ៉ារី (បន្ទាយមានជ័យ)
- ប្អូនស្រី យ៉ា សុភ: (បន្ទាយមានជ័យ)
- ឧបាសិកា កោ សេង (ភ្នំពេញ)
- លោកស្រី ប៉ាន សុគន្ធានីន និងស្វាមី ព្រមទាំងបុត្រ (ភ្នំពេញ)
- ឧបាសក ស្រុង ចាន់ណា និង ឧបាសិកា ចន ស្រីស្រស់
ព្រមទាំងបុត្រ ចាន់ណា សុធារនីរាជ, ចាន់ណា សុធារនិរោធ (ភ្នំពេញ)
- លោកស្រី ស្រុង ចាន់រស្មី និង ស្វាមី ព្រមទាំងបុត្រ (ភ្នំពេញ)
- កញ្ញា ស្រុង ចាន់រតនា (ភ្នំពេញ)
- លោក ស្រុង យូហេង (ភ្នំពេញ)
- លោក នង សុផល (កូរ៉េ)
- ប្អូនស្រី សុខ អេង (កំពង់ចាម)
- កញ្ញា ចន កក្កដា (បាត់ដំបង)
- លោកស្រី ចន សត្យា និងលោក ទួត សេរីស័ក ព្រមទាំងបុត្រ (ភ្នំពេញ)
- លោក ចន រចនា (បាត់ដំបង)
- កញ្ញា ស៊ែ សុផារី (បាត់ដំបង)
- កញ្ញា យឿម សុផានី (បាត់ដំបង)
- លោក ម៉ៅ គន្ធា និងលោកស្រី ធៀង សេដ្ឋា (បាត់ដំបង)
- លោក សៅ សារ៉ុម (បាត់ដំបង)
- ព្រះតេជព្រះគុណ ជុំ សារ: (ព្រះចៅអធិការវត្ត សម សាន្ត ខេត្តបាត់ដំបង)
- ឧបាសិកា វ៉ាន់ លុយ និងស្វាមី ព្រមទាំងបុត្រ (ភ្នំពេញ)
- លោកស្រី ហួ ច័ន្ទសុវណ្ណ និងស្វាមី ព្រមទាំងបុត្រ (ស.រ.អ)

# ព្រះ
# ត្រៃបិដកបាលី
## និង
# សេចក្ដីប្រែជាភាសាខ្មែរ
# អភិធម្មបិដក
# ធម្មសង្គណី ទុតិយភាគ
# ៧៩

បោះពុម្ពលើកទី ១

ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

ព.ស. ២៥០៧

## ឧទ្ទិសកថា

យើងខ្ញុំ សូមផ្តល់ស្នារតីសូត្រព្រះធម៌ឧទ្ទិសជូនជនជាតិខ្មែរ ។

ឥឡូវ យើងខ្ញុំអាចជូនគម្ពីរព្រះត្រៃបិដកនេះ ទៅអ្នកកាន់ព្រះពុទ្ធសាសនាជនជាតិខ្មែរបានហើយ ។

ព្រះធម៌នៃព្រះពុទ្ធជាម្ចាស់នេះ ត្រូវបានសូត្រចេញពីជម្រៅដួងចិត្តនៃអ្នកកាន់ព្រះពុទ្ធសាសនាជនជាតិជប៉ុន ។

このカンボジア版南伝大蔵経を
カンボジアの佛教徒へ
贈ることができることに感謝します。
これが日本の佛教徒の心です。

It is with a deep sense of gratitude that I present the translation of the complete TRIPITAKA to Cambodian Buddhists on behalf of the Japanese Buddhist community.

# អារម្ភកថា

ជូនចំពោះជនជាតិខ្មែរ ជាទីរាប់អាន !

ជូនចំពោះជនជាតិខ្មែរដែលកាន់ព្រះពុទ្ធសាសនា ជាទីគោរព !

គម្ពីរព្រះត្រៃបិដកខ្មែរនេះ ត្រូវបាន " ក្រុមជំនុំព្រះត្រៃបិដក " នៃពុទ្ធសាសនបណ្ឌិត្យនៅភ្នំពេញ បកប្រែពីភាសាបាលីមកជាភាសាខ្មែរ តាំងពីឆ្នាំ ១៩៣០ ទៅឆ្នាំ ១៩៦៨ គឺត្រូវចំណាយពេល ៣៩ ឆ្នាំ ទើបបានសម្រេចហើយសព្វគ្រប់ ។ នេះពិតជាកំណាប់ព្រះធម៌របស់ព្រះពុទ្ធសាសនាខ្មែរ ហើយក៏ជាកំណាប់វប្បធម៌ខាងផ្នែកបោះពុម្ពរបស់ជនជាតិខ្មែរផងដែរ ។ យើងខ្ញុំ ពុទ្ធសាសនិកជាតិជប៉ុន មានសន្តានចិត្តរីករាយនឹងបោះពុម្ពជាថ្មីឡើងវិញ ដោយសង្ឃឹមថា ព្រះពុទ្ធសាសនាខ្មែរក៏នឹងរុងរឿងឡើងវិញដែរ ។

នេះគឺជាអំណោយពីជម្រៅដួងចិត្ត ជូនទៅដល់ជនជាតិខ្មែរទាំងអស់ ព្រមទាំងមនុស្សជាតិទូទៅ នៅក្នុងពិភពលោកនេះ ដែលមានចិត្តស្រឡាញ់សន្តិភាព ។

ខ្មែរបានរងសោកនាដកម្មដែលមិនធ្លាប់មានពីមុនមក ។ ម្យ៉ាងទៀត ព្រះពុទ្ធសាសនាខ្មែរ ក៏ត្រូវអន្តរាយយ៉ាងខ្លាំង ក៏ប៉ុន្តែឥឡូវនេះ យើងទាំងអស់គ្នា បានឈានជើងកន្លងផុតពីសេចក្តីទុក្ខសោកដ៏ធ្ងន់ធ្ងរនេះ ចាកផុតពីអំពើឃោរឃៅ បញ្ចប់គំនុំគុំគួន ដើរតាមពុទ្ធដីកាព្រះបរមគ្រូខិតខំព្យាយាមធ្វើឱ្យមានសន្តិភាពក្នុងពិភពលោក ។

ការណ៍ដែលយើងខ្ញុំជូនគម្ពីរព្រះត្រៃបិដកពេលនេះ គឺជានិមិត្តរូបនៃការប្តេជ្ញាចិត្តរបស់អ្នកកាន់ព្រះពុទ្ធសាសនាជនជាតិជប៉ុនថា យើងខ្ញុំធ្វើសហប្រតិបត្តិការដើម្បីសន្តិភាពក្នុងពិភពលោក ដើម្បីទុកជាភស្តុតាងនៃចំណងមេត្រីភាព និងមិត្តភាពរវាងប្រជាជាតិជប៉ុន និងប្រជាជាតិខ្មែរ ។

ថ្ងៃនក្ខត្តឫក្ស កក្កដា ឆ្នាំ ១៩៩៤

សមាគមជំនួយដល់ការបោះពុម្ពព្រះត្រៃបិដកឡើងវិញ

**អ្នកតំណាងចាត់ការ** The Rev. Seikyo Muchaku

**ប្រធានការិយាល័យ** The Rev. Eiitsu Shinohara

**អ្នកចាត់ការ**

The Rev. Zendo Matsunaga The Rev. Jitsujo Arima The Rev. Yoshimichi Ito
The Rev. Keiichi Watai The Rev. Gijun Sugitani The Rev. Shincho Shigeta
The Rev. Risho Maeda The Rev. Kyoshi Nakajima Mr. Rokusuke Ei

# 『トリピタカ』復刻進呈にあたって

親愛なるカンボジアの皆さん！
敬愛するカンボジアの仏教徒の皆さん！

カンボジア版『トリピタカ』は、プノンペンの仏教研究所が、仏教界の英知を集め、1930年から1968年まで、39年の歳月をかけて翻訳し、分類し、集大成して完成されました。まさにカンボジア仏教の法宝であると共に、カンボジア出版文化の至宝です。日本仏教徒の有志は、カンボジア仏教の復興再生を願いつつ、これを復刻刊行し、贈らせていただきます。

これはカンボジア仏教徒のみならず、カンボジア全人民、否、平和を愛する地球上のすべての人々への、心からの贈り物です。

カンボジアは、古今未曾有の悲劇を体験しました。カンボジア仏教もこの受難の時代に壊滅的な打撃を受けました。しかし、今はその悲しみを乗りこえ、瞋りを離れ、怨みを恕し、ブッダの教えに従い、世界平和の実現に努力するときです。

この本の贈呈は、日本の仏教徒も共々に、世界平和のために努力することを誓うしるしであり、相互の連帯と友情の証なのです。

合掌

1994年７月吉日

カンボジア版トリピタカ（南伝大蔵経）復刻救援委員会

世話人代表　無着　成恭
事務局長　篠原　鋭一

世話人　松永　然道　有馬　実成
伊藤　佳通　渡井　奎一
杉谷　義純　茂田　真澄
前田　利勝　中島　教之
永　六輔

# Acknowledgment

Dear Cambodian friends and respected members of the Cambodian Buddhist community,

It is a matter of great joy that the translation into Cambodian of the Pali Tripitaka has been completed and published. The Tripitaka Commisson of the Buddhist Institute, Phnom Penh, launched the translation project in 1930 and completed the translation, after 39 years of effort, in 1968.

The Cambodian translation of this great work will not only become a cherished treasure of the Cambodian Buddhist community but will also be an important milestone in the history of publication in Cambodia.

The revival and prosperity of Buddhism in Cambodia are the ardent wish of the Japanese Buddhist community, it is in this spirit that we have completed this important project and now present the entire work to the Cambodian Buddhist community, it is a gift not only to the Buddhist community in Cambodia but also to all Cambodian people and all peace-loving people in the world.

Cambodia experienced great tragedies in modern times, and the Cambodian Buddhist community also underwent severe trials and suffered crushing blows during this period. But now a time has come to surmount grief and anger, to forgive, and to start working again for world peace.

This great work is a symbol of the Japanese Buddhist community's resolve to work with our Cambodian brothers and sisters toward world peace and is a testimony to the friendship between our people.

With hands joined in reverence.
July 1994

**TRIPITAKA PUBLISHING SUPPORT COMMITTEE**
Project Manager : The Rev. Seikyo Muchaku
Secretary General : The Rev. Eiitsu Shinohara
Management Team :
The Rev. Zendo Matsunaga  The Rev. Jitsujo Arima  The Rev. Yoshimichi Ito
The Rev. Keiichi Watai  The Rev. Gijun Sugitani  The Rev. Shincho Shigeta
The Rev. Risho Maeda  The Rev. Kyoshi Nakajima  Mr. Rokusuke Ei

# អភិធម្មបិដក

## ធម្មសង្គណី ទុតិយភាគ

៧៩

ព.ស. ២៥០៧

# អភិធម្មបិដកេ

## ធម្មសង្គណិ ទុតិយភាគោ

(១) កតមេ ធម្មា អព្យាកតា ។ កុសលា-កុសលានំ ធម្មានំ វិបាកា កាមាវចរា រូបាវចរា អរូបាវចរា អបរិយាបន្នា វេទនាក្ខន្ធោ សញ្ញាក្ខន្ធោ សង្ខារក្ខន្ធោ វិញ្ញាណក្ខន្ធោ យេ ច ធម្មា កិរិយា នេវ កុសលា នាកុសលា ន ច កម្មវិបាកា សព្វំ ច រូបំ អសង្ខតា ច ធាតុ ឥមេ ធម្មា អ-ព្យាកតា ។

(២) តត្ថ កតមំ សព្វំ រូបំ ។ ចត្តារោ ច មហាភូតា ចតុន្នំ ច មហាភូតានំ ឧបាទាយ រូបំ ឥទំ វុច្ចតិ សព្វំ រូបំ ។

(៣) សព្វំ រូបំ ន ហេតុ អហេតុកំ ហេតុវិប្ប-យុត្តំ សប្បច្ចយំ សង្ខតំ រូបំ លោកិយំ សាសវំ សញ្ញោជនិយំ(១) គន្ថនិយំ ឱឃនិយំ យោគនិយំ

១ ឱ. ម. សំយោជនិយំ ។

# អភិធម្មបិដក

## ធម្មសង្គណិ ទុតិយភាគ

(១) ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ វិបាកនៃពួកធម៌ជាកុសលនិងអកុសល ជាកាមាវចរ រូបាវចរ អរូបាវចរ ជាអបរិយាបន្ន: (មិនរាប់ចូលក្នុងភូមិវដ្ត:ទាំង៣) វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ ទាំងពួកធម៌ដែលជាកិរិយា មិនមែនជាកុសល មិនមែនជាអកុសលក្តី មិនមែនជាកម្មវិបាកក្តី រូបទាំងអស់ក្តី ធាតុដែលបច្ច័យមិនបានប្រជុំតាក់តែង (ព្រះនិព្វាន) ក្តី នេះពួកធម៌ជាអព្យាក្រឹត ។

(២) បណ្តាធម៌ទាំងនោះ រូបទាំងអស់ តើដូចម្តេច ។ មហាភូតរូប ៤ និងរូបដែលអាស្រ័យមហាភូតរូបទាំង ៤ នេះហៅថា រូបទាំងអស់ ។

(៣) រូបទាំងអស់ មិនមែនជាហេតុ ឥតហេតុ ប្រាសចាកហេតុ ប្រកបដោយបច្ច័យ រូបដែលបច្ច័យតាក់តែង ជាលោកិយ ប្រកបដោយអាសវ: ជាប្រយោជន៍ដល់សញ្ញោជន: ដែលគន្ថ:គប្បីដោតក្រង ដែលឱឃ:គប្បីប្រព្រឹត្តកន្លង ដែលយោគ:គប្បីប្រព្រឹត្តកន្លង

នីវរណិយំ បរាមដ្ឋំ ឧបាទានិយំ សង្កិលេសិកំ អព្យាកតំ អនារម្មណំ អចេតសិកំ ចិត្តវិប្បយុត្តំ នេវវិបាកនវិបាកធម្មធម្មំ អសង្កិលិដ្ឋសង្កិលេសិកំ នសវិតក្កសវិចារំ នអវិតក្កវិចារមត្តំ អវិតក្កអវិចារំ នបីតិសហគតំ នសុខសហគតំ នឧបេក្ខាសហគតំ នេវទស្សនេន នភាវនាយ បហាតព្វំ នេវទស្សនេន នភាវនាយ បហាតព្វហេតុកំ នេវាចយគាមិនអបចយគាមិ នេវសេក្ខនាសេក្ខំ បរិត្តំ កាមាវចរំ នរូបាវចរំ នអរូបាវចរំ បរិយាបន្នំ នោ(១)អបរិយាបន្នំ អនិយតំ អនិយ្យានិកំ ឧប្បន្នំ ឆហិ វិញ្ញាណេហិ វិញ្ញេយ្យំ អនិច្ចំ ជរាភិភូតំ ឯវំ ឯកវិធេន រូបសង្គហោ ។

ឯកកំ ។

---

១ ឱ. ន ។

ជាប្រយោជន៍ដល់នីវរណៈ ដែលបរាមាសៈស្ទាបអង្អែល ជាប្រយោជន៍ដល់ឧបាទាន គួរដល់សេចក្ដីសៅហ្មង ជាអព្យាក្រឹត មិនមានអារម្មណ៍ មិនមែនជាចេតសិក ប្រាសចាកចិត្ត ជាសភាវៈមិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ជារូបមិនសៅហ្មង តែគួរដល់សេចក្ដីសៅហ្មង មិនមែនប្រកបដោយវិតក្កៈ ប្រកបដោយវិចារៈទេ មិនមែនមិនមានវិតក្កៈ ហើយមានត្រឹមតែវិចារៈទេ ជារូបមិនមានវិតក្កៈ មិនមានវិចារៈ មិនប្រកបដោយបីតិ មិនប្រកបដោយសុខៈ មិនប្រកបដោយឧបេក្ខា ជារូបមិនត្រូវលះដោយទស្សនៈ ទាំងមិនត្រូវលះដោយភាវនា ជារូបមានហេតុមិនត្រូវលះដោយទស្សនៈ ទាំងមិនត្រូវលះដោយភាវនា ជារូបមិនមែនជាដល់នូវការសន្សំកពូនឡើង មិនមែនជាមិនដល់នូវការសន្សំកពូនឡើង មិនមែនជាសេក្ខៈ មិនមែនជាអសេក្ខៈ មានសភាពតូចឆ្មារ ជាកាមាវចរ មិនមែនជារូបាវចរ មិនមែនជាអរូបាវចរ រាប់ចូលក្នុងវដ្ដៈ មិនមែនជាមិនរាប់ចូលក្នុងវដ្ដៈ ជាអនិយតៈ មិនមែនជានិយ្យានិកៈ ជាឧប្បន្នរូប ជារូបត្រូវដឹងដោយវិញ្ញាណ ៦ ជារូបមិនទៀងដែលជរាគ្របសង្កត់ ការសង្គ្រោះរូបដោយចំណែក ១ យ៉ាងនេះ ។

ចប់ ធម៌មានប្រមាណមួយ ។

## អព្យាកតេ រូបសង្គហេ មាតិកា

(២) ទុវិធេន រូបសង្គហោ អត្ថិ រូបំ ឧបាទា អត្ថិ រូបំ នោ ឧបាទា អត្ថិ រូបំ ឧបាទិន្នំ អត្ថិ រូបំ អនុបាទិន្នំ អត្ថិ រូបំ ឧបាទិន្នុបាទានិយំ អត្ថិ រូបំ អនុបាទិន្នុបាទានិយំ អត្ថិ រូបំ សនិទស្សនំ អត្ថិ រូបំ អនិទស្សនំ អត្ថិ រូបំ សប្បដិឃំ អត្ថិ រូបំ អប្បដិឃំ អត្ថិ រូបំ ឥន្ទ្រិយំ អត្ថិ រូបំ ន ឥន្ទ្រិយំ អត្ថិ រូបំ មហាភូតំ អត្ថិ រូបំ ន មហាភូតំ អត្ថិ រូបំ វិញ្ញត្តិ អត្ថិ រូបំ ន វិញ្ញត្តិ អត្ថិ រូបំ ចិត្តសមុដ្ឋានំ អត្ថិ រូបំ ន ចិត្តសមុដ្ឋានំ អត្ថិ រូបំ ចិត្តសហភុ អត្ថិ រូបំ ន ចិត្តសហភុ អត្ថិ រូបំ ចិត្តានុបរិវត្តិ អត្ថិ រូបំ ន ចិត្តានុបរិវត្តិ អត្ថិ រូបំ អជ្ឈត្តិកំ អត្ថិ រូបំ ពាហិរំ អត្ថិ រូបំ ឱឡារិកំ អត្ថិ រូបំ សុខុមំ អត្ថិ រូបំ ទូរេ អត្ថិ រូបំ សន្តិកេ ។ អត្ថិ រូបំ ចក្ខុសម្ផស្សស្ស វត្ថុ អត្ថិ រូបំ ចក្ខុសម្ផស្សស្ស ន វត្ថុ អត្ថិ រូបំ ចក្ខុសម្ផស្សជាយ វេទនាយ ។ បេ ។ សញ្ញាយ ។ បេ ។ ចេតនាយ ។ បេ ។

អព្យាកតៈ រូបសង្គហៈ មាតិកា

(៤) ការសង្គ្រោះរូបដោយចំណែក ២ គឺរូបជាឧបាទា និងរូបមិនមែនជាឧបាទា រូបជាឧបាទិន្ន និងរូបជាអនុបាទិន្ន រូបជាឧបាទិន្នុបាទានិយៈ និងរូបជាអនុបាទិន្នុបាទានិយៈ រូបជាសនិទស្សនៈ និងរូបជាអនិទស្សនៈ រូបជាសប្បដិឃៈ និងរូបជាអប្បដិឃៈ រូបជាឥន្ទ្រិយ និងរូបមិនមែនជាឥន្ទ្រិយ រូបជាមហាភូត និងរូបមិនមែនជាមហាភូត រូបជាវិញ្ញត្តិ និងរូបមិនមែនជាវិញ្ញត្តិ រូបជាចិត្តសមុដ្ឋាន និងរូបមិនមែនជាចិត្តសមុដ្ឋាន រូបកើតជាមួយនឹងចិត្ត និងរូបមិនកើតជាមួយនឹងចិត្ត រូបប្រព្រឹត្តទៅតាមចិត្ត និងរូបមិនប្រព្រឹត្តទៅតាមចិត្ត រូបខាងក្នុង និងរូបខាងក្រៅ រូបគ្រោតគ្រាត និងរូបល្អិត រូបឆ្ងាយ និងរូបជិត ។ រូបជាវត្ថុនៃចក្ខុសម្ផស្ស និងរូបមិនមែនជាវត្ថុនៃចក្ខុសម្ផស្ស រូបជាវត្ថុនៃវេទនា ។ បេ ។ នៃសញ្ញា ។ បេ ។ នៃចេតនា ដែលកើតអំពីចក្ខុសម្ផស្ស ។ បេ ។

ចក្ខុវិញ្ញាណស្ស វត្ថុ អត្ថិ រូបំ ចក្ខុវិញ្ញាណស្ស ន វត្ថុ អត្ថិ រូបំ សោតសម្ផស្សស្ស ។ បេ ។ ឃានសម្ផស្សស្ស ។ បេ ។ ជិវ្ហាសម្ផស្សស្ស ។ បេ ។ កាយសម្ផស្សស្ស វត្ថុ អត្ថិ រូបំ កាយសម្ផស្សស្ស ន វត្ថុ អត្ថិ រូបំ កាយសម្ផស្សជាយ វេទនាយ ។ បេ ។ សញ្ញាយ ។ បេ ។ ចេតនាយ ។ បេ ។ កាយវិញ្ញាណស្ស វត្ថុ អត្ថិ រូបំ កាយវិញ្ញាណស្ស ន វត្ថុ ។ អត្ថិ រូបំ ចក្ខុសម្ផស្សស្ស អារម្មណំ អត្ថិ រូបំ ចក្ខុសម្ផស្សស្ស ន អារម្មណំ អត្ថិ រូបំ ចក្ខុសម្ផស្សជាយ វេទនាយ ។ បេ ។ សញ្ញាយ ។ បេ ។ ចេតនាយ ។ បេ ។ ចក្ខុវិញ្ញាណស្ស អារម្មណំ អត្ថិ រូបំ ចក្ខុវិញ្ញាណស្ស ន អារម្មណំ ។ អត្ថិ រូបំ សោតសម្ផស្សស្ស ។ បេ ។ ឃានសម្ផស្សស្ស ។ បេ ។ ជិវ្ហាសម្ផស្សស្ស ។ បេ ។ កាយសម្ផស្សស្ស អារម្មណំ អត្ថិ រូបំ កាយសម្ផស្សស្ស ន អារម្មណំ អត្ថិ រូបំ កាយសម្ផស្សជាយ វេទនាយ ។ បេ ។ សញ្ញាយ ។ បេ ។

នៃចក្ខុវិញ្ញាណ និងរូបមិនមែនជាវត្ថុ នៃចក្ខុវិញ្ញាណ រូបជាវត្ថុ នៃសោតសម្ផស្ស ។ បេ ។ នៃឃានសម្ផស្ស ។ បេ ។ នៃជិវ្ហាសម្ផស្ស ។ បេ ។ នៃកាយសម្ផស្ស និងរូបមិនមែនជាវត្ថុ នៃកាយសម្ផស្ស រូបជាវត្ថុ នៃវេទនា ។ បេ ។ នៃសញ្ញា ។ បេ ។ នៃចេតនា ដែលកើតអំពីកាយសម្ផស្ស ។ បេ ។ នៃកាយវិញ្ញាណ និងរូបមិនមែនជាវត្ថុ នៃកាយវិញ្ញាណ ។ រូបជាអារម្មណ៍ នៃចក្ខុសម្ផស្ស និងរូបមិនមែនជាអារម្មណ៍ នៃចក្ខុសម្ផស្ស រូបជាអារម្មណ៍ នៃវេទនា ។ បេ ។ នៃសញ្ញា ។ បេ ។ នៃចេតនា ដែលកើតអំពីចក្ខុសម្ផស្ស ។ បេ ។ នៃចក្ខុវិញ្ញាណ និងរូបមិនមែនជាអារម្មណ៍ នៃចក្ខុវិញ្ញាណ ។ រូបជាអារម្មណ៍ នៃសោតសម្ផស្ស ។ បេ ។ នៃឃានសម្ផស្ស ។ បេ ។ នៃជិវ្ហាសម្ផស្ស ។ បេ ។ នៃកាយសម្ផស្ស និងរូបមិនមែនជាអារម្មណ៍នៃកាយសម្ផស្ស រូបជាអារម្មណ៍ នៃវេទនា ។ បេ ។ នៃសញ្ញា ។ បេ ។

## អព្យាកតេ រូបសង្គហេ មាតិកា

ចេតនាយ ។ បេ ។ កាយវិញ្ញាណស្ស អារម្មណំ អត្ថិ រូបំ កាយវិញ្ញាណស្ស ន អារម្មណំ ។ អត្ថិ រូបំ ចក្ខាយតនំ អត្ថិ រូបំ ន ចក្ខាយតនំ អត្ថិ រូបំ សោតាយតនំ អត្ថិ រូបំ ន សោតាយតនំ អត្ថិ រូបំ ឃានាយតនំ ។ បេ ។ ជិវ្ហាយតនំ ។ បេ ។ កាយាយតនំ អត្ថិ រូបំ ន កាយាយតនំ អត្ថិ រូបំ រូបាយតនំ អត្ថិ រូបំ ន រូបាយតនំ អត្ថិ រូបំ សទ្ទាយតនំ ។ បេ ។ គន្ធាយតនំ ។ បេ ។ រសាយតនំ ។ បេ ។ ផោដ្ឋព្វាយតនំ អត្ថិ រូបំ ន ផោដ្ឋព្វាយតនំ ។ អត្ថិ រូបំ ចក្ខុធាតុ អត្ថិ រូបំ ន ចក្ខុធាតុ អត្ថិ រូបំ សោតធាតុ ។ បេ ។ ឃានធាតុ ។ បេ ។ ជិវ្ហាធាតុ ។ បេ ។ កាយធាតុ អត្ថិ រូបំ ន កាយធាតុ អត្ថិ រូបំ រូបធាតុ អត្ថិ រូបំ ន រូបធាតុ អត្ថិ រូបំ សទ្ទធាតុ ។ បេ ។ គន្ធធាតុ ។ បេ ។ រសធាតុ ។ បេ ។ ផោដ្ឋព្វធាតុ អត្ថិ រូបំ ន ផោដ្ឋព្វធាតុ ។ អត្ថិ រូបំ ចក្ខុន្ទ្រិយំ អត្ថិ រូបំ ន ចក្ខុន្ទ្រិយំ អត្ថិ រូបំ សោតិន្ទ្រិយំ ។ បេ ។ ឃានិន្ទ្រិយំ ។ បេ ។ ជិវ្ហិន្ទ្រិយំ ។ បេ ។

នៃចេតនា ដែលកើតអំពីកាយសម្ផស្ស ។ បេ ។ នៃកាយវិញ្ញាណ និងរូបមិនមែនជាអារម្មណ៍នៃកាយវិញ្ញាណ ។ រូបជាចក្ខាយតនៈ និងរូបមិនមែនជាចក្ខាយតនៈ រូបជាសោតាយតនៈ និងរូបមិនមែនជាសោតាយតនៈ រូបជាឃានាយតនៈ ។ បេ ។ ជាជិវ្ហាយតនៈ ។ បេ ។ ជាកាយាយតនៈ និងរូបមិនមែនជាកាយាយតនៈ រូបជារូបាយតនៈ និងរូបមិនមែនជារូបាយតនៈ រូបជាសទ្ទាយតនៈ ។ បេ ។ ជាគន្ធាយតនៈ ។ បេ ។ ជារសាយតនៈ ។ បេ ។ ជាផោដ្ឋព្វាយតនៈ និងរូបមិនមែនជាផោដ្ឋព្វាយតនៈ ។ រូបជាចក្ខុធាតុ និងរូបមិនមែនជាចក្ខុធាតុ រូបជាសោតធាតុ ។ បេ ។ ជាឃានធាតុ ។ បេ ។ ជាជិវ្ហាធាតុ ។ បេ ។ ជាកាយធាតុ និងរូបមិនមែនជាកាយធាតុ រូបជារូបធាតុ និងរូបមិនមែនជារូបធាតុ រូបជាសទ្ទធាតុ ។ បេ ។ ជាគន្ធធាតុ ។ បេ ។ ជារសធាតុ ។ បេ ។ ជាផោដ្ឋព្វធាតុ និងរូបមិនមែនជាផោដ្ឋព្វធាតុ ។ រូបជាចក្ខុន្ទ្រិយ និងរូបមិនមែនជាចក្ខុន្ទ្រិយ រូបជាសោតិន្ទ្រិយ ។ បេ ។ ជាឃានិន្ទ្រិយ ។ បេ ។ ជាជិវ្ហិន្ទ្រិយ ។ បេ ។

កាយិន្ទ្រិយំ អត្ថិ រូបំ ន កាយិន្ទ្រិយំ អត្ថិ រូបំ ឥត្ថិន្ទ្រិយំ អត្ថិ រូបំ ន ឥត្ថិន្ទ្រិយំ អត្ថិ រូបំ បុរិសិន្ទ្រិយំ អត្ថិ រូបំ ន បុរិសិន្ទ្រិយំ អត្ថិ រូបំ ជីវិតិន្ទ្រិយំ អត្ថិ រូបំ ន ជីវិតិន្ទ្រិយំ ។ អត្ថិ រូបំ កាយវិញ្ញត្តិ អត្ថិ រូបំ ន កាយវិញ្ញត្តិ អត្ថិ រូបំ វចីវិញ្ញត្តិ អត្ថិ រូបំ ន វចីវិញ្ញត្តិ អត្ថិ រូបំ អាកាសធាតុ អត្ថិ រូបំ ន អាកាសធាតុ អត្ថិ រូបំ អាបោធាតុ អត្ថិ រូបំ ន អាបោធាតុ អត្ថិ រូបំ រូបស្ស លហុតា អត្ថិ រូបំ រូបស្ស ន លហុតា អត្ថិ រូបំ រូបស្ស មុទុតា អត្ថិ រូបំ រូប-ស្ស ន មុទុតា អត្ថិ រូបំ រូបស្ស កម្មញ្ញតា អត្ថិ រូបំ រូបស្ស ន កម្មញ្ញតា អត្ថិ រូបំ រូបស្ស ឧបចយោ អត្ថិ រូបំ រូបស្ស ន ឧបចយោ អត្ថិ រូបំ រូបស្ស សន្តតិ អត្ថិ រូបំ រូបស្ស ន សន្តតិ អត្ថិ រូបំ រូបស្ស ជរតា អត្ថិ រូបំ រូបស្ស ន ជរតា អត្ថិ រូបំ រូបស្ស អនិច្ចតា អត្ថិ រូបំ រូបស្ស ន អនិច្ចតា អត្ថិ រូបំ កពឡិង្ការោ អាហារោ អត្ថិ រូបំ ន កពឡិង្ការោ អាហារោ ឯវំ ទុវិធេន រូបសង្គហោ ។

ទុកំ ។

ជាកាយិន្ទ្រិយ និងរូបមិនមែនជាកាយិន្ទ្រិយ រូបជាឥត្ថិន្ទ្រិយ និងរូបមិនមែនជាឥត្ថិន្ទ្រិយ រូបជាបុរិសិន្ទ្រិយ និងរូបមិនមែនជាបុរិសិន្ទ្រិយ រូបជាជីវិតិន្ទ្រិយ និងរូបមិនមែនជាជីវិតិន្ទ្រិយ ។ រូបជាកាយវិញ្ញត្តិ និងរូបមិនមែនជាកាយវិញ្ញត្តិ រូបជាវចីវិញ្ញត្តិ និងរូបមិនមែនជាវចីវិញ្ញត្តិ រូបជាអាកាសធាតុ និងរូបមិនមែនជាអាកាសធាតុ រូបជាអាបោធាតុ និងរូបមិនមែនជាអាបោធាតុ រូបជារូបស្សលហុតា និងរូបមិនមែនជារូបស្សលហុតា រូបជារូបស្សមុទុតា និងរូបមិនមែនជារូបស្សមុទុតា រូបជារូបស្សកម្មញ្ញតា និងរូបមិនមែនជារូបស្សកម្មញ្ញតា រូបជារូបស្សឧបចយៈ និងរូបមិនមែនជារូបស្សឧបចយៈ រូបជារូបស្សសន្តតិ និងរូបមិនមែនជារូបស្សសន្តតិ រូបជារូបស្សជរតា និងរូបមិនមែនជារូបស្សជរតា រូបជារូបស្សអនិច្ចតា និងរូបមិនមែនជារូបស្សអនិច្ចតា រូបជាកពឡិង្ការាហារ និងរូបមិនមែនជាកពឡិង្ការាហារ ការសង្គ្រោះរូប ដោយចំណែក ២ យ៉ាងនេះ ។

ចប់ ធម៌មានប្រមាណពីរ ។

## អព្យាកតេ រូបសង្គហេ មាតិកា

(៨) តិវិធេន រូបសង្គហោ យន្តំ រូបំ អជ្ឈត្តិកំ តំ ឧបាទា យន្តំ រូបំ ពាហិរំ តំ អត្ថិ ឧបាទា អត្ថិ នោ ឧបាទា យន្តំ រូបំ អជ្ឈត្តិកំ តំ ឧបាទិន្នំ យន្តំ រូបំ ពាហិរំ តំ អត្ថិ ឧបាទិន្នំ អត្ថិ អនុបាទិន្នំ យន្តំ រូបំ អជ្ឈត្តិកំ តំ ឧបាទិន្នុបាទានិយំ យន្តំ រូបំ ពាហិរំ តំ អត្ថិ ឧបាទិន្នុបាទានិយំ អត្ថិ អនុបាទិន្នុបាទានិយំ យន្តំ រូបំ អជ្ឈត្តិកំ តំ អនិទស្សនំ យន្តំ រូបំ ពាហិរំ តំ អត្ថិ សនិទស្សនំ អត្ថិ អនិទស្សនំ យន្តំ រូបំ អជ្ឈត្តិកំ តំ សប្បដិឃំ យន្តំ រូបំ ពាហិរំ តំ អត្ថិ សប្បដិឃំ អត្ថិ អប្បដិឃំ យន្តំ រូបំ អជ្ឈត្តិកំ តំ ឥន្ទ្រិយំ យន្តំ រូបំ ពាហិរំ តំ អត្ថិ ឥន្ទ្រិយំ អត្ថិ ន ឥន្ទ្រិយំ យន្តំ រូបំ អជ្ឈត្តិកំ តំ ន មហាភូតំ យន្តំ រូបំ ពាហិរំ តំ អត្ថិ មហាភូតំ អត្ថិ ន មហាភូតំ យន្តំ រូបំ អជ្ឈត្តិកំ តំ ន វិញ្ញត្តិ យន្តំ រូបំ ពាហិរំ តំ អត្ថិ វិញ្ញត្តិ អត្ថិ ន វិញ្ញត្តិ

អព្យាកត: រូបសង្គហ: មាតិកា

[ ៥ ] ការសង្គ្រោះរូបដោយចំណែក ៣ គឺរូបណាខាងក្នុង រូបនោះជាឧបាទា រូបណាខាងក្រៅ រូបនោះជាឧបាទា និងមិនមែនជាឧបាទាក៏មាន រូបណាខាងក្នុង រូបនោះជាឧបាទិន្ន រូបណាខាងក្រៅ រូបនោះជាឧបាទិន្ន និងជាអនុបាទិន្នក៏មាន រូបណាខាងក្នុង រូបនោះជាឧបាទិន្នុបាទានិយៈ រូបណាខាងក្រៅ រូបនោះជាឧបាទិន្នុបាទានិយមៈ និងជាអនុបាទិន្នុបាទានិយៈក៏មាន រូបណាខាងក្នុង រូបនោះជាអនិទស្សនៈ រូបណាខាងក្រៅ រូបនោះជាសនិទស្សនៈ និងជាអនិទស្សនៈក៏មាន រូបណាខាងក្នុង រូបនោះជាសប្បដិឃៈ រូបណាខាងក្រៅ រូបនោះជាសប្បដិឃៈ និងជាអប្បដិឃៈក៏មាន រូបណាខាងក្នុង រូបនោះជាឥន្ទ្រិយ រូបណាខាងក្រៅ រូបនោះជាឥន្ទ្រិយ និងមិនមែនជាឥន្ទ្រិយក៏មាន រូបណាខាងក្នុង រូបនោះមិនមែនជាមហាភូត. រូបណាខាងក្រៅ រូបនោះជាមហាភូត និងមិនមែនជាមហាភូតក៏មាន រូបណាខាងក្នុង រូបនោះមិនមែនជាវិញ្ញត្តិ រូបណាខាងក្រៅ រូបនោះជាវិញ្ញត្តិ និងមិនមែនជាវិញ្ញត្តិក៏មាន

យន្តំ រូបំ អជ្ឈត្តិកំ តំ ន ចិត្តសមុដ្ឋានំ យន្តំ រូបំ ពាហិរំ តំ អត្ថិ ចិត្តសមុដ្ឋានំ អត្ថិ ន ចិត្តសមុដ្ឋានំ យន្តំ រូបំ អជ្ឈត្តិកំ តំ ន ចិត្តសហភុ យន្តំ រូបំ ពាហិរំ តំ អត្ថិ ចិត្តសហភុ អត្ថិ ន ចិត្តសហភុ យន្តំ រូបំ អជ្ឈត្តិកំ តំ ន ចិត្តានុបរិវត្តិ យន្តំ រូបំ ពាហិរំ តំ អត្ថិ ចិត្តានុបរិវត្តិ អត្ថិ ន ចិត្តានុបរិវត្តិ យន្តំ រូបំ អជ្ឈត្តិកំ តំ ឱឡារិកំ យន្តំ រូបំ ពាហិរំ តំ អត្ថិ ឱឡារិកំ អត្ថិ សុខុមំ យន្តំ រូបំ អជ្ឈត្តិកំ តំ សន្តិកេ យន្តំ រូបំ ពាហិរំ តំ អត្ថិ ទូរេ អត្ថិ សន្តិកេ ។ យន្តំ រូបំ ពាហិរំ តំ ចក្ខុសម្ផស្សស្ស ន វត្ថុ យន្តំ រូបំ អជ្ឈត្តិកំ តំ អត្ថិ ចក្ខុសម្ផស្សស្ស វត្ថុ អត្ថិ ចក្ខុសម្ផស្សស្ស ន វត្ថុ យន្តំ រូបំ ពាហិរំ តំ អត្ថិ ចក្ខុសម្ផស្សជាយ វេទនាយ ។បេ។ សញ្ញាយ ។បេ។ ចេតនាយ ។បេ។ ចក្ខុវិញ្ញាណស្ស ន វត្ថុ យន្តំ រូបំ អជ្ឈត្តិកំ តំ អត្ថិ ចក្ខុវិញ្ញាណស្ស វត្ថុ អត្ថិ ចក្ខុវិញ្ញាណស្ស ន វត្ថុ យន្តំ រូបំ ពាហិរំ តំ សោតសម្ផស្សស្ស ។បេ។

រូបណាខាងក្នុង រូបនោះមិនមែនជាចិត្តសមុដ្ឋាន រូបណាខាងក្រៅ រូបនោះជាចិត្តសមុដ្ឋាន និងមិនមែនជាចិត្តសមុដ្ឋានក៏មាន រូបណាខាងក្នុង រូបនោះមិនមែនជាចិត្តសហភូ រូបណាខាងក្រៅ រូបនោះជាចិត្តសហភូ និងមិនមែនជាចិត្តសហភូក៏មាន រូបណាខាងក្នុង រូបនោះ មិនមែនជាចិត្តានុបរិវត្តិ រូបណាខាងក្រៅ រូបនោះជាចិត្តានុបរិវត្តិ និងមិនមែនជាចិត្តានុបរិវត្តិក៏មាន រូបណាខាងក្នុង រូបនោះជាឧឡារិកៈ រូបណាខាងក្រៅ រូបនោះជាឧឡារិកៈ និងជាសុខុមៈក៏មាន រូបណាខាងក្នុង រូបនោះជាសន្តិកេរូប រូបណាខាងក្រៅ រូបនោះជាទូរេរូប និងជាសន្តិកេរូបក៏មាន ។ រូបណាខាងក្រៅ រូបនោះមិនមែនជាវត្ថុ នៃចក្ខុសម្ផស្ស រូបណាខាងក្នុង រូបនោះជាវត្ថុនៃចក្ខុសម្ផស្ស និងមិនមែនជាវត្ថុ នៃចក្ខុសម្ផស្សក៏មាន រូបណាខាងក្រៅ រូបនោះមិនមែនជាវត្ថុនៃវេទនា ។ បេ ។ នៃសញ្ញា ។ បេ ។ នៃចេតនា ដែលកើតអំពីចក្ខុសម្ផស្ស ។ បេ ។ នៃចក្ខុវិញ្ញាណក៏មាន រូបណាខាងក្នុង រូបនោះជាវត្ថុ នៃចក្ខុវិញ្ញាណ និងមិនមែនជាវត្ថុ នៃចក្ខុវិញ្ញាណក៏មាន រូបណាខាងក្រៅ រូបនោះមិនមែនជាវត្ថុ នៃសោតសម្ផស្ស ។ បេ ។

## អព្យាកតេ រូបសង្គហេ មាតិកា

ឃានសម្ផស្សស្ស ។ បេ ។ ជិវ្ហាសម្ផស្សស្ស ។ បេ ។ កាយសម្ផស្សស្ស ន វត្ថុ យន្តំ រូបំ អជ្ឈត្តិកំ តំ អត្ថិ កាយសម្ផស្សស្ស វត្ថុ អត្ថិ កាយសម្ផស្សស្ស ន វត្ថុ យន្តំ រូបំ ពាហិរំ តំ កាយសម្ផស្សជាយ វេទនាយ ។ បេ ។ សញ្ញាយ ។ បេ ។ ចេតនាយ ។ បេ ។ កាយវិញ្ញាណស្ស ន វត្ថុ យន្តំ រូបំ អជ្ឈត្តិកំ តំ អត្ថិ កាយវិញ្ញាណស្ស វត្ថុ អត្ថិ កាយវិញ្ញាណស្ស ន វត្ថុ ។ យន្តំ រូបំ អជ្ឈត្តិកំ តំ ចក្ខុសម្ផស្សស្ស ន អារម្មណំ យន្តំ រូបំ ពាហិរំ តំ អត្ថិ ចក្ខុសម្ផស្សស្ស អារម្មណំ អត្ថិ ចក្ខុសម្ផស្សស្ស ន អារម្មណំ យន្តំ រូបំ អជ្ឈត្តិកំ តំ ចក្ខុសម្ផស្សជាយ វេទនាយ ។ បេ ។ សញ្ញាយ ។ បេ ។ ចេតនាយ ។ បេ ។ ចក្ខុវិញ្ញាណស្ស ន អារម្មណំ យន្តំ រូបំ ពាហិរំ តំ អត្ថិ ចក្ខុវិញ្ញាណស្ស អារម្មណំ អត្ថិ ចក្ខុវិញ្ញាណស្ស ន អារម្មណំ យន្តំ រូបំ អជ្ឈត្តិកំ តំ សោតសម្ផស្សស្ស ។ បេ ។

នៃឃានសម្ផ័ស្ស ។ បេ ។ នៃជិវ្ហាសម្ផ័ស្ស ។ បេ ។ នៃកាយសម្ផ័ស្ស រូបណាខាងក្នុង រូបនោះជាវត្ថុនៃកាយសម្ផ័ស្ស និងមិនមែនជាវត្ថុ នៃកាយសម្ផ័ស្សក៏មាន រូបណាខាងក្រៅ រូបនោះមិនមែនជាវត្ថុ នៃវេទនា ។ បេ ។ នៃសញ្ញា ។ បេ ។ នៃចេតនា ដែលកើតអំពីកាយសម្ផ័ស្ស ។ បេ ។ នៃកាយវិញ្ញាណ រូបណាខាងក្នុង រូបនោះជាវត្ថុនៃកាយ-វិញ្ញាណ និងមិនមែនជាវត្ថុនៃកាយវិញ្ញាណក៏មាន ។ រូបណាខាងក្នុង រូបនោះមិនមែនជាអារម្មណ៍នៃចក្ខុសម្ផ័ស្ស រូបណាខាងក្រៅ រូបនោះជាអារម្មណ៍ នៃចក្ខុសម្ផ័ស្ស និងមិនមែនជាអារម្មណ៍ នៃចក្ខុសម្ផ័-ស្សក៏មាន រូបណាខាងក្នុង រូបនោះមិនមែនជាអារម្មណ៍ នៃវេទនា ។ បេ ។ នៃសញ្ញា ។ បេ ។ នៃចេតនា ដែលកើតអំពីចក្ខុសម្ផ័ស្ស ។ បេ ។ នៃចក្ខុវិញ្ញាណ រូបណាខាងក្រៅ រូបនោះជាអារម្មណ៍នៃចក្ខុវិញ្ញាណ និងមិនមែនជាអារម្មណ៍នៃចក្ខុវិញ្ញាណក៏មាន រូបណាខាងក្នុង រូបនោះមិនមែនជាអារម្មណ៍ នៃសោតសម្ផ័ស្ស ។ បេ ។

ឃានសម្ផស្សស្ស ។បេ។ ជិវ្ហាសម្ផស្សស្ស ។បេ។ កាយសម្ផស្សស្ស ន អារម្មណំ យន្តំ រូបំ ពាហិរំ តំ អត្ថិ កាយសម្ផស្សស្ស អារម្មណំ អត្ថិ កាយសម្ផស្សស្ស ន អារម្មណំ យន្តំ រូបំ អជ្ឈត្តិកំ តំ កាយសម្ផស្សជាយ វេទនាយ ។បេ។ សញ្ញាយ ។បេ។ ចេតនាយ ។បេ។ កាយវិញ្ញាណស្ស ន អារម្មណំ យន្តំ រូបំ ពាហិរំ តំ អត្ថិ កាយវិញ្ញាណស្ស អារម្មណំ អត្ថិ កាយវិញ្ញាណស្ស ន អារម្មណំ ។ យន្តំ រូបំ ពាហិរំ តំ ន ចក្ខាយតនំ យន្តំ រូបំ អជ្ឈត្តិកំ តំ អត្ថិ ចក្ខាយតនំ អត្ថិ ន ចក្ខាយតនំ យន្តំ រូបំ ពាហិរំ តំ ន សោតាយតនំ ។បេ។ ន ឃានាយតនំ ។បេ។ ន ជិវ្ហាយតនំ ។បេ។ ន កាយាយតនំ យន្តំ រូបំ អជ្ឈត្តិកំ តំ អត្ថិ កាយាយតនំ អត្ថិ ន កាយាយតនំ យន្តំ រូបំ អជ្ឈត្តិកំ តំ ន រូបាយតនំ យន្តំ រូបំ ពាហិរំ តំ អត្ថិ រូបាយតនំ អត្ថិ ន រូបាយតនំ យន្តំ រូបំ អជ្ឈត្តិកំ តំ ន សទ្ទាយតនំ ។បេ។

នៃឃានសម្ផស្ស ។ បេ ។ នៃជិវ្ហាសម្ផស្ស ។ បេ ។ នៃកាយសម្ផស្ស រូបណាខាងក្រៅ រូបនោះជាអារម្មណ៍ នៃកាយសម្ផស្ស និងមិនមែនជាអារម្មណ៍ នៃកាយសម្ផស្សក៏មាន រូបណាខាងក្នុង រូបនោះមិនមែនជាអារម្មណ៍នៃវេទនា ។ បេ ។ នៃសញ្ញា ។ បេ ។ នៃចេតនា ដែលកើតអំពីកាយសម្ផស្ស ។ បេ ។ នៃកាយវិញ្ញាណ រូបណាខាងក្រៅ រូបនោះជាអារម្មណ៍នៃកាយវិញ្ញាណ និងមិនមែនជាអារម្មណ៍ នៃកាយវិញ្ញាណក៏មាន ។ រូបណាខាងក្រៅ រូបនោះមិនមែនជាចក្ខាយតនៈ រូបណាខាងក្នុង រូបនោះជាចក្ខាយតនៈ និងមិនមែនជាចក្ខាយតនៈក៏មាន រូបណាខាងក្រៅ រូបនោះមិនមែនជាសោតាយតនៈ ។ បេ ។ មិនមែនជាឃានាយតនៈ ។ បេ ។ មិនមែនជាជិវ្ហាយតនៈ ។ បេ ។ មិនមែនជាកាយាយតនៈ រូបណាខាងក្នុង រូបនោះជាកាយាយតនៈ និងមិនមែនជាកាយាយតនៈក៏មាន រូបណាខាងក្នុង រូបនោះមិនមែនជារូបាយតនៈ រូបណាខាងក្រៅ រូបនោះជារូបាយតនៈ និងមិនមែនជារូបាយតនៈក៏មាន រូបណាខាងក្នុង រូបនោះមិនមែនជាសទ្ទាយតនៈ ។ បេ ។

## អព្យាកតេ រូបសង្គហេ មាតិកា

ន គន្ធាយតនំ ។ បេ ។ ន រសាយតនំ ។ បេ ។ ន ផោដ្ឋព្វាយតនំ យន្តំ រូបំ ពាហិរំ តំ អត្ថិ ផោដ្ឋព្វាយតនំ អត្ថិ ន ផោដ្ឋព្វាយតនំ ។ យន្តំ រូបំ ពាហិរំ តំ ន ចក្ខុធាតុ យន្តំ រូបំ អជ្ឈត្តិកំ តំ អត្ថិ ចក្ខុធាតុ អត្ថិ ន ចក្ខុធាតុ យន្តំ រូបំ ពាហិរំ តំ ន សោតធាតុ ។ បេ ។ ន ឃានធាតុ ។ បេ ។ ន ជិវ្ហាធាតុ ។ បេ ។ ន កាយធាតុ យន្តំ រូបំ អជ្ឈត្តិកំ តំ អត្ថិ កាយធាតុ អត្ថិ ន កាយធាតុ យន្តំ រូបំ អជ្ឈត្តិកំ តំ ន រូបធាតុ យន្តំ រូបំ ពាហិរំ តំ អត្ថិ រូបធាតុ អត្ថិ ន រូបធាតុ យន្តំ រូបំ អជ្ឈត្តិកំ តំ ន សទ្ទធាតុ ។ បេ ។ ន គន្ធធាតុ ។ បេ ។ ន រសធាតុ ។ បេ ។ ន ផោដ្ឋព្វធាតុ យន្តំ រូបំ ពាហិរំ តំ អត្ថិ ផោដ្ឋព្វធាតុ អត្ថិ ន ផោដ្ឋព្វធាតុ ។ យន្តំ រូបំ ពាហិរំ តំ ន ចក្ខុន្ទ្រិយំ យន្តំ រូបំ អជ្ឈត្តិកំ តំ អត្ថិ ចក្ខុន្ទ្រិយំ អត្ថិ ន ចក្ខុន្ទ្រិយំ យន្តំ រូបំ ពាហិរំ តំ ន សោតិន្ទ្រិយំ ។ បេ ។ ន ឃានិន្ទ្រិយំ ។ បេ ។

មិនមែនជាគន្ធាយតនៈ ។ បេ ។ មិនមែនជាសោយតនៈ ។ បេ ។ មិនមែនជាផោដ្ឋព្វាយតនៈ រូបណាខាងក្រៅ រូបនោះជាផោដ្ឋព្វាយតនៈ និងមិនមែនជាផោដ្ឋព្វាយតនៈក៏មាន ។ រូបណាខាងក្រៅ រូបនោះមិនមែនជាចក្ខុធាតុ រូបណាខាងក្នុង រូបនោះជាចក្ខុធាតុ និងមិនមែនជាចក្ខុធាតុក៏មាន រូបណាខាងក្រៅ រូបនោះមិនមែនជាសោតធាតុ ។ បេ ។ មិនមែនជាឃានធាតុ ។ បេ ។ មិនមែនជាជិវ្ហាធាតុ ។ បេ ។ មិនមែនជាកាយធាតុ រូបណាខាងក្នុង រូបនោះជាកាយធាតុ និងមិនមែនជាកាយធាតុក៏មាន រូបណាខាងក្នុង រូបនោះមិនមែនជារូបធាតុ រូបណាខាងក្រៅ រូបនោះជារូបធាតុ និងមិនមែនជារូបធាតុក៏មាន រូបណាខាងក្នុង រូបនោះមិនមែនជាសទ្ទធាតុ ។ បេ ។ មិនមែនជាគន្ធធាតុ ។ បេ ។ មិនមែនជារសធាតុ ។ បេ ។ មិនមែនជាផោដ្ឋព្វធាតុ រូបណាខាងក្រៅ រូបនោះ ជាផោដ្ឋព្វធាតុ និងមិនមែនជាផោដ្ឋព្វធាតុក៏មាន ។ រូបណាខាងក្រៅ រូបនោះមិនមែនជាចក្ខុន្ទ្រិយ រូបណាខាងក្នុង រូបនោះ ជាចក្ខុន្ទ្រិយ និងមិនមែនជាចក្ខុន្ទ្រិយក៏មាន រូបណាខាងក្រៅ រូបនោះមិនមែនជាសោតិន្ទ្រិយ ។ បេ ។ មិនមែនជាឃានិន្ទ្រិយ ។ បេ ។

ន ជិវ្ហិន្ទ្រិយំ ។បេ។ ន កាយិន្ទ្រិយំ យំ រូបំ អជ្ឈត្តិកំ តំ អត្ថិ កាយិន្ទ្រិយំ អត្ថិ ន កាយិន្ទ្រិយំ យំ រូបំ អជ្ឈត្តិកំ តំ ន ឥត្ថិន្ទ្រិយំ យំ រូបំ ពាហិរំ តំ អត្ថិ ឥត្ថិន្ទ្រិយំ អត្ថិ ន ឥត្ថិន្ទ្រិយំ យំ រូបំ អជ្ឈត្តិកំ តំ ន បុរិសិន្ទ្រិយំ យំ រូបំ ពាហិរំ តំ អត្ថិ បុរិសិន្ទ្រិយំ អត្ថិ ន បុរិសិន្ទ្រិយំ យំ រូបំ អជ្ឈត្តិកំ តំ ន ជីវិតិន្ទ្រិយំ យំ រូបំ ពាហិរំ តំ អត្ថិ ជីវិតិន្ទ្រិយំ អត្ថិ ន ជីវិតិន្ទ្រិយំ ។ យំ រូបំ អជ្ឈត្តិកំ តំ ន កាយវិញ្ញត្តិ យំ រូបំ ពាហិរំ តំ អត្ថិ កាយវិញ្ញត្តិ អត្ថិ ន កាយវិញ្ញត្តិ យំ រូបំ អជ្ឈត្តិកំ តំ ន វចីវិញ្ញត្តិ យំ រូបំ ពាហិរំ តំ អត្ថិ វចីវិញ្ញត្តិ អត្ថិ ន វចីវិញ្ញត្តិ យំ រូបំ អជ្ឈត្តិកំ តំ ន អាកាសធាតុ យំ រូបំ ពាហិរំ តំ អត្ថិ អាកាសធាតុ អត្ថិ ន អាកាសធាតុ យំ រូបំ អជ្ឈត្តិកំ តំ ន អាបោធាតុ យំ រូបំ ពាហិរំ តំ អត្ថិ អាបោធាតុ អត្ថិ ន អាបោធាតុ

មិនមែនជាជិវ្ហិន្ទ្រិយ ។ បេ ។ មិនមែនជាកាយិន្ទ្រិយ រូបណាខាងក្នុង រូបនោះជាកាយិន្ទ្រិយ និងមិនមែនជាកាយិន្ទ្រិយក៏មាន រូបណាខាងក្នុង រូបនោះមិនមែនជាឥត្ថិន្ទ្រិយ រូបណាខាងក្រៅ រូបនោះ ជាឥត្ថិន្ទ្រិយ និងមិនមែនជាឥត្ថិន្ទ្រិយក៏មាន រូបណាខាងក្នុង រូបនោះមិនមែនជាបុរិសិន្ទ្រិយ រូបណាខាងក្រៅ រូបនោះជាបុរិសិន្ទ្រិយ និងមិនមែនជាបុរិសិន្ទ្រិយក៏មាន រូបណាខាងក្នុង រូបនោះមិនមែនជាជីវិតិន្ទ្រិយ រូបណាខាងក្រៅ រូបនោះជាជីវិតិន្ទ្រិយ និងមិនមែនជាជីវិតិន្ទ្រិយក៏មាន ។ រូបណាខាងក្នុង រូបនោះមិនមែនជាកាយវិញ្ញត្តិ រូបណាខាងក្រៅ រូបនោះជាកាយវិញ្ញត្តិ និងមិនមែនជាកាយវិញ្ញត្តិក៏មាន រូបណាខាងក្នុង រូបនោះមិនមែនជាវចីវិញ្ញត្តិ រូបណាខាងក្រៅ រូបនោះជាវចីវិញ្ញត្តិ និងមិនមែនជាវចីវិញ្ញត្តិក៏មាន រូបណាខាងក្នុង រូបនោះមិនមែនជាអាកាសធាតុ រូបណាខាងក្រៅ រូបនោះជាអាកាសធាតុ និងមិនមែនជាអាកាសធាតុក៏មាន រូបណាខាងក្នុង រូបនោះមិនមែនជាអាបោធាតុ រូបណាខាងក្រៅ រូបនោះជាអាបោធាតុ និងមិនមែនជាអាបោធាតុក៏មាន

## អព្យាកតេ រូបសង្គហេ មាតិកា

យន្តំ រូបំ អជ្ឈត្តិកំ តំ រូបស្ស ន លហុតា យន្តំ រូបំ ពាហិរំ តំ អត្ថិ រូបស្ស លហុតា អត្ថិ រូបស្ស ន លហុតា យន្តំ រូបំ អជ្ឈត្តិកំ តំ រូបស្ស ន មុទុតា យន្តំ រូបំ ពាហិរំ តំ អត្ថិ រូបស្ស មុទុតា អត្ថិ រូបស្ស ន មុទុតា យន្តំ រូបំ អជ្ឈត្តិកំ តំ រូបស្ស ន កម្មញ្ញតា យន្តំ រូបំ ពាហិរំ តំ អត្ថិ រូបស្ស កម្មញ្ញតា អត្ថិ រូបស្ស ន កម្មញ្ញតា យន្តំ រូបំ អជ្ឈត្តិកំ តំ រូបស្ស ន ឧបច្ចយោ យន្តំ រូបំ ពាហិរំ តំ អត្ថិ រូបស្ស ឧបច្ចយោ អត្ថិ រូបស្ស ន ឧបច្ចយោ យន្តំ រូបំ អជ្ឈត្តិកំ តំ រូបស្ស ន សន្តតិ យន្តំ រូបំ ពាហិរំ តំ អត្ថិ រូបស្ស សន្តតិ អត្ថិ រូបស្ស ន សន្តតិ យន្តំ រូបំ អជ្ឈត្តិកំ តំ រូបស្ស ន ជរតា យន្តំ រូបំ ពាហិរំ តំ អត្ថិ រូបស្ស ជរតា អត្ថិ រូបស្ស ន ជរតា យន្តំ រូបំ អជ្ឈត្តិកំ តំ រូបស្ស ន អនិច្ចតា យន្តំ រូបំ ពាហិរំ តំ អត្ថិ រូបស្ស អនិច្ចតា អត្ថិ រូបស្ស ន អនិច្ចតា

រូបណាខាងក្នុង រូបនោះមិនមែនជារូបស្សលហុតា រូបណាខាងក្រៅ រូបនោះជារូបស្សលហុតា និងមិនមែនជារូបស្សលហុតាក៏មាន រូបណាខាងក្នុង រូបនោះមិនមែនជារូបស្សមុទុតា រូបណាខាងក្រៅ រូបនោះជារូបស្សមុទុតា និងមិនមែនជារូបស្សមុទុតាក៏មាន រូបណាខាងក្នុង រូបនោះមិនមែនជារូបស្សកម្មញ្ញតា រូបណាខាងក្រៅ រូបនោះជារូបស្សកម្មញ្ញតា និងមិនមែនជារូបស្សកម្មញ្ញតាក៏មាន រូបណាខាងក្នុង រូបនោះមិនមែនជារូបស្សឧបចយៈ រូបណាខាងក្រៅ រូបនោះជារូបស្សឧបចយៈ និងមិនមែនជារូបស្សឧបចយៈក៏មាន រូបណាខាងក្នុង រូបនោះមិនមែនជារូបស្សសន្តតិ រូបណាខាងក្រៅ រូបនោះជារូបស្សសន្តតិ និងមិនមែនជារូបស្សសន្តតិក៏មាន រូបណាខាងក្នុង រូបនោះមិនមែនជារូបស្សជរតា រូបណាខាងក្រៅ រូបនោះជារូបស្សជរតា និងមិនមែនជារូបស្សជរតាក៏មាន រូបណាខាងក្នុង រូបនោះមិនមែនជារូបស្សអនិច្ចតា រូបណាខាងក្រៅ រូបនោះជារូបស្សអនិច្ចតា និងមិនមែនជារូបស្សអនិច្ចតាក៏មាន

យន្តំ រូបំ អជ្ឈត្តិកំ តំ ន កពឡីការោ អាហារោ យន្តំ រូបំ ពាហិរំ តំ អត្ថិ កពឡីការោ អាហារោ អត្ថិ ន កពឡីការោ អាហារោ ឯវំ តិវិធេន រូបសង្គហោ ។

តិកំ ។

(៦) ចតុព្វិធេន រូបសង្គហោ យន្តំ រូបំ ឧបាទា តំ អត្ថិ ឧបាទិន្នំ អត្ថិ អនុបាទិន្នំ យន្តំ រូបំ អនុបាទា តំ អត្ថិ ឧបាទិន្នំ អត្ថិ អនុបាទិន្នំ យន្តំ រូបំ ឧបាទា តំ អត្ថិ ឧបាទិន្នុបាទានិយំ អត្ថិ អនុបាទិន្នុបាទានិយំ យន្តំ រូបំ អនុបាទា តំ អត្ថិ ឧបាទិន្នុបាទានិយំ អត្ថិ អនុបាទិន្នុបាទានិយំ យន្តំ រូបំ ឧបាទា តំ អត្ថិ សប្បដិឃំ អត្ថិ អប្បដិឃំ យន្តំ រូបំ អនុបាទា តំ អត្ថិ សប្បដិឃំ អត្ថិ អប្បដិឃំ យន្តំ រូបំ ឧបាទា តំ អត្ថិ ឱឡារិកំ អត្ថិ សុខុមំ យន្តំ រូបំ អនុបាទា តំ អត្ថិ ឱឡារិកំ អត្ថិ សុខុមំ យន្តំ រូបំ ឧបាទា តំ អត្ថិ ទូរេ អត្ថិ សន្តិកេ យន្តំ រូបំ អនុបាទា តំ អត្ថិ ទូរេ អត្ថិ សន្តិកេ ។

រូបណាខាងក្នុង រូបនោះមិនមែនជាកពឡីការាហារ រូបណាខាងក្រៅ រូបនោះជាកពឡីការាហារ ទាំងមិនមែនជាកពឡីការាហារក៏មាន ការសង្គ្រោះរូបដោយចំណែក ៣ យ៉ាងនេះ ។

បប់ រូបមានប្រមាណ ៣ ។

( ៦ ) ការសង្គ្រោះរូប ដោយចំណែក ៤ គឺរូបណាជាឧបាទា រូបនោះជាឧបាទិន្នក៏មាន ជាអនុបាទិន្នក៏មាន រូបណាជាអនុបាទា រូបនោះជាឧបាទិន្នក៏មាន ជាអនុបាទិន្នក៏មាន រូបណាជាឧបាទា រូបនោះជាឧបាទិន្នុបាទានិយៈក៏មាន ជាអនុបាទិន្នុបាទានិយៈក៏មាន រូបណាជាអនុបាទា រូបនោះជាឧបាទិន្នុបាទានិយៈក៏មាន ជាអនុបាទិន្នុបាទានិយៈក៏មាន រូបណាជាឧបាទា រូបនោះជាសប្បដិឃៈក៏មាន ជាអប្បដិឃៈក៏មាន រូបណាជាអនុបាទា រូបនោះជាសប្បដិឃៈក៏មាន ជាអប្បដិឃៈក៏មាន រូបណាជាឧបាទា រូបនោះជាឱឡារិកៈក៏មាន ជាសុខុមៈក៏មាន រូបណាជាអនុបាទា រូបនោះជាឱឡារិកៈក៏មាន ជាសុខុមៈក៏មាន រូបណាជាឧបាទា រូបនោះជាទូរេរូបក៏មាន ជាសន្តិកេរូបក៏មាន រូបណាជាអនុបាទា រូបនោះជាទូរេរូបក៏មាន ជាសន្តិកេរូបក៏មាន ។

## អព្យាកតេ រូបសង្គហេ មាតិកា

យន្តំ រូបំ ឧបាទិណ្ណំ តំ អត្ថិ សនិទស្សនំ អត្ថិ អនិទស្សនំ យន្តំ រូបំ អនុបាទិណ្ណំ តំ អត្ថិ សនិទស្សនំ អត្ថិ អនិទស្សនំ យន្តំ រូបំ ឧបាទិណ្ណំ តំ អត្ថិ សប្បដិឃំ អត្ថិ អប្បដិឃំ យន្តំ រូបំ អនុបាទិណ្ណំ តំ អត្ថិ សប្បដិឃំ អត្ថិ អប្បដិឃំ យន្តំ រូបំ ឧបាទិណ្ណំ តំ អត្ថិ មហាភូតំ អត្ថិ ន មហាភូតំ យន្តំ រូបំ អនុបាទិណ្ណំ តំ អត្ថិ មហាភូតំ អត្ថិ ន មហាភូតំ យន្តំ រូបំ ឧបាទិណ្ណំ តំ អត្ថិ ឱឡារិកំ អត្ថិ សុខុមំ យន្តំ រូបំ អនុបាទិណ្ណំ តំ អត្ថិ ឱឡារិកំ អត្ថិ សុខុមំ យន្តំ រូបំ ឧបាទិណ្ណំ តំ អត្ថិ ទូរេ អត្ថិ សន្តិកេ យន្តំ រូបំ អនុបាទិណ្ណំ តំ អត្ថិ ទូរេ អត្ថិ សន្តិកេ ។ យន្តំ រូបំ ឧបាទិណ្ណុបាទានិយំ តំ អត្ថិ សនិទស្សនំ អត្ថិ អនិទស្សនំ យន្តំ រូបំ អនុបាទិណ្ណុបាទានិយំ តំ អត្ថិ សនិទស្សនំ អត្ថិ អនិទស្សនំ យន្តំ រូបំ ឧបាទិណ្ណុបាទានិយំ តំ អត្ថិ សប្បដិឃំ អត្ថិ អប្បដិឃំ យន្តំ រូបំ អនុបាទិណ្ណុបាទានិយំ

រូបណាជាឧបាទិន្ន រូបនោះជាសនិទស្សនៈក៏មាន ជាអនិទស្សនៈក៏មាន រូបណាជាអនុបាទិន្ន រូបនោះជាសនិទស្សនៈក៏មាន ជាអនិទស្សនៈក៏មាន រូបណាជាឧបាទិន្ន រូបនោះជាសប្បដិឃៈក៏មាន ជាអប្បដិឃៈក៏មាន រូបណាជាអនុបាទិន្ន រូបនោះជាសប្បដិឃៈក៏មាន ជាអប្បដិឃៈក៏មាន រូបណាជាឧបាទិន្ន រូបនោះជាមហាភូតក៏មាន មិនមែនជាមហាភូតក៏មាន រូបណាជាអនុបាទិន្ន រូបនោះជាមហាភូតក៏មាន មិនមែនជាមហាភូតក៏មាន រូបណាជាឧបាទិន្ន រូបនោះជាឱឡារិកៈក៏មាន ជាសុខុមៈក៏មាន រូបណាជាអនុបាទិន្ន រូបនោះជាឱឡារិកៈក៏មាន ជាសុខុមៈក៏មាន រូបណាជាឧបាទិន្ន រូបនោះជាទូរេរូបក៏មាន ជាសន្តិកេរូបក៏មាន រូបណាជាអនុបាទិន្ន រូបនោះជាទូរេរូបក៏មាន ជាសន្តិកេរូបក៏មាន ។ រូបណាជាឧបាទិន្នុបាទានិយៈ រូបនោះជាសនិទស្សនៈក៏មាន ជាអនិទស្សនៈក៏មាន រូបណាជាអនុបាទិន្នុបាទានិយៈ រូបនោះជាសនិទស្សនៈក៏មាន ជាអនិទស្សនៈក៏មាន រូបណាជាឧបាទិន្នុបាទានិយៈ រូបនោះជាសប្បដិឃៈក៏មាន ជាអប្បដិឃៈក៏មាន រូបណាជាអនុបាទិន្នុបាទានិយៈ

តំ អត្ថិ សប្បដិឃំ អត្ថិ អប្បដិឃំ យន្តំ រូបំ ឧបាទិន្នុបាទានិយំ តំ អត្ថិ មហាភូតំ អត្ថិ ន មហាភូតំ យន្តំ រូបំ អនុបាទិន្នុបាទានិយំ តំ អត្ថិ មហាភូតំ អត្ថិ ន មហាភូតំ យន្តំ រូបំ ឧបាទិន្នុ-បាទានិយំ តំ អត្ថិ ឱឡារិកំ អត្ថិ សុខុមំ យន្តំ រូបំ អនុបាទិន្នុបាទានិយំ តំ អត្ថិ ឱឡារិកំ អត្ថិ សុខុមំ យន្តំ រូបំ ឧបាទិន្នុបាទានិយំ តំ អត្ថិ ទូរេ អត្ថិ សន្តិកេ យន្តំ រូបំ អនុបាទិន្នុបាទានិយំ តំ អត្ថិ ទូរេ អត្ថិ សន្តិកេ ។ យន្តំ រូបំ សប្បដិឃំ តំ អត្ថិ ឥន្ទ្រិយំ អត្ថិ ន ឥន្ទ្រិយំ យន្តំ រូបំ អប្ប-ដិឃំ តំ អត្ថិ ឥន្ទ្រិយំ អត្ថិ ន ឥន្ទ្រិយំ យន្តំ រូបំ សប្បដិឃំ តំ អត្ថិ មហាភូតំ អត្ថិ ន មហាភូតំ យន្តំ រូបំ អប្បដិឃំ តំ អត្ថិ មហាភូតំ អត្ថិ ន មហាភូតំ ។ យន្តំ រូបំ ឥន្ទ្រិយំ តំ អត្ថិ ឱឡារិកំ អត្ថិ សុខុមំ យន្តំ រូបំ ន ឥន្ទ្រិយំ តំ អត្ថិ ឱឡារិកំ អត្ថិ សុខុមំ យន្តំ រូបំ ឥន្ទ្រិយំ តំ អត្ថិ ទូរេ អត្ថិ សន្តិកេ យន្តំ រូបំ ន ឥន្ទ្រិយំ តំ អត្ថិ ទូរេ អត្ថិ សន្តិកេ ។

រូបនោះជាសប្បដិឃៈក៏មាន ជាអប្បដិឃៈក៏មាន រូបណាជាឧបាទិន្នុបាទានិយៈ រូបនោះជាមហាភូតក៏មាន មិនមែនជាមហាភូតក៏មាន រូបណាជាអនុបាទិន្នុបាទានិយៈ រូបនោះជាមហាភូតក៏មាន មិនមែនជាមហាភូតក៏មាន រូបណាជាឧបាទិន្នុបាទានិយៈ រូបនោះជាឱឡារិកៈក៏មាន ជាសុខុមៈក៏មាន រូបណាជាអនុបាទិន្នុបាទានិយៈ រូបនោះជាឱឡារិកៈក៏មាន ជាសុខុមៈក៏មាន រូបណាជាឧបាទិន្នុបាទានិយៈ រូបនោះជាទូរេរូបក៏មាន ជាសន្តិកេរូបក៏មាន រូបណា ជាអនុបាទិន្នុបាទានិយៈ រូបនោះជាទូរេរូបក៏មាន ជាសន្តិកេរូបក៏មាន ។ រូបណា ជាសប្បដិឃៈ រូបនោះជាឥន្ទ្រិយក៏មាន មិនមែនជាឥន្ទ្រិយក៏មាន រូបណាជាអប្បដិឃៈ រូបនោះជាឥន្ទ្រិយក៏មាន មិនមែនជាឥន្ទ្រិយក៏មាន រូបណាជាសប្បដិឃៈ រូបនោះ ជាមហាភូតក៏មាន មិនមែនជាមហាភូតក៏មាន រូបណា ជាអប្បដិឃៈ រូបនោះ ជាមហាភូតក៏មាន មិនមែនជាមហាភូតក៏មាន ។ រូបណាជាឥន្ទ្រិយ រូបនោះជាឱឡារិកៈក៏មាន ជាសុខុមៈក៏មាន រូបណាមិនមែនជាឥន្ទ្រិយ រូបនោះ ជាឱឡារិកៈក៏មាន ជាសុខុមៈក៏មាន រូបណា ជាឥន្ទ្រិយ រូបនោះជាទូរេរូបក៏មាន ជាសន្តិកេរូបក៏មាន រូបណាមិនមែនជាឥន្ទ្រិយ រូបនោះជាទូរេរូបក៏មាន ជាសន្តិកេរូបក៏មាន ។

## អព្យាកតេ រូបសង្គហេ មាតិកា

យន្តំ រូបំ មហាភូតំ តំ អត្ថិ ឱឡារិកំ អត្ថិ សុខុមំ យន្តំ រូបំ ន មហាភូតំ តំ អត្ថិ ឱឡារិកំ អត្ថិ សុខុមំ យន្តំ រូបំ មហាភូតំ តំ អត្ថិ ទូរេ អត្ថិ សន្តិកេ យន្តំ រូបំ ន មហាភូតំ តំ អត្ថិ ទូរេ អត្ថិ សន្តិកេ ។ ទិដ្ឋំ សុតំ មុតំ វិញ្ញាតំ រូបំ ឯវំ ចតុព្វិធេន រូបសង្គហោ ។

### បតុក្កំ ។

(៧) បញ្ចវិធេន រូបសង្គហោ បថវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតុ យញ្ច រូបំ ឧបាទា ឯវំ បញ្ចវិធេន រូបសង្គហោ ។

### បញ្ចកំ ។

(៨) ឆព្វិធេន រូបសង្គហោ ចក្ខុវិញ្ញេយ្យំ រូបំ សោតវិញ្ញេយ្យំ រូបំ ឃានវិញ្ញេយ្យំ រូបំ ជិវ្ហាវិញ្ញេយ្យំ រូបំ កាយវិញ្ញេយ្យំ រូបំ មនោវិញ្ញេយ្យំ រូបំ ឯវំ ឆព្វិធេន រូបសង្គហោ ។

### ឆក្កំ ។

រូបណាជាមហាភូត រូបនោះជាឧឡារិក:ក៏មាន ជាសុខុម:ក៏មាន រូបណាមិនមែនជាមហាភូត រូបនោះជាឧឡារិក:ក៏មាន ជាសុខុម:ក៏មាន រូបណាជាមហាភូត រូបនោះជាទូរេរូបក៏មាន ជាសន្តិកេរូបក៏មាន រូបណាមិនមែនជាមហាភូត រូបនោះ ជាទូរេរូបក៏មាន ជាសន្តិកេរូបក៏មាន ។ (បានដល់) រូបដែលបុគ្គលឃើញ ឮ លិខ្ន ភុក្ស ដឹងច្បាស់ ការសង្គ្រោះរូបដោយចំណែក ៤ យ៉ាងនេះ ។

ចប់ រូបមានប្រមាណ ៤ ។

( ៧ ) ការសង្គ្រោះរូប ដោយចំណែក ៥ គឺ បឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតុ និងឧបាទារូប ការសង្គ្រោះរូបដោយចំណែក ៥ យ៉ាងនេះ ។

ចប់ រូបមានប្រមាណ ៥ ។

( ៨ ) ការសង្គ្រោះរូប ដោយចំណែក ៦ គឺ រូបដែលគប្បីដឹងដោយភ្នែក រូបដែលគប្បីដឹងដោយត្រចៀក រូបដែលគប្បីដឹងដោយច្រមុះ រូបដែលគប្បីដឹងដោយអណ្តាត រូបដែលគប្បីដឹងដោយកាយ រូបដែលគប្បីដឹងដោយចិត្ត ការសង្គ្រោះរូបដោយចំណែក ៦ យ៉ាងនេះ ។

ចប់ រូបមានប្រមាណ ៦ ។

(៩) សត្តវិធេន រូបសង្គហោ ចក្ខុវិញ្ញេយ្យំ រូបំ សោតវិញ្ញេយ្យំ រូបំ ឃានវិញ្ញេយ្យំ រូបំ ជិវ្ហាវិញ្ញេយ្យំ រូបំ កាយវិញ្ញេយ្យំ រូបំ មនោធាតុវិញ្ញេយ្យំ រូបំ មនោវិញ្ញាណធាតុវិញ្ញេយ្យំ រូបំ ឯវំ សត្តវិធេន រូបសង្គហោ ។

សត្តកំ ។

(១០) អដ្ឋវិធេន រូបសង្គហោ ចក្ខុវិញ្ញេយ្យំ រូបំ សោតវិញ្ញេយ្យំ រូបំ ឃានវិញ្ញេយ្យំ រូបំ ជិវ្ហាវិញ្ញេយ្យំ រូបំ កាយវិញ្ញេយ្យំ រូបំ អត្ថិ សុខសម្ផស្សំ អត្ថិ ទុក្ខសម្ផស្សំ មនោធាតុវិញ្ញេយ្យំ រូបំ មនោវិញ្ញាណធាតុវិញ្ញេយ្យំ រូបំ ឯវំ អដ្ឋវិធេន រូបសង្គហោ ។

អដ្ឋកំ ។

(១១) នវវិធេន រូបសង្គហោ ចក្ខុន្ទ្រិយំ សោតិន្ទ្រិយំ ឃានិន្ទ្រិយំ ជិវ្ហិន្ទ្រិយំ កាយិន្ទ្រិយំ ឥត្ថិន្ទ្រិយំ បុរិសិន្ទ្រិយំ ជីវិតិន្ទ្រិយំ យញ្ច រូបំ ន ឥន្ទ្រិយំ ឯវំ នវវិធេន រូបសង្គហោ ។

នវកំ ។

( ៩ ) ការសង្គ្រោះរូបដោយចំណែក ៧ គឺ រូបដែលគប្បីដឹងដោយភ្នែក រូបដែលគប្បីដឹងដោយត្រចៀក រូបដែលគប្បីដឹងដោយច្រមុះ រូបដែលគប្បីដឹងដោយអណ្តាត រូបដែលគប្បីដឹង ដោយកាយ រូបដែលគប្បីដឹងដោយមនោធាតុ រូបដែលគប្បីដឹង ដោយមនោវិញ្ញាណធាតុ ការសង្គ្រោះរូបដោយចំណែក ៧ យ៉ាងនេះ ។

ចប់ រូបមានប្រមាណ ៧ ។

( ១០ ) ការសង្គ្រោះរូបដោយចំណែក ៨ គឺ រូបដែលគប្បីដឹងដោយភ្នែក រូបដែលគប្បីដឹងដោយត្រចៀក រូបដែលគប្បីដឹងដោយច្រមុះ រូបដែលគប្បីដឹង ដោយអណ្តាត រូបដែលគប្បីដឹងដោយកាយ រូបមានសម្ផស្សជាសុខ មានសម្ផស្សជាទុក្ខ រូបដែលគប្បីដឹង ដោយមនោធាតុ រូបដែលគប្បីដឹងដោយមនោវិញ្ញាណធាតុ ការសង្គ្រោះរូបដោយចំណែក ៨ យ៉ាងនេះ ។

ចប់ រូបមានប្រមាណ ៨ ។

(១១) ការសង្គ្រោះរូបដោយចំណែក ៩ គឺ ចក្ខុន្ទ្រិយ សោតិន្ទ្រិយ ឃានិន្ទ្រិយ ជិវ្ហិន្ទ្រិយ កាយិន្ទ្រិយ ឥត្ថិន្ទ្រិយ បុរិសិន្ទ្រិយ ជីវិតិន្ទ្រិយ និងរូប ដែលមិនមែនជាឥន្ទ្រិយ ការសង្គ្រោះរូប ដោយចំណែក ៩ យ៉ាងនេះ ។

ចប់ រូបមានប្រមាណ ៩ ។

អព្យាកតេ រូបសង្គហេ មាតិកា

(១២) ទសវិធេន រូបសង្គហោ ចក្ខុន្ទ្រិយំ សោតិន្ទ្រិយំ ឃានិន្ទ្រិយំ ជិវ្ហិន្ទ្រិយំ កាយិន្ទ្រិយំ ឥត្ថិន្ទ្រិយំ បុរិសិន្ទ្រិយំ ជីវិតិន្ទ្រិយំ ន ឥន្ទ្រិយំ រូបំ អត្ថិ សប្បដិឃំ អត្ថិ អប្បដិឃំ ឯវំ ទសវិធេន រូបសង្គហោ ។

ទសកំ ។

(១៣) ឯកាទសវិធេន រូបសង្គហោ ចក្ខាយតនំ សោតាយតនំ ឃានាយតនំ ជិវ្ហាយតនំ កាយាយតនំ រូបាយតនំ សទ្ទាយតនំ គន្ធាយតនំ រសាយតនំ ផោដ្ឋព្វាយតនំ យញ្ច រូបំ អនិទស្សនំ អប្បដិឃំ ធម្មាយតនបរិយាបន្នំ ឯវំ ឯកាទសវិធេន រូបសង្គហោ ។

ឯកាទសកំ ។

មាតិកា ។

(១៤) សព្វំ រូបំ នហេតុមេវ អហេតុកមេវ ហេតុវិប្បយុត្តមេវ សប្បច្ចយមេវ សង្ខតមេវ រូបមេវ លោកិយមេវ សាសវមេវ សញ្ញោជនិយមេវ គន្ថនិយមេវ ឱឃនិយមេវ យោគនិយមេវ នីវរណិយមេវ

[ ១២ ] ការសង្គ្រោះរូបដោយចំណែក ១០ គឺ ចក្ខុន្ទ្រិយ សោតិន្ទ្រិយ ឃានិន្ទ្រិយ ជិវ្ហិន្ទ្រិយ កាយិន្ទ្រិយ ឥត្ថិន្ទ្រិយ បុរិសិន្ទ្រិយ ជីវិតិន្ទ្រិយ រូបមិនមែនជាឥន្ទ្រិយ រូបជាសប្បដិឃៈ ជាអប្បដិឃៈ ការសង្គ្រោះរូបដោយចំណែក ១០ យ៉ាងនេះ ។

ចប់ រូបមានប្រមាណ ១០ ។

[ ១៣ ] ការសង្គ្រោះរូបដោយចំណែក ១១ គឺ ចក្ខាយតនៈ សោតាយតនៈ ឃានាយតនៈ ជិវ្ហាយតនៈ កាយាយតនៈ រូបាយតនៈ សទ្ទាយតនៈ គន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈ និងរូបជាអនិទស្សនៈ ជាអប្បដិឃៈ ដែលរាប់ចូលក្នុងធម្មាយតនៈ ការសង្គ្រោះរូបដោយចំណែក ១១ យ៉ាងនេះ ។

ចប់ រូបមានប្រមាណ ១១ ។

ចប់ មាតិកា ។

[ ១៤ ] រូបទាំងអស់ សុទ្ធតែគ្មានហេតុ សុទ្ធតែឥតហេតុ សុទ្ធតែប្រាសចាកហេតុ សុទ្ធតែប្រកបដោយបច្ច័យ សុទ្ធតែមានបច្ច័យតាក់តែង សុទ្ធតែជារូបតែម្យ៉ាង សុទ្ធតែជាប់នៅក្នុងលោក សុទ្ធតែប្រកបដោយអាសវៈ សុទ្ធតែជាប្រយោជន៍ដល់សញ្ញោជនៈ សុទ្ធតែជារូបដែលគន្ថៈគប្បីដោតក្រង សុទ្ធតែជារូបដែលឱឃៈគប្បីប្រព្រឹត្តកន្លង សុទ្ធតែជារូបដែលយោគៈគប្បីប្រព្រឹត្តកន្លង សុទ្ធតែជាប្រយោជន៍ដល់នីវរណៈ

បរាមដ្ឋមេវ ឧបាទានិយមេវ សង្កិលេសិកមេវ អព្យាកតមេវ អនារម្មណមេវ អចេតសិកមេវ ចិត្តវិប្បយុត្តមេវ នេវវិបាកនវិបាកធម្មធម្មមេវ អសង្កិលិដ្ឋសង្កិលេសិកមេវ នសវិតក្កសវិចារមេវ នអវិតក្កវិចារមត្តមេវ អវិតក្កអវិចារមេវ នបីតិសហគតមេវ នសុខសហគតមេវ នឧបេក្ខាសហគតមេវ នេវទស្សនេន នភាវនាយ បហាតព្វមេវ នេវទស្សនេន នភាវនាយ បហាតព្វហេតុកមេវ នេវអាចយគាមិនអបចយគាមិមេវ នេវសេក្ខានាសេក្ខមេវ បរិត្តមេវ កាមាវចរមេវ នរូបាវចរមេវ នអរូបាវចរមេវ បរិយាបន្នមេវ នោអបរិយាបន្នមេវ អនិយតមេវ អនិយ្យានិកមេវ ឧប្បន្នំ ឆហិ វិញ្ញាណេហិ វិញ្ញេយ្យមេវ អនិច្ចមេវ ជរាភិភូតមេវ ឯវំ ឯកវិធេន រូបសង្គហោ ។

ឯកកនិទ្ទេសោ ។

(១៥) កតមន្តំ រូបំ ឧបាទា ។ ចក្ខាយតនំ សោតាយតនំ ឃានាយតនំ ជិវ្ហាយតនំ កាយាយតនំ

សុទ្ធតែជារូប ដែលបកមាសៈស្លាបអន្លើល សុទ្ធតែជាប្រយោជន៍ដល់ឧបាទាន សុទ្ធតែគួរដល់សេចក្ដីសៅហ្មង សុទ្ធតែជាអព្យាក្រឹត សុទ្ធតែគ្មានអារម្មណ៍ សុទ្ធតែមិនមែនជាចេតសិក សុទ្ធតែប្រាសចាកចិត្ត សុទ្ធតែមិនមែនជាវិបាក មិនមែនមានវិបាកជាធម្មតា ជារូបមិនសៅហ្មង តែគួរដល់សេចក្ដីសៅហ្មង មិនមែនប្រកបដោយវិតក្កៈ ប្រកបដោយវិចារៈទេ មិនមែនមិនមានវិតក្កៈ មានត្រឹមតែវិចារៈទេ សុទ្ធតែមិនមានវិតក្កៈមិនមានវិចារៈ មិនមែនប្រកបដោយបីតិ មិនប្រកបដោយសុខៈ មិនប្រកបដោយឧបេក្ខា ជារូបមិនគប្បីលះដោយទស្សនៈ មិនគប្បីលះដោយភាវនា ជារូបមានហេតុមិនគប្បីលះដោយទស្សនៈ មិនគប្បីលះដោយភាវនា មិនដល់នូវការសន្សំកពូនឡើង មិនមែនជាការមិនដល់នូវការសន្សំកពូនឡើង មិនមែនជាសេក្ខៈ មិនមែនជាអសេក្ខៈ ជារូបតូចឆ្មារ ជាកាមាវចរ មិនមែនជារូបាវចរ មិនមែនជាអរូបាវចរ រាប់ចូលក្នុងវដ្ដៈ មិនមែនមិនរាប់ចូលក្នុងវដ្ដៈ ជាអនិយតៈ មិនមែនជានិយ្យានិកៈ ជារូបកើតឡើងហើយ គប្បីដឹងដោយវិញ្ញាណ ៦ ជារូបមិនទៀង សុទ្ធតែត្រូវជរាគ្របសង្កត់បាន ការសង្គ្រោះរូបដោយចំណែក ១ យ៉ាងនេះ ។

ចប់ ឯកកនិទ្ទេស ។

[ ១៤ ] រូបជាឧបាទានោះ តើដូចម្ដេច ។ ចក្ខាយតនៈ សោតាយតនៈ ឃានាយតនៈ ជិវ្ហាយតនៈ កាយាយតនៈ

រូបាយតនំ សទ្ទាយតនំ គន្ធាយតនំ រសាយតនំ ឥត្-ថិន្ទ្រិយំ បុរិសិន្ទ្រិយំ ជីវិតិន្ទ្រិយំ កាយវិញ្ញត្តិ វចី-វិញ្ញត្តិ អាកាសធាតុ រូបស្ស លហុតា រូបស្ស មុទុតា រូបស្ស កម្មញ្ញតា រូបស្ស ឧបចយោ រូបស្ស សន្តតិ រូបស្ស ជរតា រូបស្ស អនិច្ចតា កពឡីការោ អាហារោ ។

(៣៦) កតមន្តំ រូបំ ចក្ខាយតនំ ។ យំ ចក្ខុំ ចតុន្នំ មហាភូតានំ ឧបាទាយ បសាទោ អត្តភាវបរិយាបន្នោ អនិទស្សនោ សប្បដិឃោ យេន ចក្ខុនា អនិទស្សនេន សប្បដិឃេន រូបំ សនិទស្សនំ សប្បដិឃំ បស្សិ វា បស្សតិ វា បស្សិស្សតិ វា បស្សេ វា ចក្ខុំបេតំ ចក្ខាយតនំបេតំ ចក្ខុធាតុបេសា ចក្ខុន្ទ្រិយំបេតំ លោកោបេសោ ទ្វារាបេសា សមុទ្ទោបេសោ បណ្ឌរំបេតំ ខេត្តំបេតំ វត្ថុំបេតំ

អព្យាកតៈ រូបសង្គហៈ ទុកនិទ្ទេស

រូបាយតនៈ សទ្ទាយតនៈ គន្ធាយតនៈ រសាយតនៈ ឥត្ថិន្ទ្រិយ បុរិសិន្ទ្រិយ ជីវិតិន្ទ្រិយ កាយវិញ្ញត្តិ វចីវិញ្ញត្តិ អាកាសធាតុ រូបស្ស-លហុតា រូបស្សមុទុតា រូបស្សកម្មញ្ញតា រូបស្សឧបចយៈ រូបស្ស-សន្តតិ រូបស្សជរតា រូបស្សអនិច្ចតា កពឡីការាហារ ។

[១៦] រូបជាចក្ខាយតនៈនោះ តើដូចម្តេច ។ ភ្នែកណា គឺប្រសាទ អាស្រ័យមហាភូតទាំង ៤ រាប់ចូលក្នុងអត្តភាព ដែលមិនអាចឃើញដោយចក្ខុវិញ្ញាណ ប្រកបដោយការប៉ះពាល់ (ឬថា) បុគ្គលឃើញហើយក្តី កំពុងឃើញក្តី នឹងឃើញក្តី គប្បីឃើញក្តី នូវរូបដែលប្រកបដោយការឃើញ ប្រកបដោយការប៉ះពាល់ដោយភ្នែកណា ដែលមិនអាចឃើញដោយចក្ខុវិញ្ញាណ ប្រកបដោយការប៉ះពាល់ ភ្នែកនុ៎ះ ហៅថាចក្ខុក៏បាន (ព្រោះជាអ្នកត្រួតត្រាខាងការឃើញ) ហៅថាចក្ខាយតនៈក៏បាន (ព្រោះជាទីប្រជុំចុះនៃកំណើតរបស់ខ្លួន) ហៅថាចក្ខុធាតុក៏បាន (ព្រោះជាសភាវៈសូន្យ ទាំងមិនមែន) ហៅថាចក្ខុន្ទ្រិយក៏បា (ព្រោះមាននាទីខាងការឃើញ) ហៅថាលោកក៏បាន (ព្រោះជារបស់សម្រាប់វិនាស) ហៅថាទ្វារក៏បាន (ព្រោះជារបស់សម្រាប់បើកបិទ) ហៅថាសមុទ្រក៏បាន (ព្រោះបំពេញបានដោយក្រ) ហៅថាបណ្ឌរៈក៏បាន (ព្រោះជារបស់ថ្លាបរិសុទ្ធ) ហៅថាខេត្តក៏បាន (ព្រោះជាកន្លែងកើតផស្សៈជាដើម) ហៅថាវត្ថុក៏បាន (ព្រោះជាទីតម្កល់ផស្សៈជាដើម)

នេត្តំបេតំ នយនំបេតំ ឱរិមន្តីរំបេតំ សុញ្ញោ គាមោបេសោ ឥទន្តំ រូបំ ចក្ខាយតនំ ។ កតមន្តំ រូបំ ចក្ខាយតនំ ។ យំ ចក្ខុំ ចតុន្នំ មហាភូតានំ ឧបាទាយ បសាទោ អត្តភាវបរិយាបន្នោ អនិទស្សនោ សប្បដិឃោ យម្ហិ ចក្ខុម្ហិ អនិទស្សនម្ហិ សប្បដិឃម្ហិ រូបំ សនិទស្សនំ សប្បដិឃំ បដិហញ្ញិ វា បដិហញ្ញតិ វា បដិហញ្ញិស្សតិ វា បដិហញ្ញេ វា ចក្ខុំបេតំ ចក្ខាយតនំបេតំ ចក្ខុធាតុបេសា ចក្ខុន្ទ្រិយំបេតំ លោកោបេសោ ទ្វារាបេសា សមុទ្ទោបេសោ បណ្ឌរំបេតំ ខេត្តំបេតំ វត្ថុំបេតំ នេត្តំបេតំ នយនំបេតំ ឱរិមន្តីរំបេតំ សុញ្ញោ គាមោបេសោ ឥទន្តំ រូបំ ចក្ខាយតនំ ។ កតមន្តំ រូបំ ចក្ខាយតនំ ។ យំ ចក្ខុំ ចតុន្នំ មហាភូតានំ ឧបាទាយ បសាទោ អត្តភាវបរិយាបន្នោ

ហៅថានេត្រក៏បាន (ព្រោះបង្ហាញទីស្មើនិងទីមិនស្មើ ហើយនាំអត្តភាពទៅ) ហៅថានយនៈក៏បាន (ព្រោះសេចក្ដីដូចគ្នានឹងនេត្រនោះ) ហៅថាត្រើយអាយក៏បាន (ព្រោះរាប់បញ្ចូលខាងកាយខ្លួន) ហៅថាស្រុកទំនេរក៏បាន (ព្រោះជារបស់សាធារណ៍ដល់របស់ច្រើន ទាំងគ្មានម្ចាស់) នេះរូបជាចក្ខាយតនៈ ។ រូបជាចក្ខាយតនៈនោះ តើដូចម្ដេច ។ ភ្នែកណា គឺប្រសាទ អាស្រ័យមហាភូតទាំង ៤ ដែលរាប់ចូលក្នុងអត្តភាព ដែលមិនអាចឃើញដោយចក្ខុវិញ្ញាណ ប្រកបដោយការប៉ះពាល់ (ឬ ថា) បុគ្គលខ្លាំងខ្លប់ហើយក្ដី កំពុងខ្លាំងខ្លប់ក្ដី នឹងខ្លាំងខ្លប់ក្ដី គប្បីខ្លាំងខ្លប់ក្ដី នូវរូបដែលប្រកបដោយការឃើញ ប្រកបដោយការប៉ះពាល់ ក្នុងភ្នែកណា ដែលមិនអាចឃើញដោយចក្ខុវិញ្ញាណ ប្រកបដោយការប៉ះពាល់ ភ្នែកនុ៎ះ ហៅថាចក្ខុក៏បាន ថាចក្ខាយតនៈក៏បាន ថាចក្ខុធាតុក៏បាន ថាចក្ខុន្ទ្រិយក៏បាន ថាលោកក៏បាន ថាទ្វារក៏បាន ថាសមុទ្រក៏បាន ថាបណ្ឌរៈក៏បាន ថាខេត្តក៏បាន ថាវត្ថុក៏បាន ថានេត្រក៏បាន ថា នយនៈក៏បាន ថាត្រើយខាងអាយក៏បាន ថាស្រុកទំនេរក៏បាន នេះរូបជាចក្ខាយតនៈ ។ រូបជាចក្ខាយតនៈនោះ តើដូចម្ដេច ។ ភ្នែកណា គឺប្រសាទ អាស្រ័យមហាភូតទាំង ៤ រាប់ចូលក្នុងអត្តភាព

## អព្យាកតេ រូបសង្គហេ ទុកនិទ្ទេសោ

អនិទស្សនោ សប្បដិឃោ យំ ចក្ខុំ អនិទស្សនំ សប្ប-
ដិឃំ រូបម្ហិ សនិទស្សនម្ហិ សប្បដិឃម្ហិ បដិហញ្ញិ វា
បដិហញ្ញតិ វា បដិហញ្ញិស្សតិ វា បដិហញ្ញេ វា ចក្ខុំ-
បេតំ ចក្ខាយតនំបេតំ ចក្ខុធាតុបេសា ចក្ខុន្ទ្រិយំបេតំ
លោកោបេសោ ទ្វារាបេសា សមុទ្ទោបេសោ បណ្ឌរំ-
បេតំ ខេត្តំបេតំ វត្ថុំបេតំ នេត្តំបេតំ នយនំបេតំ ឱរិមន្តីរំ-
បេតំ សុញ្ញោ គាមោបេសោ ឥទន្តំ រូបំ ចក្ខាយ-
តនំ ។ កតមន្តំ រូបំ ចក្ខាយតនំ ។ យំ ចក្ខុំ
ចតុន្នំ មហាភូតានំ ឧបាទាយ បសាទោ អត្តភាវបរិ-
យាបន្នោ អនិទស្សនោ សប្បដិឃោ យំ ចក្ខុំ និស្សា-
យ រូបំ អារព្ភ ចក្ខុសម្ផស្សោ ឧប្បជ្ជិ វា ឧប្បជ្ជតិ
វា ឧប្បជ្ជិស្សតិ វា ឧប្បជ្ជេ វា ៗ បេ ៗ យំ ចក្ខុំ
និស្សាយ រូបំ អារព្ភ ចក្ខុសម្ផស្សជា វេទនា ៗ បេ ៗ
សញ្ញា ៗ បេ ៗ ចេតនា ៗ បេ ៗ ចក្ខុវិញ្ញាណំ ឧប្ប-
ជ្ជិ វា ឧប្បជ្ជតិ វា ឧប្បជ្ជិស្សតិ វា ឧប្បជ្ជេ វា ៗ បេ ៗ
យំ ចក្ខុំ និស្សាយ រូបារម្មណោ ចក្ខុសម្ផស្សោ ឧប្បជ្ជិ
វា ឧប្បជ្ជតិ វា ឧប្បជ្ជិស្សតិ វា ឧប្បជ្ជេ វា ៗ បេ ៗ

ដែលមិនអាចឃើញ ដោយចក្ខុវិញ្ញាណបាន ប្រកបដោយការប៉ះពាល់ ឬថា ភ្នែកណា ដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ ខ្ទាំងខ្ទប់ហើយក្តី កំពុងខ្ទាំងខ្ទប់ក្តី នឹងខ្ទាំងខ្ទប់ក្តី គប្បីខ្ទាំងខ្ទប់ក្តី កងរូប ដែលប្រកបដោយការឃើញ ប្រកបដោយការប៉ះពាល់ ភ្នែកនុ៎ះ ហៅថា ចក្ខុក៏បាន ថាចក្ខាយតនៈក៏បាន ថាចក្ខុធាតុក៏បាន ថាចក្ខុន្ទ្រិយក៏បាន ថាលោកក៏បាន ថាទ្វារក៏បាន ថាសមុទ្រក៏បាន ថាបណ្ឌរៈក៏បាន ថាខេត្តក៏បាន ថាវត្ថុក៏បាន ថានេត្រក៏បាន ថានយនៈក៏បាន ថាត្រើយអាយក៏បាន ថាស្រុកទំនេរក៏បាន នេះរូបជាចក្ខាយតនៈ ។ រូបជាចក្ខាយតនៈនោះ តើដូចម្តេច ។ ភ្នែកណា គឺប្រសាទ អាស្រ័យមហាភូតទាំង ៤ រាប់ចូលក្នុងអត្តភាព មិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ ឬថា ចក្ខុសម្ផស្សប្រារព្ធរូប កើតឡើងហើយក្តី កំពុងកើតក្តី នឹងកើតក្តី គប្បីកើតក្តី ព្រោះអាស្រ័យភ្នែកណា ។ បេ ។ វេទនាកើតអំពីចក្ខុសម្ផស្សប្រារព្ធរូប ព្រោះអាស្រ័យនូវភ្នែកណា ។ បេ ។ សញ្ញា ។ បេ ។ ចេតនា ។ បេ ។ ចក្ខុវិញ្ញាណ កើតឡើងហើយក្តី កំពុងកើតក្តី នឹងកើតក្តី គប្បីកើតក្តី ។ បេ ។ ចក្ខុសម្ផស្ស មានរូបជាអារម្មណ៍ កើតឡើងហើយក្តី កំពុងកើតក្តី នឹងកើតក្តី គប្បីកើតក្តី ព្រោះអាស្រ័យភ្នែកណា ។ បេ ។

យំ ចក្ខុំ និស្សាយ រូបារម្មណា ចក្ខុសម្ផស្ស-
ជា វេទនា ។បេ។ សញ្ញា ។បេ។ ចេតនា ។បេ។
ចក្ខុវិញ្ញាណំ ឧប្បជ្ជិ វា ឧប្បជ្ជតិ វា ឧប្បជ្ជិស្ស-
តិ វា ឧប្បជ្ជេ វា ចក្ខុំបេតំ ចក្ខាយតនំបេតំ
ចក្ខុធាតុបេសា ចក្ខុន្ទ្រិយំបេតំ លោកោបេសោ
ទ្វារាបេសា សមុទ្ទោបេសោ បណ្ឌរំបេតំ ខេត្តំបេតំ
វត្ថុំបេតំ នេត្តំបេតំ នយនំបេតំ ឱរិមតីរំបេតំ សុ-
ញ្ញោ គាមោបេសោ ឥទន្តំ រូបំ ចក្ខាយតនំ ។

(១៧) កតមន្តំ រូបំ សោតាយតនំ ។ យំ
សោតំ ចតុន្នំ មហាភូតានំ ឧបាទាយ បសាទោ
អត្តភាវបរិយាបន្នោ អនិទស្សនោ សប្បដិឃោ យេន
សោតេន អនិទស្សនេន សប្បដិឃេន សទ្ទំ អ-
និទស្សនំ សប្បដិឃំ សុណិ វា សុណាតិ វា
សុណិស្សតិ វា សុណេ វា សោតំបេតំ សោ-
តាយតនំបេតំ សោតធាតុបេសា សោតិន្ទ្រិយំបេតំ
លោកោបេសោ ទ្វារាបេសា សមុទ្ទោបេសោ
បណ្ឌរំបេតំ ខេត្តំបេតំ វត្ថុំបេតំ ឱរិមតីរំបេតំ សុ-
ញ្ញោ គាមោបេសោ ឥទន្តំ រូបំ សោតាយតនំ ។

វេទនាកើតអំពីចក្ខុសម្ផស្ស មានរូបជាអារម្មណ៍ ព្រោះអាស្រ័យភ្នែកណា ។ បេ ។ សញ្ញា ។ បេ ។ ចេតនា ។ បេ ។ ចក្ខុវិញ្ញាណ កើតឡើងហើយក្តី កំពុងកើតក្តី នឹងកើតក្តី គប្បីកើតក្តី ភ្នែកនុ៎ះ ហៅថាចក្ខុក៏បាន ថាចក្ខាយតនៈក៏បាន ថាចក្ខុធាតុក៏បាន ថាចក្ខុន្ទ្រិយក៏បាន ថាលោកក៏បាន ថាទ្វារក៏បាន ថាសមុទ្រក៏បាន ថាបណ្ឌរៈក៏បាន ថាខេត្តក៏បាន ថាវត្ថុក៏បាន ថានេត្រក៏បាន ថានយនៈក៏បាន ថាត្រើយអាយក៏បាន ថាស្រុកទំនេរក៏បាន នេះរូបជាចក្ខាយតនៈ ។

( ១៧ ) រូបជាសោតាយតនៈនោះ តើដូចម្តេច ។ ត្រចៀកណា គឺប្រសាទ អាស្រ័យមហាភូតទាំង ៤ រាប់ចូលក្នុងអត្តភាព មិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ ឬថាបុគ្គលស្តាប់ហើយក្តី កំពុងស្តាប់ក្តី នឹងស្តាប់ក្តី គប្បីស្តាប់ក្តី នូវសំឡេងដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ ដោយត្រចៀកណា ដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ ត្រចៀកនុ៎ះ ហៅថាសោតៈក៏បាន ថាសោតាយតនៈក៏បាន ថាសោតធាតុក៏បាន ថាសោតិន្ទ្រិយក៏បាន ថាលោកក៏បាន ថាទ្វារក៏បាន ថាសមុទ្ទក៏បាន ថាបណ្ឌរៈក៏បាន ថាខេត្តក៏បាន ថាវត្ថុក៏បាន ថាត្រើយអាយក៏បាន ថាស្រុកទំនេរក៏បាន នេះរូបជាសោតាយតនៈ ។

អព្យាកតេ រូបសង្គហេ ទុកនិទ្ទេសោ

កតមន្តំ រូបំ សោតាយតនំ ។ យំ សោតំ ចតុន្នំ មហាភូតានំ ឧបាទាយ បសាទោ អត្តភាវបរិយាបន្នោ អនិទស្សនោ សប្បដិឃោ យម្ហិ សោតម្ហិ អនិទស្សនម្ហិ សប្បដិឃម្ហិ សទ្ទោ អនិទស្សនោ សប្បដិឃោ បដិហញ្ញិ វា បដិហញ្ញតិ វា បដិហញ្ញិស្សតិ វា បដិហញ្ញេ វា សោតំបេតំ សោតាយតនំបេតំ សោតធាតុបេសា សោតិន្ទ្រិយំបេតំ លោកោបេសោ ទ្វារាបេសា សមុទ្ទោបេសោ បណ្ឌរំបេតំ ខេត្តំបេតំ វត្ថុំបេតំ ឱរិមន្តីរំបេតំ សុញ្ញោ គាមោបេសោ ឥទន្តំ រូបំ សោតាយតនំ ។ កតមន្តំ រូបំ សោតាយតនំ ។ យំ សោតំ ចតុន្នំ មហាភូតានំ ឧបាទាយ បសាទោ អត្តភាវបរិយាបន្នោ អនិទស្សនោ សប្បដិឃោ យំ សោតំ អនិទស្សនំ សប្បដិឃំ សទ្ទម្ហិ អនិទស្សនម្ហិ សប្បដិឃម្ហិ បដិហញ្ញិ វា បដិហញ្ញតិ វា បដិហញ្ញិស្សតិ វា បដិហញ្ញេ វា សោតំបេតំ សោតាយនំបេតំ សោតធាតុបេសា សោតិន្ទ្រិយំបេតំ លោកោបេសោ ទ្វារាបេសា សមុទ្ទោបេសោ បណ្ឌរំបេតំ ខេត្តំបេតំ

រូបជាសោតាយតនៈនោះ តើដូចម្តេច ។ ត្រចៀកណា គឺប្រសាទ អាស្រ័យមហាភូតទាំង ៤ រាប់ចូលក្នុងអត្តភាព ដែលមិនអាចឃើញបាន ប្រកបដោយការប៉ះពាល់ ឬជាសំឡេងដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ ខ្ទាំងខ្ទប់ហើយក្តី កំពុងខ្ទាំងខ្ទប់ក្តី នឹងខ្ទាំងខ្ទប់ក្តី គប្បីខ្ទាំងខ្ទប់ក្តី ក្នុងត្រចៀកណា ដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ ត្រចៀកនុ៎ះ ហៅថាសោតៈក៏បាន ជាសោតាយតនៈក៏បាន ជាសោតធាតុក៏បាន ជាសោតិន្ទ្រិយក៏បាន ជាលោកក៏បាន ជាទ្វារក៏បាន ជាសមុទ្ទក៏បាន ជាបណ្ឌរៈក៏បាន ជាខេត្តក៏បាន ជាវត្ថុក៏បាន ជាត្រើយអាយក៏បាន ជាស្រុកទំនេរក៏បាន នេះរូបជាសោតាយតនៈ ។ រូបជាសោតាយតនៈនោះ តើដូចម្តេច ។ ត្រចៀកណាគឺប្រសាទ អាស្រ័យមហាភូតទាំង ៤ រាប់ចូលក្នុងអត្តភាព ដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ ឬជាត្រចៀកណា ដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ ខ្ទាំងខ្ទប់ហើយក្តី កំពុងខ្ទាំងខ្ទប់ក្តី នឹងខ្ទាំងខ្ទប់ក្តី គប្បីខ្ទាំងខ្ទប់ក្តី ក្នុងសំឡេងដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ ត្រចៀកនុ៎ះ ហៅថាសោតៈក៏បាន ជាសោតាយតនៈក៏បាន ជាសោតធាតុក៏បាន ជាសោតិន្ទ្រិយក៏បាន ជាលោកក៏បាន ជាទ្វារក៏បាន ជាសមុទ្ទក៏បាន ជាបណ្ឌរៈក៏បាន ជាខេត្តក៏បាន

វត្ថុំបេតំ ឱរិមតីរំបេតំ សុញ្ញោ គាមោបេសោ ឥទន្តំ រូបំ សោតាយតនំ ។ កតមន្តំ រូបំ សោតាយតនំ ។ យំ សោតំ ចតុន្នំ មហាភូតានំ ឧបាទាយ បសាទោ អត្តភាវបរិយាបន្នោ អនិទស្សនោ សប្បដិឃោ យំ សោតំ និស្សាយ សទ្ទំ អារព្ភ សោតសម្ផស្សោ ឧប្បជ្ជិ វា ឧប្បជ្ជតិ វា ឧប្បជ្ជិស្សតិ វា ឧប្បជ្ជេ វា ។ បេ ។ យំ សោតំ និស្សាយ សទ្ទំ អារព្ភ សោតសម្ផស្សជា វេទនា ។ បេ ។ សញ្ញា ។ បេ ។ ចេតនា ។ បេ ។ សោតវិញ្ញាណំ ឧប្បជ្ជិ វា ឧប្បជ្ជតិ វា ឧប្បជ្ជិស្សតិ វា ឧប្បជ្ជេ វា ។ បេ ។ យំ សោតំ និស្សាយ សទ្ទារម្មណោ សោតសម្ផស្សោ ឧប្បជ្ជិ វា ឧប្បជ្ជតិ វា ឧប្បជ្ជិស្សតិ វា ឧប្បជ្ជេ វា ។ បេ ។ យំ សោតំ និស្សាយ សទ្ទារម្មណា សោតសម្ផស្សជា វេទនា ។ បេ ។ សញ្ញា ។ បេ ។ ចេតនា ។ បេ ។ សោតវិញ្ញាណំ ឧប្បជ្ជិ វា ឧប្បជ្ជតិ វា ឧប្បជ្ជិស្សតិ វា ឧប្បជ្ជេ វា សោតំបេតំ សោតាយតនំបេតំ សោតធាតុបេសា សោតិន្ទ្រិយំបេតំ លោកោបេសោ

ថាវត្ថុក៏បាន ថាត្រើយអាយក៏បាន ថាស្រុកទំនេរក៏បាន នេះរូបជាសោតាយតនៈ ៗ រូបជាសោតាយតនៈនោះ តើដូចម្ដេច ៗ ត្រចៀកណា គឺប្រសាទៈ អាស្រ័យមហាភូតទាំង៤ កប់ចូលក្នុងអត្តភាព មិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ ឬថាសោតសម្ផ័ស្ស ប្រារព្ធនូវសំឡេង កើតឡើងហើយក្ដី កំពុងកើតក្ដី នឹងកើតក្ដី គប្បីកើតក្ដី ព្រោះអាស្រ័យត្រចៀកណា ៗ បេ ៗ វេទនាកើតអំពីសោតសម្ផ័ស្ស ប្រារព្ធនូវសំឡេង ព្រោះអាស្រ័យត្រចៀកណា ៗ បេ ៗ សញ្ញា ៗ បេ ៗ ចេតនា ៗ បេ ៗ សោតវិញ្ញាណ កើតឡើងហើយក្ដី កំពុងកើតក្ដី នឹងកើតក្ដី គប្បីកើតក្ដី ៗ បេ ៗ សោតសម្ផ័ស្ស មានសំឡេងជាអារម្មណ៍ កើតឡើងហើយក្ដី កំពុងកើតក្ដី នឹងកើតក្ដី គប្បីកើតក្ដី ព្រោះអាស្រ័យត្រចៀកណា ៗ បេ ៗ វេទនាកើតអំពីសោតសម្ផ័ស្ស មានសំឡេងជាអារម្មណ៍ អាស្រ័យនូវត្រចៀកណា ៗ បេ ៗ សញ្ញា ៗ បេ ៗ ចេតនា ៗ បេ ៗ សោតវិញ្ញាណ កើតឡើងហើយក្ដី កំពុងកើតក្ដី នឹងកើតក្ដី គប្បីកើតក្ដី ត្រចៀកនុ៎ះ ហៅថាសោតៈក៏បាន ថាសោតាយតនៈក៏បាន ថាសោតធាតុក៏បាន ថាសោតិន្ទ្រិយក៏បាន ថាលោកក៏បាន

ទ្វារាបេសា សមុទ្ទោបេសោ បណ្ឌរំបេតំ ខេត្តំបេតំ វត្ថុំបេតំ ឱរិមន្តីរំបេតំ សុញ្ញោ គាមោបេសោ ឥទន្តំ រូបំ សោតាយតនំ ។

(១៨) កតមន្តំ រូបំ ឃានាយតនំ ។ យំ ឃានំ ចតុន្នំ មហាភូតានំ ឧបាទាយ បសាទោ អត្តភាវបរិយាបន្នោ អនិទស្សនោ សប្បដិឃោ យេន ឃានេន អនិទស្សនេន សប្បដិឃេន គន្ធំ អនិទស្សនំ សប្បដិឃំ ឃាយិ វា ឃាយតិ វា ឃាយិស្សតិ វា ឃាយេ វា ឃានំបេតំ ឃានាយតនំបេតំ ឃានធាតុបេសា ឃានិន្ទ្រិយំបេតំ លោកោបេសោ ទ្វារាបេសា សមុទ្ទោបេសោ បណ្ឌរំបេតំ ខេត្តំបេតំ វត្ថុំបេតំ ឱរិមន្តីរំបេតំ សុញ្ញោ គាមោបេសោ ឥទន្តំ រូបំ ឃានាយតនំ ។ កតមន្តំ រូបំ ឃានាយតនំ ។ យំ ឃានំ ចតុន្នំ មហាភូតានំ ឧបាទាយ បសាទោ អត្តភាវបរិយាបន្នោ អនិទស្សនោ សប្បដិឃោ យម្ហិ ឃានម្ហិ អនិទស្សនម្ហិ សប្បដិឃម្ហិ គន្ធោ អនិទស្សនោ សប្បដិឃោ បដិហញ្ញិ វា បដិហញ្ញតិ វា បដិហញ្ញិស្សតិ វា បដិហញ្ញេ វា ឃានំបេតំ ឃានាយតនំបេតំ

ជាទ្វារក៏បាន ជាសមុទ្រក៏បាន ជាបណ្ឌរៈក៏បាន ជាខេត្តក៏បាន ជាវត្ថុក៏បាន ជាត្រើយអាយក៏បាន ជាស្រុកទំនេរក៏បាន នេះរូបជាសោតាយតនៈ ។

(១៨) រូបជាឃានាយតនៈនោះ តើដូចម្តេច ។ ប្រមុះណា គឺប្រសាទ អាស្រ័យមហាភូតទាំង ៤ រាប់បញ្ចូលក្នុងអត្តភាព ដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ ឬជាបុគ្គលធុំហើយក្តី កំពុងធុំក្តី នឹងធុំក្តី គប្បីធុំក្តី នូវក្លិនដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ ដោយប្រមុះណា ដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ ប្រមុះនុ៎ះ ហៅថាឃានៈក៏បាន ថាឃានាយតនៈក៏បាន ថាឃានធាតុក៏បាន ថាឃានិន្ទ្រិយក៏បាន ថាលោកក៏បាន ថាទ្វារក៏បាន ថាសមុទ្ទក៏បាន ថាបណ្ឌរៈក៏បាន ថាខេត្តក៏បាន ថាវត្ថុក៏បាន ថាត្រើយអាយក៏បាន ថាស្រុកទំនេរក៏បាន នេះរូបជាឃានាយតនៈ ។ រូបជាឃា-នាយតនៈនោះ តើដូចម្តេច ។ ប្រមុះណា គឺប្រសាទ អាស្រ័យមហាភូតទាំង ៤ រាប់បញ្ចូលក្នុងអត្តភាព ដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ ឬថា ក្លិនដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ ខ្ទាំងខ្ទប់ហើយក្តី កំពុងខ្ទាំងខ្ទប់ក្តី នឹងខ្ទាំងខ្ទប់ក្តី គប្បីខ្ទាំងខ្ទប់ក្តី ក្នុងប្រមុះណា ដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ ប្រមុះនុ៎ះ ហៅថាឃានៈក៏បាន ថាឃានាយតនៈក៏បាន

ឃានធាតុបេសា ឃានិន្ទ្រិយំបេតំ លោកោបេសោ ទ្វារាបេសា សមុទ្ទោបេសោ បណ្ឌរំបេតំ ខេត្តំបេតំ វត្ថុំបេតំ ឱរិមន្តីរំបេតំ សុញ្ញោ គាមោបេសោ ឥទន្តំ រូបំ ឃានាយតនំ ។ កតមន្តំ រូបំ ឃានាយតនំ ។ យំ ឃានំ ចតុន្នំ មហាភូតានំ ឧបាទាយ បសាទោ អត្តភាវបរិយាបន្នោ អនិទស្សនោ សប្បដិឃោ យំ ឃានំ អនិទស្សនំ សប្បដិឃំ គន្ធម្ហិ អនិទស្សនម្ហិ សប្បដិឃម្ហិ បដិហញ្ញិ វា បដិហញ្ញតិ វា បដិហញ្ញិស្សតិ វា បដិហញ្ញេ វា ឃានំបេតំ ឃានាយតនំបេតំ ឃានធាតុបេសា ឃានិន្ទ្រិយំបេតំ លោកោបេសោ ទ្វារាបេសា សមុទ្ទោបេសោ បណ្ឌរំបេតំ ខេត្តំបេតំ វត្ថុំបេតំ ឱរិមន្តីរំបេតំ សុញ្ញោ គាមោបេសោ ឥទន្តំ រូបំ ឃានាយតនំ ។ កតមន្តំ រូបំ ឃានាយតនំ ។ យំ ឃានំ ចតុន្នំ មហាភូតានំ ឧបាទាយ បសាទោ អត្តភាវបរិយាបន្នោ អនិទស្សនោ សប្បដិឃោ យំ ឃានំ និស្សាយ គន្ធំ អារព្ភ ឃានសម្ផស្សោ ឧប្បជ្ជិ វា ឧប្បជ្ជតិ វា ឧប្បជ្ជិស្សតិ វា ឧប្បជ្ជេ វា ។ បេ ។

ថាឃានធាតុក៏បាន ថាឃានិន្ទ្រិយក៏បាន ថាលោកក៏បាន ថាទ្វារក៏បាន ថាសមុទ្រក៏បាន ថាបណ្ឌរៈក៏បាន ថាខេត្តក៏បាន ថាវត្ថុក៏បាន ថាត្រើយអាយក៏បាន ថាស្រុកទំនេរក៏បាន នេះរូបជាឃានាយតនៈ ។ រូបជាឃានាយតនៈនោះ តើដូចម្តេច ។ ប្រមុះណា គឺប្រសាទ អាស្រ័យមហាភូតទាំង ៤ រាប់ចូលក្នុងអត្តភាព ដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ ឬថា ប្រមុះណា ដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ ខ្ទាំងខ្ទប់ហើយក្តី កំពុងខ្ទាំងខ្ទប់ក្តី នឹងខ្ទាំងខ្ទប់ក្តី គប្បីខ្ទាំងខ្ទប់ក្តី ក្នុងក្លិនដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ ប្រមុះនុ៎ះ ហៅថាឃានៈក៏បាន ថាឃានាយតនៈក៏បាន ថាឃានធាតុក៏បាន ថាឃានិន្ទ្រិយក៏បាន ថាលោកក៏បាន ថាទ្វារក៏បាន ថាសមុទ្រក៏បាន ថាបណ្ឌរៈក៏បាន ថាខេត្តក៏បាន ថាវត្ថុក៏បាន ថាត្រើយអាយក៏បាន ថាស្រុកទំនេរក៏បាន នេះរូបជាឃានាយតនៈ ។ រូបជាឃានាយតនៈនោះ តើដូចម្តេច ។ ប្រមុះណា គឺប្រសាទ អាស្រ័យមហាភូតទាំង ៤ រាប់ចូលក្នុងអត្តភាព ដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ ឬថា ឃានសម្ផស្សប្រារព្ធនូវក្លិន កើតឡើងហើយក្តី កំពុងកើតក្តី នឹងកើតក្តី គប្បីកើតក្តី ព្រោះអាស្រ័យនូវប្រមុះណា ។ បេ ។

យំ ឃានំ និស្សាយ គន្ធំ អារព្ភ ឃានសម្ផស្ស-
ជា វេទនា ។ បេ ។ សញ្ញា ។ បេ ។ ចេតនា
។ បេ ។ ឃានវិញ្ញាណំ ឧប្បជ្ជិ វា ឧប្បជ្ជតិ វា
ឧប្បជ្ជិស្សតិ វា ឧប្បជ្ជេ វា ។ បេ ។ យំ ឃានំ
និស្សាយ គន្ធារម្មណោ ឃានសម្ផស្សោ ឧប្បជ្ជិ
វា ឧប្បជ្ជតិ វា ឧប្បជ្ជិស្សតិ វា ឧប្បជ្ជេ វា ។ បេ ។
យំ ឃានំ និស្សាយ គន្ធារម្មណា ឃានសម្ផស្សជា
វេទនា ។ បេ ។ សញ្ញា ។ បេ ។ ចេតនា ។ បេ ។
ឃានវិញ្ញាណំ ឧប្បជ្ជិ វា ឧប្បជ្ជតិ វា ឧប្បជ្ជិស្សតិ
វា ឧប្បជ្ជេ វា ឃានំបេតំ ឃានាយតនំបេតំ ឃាន-
(១៧៨) កតមេ ធម្មា ទស្សនេន បហាតព្វហេតុកា ។ តីណិ សញ្ញោជនានិ សក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសោ ។ តត្ថ កតមា សក្កាយទិដ្ឋិ ។ បេ ។ អយំ វុច្ចតិ សក្កាយទិដ្ឋិ ។ តត្ថ កតមា វិចិកិច្ឆា ។ បេ ។ អយំ វុច្ចតិ វិចិកិច្ឆា ។ តត្ថ កតមោ សីលព្វតបរាមាសោ ។ បេ ។ អយំ វុច្ចតិ សីលព្វតបរាមាសោ ។ ឥមានិ តីណិ សញ្ញោជនានិ តទេកដ្ឋា ច កិលេសា តំសម្បយុត្តោ វេទនាក្ខន្ធោ ។ បេ ។ វិញ្ញាណក្ខន្ធោ តំសមុដ្ឋានំ កាយកម្មំ វចីកម្មំ មនោកម្មំ

ដ៏សេសសល់ ទាំងពួកកិលេសដែលតាំងនៅជាមួយគ្នា ទាំងកិលេសមានលោភៈជាដើមនោះ វេទនាខន្ធ ។ បេ ។ វិញ្ញាណក្ខន្ធ ដែលប្រកបដោយកិលេសមានលោភៈជាដើមនោះ និងកាយកម្ម វចីកម្ម មនោកម្ម ដែលតាំងឡើងអំពីកិលេសមានលោភៈជាដើមនោះ នេះពួកធម៌ត្រូវលះដោយភាវនា ។ ពួកធម៌ មិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា តើដូចម្ដេច ។ ពួកធម៌ ជាកុសលនិងអព្យាក្រឹត ជាកាមាវចរ រូបាវចរ អរូបាវចរ អបរិយាបន្នៈ វេទនាខន្ធ ។ បេ ។ វិញ្ញាណក្ខន្ធ រូបទាំងអស់ និងអសង្ខតធាតុ នេះពួកធម៌ មិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ។

[ ១៧៩ ] ពួកធម៌មានហេតុត្រូវលះដោយទស្សនៈ តើដូចម្ដេច ។ សញ្ញោជនៈ ៣ យ៉ាងគឺ សក្កាយទិដ្ឋិ វិចិកិច្ឆា និងសីលព្វតបរាមាសៈ ។ បណ្ដាសញ្ញោជនៈទាំងនោះ សក្កាយទិដ្ឋិ តើដូចម្ដេច ។ បេ ។ នេះហៅថា សក្កាយទិដ្ឋិ ។ បណ្ដាសញ្ញោជនៈទាំងនោះ វិចិកិច្ឆា តើដូចម្ដេច ។ បេ ។ នេះហៅថា វិចិកិច្ឆា ។ បណ្ដាសញ្ញោជនៈទាំងនោះ សីលព្វតបរាមាសៈ តើដូចម្ដេច ។ បេ ។ នេះហៅថា សីលព្វតបរាមាសៈ ។ សញ្ញោជនៈទាំង៣នេះ ទាំងពួកកិលេសដែលតាំងនៅជាមួយគ្នានឹងកិលេសមានលោភៈជាដើមនោះ វេទនាខន្ធ ។ បេ ។ វិញ្ញាណក្ខន្ធ ដែលប្រកបដោយកិលេសមានលោភៈជាដើមនោះ និងកាយកម្ម វចីកម្ម មនោកម្ម

ឥមេ ធម្មា ទស្សនេន បហាតព្វហេតុកា ។ តីណិ សញ្ញោជនានិ សក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសោ ឥមេ ធម្មា ទស្សនេន បហាតព្វា តទេកដ្ឋោ លោភោ ទោសោ មោហោ ឥមេ ធម្មា ទស្សនេន បហាតព្វហេតូ តទេកដ្ឋា ច កិលេសា តំសម្បយុត្តោ វេទនាក្ខន្ធោ ។ បេ ។ វិញ្ញាណក្ខន្ធោ តំសមុដ្ឋានំ កាយកម្មំ វចីកម្មំ មនោកម្មំ ឥមេ ធម្មា ទស្សនេន បហាតព្វហេតុកា ។ កតមេ ធម្មា ភាវនាយ បហាតព្វហេតុកា ។ អវសេសោ លោភោ ទោសោ មោហោ ឥមេ ធម្មា ភាវនាយ បហាតព្វហេតូ តទេកដ្ឋា ច កិលេសា តំសម្បយុត្តោ វេទនាក្ខន្ធោ ។ បេ ។ វិញ្ញាណក្ខន្ធោ តំសមុដ្ឋានំ កាយកម្មំ វចីកម្មំ មនោកម្មំ ឥមេ ធម្មា ភាវនាយបហាតព្វហេតុកា ។ កតមេ ធម្មា នេវទស្សនេន ន ភាវនាយ បហាតព្វហេតុកា ។ តេ ធម្មេ ឋបេត្វា អវសេសា កុសលាកុសលាព្យាកតា ធម្មា កាមាវចរា រូបាវចរា អរូបាវចរា អបរិយាបន្នា វេទនាក្ខន្ធោ សញ្ញាក្ខន្ធោ សង្ខារក្ខន្ធោ វិញ្ញាណក្ខន្ធោ

ដែលតាំងឡើងអំពីកិលេសមានលោភៈជាដើមនោះ នេះពួកធម៌មានហេតុត្រូវលះដោយទស្សនៈ ។ សញ្ញោជនៈ៣ យ៉ាង គឺ សក្កាយទិដ្ឋិ វិចិកិច្ឆា និងសីលព្វតបរាមាសៈ នេះពួកធម៌ ត្រូវលះដោយទស្សនៈ លោភៈ ទោសៈ មោហៈ ដែលតាំងនៅជាមួយនឹងកិលេស មានលោភៈជាដើមនោះ នេះពួកធម៌ មានហេតុត្រូវលះដោយទស្សនៈ ទាំងពួកកិលេស ដែលតាំងនៅជាមួយនឹងកិលេសមានលោភៈជាដើមនោះ វេទនាខន្ធ ។ បេ ។ វិញ្ញាណក្ខន្ធ ដែលប្រកបដោយកិលេស មានលោភៈជាដើមនោះ និងកាយកម្ម វចីកម្ម មនោកម្ម ដែលតាំងឡើងអំពីកិលេសមានលោភៈជាដើមនោះ នេះពួកធម៌ មានហេតុត្រូវលះដោយទស្សនៈ ។ ពួកធម៌មានហេតុត្រូវលះ ដោយភាវនា តើដូចម្តេច ។ លោភៈ ទោសៈ មោហៈ ដ៏សេសសល់ នេះពួកធម៌ មានហេតុត្រូវលះដោយភាវនា ទាំងពួកកិលេស ដែលតាំងនៅជាមួយនឹងកិលេស មានលោភៈជាដើមនោះ វេទនាខន្ធ ។ បេ ។ វិញ្ញាណក្ខន្ធ ដែលប្រកបដោយកិលេសមានលោភៈជាដើមនោះ និងកាយកម្ម វចីកម្ម មនោកម្ម ដែលតាំងឡើងអំពីកិលេសមានលោភៈជាដើមនោះ នេះពួកធម៌មានហេតុត្រូវលះដោយភាវនា ។ ពួកធម៌មានហេតុមិនត្រូវលះ ដោយទស្សនៈ មិនត្រូវលះដោយភាវនា តើដូចម្តេច ។ វៀរតែធម៌ទាំងនោះចេញ ពួកធម៌ជាកុសល អកុសល និង អព្យាក្រឹត ជាកាមាវចរ រូបាវចរ អរូបាវចរ អបរិយាបន្នៈ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ

សព្វញ្ច រូបំ អសង្ខតា ច ធាតុ ឥមេ ធម្មា នេវ-ទស្សនេន ន ភាវនាយ បហាតព្វហេតុកា ។

(១៧៦) កតមេ ធម្មា អាចយគាមិនោ ។ សាសវា កុសលាកុសលា ធម្មា កាមាវចរា រូបាវចរា អរូបាវចរា វេទនាក្ខន្ធោ ។ បេ ។ វិញ្ញាណក្ខន្ធោ ឥមេ ធម្មា អាចយគាមិនោ ។ កតមេ ធម្មា អបចយគាមិនោ ។ ចត្តារោ មគ្គា អបរិយាបន្នា ឥមេ ធម្មា អបចយគាមិនោ ។ កតមេ ធម្មា នេវាចយគាមិនោ នាបចយគាមិនោ(១) ។ កុសលាកុសលានំ ធម្មានំ វិបាកា កាមាវចរា រូបាវចរា អរូបាវចរា អបរិយាបន្នា វេទនាក្ខន្ធោ ។ បេ ។ វិញ្ញាណក្ខន្ធោ យេ ច ធម្មា កិរិយា នេវ កុសលា នាកុសលា ន ច កម្មវិបាកា សព្វញ្ច រូបំ អសង្ខតា ច ធាតុ ឥមេ ធម្មា នេវាចយគាមិនោ នាបចយគាមិនោ ។

---

១ ឱ. នេវអាចយគាមិនោ ន អបចយគាមិនោ ។

រូបទាំងអស់ និងអសង្ខតធាតុ នេះពួកធម៌ មានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ។

( ១៧៦ ) ពួកធម៌ដល់នូវការសន្សំកពូនឡើង ដោយកម្មកិលេស តើដូចម្តេច ។ ពួកធម៌ប្រកបដោយអាសវៈ ជាកុសលនិងអកុសល ជាកាមាវចរ រូបាវចរ អរូបាវចរ និងវេទនាខន្ធ ។ បេ ។ វិញ្ញាណក្ខន្ធ នេះពួកធម៌ដល់នូវការសន្សំកពូនឡើង ដោយកម្មកិលេស ។ ពួកធម៌មិនដល់នូវការសន្សំកពូនឡើង តើដូចម្តេច ។ មគ្គ ៤ និងអបរិយាបន្នៈ នេះពួកធម៌ មិនដល់នូវការសន្សំកពូនឡើង ។ ពួកធម៌មិនមែនជាដល់នូវការសន្សំកពូនឡើង ទាំងមិនមែនជាមិនដល់ នូវការសន្សំកពូនឡើង តើដូចម្តេច ។ វិបាក ជាកាមាវចរ រូបាវចរ អរូបាវចរ អបរិយាបន្នៈនៃធម៌ជាកុសលនិងអកុសល វេទនាខន្ធ ។ បេ ។ វិញ្ញាណក្ខន្ធ ទាំងពួកធម៌ដែលជាកិរិយា មិនមែនកុសល មិនមែនអកុសល មិនមែនកម្មវិបាក រូបទាំងអស់ និងអសង្ខតធាតុ នេះពួកធម៌មិនមែនជាដល់នូវការសន្សំកពូនឡើង ទាំងមិនមែនជាមិនដល់នូវការសន្សំកពូនឡើង ។

(១៧៧) កតមេ ធម្មា សេក្ខា ។ ចត្តារោ មគ្គា អបរិយាបន្នា ហេដ្ឋិមានិ ច តីណិ សាមញ្ញផលានិ ឥមេ ធម្មា សេក្ខា ។ កតមេ ធម្មា អសេក្ខា ។ ឧបរិដ្ឋិមំ អរហត្តផលំ ឥមេ ធម្មា អសេក្ខា ។ កតមេ ធម្មា នេវ សេក្ខា នាសេក្ខា ។ តេ ធម្មេ ឋបេត្វា អវសេសា កុសលាកុសលាព្យាកតា ធម្មា កាមាវចរា រូបាវចរា អរូបាវចរា វេទនាក្ខន្ធោ ។ បេ ។ វិញ្ញាណក្ខន្ធោ សព្វញ្ច រូបំ អសង្ខតា ច ធាតុ ឥមេ ធម្មា នេវសេក្ខា នាសេក្ខា ។

(១៧៨) កតមេ ធម្មា បរិត្តា ។ សព្វេវ កាមាវចរា កុសលាកុសលាព្យាកតា ធម្មា រូបក្ខន្ធោ ។ បេ ។ វិញ្ញាណក្ខន្ធោ ឥមេ ធម្មា បរិត្តា ។ កតមេ ធម្មា មហគ្គតា ។ រូបាវចរា អរូបាវចរា កុសលាកុសលាព្យាកតា ធម្មា វេទនាក្ខន្ធោ ។ បេ ។ វិញ្ញាណក្ខន្ធោ ឥមេ ធម្មា មហគ្គតា ។ កតមេ ធម្មា អប្បមាណា ។ អបរិយាបន្នា មគ្គា ច មគ្គផលានិ ច អសង្ខតា ច ធាតុ ឥមេ ធម្មា អប្បមាណា ។

( ១៧៧ ) ពួកធម៌ជារបស់សេក្ខបុគ្គល តើដូចម្តេច ។ មគ្គ ៤ ជាអបរិយាបន្នៈ និងសាមញ្ញផល ៣ ខាងក្រោម នេះពួកធម៌ជារបស់សេក្ខបុគ្គល ។ ពួកធម៌ជារបស់អសេក្ខបុគ្គល តើដូចម្តេច ។ អរហត្តផលខាងលើ នេះពួកធម៌ ជារបស់អសេក្ខបុគ្គល ។ ពួកធម៌មិនមែនជារបស់សេក្ខបុគ្គល ទាំងមិនមែនជារបស់អសេក្ខបុគ្គល តើដូចម្តេច ។ វៀរតែធម៌ទាំងនោះចេញ ពួកធម៌ដ៏សេសសល់ ជាកុសល អកុសលនិងអព្យាក្រឹត ជាកាមាវចរ រូបាវចរ អរូបាវចរ វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ រូបទាំងអស់ និងអសង្ខតធាតុ នេះពួកធម៌មិនមែនជារបស់សេក្ខបុគ្គល ទាំងមិនមែនជារបស់អសេក្ខបុគ្គល ។

( ១៧៨ ) ពួកធម៌មានសភាពតូចឆ្មារ តើដូចម្តេច ។ ពួកធម៌ជាកាមាវចរទាំងអស់ ជាកុសល អកុសល អព្យាក្រឹត និងរូបក្ខន្ធ ។បេ។ វិញ្ញាណក្ខន្ធ នេះពួកធម៌មានសភាពតូចឆ្មារ ។ ពួកធម៌ដល់នូវសភាពធំ តើដូចម្តេច ។ ពួកធម៌ជារូបាវចរ អរូបាវចរ ជាកុសល អកុសល អព្យាក្រឹត និងវេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ នេះពួកធម៌ដល់នូវសភាពធំ ។ ពួកធម៌ប្រមាណមិនបាន តើដូចម្តេច ។ មគ្គជាអបរិយាបន្នៈ ផលដែលកើតអំពីមគ្គ និងអសង្ខតធាតុ នេះពួកធម៌ប្រមាណមិនបាន ។

### តិកេ និក្ខេបោ

(១៧៩) កតមេ ធម្មា បរិត្តារម្មណា ។ បរិត្តេ ធម្មេ អារព្ភ យេ ឧប្បជ្ជន្តិ ចិត្តចេតសិកា ធម្មា ឥមេ ធម្មា បរិត្តារម្មណា ។ កតមេ ធម្មា មហគ្គតារម្មណា ។ មហគ្គតេ ធម្មេ អារព្ភ យេ ឧប្បជ្ជន្តិ ចិត្តចេតសិកា ធម្មា ឥមេ ធម្មា មហគ្គតារម្មណា ។ កតមេ ធម្មា អប្បមាណារម្មណា ។ អប្បមាណេ ធម្មេ អារព្ភ យេ ឧប្បជ្ជន្តិ ចិត្តចេតសិកា ធម្មា ឥមេ ធម្មា អប្បមាណារម្មណា ។

(១៨០) កតមេ ធម្មា ហីនា ។ តីណិ អកុសលមូលានិ លោភោ ទោសោ មោហោ តទេកដ្ឋា ច កិលេសា តំសម្បយុត្តោ វេទនាក្ខន្ធោ ។ បេ ។ វិញ្ញាណក្ខន្ធោ តំសមុដ្ឋានំ កាយកម្មំ វចីកម្មំ មនោកម្មំ ឥមេ ធម្មា ហីនា ។ កតមេ ធម្មា មជ្ឈិមា ។ សាសវា កុសលាព្យាកតា ធម្មា កាមាវចរា រូបាវចរា អរូបាវចរា រូបក្ខន្ធោ ។ បេ ។ វិញ្ញាណក្ខន្ធោ ឥមេ ធម្មា មជ្ឈិមា ។ កតមេ ធម្មា បណីតា ។ អបរិយាបន្នា មគ្គា ច មគ្គផលានិ ច អសង្ខតា ច ធាតុ ឥមេ ធម្មា បណីតា ។

តិកនិក្ខេប

[ ១៧៩ ] ពួកធម៌មានអារម្មណ៍តូចឆ្មារ តើដូចម្តេច ។ ពួកធម៌ណាប្រព្រឹត្តទៅក្នុងចិត្តនិងចេតសិក កើតឡើងព្រោះប្រារព្ធនូវធម៌មានសភាពតូចឆ្មារ នេះពួកធម៌មានអារម្មណ៍តូចឆ្មារ ។ ពួកធម៌មានអារម្មណ៍ដល់នូវសភាពធំ តើដូចម្តេច ។ ពួកធម៌ណាប្រព្រឹត្តទៅក្នុងចិត្តនិងចេតសិក កើតឡើងព្រោះប្រារព្ធនូវធម៌ដល់នូវសភាពធំ នេះពួកធម៌មានអារម្មណ៍ដល់នូវសភាពធំ ។ ពួកធម៌មានអារម្មណ៍ប្រមាណមិនបាន តើដូចម្តេច ។ ពួកធម៌ណាប្រព្រឹត្តទៅក្នុងចិត្តនិងចេតសិក កើតឡើងព្រោះប្រារព្ធនូវធម៌ប្រមាណមិនបាន នេះពួកធម៌មានអារម្មណ៍ប្រមាណមិនបាន ។

[ ១៨០ ] ពួកធម៌ដ៏ថោកទាប តើដូចម្តេច ។ អកុសលមូល ៣ យ៉ាងគឺ លោភៈ ទោសៈ និងមោហៈ ទាំងពួកកិលេសដែលតាំងនៅជាមួយគ្នា និងអកុសលមូលមានលោភៈជាដើមនោះ វេទនាខន្ធ ។ បេ ។ វិញ្ញាណក្ខន្ធ ដែលប្រកបដោយអកុសលមូលមានលោភៈជាដើមនោះ និងកាយកម្ម វចីកម្ម មនោកម្ម ដែលតាំងឡើងអំពីអកុសលមូលមានលោភៈជាដើមនោះ នេះពួកធម៌ដ៏ថោកទាប ។ ពួកធម៌ជាកណ្តាល តើដូចម្តេច ។ ពួកធម៌ប្រកបដោយអាសវៈ ជាកុសលនិងអព្យាក្រឹត ជាកាមាវចរ រូបាវចរ អរូបាវចរ និងរូបក្ខន្ធ ។បេ។ វិញ្ញាណក្ខន្ធ នេះពួកធម៌ជាកណ្តាល ។ ពួកធម៌ដ៏ឧត្តម តើដូចម្តេច ។ មគ្គជាបរិយាបន្នៈ ផលដែលកើតអំពីមគ្គ និងអសង្ខតធាតុ នេះពួកធម៌ដ៏ឧត្តម ។

(១៨១) កតមេ ធម្មា មិច្ឆត្តនិយតា ។ បញ្ច កម្មានិ អានន្តរិកានិ យា ច មិច្ឆាទិដ្ឋិ និយតា ឥមេ ធម្មា មិច្ឆត្តនិយតា ។ កតមេ ធម្មា សម្មត្តនិយតា ។ ចត្តារោ មគ្គា អបរិយាបន្នា ឥមេ ធម្មា សម្មត្តនិយតា ។ កតមេ ធម្មា អនិយតា ។ តេ ធម្មេ ឋបេត្វា អវសេសា កុសលាកុសលាព្យាកតា ធម្មា កាមាវចរា រូបាវចរា អរូបាវចរា អបរិយាបន្នា វេទនាក្ខន្ធោ ។បេ។ វិញ្ញាណក្ខន្ធោ សព្វញ្ច រូបំ អសង្ខតា ច ធាតុ ឥមេ ធម្មា អនិយតា ។

(១៨២) កតមេ ធម្មា មគ្គារម្មណា ។ អរិយមគ្គំ អារព្ភ យេ ឧប្បជ្ជន្តិ ចិត្តចេតសិកា ធម្មា ឥមេ ធម្មា មគ្គារម្មណា ។ កតមេ ធម្មា មគ្គហេតុកា ។ អរិយមគ្គសមង្គិស្ស មគ្គង្គានិ ឋបេត្វា តំសម្បយុត្តោ វេទនាក្ខន្ធោ ។បេ។ វិញ្ញាណក្ខន្ធោ ឥមេ ធម្មា មគ្គហេតុកា ។ អរិយមគ្គសមង្គិស្ស សម្មាទិដ្ឋិ មគ្គោ ចេវ ហេតុ ច សម្មាទិដ្ឋឹ ឋបេត្វា តំសម្បយុត្តោ វេទនាក្ខន្ធោ ។បេ។ វិញ្ញាណក្ខន្ធោ ឥមេ ធម្មា មគ្គហេតុកា ។ អរិយមគ្គសមង្គិស្ស

[ ១៨១ ] ពួកធម៌មានសភាពខុសនិងទៀង តើដូចម្ដេច ។ អនន្តរិកកម្ម ៥ និងនិយតមិច្ឆាទិដ្ឋិ នេះពួកធម៌មានសភាពខុសនិងទៀង ។ ពួកធម៌មានសភាពត្រូវនិងទៀង តើដូចម្ដេច ។ មគ្គ ៤ ជាអបរិយាបន្នៈ នេះពួកធម៌មានសភាពត្រូវនិងទៀង ។ ពួកធម៌មិនទៀង តើដូចម្ដេច ។ វៀរតែធម៌ទាំងនោះចេញ ពួកធម៌ដ៏សេសសល់ ជាកុសល អកុសល និងអព្យាក្រឹត ជាកាមាវចរ រូបាវចរ អរូបាវចរ អបរិយាបន្នៈ វេទនាខន្ធ ។ បេ ។ វិញ្ញាណក្ខន្ធ រូបទាំងអស់ និងអសង្ខតធាតុ នេះពួកធម៌មិនទៀង ។

[ ១៨២ ] ពួកធម៌មានមគ្គជាអារម្មណ៍ តើដូចម្ដេច ។ ពួកធម៌ណា ប្រព្រឹត្តទៅក្នុងចិត្តនិងចេតសិក កើតឡើងព្រោះប្រារព្ធនូវអរិយមគ្គ នេះពួកធម៌ មានមគ្គជាអារម្មណ៍ ។ ពួកធម៌ មានមគ្គជាហេតុ តើដូចម្ដេច ។ វៀរតែអង្គនៃមគ្គ របស់បុគ្គលដែលព្រមព្រៀង ដោយអរិយមគ្គចេញ វេទនាខន្ធ ។ បេ ។ វិញ្ញាណក្ខន្ធ ដែលប្រកបដោយមគ្គនោះ នេះពួកធម៌ មានមគ្គជាហេតុ ។ សម្មាទិដ្ឋិ របស់បុគ្គលដែលព្រមព្រៀង ដោយអរិយមគ្គ ជាមគ្គផង ជាហេតុផង វៀរលែងតែសម្មាទិដ្ឋិចេញ វេទនាខន្ធ ។ បេ ។ វិញ្ញាណក្ខន្ធ ដែលប្រកបដោយមគ្គ និងហេតុនោះ នេះពួកធម៌ មានមគ្គជាហេតុ ។

អលោភោ អទោសោ អមោហោ ឥមេ ធម្មា មគ្គហេតូ តំសម្បយុត្តា វេទនាក្ខន្ធោ ។បេ។ វិញ្ញាណក្ខន្ធោ ឥមេ ធម្មា មគ្គហេតុកា ។ កតមេ ធម្មា មគ្គាធិបតិនោ ។ អរិយមគ្គំ អធិបតឹ ករិត្វា យេ ឧប្បជ្ជន្តិ ចិត្តចេតសិកា ធម្មា ឥមេ ធម្មា មគ្គាធិបតិនោ ។ អរិយមគ្គសមង្គិស្ស វីមំសាធិបតេយ្យំ មគ្គំ ភាវយន្តស្ស វីមំសំ ឋបេត្វា តំសម្បយុត្តោ វេទនាក្ខន្ធោ ។បេ។ វិញ្ញាណក្ខន្ធោ ឥមេ ធម្មា មគ្គាធិបតិនោ ។

(១៨៣) កតមេ ធម្មា ឧប្បន្នា ។

យេ ធម្មា ជាតា ភូតា សញ្ជាតា និព្វត្តា អភិនិព្វត្តា បាតុភូតា ឧប្បន្នា សមុប្បន្នា ឧដ្ឋិតា សមុដ្ឋិតា ឧប្បន្នា ឧប្បន្នំសេន សង្គហិតា រូបា វេទនា សញ្ញា សង្ខារា វិញ្ញាណំ ឥមេ ធម្មា ឧប្បន្នា ។ កតមេ ធម្មា អនុប្បន្នា ។ យេ ធម្មា

## តិកនិក្ខេប

អលោភៈ អទោសៈ អមោហៈ របស់បុគ្គលដែលព្រមព្រៀងដោយអរិយមគ្គ នេះពួកធម៌មានមគ្គជាហេតុ វេទនាខន្ធ ។ បេ ។ វិញ្ញាណក្ខន្ធដែលប្រកបដោយមគ្គជាហេតុនោះ នេះពួកធម៌មានមគ្គជាហេតុ ។ ពួកធម៌ មានមគ្គជាអធិបតី តើដូចម្តេច ។ ពួកធម៌ណា ប្រព្រឹត្តទៅក្នុងចិត្តនិងចេតសិក កើតឡើងព្រោះធ្វើនូវអរិយមគ្គឲ្យជាអធិបតី នេះពួកធម៌មានមគ្គជាអធិបតី ។ វៀរលែងតែវីមំសា របស់បុគ្គលដែលព្រមព្រៀងដោយអរិយមគ្គ កាលចំរើននូវមគ្គមានវីមំសាជាអធិបតីចេញ វេទនាខន្ធ ។ បេ ។ វិញ្ញាណក្ខន្ធ ដែលប្រកបដោយវីមំសានោះ នេះពួកធម៌មានមគ្គជាអធិបតី ។

(១៨៣) ពួកធម៌កើតឡើងហើយ តើដូចម្តេច ។ ពួកធម៌ណា គឺរូប វេទនា សញ្ញា សង្ខារ វិញ្ញាណ កើតហើយ មានហើយ កើតព្រមហើយ វិលមកកើតហើយ ត្រឡប់កើតហើយ កើតប្រាកដហើយ កើតឡើងហើយ កើតឡើងព្រមហើយ តាំងឡើងហើយ តាំងឡើងព្រមហើយ កើតហើយ សង្គ្រោះហើយ ដោយចំណែក នៃធម៌ដែលកើតហើយ នេះពួកធម៌ កើតឡើងហើយ ។ ពួកធម៌មិនទាន់កើតឡើង តើដូចម្តេច ។ ពួកធម៌ណា គឺរូប វេទនា

អជាតា អភូតា អសញ្ជាតា អនិព្វត្តា អនភិនិព្វត្តា អបាតុភូតា អនុប្បន្នា អសមុប្បន្នា អនុដ្ឋិតា អសមុដ្ឋិតា អនុប្បន្នំសេន សង្គហិតា រូបា វេទនា សញ្ញា សង្ខារា វិញ្ញាណំ ឥមេ ធម្មា អនុប្បន្នា ។ កតមេ ធម្មា ឧប្បាទិនោ ។ កុសលាកុសលានំ ធម្មានំ អវិបក្កវិបាកានំ(១) វិបាកា កាមាវចរា រូបាវចរា អរូបាវចរា អបរិយាបន្នា វេទនាក្ខន្ធោ ។ បេ ។ វិញ្ញាណក្ខន្ធោ យញ្ច រូបំ កម្មស្ស កតត្តា ឧប្បជ្ជិស្សតិ ឥមេ ធម្មា ឧប្បាទិនោ ។

(១៨៤) កតមេ ធម្មា អតីតា ។ យេ ធម្មា អតីតា និរុទ្ធា វិគតា(២) វិបរិណតា អត្ថង្គតា អព្ភត្ថង្គតា ឧប្បជ្ជិត្វា វិគតា អតីតា អតីតំសេន សង្គហិតា រូបា វេទនា សញ្ញា សង្ខារា វិញ្ញាណំ ឥមេ ធម្មា អតីតា ។ កតមេ ធម្មា អនាគតា ។ យេ

---

១ ឱរោបិយមរម្មបោត្ថកេសុ អយំ បាឋោ ន ទិស្សតិ ។ ២ ឱ. និរុទ្ធគតាតិ ទិស្សតិ ។

សញ្ញា សង្ខារ វិញ្ញាណ ដែលមិនទាន់កើត មិនទាន់មាន មិនទាន់កើតព្រម មិនទាន់វិលមកកើត មិនទាន់ត្រឡប់មកកើត មិនទាន់កើតប្រាកដ មិនទាន់កើតឡើង មិនទាន់កើតឡើងព្រម មិនទាន់តាំងឡើង មិនទាន់តាំងឡើងព្រម មិនទាន់កើតឡើង ដែលសង្គ្រោះហើយដោយចំណែកនៃធម៌ ដែលមិនទាន់កើតឡើង នេះពួកធម៌មិនទាន់កើតឡើង ។ ពួកធម៌បំរុងនឹងកើតឡើង តើដូចម្តេច ។ វិបាកជាកាមាវចរ រូបាវចរ អរូបាវចរ អបរិយាបន្នៈ នៃធម៌ជាកុសលនិងអកុសល ដែលមានវិបាកមិនទាន់ចាស់ក្លា វេទនាខន្ធ ។ បេ ។ វិញ្ញាណក្ខន្ធ និងកម្មសមុដ្ឋានរូប ដែលបំរុងនឹងកើតឡើង នេះពួកធម៌បំរុងនឹងកើតឡើង ។

( ១៨៤ ) ពួកធម៌ជាអតីត តើដូចម្តេច ។ ពួកធម៌ណា គឺរូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ដែលកន្លងហើយ រលត់ទៅហើយ ប្រាសទៅហើយ ប្រែប្រួលទៅហើយ វិនាសទៅហើយ វិនាសទៅយូរហើយ កើតឡើងហើយប្រាសទៅវិញហើយ កន្លងទៅហើយ ដែលសង្គ្រោះដោយចំណែក នៃធម៌ដែលកន្លងហើយ នេះពួកធម៌ ជាអតីត ។ ពួកធម៌ ជាអនាគត តើដូចម្តេច ។ ពួកធម៌ណា គឺរូប វេទនា

ធម្មា អជាតា អភូតា អសញ្ជាតា អនិព្វត្តា អនភិនិព្វត្តា អបាតុភូតា អនុប្បន្នា អសមុប្បន្នា អនុដ្ឋិតា អសមុដ្ឋិតា អនាគតា អនាគតំសេន សង្គហិតា រូបា វេទនា សញ្ញា សង្ខារា វិញ្ញាណំ ឥមេ ធម្មា អនាគតា ។ កតមេ ធម្មា បច្ចុប្បន្នា ។ យេ ធម្មា ជាតា ភូតា សញ្ជាតា និព្វត្តា អភិនិព្វត្តា បាតុភូតា ឧប្បន្នា សមុប្បន្នា ឧដ្ឋិតា សមុដ្ឋិតា បច្ចុប្បន្នា បច្ចុប្បន្នំសេន សង្គហិតា រូបា វេទនា សញ្ញា សង្ខារា វិញ្ញាណំ ឥមេ ធម្មា បច្ចុប្បន្នា ។

[១៨៥] កតមេ ធម្មា អតីតារម្មណា ។ អតីតេ ធម្មេ អារព្ភ យេ ឧប្បជ្ជន្តិ ចិត្តចេតសិកា ធម្មា ឥមេ ធម្មា អតីតារម្មណា ។ កតមេ ធម្មា អនាគតារម្មណា ។ អនាគតេ ធម្មេ អារព្ភ យេ ឧប្បជ្ជន្តិ ចិត្តចេតសិកា ធម្មា ឥមេ ធម្មា អនាគតារម្មណា ។ កតមេ ធម្មា បច្ចុប្បន្នារម្មណា ។ បច្ចុប្បន្នេ ធម្មេ អារព្ភ យេ ឧប្បជ្ជន្តិ ចិត្តចេតសិកា ធម្មា ឥមេ ធម្មា បច្ចុប្បន្នារម្មណា ។

សញ្ញា សង្ខារ វិញ្ញាណ ដែលមិនទាន់កើត មិនទាន់មាន មិនទាន់កើតព្រម មិនទាន់វិលមកកើត មិនទាន់ត្រឡប់មកកើត មិនទាន់កើតប្រាកដ មិនទាន់កើតឡើង មិនទាន់កើតឡើងព្រម មិនទាន់តាំងឡើង មិនទាន់តាំងឡើងព្រម មិនទាន់មកដល់ ដែលសង្គ្រោះដោយចំណែក នៃធម៌ដែលមិនទាន់មកដល់ នេះពួកធម៌ ជាអនាគត ។ ពួកធម៌ជាបច្ចុប្បន្ន តើដូចម្តេច ។ ពួកធម៌ណា គឺរូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ដែលកំពុងកើត មាន កើតព្រម វិលមកកើត ត្រឡប់មកកើត កើតប្រាកដ កើតឡើង កើតឡើងព្រម តាំងឡើង តាំងឡើងព្រម កើតឡើងចំពោះមុខ ដែលសង្គ្រោះដោយចំណែកនៃធម៌ ដែលកើតឡើងចំពោះមុខ នេះពួកធម៌ជាបច្ចុប្បន្ន ។

[ ១៨៥ ] ពួកធម៌មានអារម្មណ៍ជាអតីត តើដូចម្តេច ។ ពួកធម៌ណា ប្រព្រឹត្តទៅកង់ចិត្តនិងចេតសិក កើតឡើងព្រោះប្រារព្ធនូវធម៌ដែលកន្លងហើយ នេះពួកធម៌មានអារម្មណ៍ជាអតីត ។ ពួកធម៌មានអារម្មណ៍ជាអនាគត តើដូចម្តេច ។ ពួកធម៌ណា ប្រព្រឹត្តទៅកង់ចិត្តនិងចេតសិក កើតឡើង ព្រោះប្រារព្ធនូវធម៌ដែលមិនទាន់មកដល់ នេះពួកធម៌ មានអារម្មណ៍ជាអនាគត ។ ពួកធម៌មានអារម្មណ៍ជាបច្ចុប្បន្ន តើដូចម្តេច ។ ពួកធម៌ណា ប្រព្រឹត្តទៅកង់ចិត្តនិងចេតសិក កើតឡើងព្រោះប្រារព្ធនូវធម៌ដែលកើតឡើងចំពោះមុខ នេះពួកធម៌មានអារម្មណ៍ជាបច្ចុប្បន្ន ។

(១៨៦) កតមេ ធម្មា អជ្ឈត្តា ។ យេ ធម្មា តេសំ តេសំ សត្តានំ អជ្ឈត្តំ បច្ចត្តំ និយកា(១) បាដិបុគ្គលិកា ឧបាទិន្នា រូបា វេទនា សញ្ញា សង្ខារា វិញ្ញាណំ ឥមេ ធម្មា អជ្ឈត្តា ។ កតមេ ធម្មា ពហិទ្ធា ។ យេ ធម្មា តេសំ តេសំ បរសត្តានំ បរបុគ្គលានំ អជ្ឈត្តំ បច្ចត្តំ និយកា បាដិបុគ្គលិកា ឧបាទិន្នា រូបា វេទនា សញ្ញា សង្ខារា វិញ្ញាណំ ឥមេ ធម្មា ពហិទ្ធា ។ កតមេ ធម្មា អជ្ឈត្តពហិទ្ធា ។ តទុភយំ ឥមេ ធម្មា អជ្ឈត្តពហិទ្ធា ។

(១៨៧) កតមេ ធម្មា អជ្ឈត្តារម្មណា ។ អជ្ឈត្តេ ធម្មេ អារព្ភ យេ ឧប្បជ្ជន្តិ ចិត្តចេតសិកា ធម្មា ឥមេ ធម្មា អជ្ឈត្តារម្មណា ។ កតមេ ធម្មា ពហិទ្ធារម្មណា ។ ពហិទ្ធា ធម្មេ អារព្ភ យេ ឧប្បជ្ជន្តិ ចិត្តចេតសិកា ធម្មា ឥមេ ធម្មា ពហិទ្ធារម្មណា ។ កតមេ ធម្មា អជ្ឈត្តពហិទ្ធារម្មណា ។ អជ្ឈត្តពហិទ្ធា ធម្មេ អារព្ភ យេ ឧប្បជ្ជន្តិ ចិត្តចេតសិកា ធម្មា ឥមេ ធម្មា អជ្ឈត្តពហិទ្ធារម្មណា ។

---

១ ឱ. ម. និយតា ។

( ១៨៦ ) ពួកធម៌ជាខាងក្នុង តើដូចម្ដេច ។ ពួកធម៌ណា គឺរូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ដែលតាំងនៅក្នុងសន្ដាន តាំងនៅក្នុងខ្លួន ទៀងទាត់ ជារបស់ចំពោះបុគ្គលម្នាក់ ប្រកាន់ខ្ជាប់ក្នុងសរីរៈនៃពួកសត្វនោះ ៗ នេះពួកធម៌ ជាខាងក្នុង ។ ពួកធម៌ជាខាងក្រៅ តើដូចម្ដេច ។ ពួកធម៌ណា គឺរូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ដែលតាំងនៅក្នុងសន្ដាន តាំងនៅក្នុងខ្លួន ទៀងទាត់ ជារបស់ចំពោះបុគ្គលម្នាក់ ប្រកាន់ខ្ជាប់ក្នុងសរីរៈនៃពួកសត្វដទៃ នៃបុគ្គលដទៃនោះ ៗ នេះពួកធម៌ជាខាងក្រៅ ។ ពួកធម៌ខាងក្នុងទាំងខាងក្រៅ តើដូចម្ដេច ។ ប្រជុំនៃខន្ធទាំងពីរនោះ (ខន្ធខាងក្នុងនិងខន្ធខាងក្រៅ) នេះពួកធម៌ខាងក្នុងទាំងខាងក្រៅ ។

( ១៨៧ ) ពួកធម៌មានអារម្មណ៍ខាងក្នុង តើដូចម្ដេច ។ ពួកធម៌ណា ប្រព្រឹត្តទៅក្នុងចិត្តនិងចេតសិក កើតឡើង ព្រោះប្រារព្ធនូវធម៌ខាងក្នុង នេះពួកធម៌ មានអារម្មណ៍ខាងក្នុង ។ ពួកធម៌មានអារម្មណ៍ខាងក្រៅ តើដូចម្ដេច ។ ពួកធម៌ណា ប្រព្រឹត្តទៅក្នុងចិត្តនិងចេតសិក កើតឡើង ព្រោះប្រារព្ធនូវធម៌ខាងក្រៅ នេះពួកធម៌មានអារម្មណ៍ខាងក្រៅ ។ ពួកធម៌ មានអារម្មណ៍ខាងក្នុងទាំងខាងក្រៅ តើដូចម្ដេច ។ ពួកធម៌ណា ប្រព្រឹត្តទៅក្នុងចិត្តនិងចេតសិក កើតឡើង ព្រោះប្រារព្ធនូវធម៌ខាងក្នុង និងខាងក្រៅ នេះពួកធម៌មានអារម្មណ៍ខាងក្នុងទាំងខាងក្រៅ ។

ហេតុគោច្ឆកេ និក្ខេបោ

(១៨៨) កតមេ ធម្មា សនិទស្សនសប្បដិឃា ។ រូបាយតនំ ឥមេ ធម្មា សនិទស្សនសប្បដិឃា ។ កតមេ ធម្មា អនិទស្សនសប្បដិឃា ។ ចក្ខាយតនំ សោតាយតនំ ឃានាយតនំ ជិវ្ហាយតនំ កាយាយតនំ សទ្ទាយតនំ គន្ធាយតនំ រសាយតនំ ផោដ្ឋព្វាយតនំ ឥមេ ធម្មា អនិទស្សនសប្បដិឃា ។ កតមេ ធម្មា អនិទស្សនាប្បដិឃា ។ វេទនាក្ខន្ធោ សញ្ញាក្ខន្ធោ សង្ខារក្ខន្ធោ វិញ្ញាណក្ខន្ធោ យញ្ច រូបំ អនិទស្សនំ អប្បដិឃំ ធម្មាយតនបរិយាបន្នំ អសង្ខតា ច ធាតុ ឥមេ ធម្មា អនិទស្សនាប្បដិឃា ។

តិកំ ។

(១៨៩) កតមេ ធម្មា ហេតូ ។ តយោ កុសលហេតូ តយោ អកុសលហេតូ តយោ អព្យាកតហេតូ នវ កាមាវចរហេតូ ឆ រូបាវចរហេតូ ឆ អរូបាវចរហេតូ ឆ អបរិយាបន្នហេតូ ។

(១៩០) តត្ថ កតមេ តយោ កុសលហេតូ ។ អលោភោ អទោសោ អមោហោ ។ តត្ថ កតមោ

ហេតុគោច្ឆកនិក្ខេប

( ១៨៨ ) ពួកធម៌ប្រកបដោយការឃើញ ទាំងប្រកបដោយការប៉ះពាល់ តើដូចម្ដេច ។ រូបាយតនៈ នេះពួកធម៌ប្រកបដោយការឃើញ ទាំងប្រកបដោយការប៉ះពាល់ ។ ពួកធម៌មិនប្រកបដោយការឃើញ តែប្រកបដោយការប៉ះពាល់ តើដូចម្ដេច ។ ចក្ខាយតនៈ សោតាយតនៈ ឃានាយតនៈ ជិវ្ហាយតនៈ កាយាយតនៈ សទ្ទាយតនៈ គន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈ នេះពួកធម៌ មិនប្រកបដោយការឃើញ តែប្រកបដោយការប៉ះពាល់ ។ ពួកធម៌មិនប្រកបដោយការឃើញ ទាំងមិនប្រកបដោយការប៉ះពាល់ តើដូចម្ដេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ រូបដែលជាអនិទស្សនៈ ជាអប្បដិឃៈ រាប់បញ្ចូលក្នុងធម្មាយតនៈ និងអសង្ខតធាតុ នេះពួកធម៌មិនប្រកបដោយការឃើញ ទាំងមិនប្រកបដោយការប៉ះពាល់ ។

ចប់ត្ដិកៈ ។

( ១៨៩ ) ពួកធម៌ជាហេតុ តើដូចម្ដេច ។ កុសលហេតុ ៣ អកុសលហេតុ ៣ អព្យាកតហេតុ ៣ កាមាវចរហេតុ ៩ រូបាវចរហេតុ ៦ អរូបាវចរហេតុ ៦ អបរិយាបន្នហេតុ ៦ ។

( ១៩០ ) បណ្ដាហេតុទាំងនោះ កុសលហេតុ (ហេតុនៃកុសល) ៣ តើដូចម្ដេច ។ អលោភៈ អទោសៈ អមោហៈ ។

អលោភោ ។ យោ អលោភោ អលុព្ភនា អលុព្ភិតត្តំ អសារាគោ អសារជ្ជនា អសារជ្ជិតត្តំ អនភិជ្ឈា អលោភោ កុសលមូលំ អយំ វុច្ចតិ អលោភោ ។ តត្ថ កតមោ អទោសោ ។ យោ អទោសោ អទុស្សនា អទុស្សិតត្តំ មេត្តិ(១) មេត្តាយនា មេត្តាយិតត្តំ អនុទ្ទា អនុទ្ទាយនា អនុទ្ទាយិតត្តំ ហិតេសិតា អនុកម្បា អព្យាបាទោ អព្យាបជ្ជោ អទោសោ កុសលមូលំ អយំ វុច្ចតិ អទោសោ ។ តត្ថ កតមោ អមោហោ ។ ទុក្ខេ ញាណំ ទុក្ខសមុទយេ ញាណំ ទុក្ខនិរោធេ ញាណំ ទុក្ខនិរោធគាមិនិយា បដិបទាយ ញាណំ បុព្វន្តេ ញាណំ អបរន្តេ ញាណំ បុព្វន្តាបរន្តេ ញាណំ ឥទប្បច្ចយតាបដិច្ចសមុប្បន្នេសុ ធម្មេសុ ញាណំ យា ឯវរូបា បញ្ញា បជាននា វិចយោ បវិចយោ ធម្មវិចយោ សល្លក្ខណា ឧបលក្ខណា បច្ចុបលក្ខណា បណ្ឌិច្ចំ កោសល្លំ នេបុញ្ញំ វេភព្យា ចិន្តា ឧបបរិក្ខា ភូរី មេធា បរិណាយិកា វិបស្សនា សម្បជញ្ញំ បតោទោ

---

១ ឱ. មេត្តំ ។

បណ្ដាកុសលហេតុទាំងនោះ អលោភៈ តើដូចម្ដេច ។ ការមិនជាប់ចំពាក់ ការមិនជាប់ស្អិត ភាពនៃចិត្តមិនជាប់ចំពាក់ក្នុងអារម្មណ៍ ការមិនត្រេកអរ ការមិនរីករាយ ភាពនៃចិត្តមិនត្រេកអរក្នុងអារម្មណ៍ ការមិនសំឡឹងរំពៃ សេចក្ដីមិនលោភ ជាកុសលមូល ណា នេះហៅថា អលោភៈ ។ បណ្ដាកុសលមូលទាំងនោះ អទោសៈ តើដូចម្ដេច ។ ការមិនប្រទូស្ដ អាការមិនប្រទូស្ដ ភាពនៃចិត្តមិនប្រទូស្ដក្នុងអារម្មណ៍ ការមេត្រី ការរាប់អាន ភាពនៃចិត្តរាប់អាន ការអាណិត ការប្រព្រឹត្តអាណិត ភាពនៃចិត្តអាណិត ការស្វែងរកនូវប្រយោជន៍ ការអនុគ្រោះ ការមិនគុំគួន ការមិនបៀតបៀន សេចក្ដីមិនប្រទូស្ដ ជាកុសលមូល ណា នេះហៅថា អទោសៈ ។ បណ្ដាកុសលមូលទាំងនោះ អមោហៈ តើដូចម្ដេច ។ ការដឹងច្បាស់ក្នុងទុក្ខ ដឹងច្បាស់ក្នុងទុក្ខសមុទ័យ ដឹងច្បាស់ក្នុងទុក្ខនិរោធ ដឹងច្បាស់ក្នុងទុក្ខនិរោធគាមិនីបដិបទា ដឹងច្បាស់ក្នុងខន្ធជាចំណែកខាងដើម ដឹងច្បាស់ក្នុងខន្ធជាចំណែកខាងចុង ដឹងច្បាស់ក្នុងខន្ធជាចំណែកខាងដើមនិងខាងចុង ដឹងច្បាស់ក្នុងពួកធម៌ ដែលកើតឡើង ព្រោះអាស្រ័យបច្ច័យនោះៗ (បដិច្ចសមុប្បន្នធម៌) និងបញ្ញា ការដឹងច្បាស់ ការសន្សំ ការប្រមូល ការពិចារណាធម៌ ការចំណាំ ការចំណាំជាប់ ការចំណាំស្និទ្ធ ភាពជាបណ្ឌិត ការឈ្លាសវៃ ការប្រសប់ ការប៉ិនប្រៀ ការគិតគូរ ការពិចារណា ប្រាជ្ញាដូចជាផែនដី ប្រាជ្ញាទម្លាយនូវកិលេស ធម្មជាតិសម្រាប់ណែនាំ ការយល់ ការឃើញច្បាស់ ការដឹងខ្លួនច្បាស់លាស់ ការចាក់ធ្លុះ ការដឹងច្បាស់

បញ្ញា បញ្ញិន្ទ្រិយំ បញ្ញាពលំ បញ្ញាសត្ថំ បញ្ញាបាសា-ទោ បញ្ញាអាលោកោ បញ្ញាឱភាសោ បញ្ញាបជ្ជោតោ បញ្ញារតនំ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ អយំ វុច្ចតិ អមោហោ ៗ ឥមេ តយោ កុសលហេតូ ៗ

(១៩១) តត្ថ កតមេ តយោ អកុសលហេតូ ៗ លោភោ ទោសោ មោហោ ៗ តត្ថ កតមោ លោភោ ៗ យោ រាគោ សារាគោ អនុនយោ អនុ-រោធោ នន្ទី នន្ទិរាគោ ចិត្តស្ស សារាគោ ឥច្ឆា មុច្ឆា អជ្ឈោសានំ គេធោ បលិគេធោ សង្គោ បង្កោ ឯជា មាយា ជនិកា សញ្ជននី សិព្វិនី ជាលិនី សរិតា វិសត្តិកា សុត្តំ វិសដា អាយូហនី ទុតិ-យា បណិធិ ភវនេត្តិ វនំ វនថោ សន្ថវោ សិនេ-ហោ អបេក្ខា បដិពន្ធុ អាសា អាសីសនា អាសី-សិតត្តំ រូបាសា សទ្ទាសា គន្ធាសា រសាសា ផោដ្ឋ-ព្វាសា លាភាសា ធនាសា បុត្តាសា ជីវិតាសា

ឥន្ទ្រិយគឺបញ្ញា កំឡាំងគឺបញ្ញា គ្រឿងសស្ត្រាគឺបញ្ញា ប្រាសាទគឺបញ្ញា ពន្លឺគឺបញ្ញា រស្មីគឺបញ្ញា ប្រទីបគឺបញ្ញា កែវគឺបញ្ញា សេចក្តីមិនវង្វេង សេចក្តីពិចារណាធម៌ សេចក្តីឃើញត្រូវ ណា ដែលមានសភាពបែបនេះ នេះហៅថា អមោហៈ ។ នេះកុសលហេតុ ៣ ។

( ១៩១ ) បណ្តាហេតុទាំងនោះ អកុសលហេតុ ៣ តើដូចម្តេច ។ លោភៈ ទោសៈ និងមោហៈ ។ បណ្តាអកុសលហេតុទាំងនោះ លោភៈ តើដូចម្តេច ។ តម្រេក ការត្រេកអរខ្លាំង ការជាប់ចំពាក់ក្នុងអារម្មណ៍ ការស្រើបស្រាល ការរីករាយ ការរីករាយខ្លាំង តម្រេកខ្លាំងនៃចិត្ត សេចក្តីប្រាថ្នា ការជ្រុលជ្រប់ ការងប់ងល់ ការពាក់ព័ន្ធ ការរួបរឹត ការជាប់ចំពាក់ ការលិចចុះ ធម្មជាតិនាំសត្វឲ្យកើតក្នុងភព មាយា ធម្មជាតិបង្កើតសត្វ ធម្មជាតិឲ្យសត្វប្រកបដោយទុក្ខ ធម្មជាតិចាក់ស្រេះសត្វទុក បណ្តាញ ការបង្ហូរ ការផ្សាយទៅកាន់អារម្មណ៍ផ្សេង ៗ ចំណងចងសត្វទុក ការផ្សាយទៅក្នុងអារម្មណ៍ ធម្មជាតិញ៉ាំងសត្វឲ្យចំរើន ធម្មជាតិជាគម្រប់ពីរ ការតាំងចិត្តទុក ធម្មជាតិនាំសត្វទៅកាន់ភព ធម្មជាតិដូចជាព្រៃ ដូចជាព្រៃញាតស្បាត ការមូលមិត្ត សេចក្តីស្រឡាញ់ ការអាឡោះអាល័យ ផៅពង្សតទៅ ការប៉ុនប៉ង ការប្រាថ្នា ភាពនៃចិត្តប៉ុនប៉ង ការប៉ុនប៉ងរូប ប៉ុនប៉ងសំឡេង ប៉ុនប៉ងក្លិន ប៉ុនប៉ងរស ប៉ុនប៉ងផ្សព្វ ប៉ុនប៉ងលាភ ប៉ុនប៉ងទ្រព្យ ប៉ុនប៉ងបុត្រ ប៉ុនប៉ងជីវិត

ជប្បា បជប្បា អភិជប្បា ជប្បា ជប្បនា ជប្បិតត្តំ
លោលុប្បំ លោលុប្បាយនា លោលុប្បាយិតត្តំ បុច្ឆញ្ជិ-
កតា សាធុកម្យតា អធម្មរាគោ វិសមលោភោ
និកន្តិ និកាមនា បត្ថនា បិហនា សម្បត្ថនា
កាមតណ្ហា ភវតណ្ហា វិភវតណ្ហា រូបតណ្ហា អរូប-
តណ្ហា និរោធតណ្ហា រូបតណ្ហា សទ្ទតណ្ហា គន្ធ-
តណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ឱឃោ
យោគោ គន្ថោ ឧបាទានំ អាវរណំ នីវរណំ ឆាទ-
នំ(១) ពន្ធនំ ឧបក្កិលេសោ អនុសយោ បរិយុដ្ឋានំ
លតា វេវិច្ឆំ ទុក្ខមូលំ ទុក្ខនិទានំ ទុក្ខប្បភវោ មារ-
បាសោ មារពលិសំ មារវិសយោ តណ្ហានទី តណ្ហា-
ជាលំ តណ្ហាគទ្ទុលំ តណ្ហាសមុទ្ទោ អភិជ្ឈា លោភោ
អកុសលមូលំ អយំ វុច្ចតិ លោភោ ។ តត្ថ
កតមោ ទោសោ ។ អនត្ថំ មេ អចរីតិ អាឃាតោ
ជាយតិ អនត្ថំ មេ ចរតីតិ អាឃាតោ ជាយតិ អនត្ថំ
មេ ចរិស្សតីតិ អាឃាតោ ជាយតិ បិយស្ស មេ

១ ឱ. ឆន្ទានំ ។

ធម្មជាតិឆ្ងេឆ្ងា ឆ្ងេឆ្ងាជ្រុល ឆ្ងេឆ្ងាខ្លាំង សេចក្តីឆ្ងេឆ្ងា អាការឆ្ងេឆ្ងា ភាពនៃចិត្តឆ្ងេឆ្ងា ការរុលត្បុល អាការរុលត្បុល ភាពនៃចិត្តរុលត្បុល ការញាប់ញ័រ ការចង់បានឲ្យសម្រេចប្រយោជន៍ ការត្រេកអរខុសគន្លងធម៌ ការលោភហួសកំណត់ ការត្រេកត្រអាល ការចង់បានមិនឈប់ ការប្រាថ្នា សេចក្តីស្រឡាញ់ ការប្រាថ្នាព្រម ប្រាថ្នាក្នុងកាម ប្រាថ្នាក្នុងភព ប្រាថ្នាប្រាសចាកភព ប្រាថ្នាក្នុងរូបភព ប្រាថ្នាក្នុងអរូបភព ប្រាថ្នាក្នុងនិរោធ ប្រាថ្នារូប ប្រាថ្នាសំឡេង ប្រាថ្នាក្លិន ប្រាថ្នារស ប្រាថ្នាផ្សព្វ ប្រាថ្នាធម៌ កិលេសដូចជាជំនន់ គ្រឿងប្រកប គ្រឿងចងក្រង គ្រឿងប្រកាន់មាំ គ្រឿងពាំងទួទៅ គ្រឿងពាំងមិនសល់ គ្រឿងបិទបាំង គ្រឿងចង គ្រឿងសៅហ្មងខ្លាំង គ្រឿងដេកចាំ គ្រឿងស្ទាក់ដំណើរ តណ្ហាដូចជាវល្លិ ប្រាថ្នាផ្សេងៗ ឫសគល់នៃទុក្ខ ហេតុនៃទុក្ខ ហេតុជាដែនកើតនៃទុក្ខ អន្ទាក់នៃមារ នុយនៃមារ អារម្មណ៍នៃមារ ស្ទឹងគឺតណ្ហា បណ្តាញគឺតណ្ហា ខ្នោះគឺតណ្ហា សមុទ្រគឺតណ្ហា ការសំឡឹងរំពៃ សេចក្តីលោភ ជាអកុសលមូល ណា នេះហៅថាលោភៈ ។ បណ្តាអកុសលមូលទាំងនោះ ទោសៈ តើដូចម្តេច ។ គំនុំកើតឡើងថា ជនឯណោះបានប្រព្រឹត្តនូវកម្មមិនជាប្រយោជន៍ដល់អាត្មាអញ គំនុំកើតឡើងថា ជនឯណោះ កំពុងប្រព្រឹត្តនូវកម្មមិនជាប្រយោជន៍ដល់អាត្មាអញ គំនុំកើតឡើងថា ជនឯណោះ នឹងប្រព្រឹត្តនូវកម្មមិនជាប្រយោជន៍ដល់អាត្មាអញ

មនាបស្ស អនត្ថំ អចរិ ។ បេ ។ អនត្ថំ ចរតិ ។ បេ ។ អនត្ថំ ចរិស្សតីតិ អាឃាតោ ជាយតិ អបិយស្ស មេ អមនាបស្ស អត្ថំ អចរិ ។ បេ ។ អត្ថំ ចរតិ ។ បេ ។ អត្ថំ ចរិស្សតីតិ អាឃាតោ ជាយតិ អដ្ឋានេ វា បន អាឃាតោ ជាយតិ យោ ឯវរូបោ ចិត្តស្ស អាឃាតោ បដិឃាតោ បដិឃំ បដិវិរោធោ កោបោ បកោបោ សម្បកោបោ ទោសោ បទោសោ សម្បទោសោ ចិត្តស្ស ព្យាបត្តិ មនោបទោសោ កោធោ កុជ្ឈនា កុជ្ឈិតត្តំ ទោសោ ទុស្សនា ទុស្សិតត្តំ ព្យាបត្តិ ព្យាបជ្ជនា ព្យាបជ្ជិតត្តំ វិរោធោ បដិវិរោធោ ចណ្ឌិក្កំ អសុរោបោ អនត្តមនតា ចិត្តស្ស អយំ វុច្ចតិ ទោសោ ។ តត្ថ កតមោ មោហោ ។ ទុក្ខេ អញ្ញាណំ ទុក្ខសមុទយេ អញ្ញាណំ ទុក្ខនិរោធេ អញ្ញាណំ ទុក្ខនិរោធគាមិនិយា បដិបទាយ អញ្ញាណំ បុព្វន្តេ អញ្ញាណំ អបរន្តេ អញ្ញាណំ បុព្វន្តាបរន្តេ អញ្ញាណំ

គំនុំកើតឡើងថា ជនឯណោះ បានប្រព្រឹត្តនូវកម្មមិនជាប្រយោជន៍ ដល់បុគ្គលជាទីស្រឡាញ់ ជាទីពេញចិត្ត របស់អាត្មាអញ ។ បេ ។ កំពុងប្រព្រឹត្តនូវកម្មមិនជាប្រយោជន៍ ។ បេ ។ គំនុំកើតឡើងថា ជនឯណោះ នឹងប្រព្រឹត្តនូវកម្មមិនជាប្រយោជន៍ ថាជនឯណោះ បានប្រព្រឹត្តនូវកម្មជាប្រយោជន៍ ដល់បុគ្គលមិនជាទីស្រឡាញ់ មិនជាទីពេញចិត្ត របស់អាត្មាអញ ។ បេ ។ កំពុងប្រព្រឹត្ត នូវកម្មជាប្រយោជន៍ ។ បេ ។ គំនុំកើតឡើងថា ជនឯណោះ នឹងប្រព្រឹត្តនូវកម្មជាប្រយោជន៍ ឬក៏ គំនុំកើតឡើងក្នុងទីមិនគួរ ការគុំគួននៃចិត្ត ការគុំគួនតប សេចក្ដីថ្នាំងថ្នាក់ ការខឹងតប ការខឹងញាប់ញ័រ ការក្រោធខ្លាំង ក្រោធញាប់ញ័រ ការប្រទូស្ត ការប្រទូស្តតប ការប្រទូស្តគ្រប់យ៉ាង ការខូចចិត្ត ការប្រទូស្តនៃចិត្ត ការក្រោធ ការខឹង ភាពនៃចិត្តខឹង សេចក្ដីប្រទូស្ត អាការប្រទូស្ត ភាពនៃចិត្តប្រទូស្ត សេចក្ដីវិនាស អាការវិនាស ភាពនៃចិត្តវិនាស ការខឹង ការខឹងតប ភាពនៃចិត្តកាច ការខឹង ការតូចចិត្ត ណា ដែលមានសភាពបែបនេះ នេះហៅថា ទោសៈ ។ បណ្ដាអកុសលមូលទាំងនោះ មោហៈ តើដូចម្ដេច ។ ការមិនដឹងច្បាស់ក្នុងទុក្ខ មិនដឹងច្បាស់ក្នុងទុក្ខសមុទ័យ មិនដឹងច្បាស់ក្នុងទុក្ខនិរោធ មិនដឹងច្បាស់ក្នុងទុក្ខនិរោធគាមិនីបដិបទា មិនដឹងច្បាស់ក្នុងខន្ធជាចំណែកខាងដើម មិនដឹងច្បាស់ក្នុងខន្ធជាចំណែកខាងចុង មិនដឹងច្បាស់ក្នុងខន្ធជាចំណែកខាងដើមនិងខាងចុង

ឥទប្បច្ចយតាបដិច្ចសមុប្បន្នេសុ ធម្មេសុ អញ្ញាណំ យំ ឯវរូបំ អញ្ញាណំ អទស្សនំ អនភិសមយោ អននុពោធោ អសម្ពោធោ អប្បដិវេធោ អសង្គាហនា អបរិយោគាហនា អសមបេក្ខនា អប្បច្ចវេក្ខណា អប្បច្ចក្ខកម្មំ ទុម្មេជ្ឈំ ពាល្យំ អសម្បជញ្ញំ មោហោ បមោហោ សម្មោហោ អវិជ្ជា អវិជ្ជោឃោ អវិជ្ជាយោគោ អវិជ្ជានុសយោ អវិជ្ជាបរិយុដ្ឋានំ អវិជ្ជាលង្គី មោហោ អកុសលមូលំ អយំ វុច្ចតិ មោហោ ។ ឥមេ តយោ អកុសលហេតូ ។

(១៩២) តត្ថ កតមេ តយោ អព្យាកតហេតូ ។ កុសលានំ វា ធម្មានំ វិបាកតោ កិរិយាព្យាកតេសុ វា ធម្មេសុ អលោភោ អទោសោ អមោហោ ឥមេ តយោ អព្យាកតហេតូ ។

(១៩៣) តត្ថ កតមេ នវ កាមាវចរហេតូ ។ តយោ កុសលហេតូ តយោ អកុសលហេតូ តយោ អព្យាកតហេតូ ឥមេ នវ កាមាវចរហេតូ ។ តត្ថ កតមេ ឆ រូបាវចរហេតូ ។ តយោ កុសលហេតូ តយោ អព្យាកតហេតូ ឥមេ ឆ រូបាវចរហេតូ ។

មិនដឹងច្បាស់ កុងពួកធម៌ដែលកើតឡើង ព្រោះអាស្រ័យបច្ច័យនោះ ៗ និងការមិនដឹងច្បាស់ ការមិនឃើញ ការមិនត្រាស់ដឹង ការមិនយល់ ការមិនត្រាស់ដឹងព្រម ការមិនចាក់ធ្លុះ ការមិនបានផ្សៀងផ្ទាត់ ការមិនចុះចិត្តស៊ប់ ការមិនរំពឹងមើល ការមិនពិចារណា អំពើមិនជាក់ច្បាស់ ការយល់ស្មុគស្មើរ ភាពនៃចិត្តល្ងង់ ការមិនដឹងខ្លួន ការវង្វេង ការវង្វេងជ្រប់ ការភ្លេចភ្លាំង អវិជ្ជា (ការមិនដឹងច្បាស់) អន្លង់គឺអវិជ្ជា ការប្រកបគឺអវិជ្ជា អនុស័យគឺអវិជ្ជា ការស្ទាក់ដំណើរគឺអវិជ្ជា គន្លឹះគឺអវិជ្ជា ការវង្វេង ជាអកុសលមូល ណា ដែលមានសភាពបែបនេះ នេះហៅថា មោហៈ ។ នេះអកុសលហេតុ ៣ ។

(១៩២) បណ្តាហេតុទាំងនោះ អព្យាកតហេតុ ៣ តើដូចម្តេច ។ អលោភៈ អទោសៈ និងអមោហៈ ខាងវិបាកនៃកុសលធម៌ផង ខាងកិរិយាអព្យាកតធម៌ផង នេះអព្យាកតហេតុ ៣ ។

(១៩៣) បណ្តាហេតុទាំងនោះ កាមាវចរហេតុ ៩ តើដូចម្តេច ។ កុសលហេតុ ៣ អកុសលហេតុ ៣ អព្យាកតហេតុ ៣ នេះកាមាវចរហេតុ ៩ ។ បណ្តាហេតុទាំងនោះ រូបាវចរហេតុ ៦ តើដូចម្តេច ។ កុសលហេតុ ៣ អព្យាកតហេតុ ៣ នេះរូបាវចរហេតុ ៦ ។

## ហេតុគោច្ឆកេ និក្ខេបោ

តត្ថ កតមេ ធ អរូបាវចរហេតូ ។ តយោ កុសលហេ-តូ តយោ អព្យាកតហេតូ ឥមេ ធ អរូបាវចរហេតូ ។

(១៩៤) តត្ថ កតមេ ធ អបរិយាបន្នហេតូ ។ តយោ កុសលហេតូ តយោ អព្យាកតហេតូ ឥមេ ធ អបរិយាបន្នហេតូ ។ តត្ថ កតមេ តយោ កុសលហេតូ ។ អលោភោ អទោសោ អមោ-ហោ ។ តត្ថ កតមោ អលោភោ ។ យោ អលោ-ភោ អលុព្ភនា អលុព្ភិតត្តំ អសារាគោ អសារជ្ជនា អសារជ្ជិតត្តំ អនភិជ្ឈា អលោភោ កុសលមូលំ អយំ វុច្ចតិ អលោភោ ។ តត្ថ កតមោ អទោ-សោ ។ យោ អទោសោ អទុស្សនា អទុស្សិតត្តំ ។ បេ ។ អព្យាបាទោ អព្យាបជ្ជោ អទោសោ កុសលមូលំ អយំ វុច្ចតិ អទោសោ ។ តត្ថ កតមោ អមោ-ហោ ។ ទុក្ខេ ញាណំ ទុក្ខសមុទយេ ញាណំ ទុក្ខនិរោធេ ញាណំ ទុក្ខនិរោធគាមិនិយា បដិប-ទាយ ញាណំ បុព្វន្តេ ញាណំ អបរន្តេ ញាណំ បុព្វន្តាបរន្តេ ញាណំ ឥទប្បច្ចយតាបដិច្ចសមុប្បន្នេសុ ធម្មេសុ ញាណំ យា ឯវរូបា បញ្ញា បជាននា

ហេតុគោច្ឆកនិក្ខេប

បណ្ដាហេតុទាំងនោះ អរូបាវចរហេតុ ៦ តើដូចម្ដេច ។ កុសលហេតុ ៣ អព្យាកតហេតុ ៣ នេះអរូបាវចរហេតុ ៦ ។

(១៩៤) បណ្ដាហេតុទាំងនោះ អបរិយាបន្នហេតុ ៦ តើដូចម្ដេច ។ កុសលហេតុ ៣ អព្យាកតហេតុ ៣ នេះអបរិយាបន្នហេតុ ៦ ។ បណ្ដាហេតុទាំងនោះ កុសលហេតុ ៣ តើដូចម្ដេច ។ អលោភៈ អទោសៈ និងអមោហៈ ។ បណ្ដាកុសលហេតុទាំងនោះ អលោភៈ តើដូចម្ដេច ។ សេចក្ដីមិនប្រាថ្នាជាប់ ការមិនជាប់ចំពាក់ ភាពនៃចិត្តមិនជាប់ចំពាក់ សេចក្ដីមិនត្រេកអរខ្លាំង ការមិនត្រេកអរ ភាពនៃចិត្តមិនត្រេកអរ ការមិនសំឡឹងរំពៃ សេចក្ដីមិនលោភ ជាកុសលមូល ណា នេះហៅថា អលោភៈ ។ បណ្ដាកុសលហេតុទាំងនោះ អទោសៈ តើដូចម្ដេច ។ សេចក្ដីមិនប្រទូស្ដ អាការមិនប្រទូស្ដ ភាពនៃចិត្តមិនប្រទូស្ដ ។ បេ ។ ការមិនគុំកួន ការមិនបៀតបៀន ការមិនខឹង ជាកុសលមូល ណា នេះហៅថា អទោសៈ ។ បណ្ដាកុសលហេតុទាំងនោះ អមោហៈ តើដូចម្ដេច ។ ការដឹងច្បាស់ក្នុងកងទុក្ខ ដឹងច្បាស់ក្នុងទុក្ខសមុទ័យ ដឹងច្បាស់ក្នុងទុក្ខនិរោធ ដឹងច្បាស់ក្នុងទុក្ខនិរោធគាមិនីបដិបទា ដឹងច្បាស់ក្នុងខន្ធជាចំណែកខាងដើម ដឹងច្បាស់ក្នុងខន្ធជាចំណែកខាងចុង ដឹងច្បាស់ ក្នុងខន្ធជាចំណែកខាងដើមនិងខាងចុង ដឹងច្បាស់ក្នុងពួកធម៌ដែលកើតឡើង ព្រោះអាស្រ័យបច្ច័យនោះ ៗ និងបញ្ញា ការដឹងច្បាស់

វិចយោ បវិចយោ ធម្មវិចយោ សល្លក្ខណា ឧប-
លក្ខណា បច្ចុបលក្ខណា បណ្ឌិច្ចំ កោសល្លំ នេ-
បុញ្ញំ វេភព្យា ចិន្តា ឧបបរិក្ខា ភូរី មេធា បរិណា-
យិកា វិបស្សនា សម្បជញ្ញំ បតោទោ បញ្ញា បញ្ញិ-
ន្ទ្រិយំ បញ្ញាពលំ បញ្ញាសត្ថំ បញ្ញាបាសាទោ បញ្ញា-
អាលោកោ បញ្ញាឱភាសោ បញ្ញាបជ្ជោតោ បញ្ញា-
រតនំ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ ធម្មវិចយ-
សម្ពោជ្ឈង្គោ មគ្គង្គំ មគ្គបរិយាបន្នំ អយំ វុច្ចតិ អមោ-
ហោ ។ ឥមេ តយោ កុសលហេតូ ។ តត្ថ កតមេ
តយោ អព្យាកតហេតូ ។ កុសលានំ ធម្មានំ វិបា-
កតោ អលោភោ អទោសោ អមោហោ ឥមេ តយោ
អព្យាកតហេតូ ។ ឥមេ ន អបរិយាបន្នហេតូ ។

ឥមេ ធម្មា ហេតូ ។

(៧៩៥) កតមេ ធម្មា ន ហេតូ ។ តេ ធម្មេ
ឋបេត្វា អវសេសា កុសលាកុសលាព្យាកតា ធម្មា
កាមាវចរា រូបាវចរា អរូបាវចរា អបរិយាបន្នា វេទ-
នាក្ខន្ធោ ។ បេ ។ វិញ្ញាណក្ខន្ធោ សព្វញ្ច រូបំ
អសង្ខតា ច ធាតុ ឥមេ ធម្មា ន ហេតូ ។

ការសន្សំ ការប្រមូល ការពិចារណាធម៌ ការចំណាំ ការចំណាំស្និទ្ធ ការចំណាំចំពោះខ្លួន ភាពជាបណ្ឌិត ការឈ្លាសវៃ ប្រសប់ ប៉ិនធ្មៀ គិតគូរ ពិចារណា ប្រាជ្ញាដូចផែនដី ប្រាជ្ញាទម្លាយនូវកិលេស ធម្មជាតិសម្រាប់ដឹកនាំ ការយល់ឃើញច្បាស់ ដឹងខ្លួនច្បាស់លាស់ ចាក់ធ្លុះ បញ្ញា ឥន្ទ្រិយគឺបញ្ញា កំឡាំងគឺបញ្ញា គ្រឿងសស្ត្រាគឺបញ្ញា ប្រាសាទគឺបញ្ញា ពន្លឺគឺបញ្ញា រស្មីគឺបញ្ញា ប្រទីបគឺបញ្ញា កែវគឺបញ្ញា ការមិនវង្វេង ការពិចារណាធម៌ ការយល់ត្រូវ អង្គនៃការត្រាស់ដឹងគឺការពិចារណាធម៌ អង្គនៃមគ្គ មគ្គបរិយាបន្នៈ ណា មានសភាពបែបនេះ នេះហៅថា អមោហៈ ៗ នេះកុសលហេតុ ៣ ៗ បណ្ដាហេតុទាំងនោះ អព្យាកតហេតុ ៣ តើដូចម្ដេច ៗ អលោភៈ អទោសៈ និងអមោហៈ ខាងវិបាកនៃពួកកុសលធម៌ នេះអព្យាកតហេតុ ៣ ៗ នេះអបរិយាបន្នហេតុ ៦ ៗ

នេះពួកធម៌ជាហេតុ ៗ

(១៩៤) ពួកធម៌មិនមែនហេតុ តើដូចម្ដេច ៗ វៀរតែធម៌ទាំងនោះចេញ ពួកធម៌ដ៏សេសសល់ ជាកុសល អកុសល និងអព្យាក្រឹត ជាកាមាវចរ រូបាវចរ អរូបាវចរ អបរិយាបន្នៈ វេទនាខន្ធ ៗ បេ ៗ វិញ្ញាណក្ខន្ធ រូបទាំងអស់ និងអសង្ខតធាតុ នេះពួកធម៌មិនមែនហេតុ ៗ

ហេតុគោច្ឆកេ និក្ខេបោ

(១៩៦) កតមេ ធម្មា សហេតុកា ។ តេហិ ធម្មេហិ យេ ធម្មា សហេតុកា វេទនាក្ខន្ធោ ។ បេ ។ វិញ្ញាណក្ខន្ធោ ឥមេ ធម្មា សហេតុកា ។ កតមេ ធម្មា អហេតុកា ។ តេហិ ធម្មេហិ យេ ធម្មា អហេតុកា វេទនាក្ខន្ធោ ។ បេ ។ វិញ្ញាណក្ខន្ធោ សព្វញ្ច រូបំ អសង្ខតា ច ធាតុ ឥមេ ធម្មា អហេតុកា ។

(១៩៧) កតមេ ធម្មា ហេតុសម្បយុត្តា ។ តេហិ ធម្មេហិ យេ ធម្មា សម្បយុត្តា វេទនាក្ខន្ធោ ។ បេ ។ វិញ្ញាណក្ខន្ធោ ឥមេ ធម្មា ហេតុសម្បយុត្តា ។ កតមេ ធម្មា ហេតុវិប្បយុត្តា ។ តេហិ ធម្មេហិ យេ ធម្មា វិប្បយុត្តា វេទនាក្ខន្ធោ ។ បេ ។ វិញ្ញាណក្ខន្ធោ សព្វញ្ច រូបំ អសង្ខតា ច ធាតុ ឥមេ ធម្មា ហេតុវិប្បយុត្តា ។

(១៩៨) កតមេ ធម្មា ហេតូ ចេវ សហេតុកា ច ។ លោភោ មោហេន ហេតុ ចេវ សហេតុកោ ច មោហោ លោភេន ហេតុ ចេវ សហេតុកោ ច ទោសោ មោហេន ហេតុ ចេវ សហេតុកោ ច

ហេតុគោច្ឆកនិក្ខេប

( ១៩៦ ) ពួកធម៌ប្រព្រឹត្តទៅជាមួយនឹងហេតុ តើដូចម្តេច ។ ពួកធម៌ណា ប្រព្រឹត្តទៅជាមួយនឹងហេតុ ដោយធម៌ទាំងនោះ និងវេទនាខន្ធ ។ បេ ។ វិញ្ញាណក្ខន្ធ នេះពួកធម៌ប្រព្រឹត្តទៅជាមួយនឹងហេតុ ។ ពួកធម៌មិនប្រព្រឹត្តទៅជាមួយនឹងហេតុ តើដូចម្តេច ។ ពួកធម៌ណា មិនប្រព្រឹត្តទៅជាមួយនឹងហេតុ ដោយធម៌ទាំងនោះ វេទនាខន្ធ ។ បេ ។ វិញ្ញាណក្ខន្ធ រូបទាំងអស់ និងអសង្ខតធាតុ នេះពួកធម៌មិនប្រព្រឹត្តទៅជាមួយនឹងហេតុ ។

( ១៩៧ ) ពួកធម៌ប្រកបដោយហេតុ តើដូចម្តេច ។ ពួកធម៌ណា ប្រកបដោយធម៌ទាំងនោះ និងវេទនាខន្ធ ។ បេ ។ វិញ្ញាណក្ខន្ធ នេះពួកធម៌ប្រកបដោយហេតុ ។ ពួកធម៌ប្រាសចាកហេតុ តើដូចម្តេច ។ ពួកធម៌ណា ប្រាសចាកធម៌ទាំងនោះ វេទនាខន្ធ ។ បេ ។ វិញ្ញាណក្ខន្ធ រូបទាំងអស់ និងអសង្ខតធាតុ នេះពួកធម៌ប្រាសចាកហេតុ ។

( ១៩៨ ) ពួកធម៌ជាហេតុផង ប្រព្រឹត្តទៅជាមួយនឹងហេតុផង តើដូចម្តេច ។ លោភៈជាហេតុផង ប្រព្រឹត្តទៅជាមួយនឹងហេតុផង ដោយមោហៈ ឯមោហៈជាហេតុផង ប្រព្រឹត្តទៅជាមួយនឹងហេតុផង ដោយលោភៈ ទោសៈជាហេតុផង ប្រព្រឹត្តទៅជាមួយនឹងហេតុផង ដោយមោហៈ ឯមោហៈជាហេតុផង ប្រព្រឹត្តទៅជាមួយនឹងហេតុផង

មោហោ ទោសេន ហេតុ ចេវ សហេតុកោ ច អលោភោ អទោសោ អមោហោ តេ អញ្ញមញ្ញំ ហេតូ ចេវ សហេតុកា ច ឥមេ ធម្មា ហេតូ ចេវ សហេតុកា ច ។ កតមេ ធម្មា សហេតុកា ចេវ ន ច ហេតូ ។ យេហិ ធម្មេហិ យេ ធម្មា សហេតុកា តេ ធម្មេ ឋបេត្វា វេទនាក្ខន្ធោ ។ បេ ។ វិញ្ញាណក្ខន្ធោ ឥមេ ធម្មា សហេតុកា ចេវ ន ច ហេតូ ។

(១៩៩) កតមេ ធម្មា ហេតូ ចេវ ហេតុសម្បយុត្តា ច ។ លោភោ មោហេន ហេតុ ចេវ ហេតុសម្បយុត្តោ ច មោហោ លោភេន ហេតុ ចេវ ហេតុសម្បយុត្តោ ច ទោសោ មោហេន ហេតុ ចេវ ហេតុសម្បយុត្តោ ច មោហោ ទោសេន ហេតុ ចេវ ហេតុសម្បយុត្តោ ច អលោភោ អទោសោ អមោហោ តេ អញ្ញមញ្ញំ ហេតូ ចេវ ហេតុសម្បយុត្តា ច ឥមេ ធម្មា ហេតូ ចេវ ហេតុសម្បយុត្តា ច ។ កតមេ ធម្មា ហេតុសម្បយុត្តា ចេវ ន ច ហេតូ ។ យេហិ ធម្មេហិ យេ ធម្មា សម្បយុត្តា

ដោយទោសៈ អលោភៈ អទោសៈ និងអមោហៈ ជាហេតុផង ប្រព្រឹត្តទៅជាមួយនឹងហេតុទាំងនោះផង ទៅវិញទៅមក នេះពួកធម៌ជាហេតុផង ប្រព្រឹត្តទៅជាមួយនឹងហេតុផង ។ ពួកធម៌គ្រាន់តែប្រព្រឹត្តទៅជាមួយនឹងហេតុ តែមិនមែនហេតុ តើដូចម្ដេច ។ ពួកធម៌ណា ប្រព្រឹត្តទៅជាមួយនឹងហេតុ ដោយធម៌ទាំងនោះ វៀរតែធម៌ទាំងនោះចេញ នឹងវេទនាខន្ធ ។ បេ ។ វិញ្ញាណក្ខន្ធ នេះពួកធម៌គ្រាន់តែប្រព្រឹត្តទៅជាមួយនឹងហេតុតែមិនមែនហេតុ ។

( ១៩៩ ) ពួកធម៌ជាហេតុផង ប្រកបដោយហេតុផង តើដូចម្ដេច ។ លោភៈជាហេតុផង ប្រកបដោយហេតុផង ដោយមោហៈ ឯមោហៈជាហេតុផង ប្រកបដោយហេតុផង ដោយលោភៈ ទោសៈជាហេតុផង ប្រកបដោយហេតុផង ដោយមោហៈ ឯមោហៈជាហេតុផង ប្រកបដោយហេតុផង ដោយទោសៈ អលោភៈ អទោសៈ អមោហៈ ជាហេតុផង ប្រកបដោយហេតុទាំងនោះផង ទៅវិញទៅមក នេះពួកធម៌ជាហេតុផង ប្រកបដោយហេតុផង ។ ពួកធម៌គ្រាន់តែប្រកបដោយហេតុ តែមិនមែនហេតុ តើដូចម្ដេច ។ ពួកធម៌ណា ប្រកបដោយធម៌ទាំងនោះ

តេ ធម្មេ ឋបេត្វា វេទនាក្ខន្ធោ ។ បេ ។ វិញ្ញាណក្ខន្ធោ ឥមេ ធម្មា ហេតុសម្បយុត្តា ចេវ ន ច ហេតូ ។

(២០០) កតមេ ធម្មា ន ហេតូ សហេតុកា ។ តេហិ ធម្មេហិ យេ ធម្មា ន ហេតូ សហេតុកា វេទនាក្ខន្ធោ ។ បេ ។ វិញ្ញាណក្ខន្ធោ ឥមេ ធម្មា ន ហេតូ សហេតុកា ។ កតមេ ធម្មា ន ហេតូ អហេតុកា ។ តេហិ ធម្មេហិ យេ ធម្មា ន ហេតូ អហេតុកា វេទនាក្ខន្ធោ ។ បេ ។ វិញ្ញាណក្ខន្ធោ សព្វញ្ច រូបំ អសង្ខតា ច ធាតុ ឥមេ ធម្មា ន ហេតូ អហេតុកា ។

(២០១) កតមេ ធម្មា សប្បច្ចយា ។ បញ្ចក្ខន្ធា រូបក្ខន្ធោ វេទនាក្ខន្ធោ សញ្ញាក្ខន្ធោ សង្ខារក្ខន្ធោ វិញ្ញាណក្ខន្ធោ ឥមេ ធម្មា សប្បច្ចយា ។ កតមេ ធម្មា អប្បច្ចយា ។ អសង្ខតា ធាតុ ឥមេ ធម្មា អប្បច្ចយា ។

(២០២) កតមេ ធម្មា សង្ខតា ។ យេវ តេ ធម្មា សប្បច្ចយា តេវ តេ ធម្មា សង្ខតា ។

វៀរតែធម៌ទាំងនោះចេញ និងវេទនាខន្ធ ។ បេ ។ វិញ្ញាណក្ខន្ធ នេះ ពួកធម៌គ្រាន់តែប្រកបដោយហេតុ តែមិនមែនហេតុ ។

[ ២០០ ] ពួកធម៌មិនមែនហេតុ តែប្រព្រឹត្តទៅជាមួយនឹងហេតុ តើដូចម្តេច ។ ពួកធម៌ណា មិនមែនហេតុ តែប្រព្រឹត្តទៅជាមួយនឹងហេតុ ដោយធម៌ទាំងនោះ និងវេទនាខន្ធ ។ បេ ។ វិញ្ញាណក្ខន្ធ នេះពួកធម៌មិនមែនហេតុ តែប្រព្រឹត្តទៅជាមួយនឹងហេតុ ។ ពួកធម៌មិនមែនហេតុ ទាំងមិនប្រព្រឹត្តទៅជាមួយនឹងហេតុ តើដូចម្តេច ។ ពួកធម៌ណា មិនមែនហេតុ ទាំងមិនប្រព្រឹត្តទៅជាមួយនឹងហេតុ ដោយធម៌ទាំងនោះ វេទនាខន្ធ ។ បេ ។ វិញ្ញាណក្ខន្ធ រូបទាំងអស់ និងអសង្ខតធាតុ នេះពួកធម៌ មិនមែនហេតុ ទាំងមិនប្រព្រឹត្តទៅជាមួយនឹងហេតុ ។

[ ២០១ ] ពួកធម៌ប្រកបដោយបច្ច័យ តើដូចម្តេច ។ ខន្ធ ៥ គឺ រូបក្ខន្ធ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ នេះពួកធម៌ប្រកបដោយបច្ច័យ ។ ពួកធម៌មិនមានបច្ច័យ តើដូចម្តេច ។ អសង្ខតធាតុ នេះពួកធម៌មិនមានបច្ច័យ ។

[ ២០២ ] ពួកធម៌មានបច្ច័យតាក់តែង តើដូចម្តេច ។ ពួកធម៌ណា ប្រកបដោយបច្ច័យ ធម៌ទាំងនោះ ជាធម៌មានបច្ច័យតាក់តែង ។

កតមេ ធម្មា អសង្ខតា ។ យោ ឯវ សោ ធម្មោ អប្បច្ចយោ សោ ឯវ សោ ធម្មោ អសង្ខតោ ។

(២០៣) កតមេ ធម្មា សនិទស្សនា ។ រូបាយតនំ ឥមេ ធម្មា សនិទស្សនា ។ កតមេ ធម្មា អនិទស្សនា ។ ចក្ខាយតនំ ។ បេ ។ ផោដ្ឋព្វាយតនំ វេទនាក្ខន្ធោ ។ បេ ។ វិញ្ញាណក្ខន្ធោ យញ្ច រូបំ អនិទស្សនំ អប្បដិឃំ ធម្មាយតនបរិយាបន្នំ អសង្ខតា ច ធាតុ ឥមេ ធម្មា អនិទស្សនា ។

(២០៤) កតមេ ធម្មា សប្បដិឃា ។ ចក្ខាយតនំ ។ បេ ។ ផោដ្ឋព្វាយតនំ ឥមេ ធម្មា សប្បដិឃា ។ កតមេ ធម្មា អប្បដិឃា ។ វេទនាក្ខន្ធោ ។ បេ ។ វិញ្ញាណក្ខន្ធោ យញ្ច រូបំ អនិទស្សនំ អប្បដិឃំ ធម្មាយតនបរិយាបន្នំ អសង្ខតា ច ធាតុ ឥមេ ធម្មា អប្បដិឃា ។

(២០៥) កតមេ ធម្មា រូបិនោ ។ ចត្តារោ ច មហាភូតា ចតុន្នំ ច មហាភូតានំ ឧបាទាយ រូបំ ឥមេ ធម្មា រូបិនោ ។ កតមេ ធម្មា អរូបិនោ ។ វេទនាក្ខន្ធោ ។ បេ ។ វិញ្ញាណក្ខន្ធោ

ពួកធម៌មិនមានបច្ច័យតាក់តែង តើដូចម្តេច ។ ធម៌ណា មិនមានបច្ច័យ ធម៌នោះឯង ជាធម៌មិនមានបច្ច័យតាក់តែង ។

( ២០៣ ) ពួកធម៌ប្រកបដោយការឃើញ តើដូចម្តេច ។ រូបា-យតនៈ នេះពួកធម៌ប្រកបដោយការឃើញ ។ ពួកធម៌មិនប្រកបដោយការឃើញ តើដូចម្តេច ។ ចក្ខាយតនៈ ។ បេ ។ ផោដ្ឋព្វាយតនៈ វេទ-នាខន្ធ ។ បេ ។ វិញ្ញាណក្ខន្ធ រូបជាអនិទស្សនៈ ជាអប្បដិឃៈ រាប់បញ្ចូលក្នុងធម្មាយតនៈ និងអសង្ខតធាតុ នេះពួកធម៌ មិនប្រកបដោយការឃើញ ។

( ២០៤ ) ពួកធម៌ប្រកបដោយការប៉ះពាល់ តើដូចម្តេច ។ ចក្ខា-យតនៈ ។ បេ ។ ផោដ្ឋព្វាយតនៈ នេះពួកធម៌ប្រកបដោយការប៉ះពាល់ ។ ពួកធម៌មិនប្រកបដោយការប៉ះពាល់ តើដូចម្តេច ។ វេទនាខន្ធ ។ បេ ។ វិញ្ញាណក្ខន្ធ រូបជាអនិទស្សនៈ ជាអប្បដិឃៈ រាប់បញ្ចូលក្នុងធម្មាយតនៈ និងអសង្ខតធាតុ នេះពួកធម៌មិនប្រកបដោយការប៉ះពាល់ ។

( ២០៥ ) ពួកធម៌មានរូប តើដូចម្តេច ។ មហាភូតរូប ៤ និង រូបដែលអាស្រ័យនូវមហាភូតរូបទាំង ៤ នេះពួកធម៌មានរូប ។ ពួកធម៌មិនមានរូប តើដូចម្តេច ។ វេទនាខន្ធ ។ បេ ។ វិញ្ញាណក្ខន្ធ

អសង្ខតា ច ធាតុ ឥមេ ធម្មា អរូបិនោ ។

(២០៦) កតមេ ធម្មា លោកិយា ។ សាសវា កុសលាកុសលាព្យាកតា ធម្មា កាមាវចរា រូបាវចរា អរូបាវចរា រូបក្ខន្ធោ ។ បេ ។ វិញ្ញាណក្ខន្ធោ ឥមេ ធម្មា លោកិយា ។ កតមេ ធម្មា លោកុត្តរា ។ អបរិយាបន្នា មគ្គា ច មគ្គផលានិ ច អសង្ខតា ច ធាតុ ឥមេ ធម្មា លោកុត្តរា ។

(២០៧) កតមេ ធម្មា កេនចិ វិញ្ញេយ្យា កេនចិ ន វិញ្ញេយ្យា ។ យេ តេ ធម្មា ចក្ខុវិញ្ញេយ្យា ន តេ ធម្មា សោតវិញ្ញេយ្យា យេ វា បន តេ ធម្មា សោតវិញ្ញេយ្យា ន តេ ធម្មា ចក្ខុវិញ្ញេយ្យា យេ តេ ធម្មា ចក្ខុវិញ្ញេយ្យា ន តេ ធម្មា ឃានវិញ្ញេយ្យា យេ វា បន តេ ធម្មា ឃានវិញ្ញេយ្យា ន តេ ធម្មា ចក្ខុវិញ្ញេយ្យា យេ តេ ធម្មា ចក្ខុវិញ្ញេយ្យា ន តេ ធម្មា ជិវ្ហាវិញ្ញេយ្យា យេ វា បន តេ ធម្មា ជិវ្ហាវិញ្ញេយ្យា ន តេ ធម្មា ចក្ខុវិញ្ញេយ្យា យេ តេ ធម្មា ចក្ខុវិញ្ញេយ្យា ន តេ ធម្មា កាយវិញ្ញេយ្យា

និងអសង្ខតធាតុ នេះពួកធម៌មិនមានរូប ។

(២០៦) ពួកធម៌ជាលោកិយ តើដូចម្តេច ។ ពួកធម៌ប្រកបដោយអាសវៈ ជាកុសល អកុសល និងអព្យាក្រឹត ជាកាមាវចរ រូបាវចរ អរូបាវចរ និងរូបក្ខន្ធ ។ បេ ។ វិញ្ញាណក្ខន្ធ នេះពួកធម៌ ជាលោកិយ ។ ពួកធម៌ជាលោកុត្តរ តើដូចម្តេច ។ មគ្គជាអបរិយាបន្នៈផង ផលដែលកើតអំពីមគ្គផង អសង្ខតធាតុផង នេះពួកធម៌ជាលោកុត្តរ ។

(២០៧) ពួកធម៌គួរដឹងច្បាស់ដោយវិញ្ញាណនីមួយ មិនគួរដឹងច្បាស់ដោយវិញ្ញាណនីមួយ តើដូចម្តេច ។ ពួកធម៌ណា ដែលគប្បីដឹងដោយចក្ខុវិញ្ញាណ ពួកធម៌នោះមិនមែនបុគ្គលដឹងដោយសោតវិញ្ញាណទេ មួយទៀត ពួកធម៌ណា ដែលគប្បីដឹងដោយសោតវិញ្ញាណ ពួកធម៌នោះ មិនមែនបុគ្គលដឹង ដោយចក្ខុវិញ្ញាណទេ ពួកធម៌ណា ដែលគប្បីដឹងដោយចក្ខុវិញ្ញាណ ពួកធម៌នោះ មិនមែនបុគ្គលដឹងដោយឃានវិញ្ញាណទេ មួយទៀត ពួកធម៌ណា ដែលគប្បីដឹងដោយឃានវិញ្ញាណ ពួកធម៌នោះ មិនមែនបុគ្គលដឹង ដោយចក្ខុវិញ្ញាណទេ ពួកធម៌ណា ដែលគប្បីដឹងដោយចក្ខុវិញ្ញាណ ពួកធម៌នោះ មិនមែនបុគ្គលដឹងដោយជិវ្ហាវិញ្ញាណទេ មួយទៀត ពួកធម៌ណា ដែលគប្បីដឹងដោយជិវ្ហាវិញ្ញាណ ពួកធម៌នោះ មិនមែនបុគ្គលដឹងដោយចក្ខុវិញ្ញាណទេ ពួកធម៌ណា ដែលគប្បីដឹងដោយចក្ខុវិញ្ញាណ ពួកធម៌នោះ មិនមែនបុគ្គលដឹងដោយកាយវិញ្ញាណទេ

យេ វា បន តេ ធម្មា កាយវិញ្ញេយ្យា ន តេ ធម្មា ចក្ខុវិញ្ញេយ្យា យេ តេ ធម្មា សោតវិញ្ញេយ្យា ន តេ ធម្មា ឃានវិញ្ញេយ្យា យេ វា បន តេ ធម្មា ឃានវិញ្ញេយ្យា ន តេ ធម្មា សោតវិញ្ញេយ្យា យេ តេ ធម្មា សោតវិញ្ញេយ្យា ន តេ ធម្មា ជិវ្ហាវិញ្ញេយ្យា យេ វា បន តេ ធម្មា ជិវ្ហាវិញ្ញេយ្យា ន តេ ធម្មា សោតវិញ្ញេយ្យា យេ តេ ធម្មា សោតវិញ្ញេយ្យា ន តេ ធម្មា កាយវិញ្ញេយ្យា យេ វា បន តេ ធម្មា កាយវិញ្ញេយ្យា ន តេ ធម្មា សោតវិញ្ញេយ្យា យេ តេ ធម្មា សោតវិញ្ញេយ្យា ន តេ ធម្មា ចក្ខុវិញ្ញេយ្យា យេ វា បន តេ ធម្មា ចក្ខុវិញ្ញេយ្យា ន តេ ធម្មា សោតវិញ្ញេយ្យា យេ តេ ធម្មា ឃានវិញ្ញេយ្យា ន តេ ធម្មា ជិវ្ហាវិញ្ញេយ្យា យេ វា បន តេ ធម្មា ជិវ្ហាវិញ្ញេយ្យា ន តេ ធម្មា ឃានវិញ្ញេយ្យា យេ តេ ធម្មា ឃានវិញ្ញេយ្យា

មួយទៀត ពួកធម៌ណា ដែលគប្បីដឹងដោយកាយវិញ្ញាណ ពួកធម៌នោះ មិនមែនបុគ្គលដឹងដោយចក្ខុវិញ្ញាណទេ ពួកធម៌ណា ដែលគប្បីដឹងដោយសោតវិញ្ញាណ ពួកធម៌នោះ មិនមែនបុគ្គលដឹងដោយឃានវិញ្ញាណទេ មួយទៀត ពួកធម៌ណា ដែលគប្បីដឹងដោយឃានវិញ្ញាណ ពួកធម៌នោះ មិនមែនបុគ្គលដឹង ដោយសោតវិញ្ញាណទេ ពួកធម៌ណា ដែលគប្បីដឹងដោយសោតវិញ្ញាណ ពួកធម៌នោះ មិនមែនបុគ្គលដឹងដោយជិវ្ហាវិញ្ញាណទេ មួយទៀត ពួកធម៌ណា ដែលគប្បីដឹងដោយជិវ្ហាវិញ្ញាណ ពួកធម៌នោះ មិនមែនបុគ្គលដឹងដោយសោតវិញ្ញាណទេ ពួកធម៌ណា ដែលគប្បីដឹងដោយសោតវិញ្ញាណ ពួកធម៌នោះ មិនមែនបុគ្គលដឹងដោយកាយវិញ្ញាណទេ មួយទៀត ពួកធម៌ណា ដែលគប្បីដឹងដោយកាយវិញ្ញាណ ពួកធម៌នោះ មិនមែនបុគ្គលដឹងដោយសោតវិញ្ញាណទេ ពួកធម៌ណា ដែលគប្បីដឹង ដោយសោតវិញ្ញាណ ពួកធម៌នោះ មិនមែនបុគ្គលដឹងដោយចក្ខុវិញ្ញាណទេ មួយទៀត ពួកធម៌ណា ដែលគប្បីដឹងដោយចក្ខុវិញ្ញាណ ពួកធម៌នោះ មិនមែនបុគ្គលដឹងដោយសោតវិញ្ញាណទេ ពួកធម៌ណា ដែលគប្បីដឹង ដោយឃានវិញ្ញាណ ពួកធម៌នោះ មិនមែនបុគ្គលដឹងដោយជិវ្ហាវិញ្ញាណទេ មួយទៀត ពួកធម៌ណា ដែលគប្បីដឹងដោយជិវ្ហាវិញ្ញាណ ពួកធម៌នោះ មិនមែនបុគ្គលដឹងដោយឃានវិញ្ញាណទេ ពួកធម៌ណា ដែលគប្បីដឹងដោយឃានវិញ្ញាណ

ចូឡន្តរទុកេ និក្ខេបោ

ន តេ ធម្មា កាយវិញ្ញេយ្យា យេ វា បន តេ ធម្មា កាយវិញ្ញេយ្យា ន តេ ធម្មា ឃានវិញ្ញេយ្យា យេ តេ ធម្មា ឃានវិញ្ញេយ្យា ន តេ ធម្មា ចក្ខុវិញ្ញេយ្យា យេ វា បន តេ ធម្មា ចក្ខុវិញ្ញេយ្យា ន តេ ធម្មា ឃានវិញ្ញេយ្យា យេ តេ ធម្មា ឃានវិញ្ញេយ្យា ន តេ ធម្មា សោតវិញ្ញេយ្យា យេ វា បន តេ ធម្មា សោតវិញ្ញេយ្យា ន តេ ធម្មា ឃានវិញ្ញេយ្យា យេ តេ ធម្មា ជិវ្ហាវិញ្ញេយ្យា ន តេ ធម្មា កាយវិញ្ញេយ្យា យេ វា បន តេ ធម្មា កាយវិញ្ញេយ្យា ន តេ ធម្មា ជិវ្ហាវិញ្ញេយ្យា យេ តេ ធម្មា ជិវ្ហាវិញ្ញេយ្យា ន តេ ធម្មា ចក្ខុវិញ្ញេយ្យា យេ វា បន តេ ធម្មា ចក្ខុវិញ្ញេយ្យា ន តេ ធម្មា ជិវ្ហាវិញ្ញេយ្យា យេ តេ ធម្មា ជិវ្ហាវិញ្ញេយ្យា ន តេ ធម្មា សោតវិញ្ញេយ្យា យេ វា បន តេ ធម្មា សោតវិញ្ញេយ្យា ន តេ ធម្មា ជិវ្ហាវិញ្ញេយ្យា យេ តេ ធម្មា ជិវ្ហាវិញ្ញេយ្យា

ពួកធម៌នោះ មិនមែនបុគ្គលដឹងដោយកាយវិញ្ញាណទេ មួយទៀត ពួកធម៌ណា ដែលគប្បីដឹងដោយកាយវិញ្ញាណ ពួកធម៌នោះ មិនមែនបុគ្គលដឹងដោយឃានវិញ្ញាណទេ ពួកធម៌ណា ដែលគប្បីដឹងដោយឃានវិញ្ញាណ ពួកធម៌នោះ មិនមែនបុគ្គលដឹងដោយចក្ខុវិញ្ញាណទេ មួយទៀត ពួកធម៌ណា ដែលគប្បីដឹងដោយចក្ខុវិញ្ញាណ ពួកធម៌នោះ មិនមែនបុគ្គលដឹងដោយឃានវិញ្ញាណទេ ពួកធម៌ណា ដែលគប្បីដឹងដោយឃានវិញ្ញាណ ពួកធម៌នោះ មិនមែនបុគ្គលដឹងដោយសោតវិញ្ញាណទេ មួយទៀត ពួកធម៌ណា ដែលគប្បីដឹងដោយសោតវិញ្ញាណ ពួកធម៌នោះ មិនមែនបុគ្គលដឹងដោយឃានវិញ្ញាណទេ ពួកធម៌ណា ដែលគប្បីដឹងដោយជិវ្ហាវិញ្ញាណ ពួកធម៌នោះ មិនមែនបុគ្គលដឹងដោយកាយវិញ្ញាណទេ មួយទៀត ពួកធម៌ណា ដែលគប្បីដឹងដោយកាយវិញ្ញាណ ពួកធម៌នោះ មិនមែនបុគ្គលដឹងដោយជិវ្ហាវិញ្ញាណទេ ពួកធម៌ណា ដែលគប្បីដឹងដោយជិវ្ហាវិញ្ញាណ ពួកធម៌នោះ មិនមែនបុគ្គលដឹងដោយចក្ខុវិញ្ញាណទេ មួយទៀត ពួកធម៌ណា ដែលគប្បីដឹងដោយចក្ខុវិញ្ញាណ ពួកធម៌នោះ មិនមែនបុគ្គលដឹងដោយជិវ្ហាវិញ្ញាណទេ ពួកធម៌ណា ដែលគប្បីដឹងដោយជិវ្ហាវិញ្ញាណ ពួកធម៌នោះ មិនមែនបុគ្គលដឹងដោយសោតវិញ្ញាណទេ មួយទៀត ពួកធម៌ណា ដែលគប្បីដឹងដោយសោតវិញ្ញាណ ពួកធម៌នោះ មិនមែនបុគ្គលដឹងដោយជិវ្ហាវិញ្ញាណទេ ពួកធម៌ណា ដែលគប្បីដឹងដោយជិវ្ហាវិញ្ញាណ

ន តេ ធម្មា ឃានវិញ្ញេយ្យា យេ វា បន តេ ធម្មា ឃានវិញ្ញេយ្យា ន តេ ធម្មា ជិវ្ហាវិញ្ញេយ្យា យេ តេ ធម្មា កាយវិញ្ញេយ្យា ន តេ ធម្មា ចក្ខុវិញ្ញេយ្យា យេ វា បន តេ ធម្មា ចក្ខុវិញ្ញេយ្យា ន តេ ធម្មា កាយវិញ្ញេយ្យា យេ តេ ធម្មា កាយវិញ្ញេយ្យា ន តេ ធម្មា សោតវិញ្ញេយ្យា យេ វា បន តេ ធម្មា សោតវិញ្ញេយ្យា ន តេ ធម្មា កាយវិញ្ញេយ្យា យេ តេ ធម្មា កាយវិញ្ញេយ្យា ន តេ ធម្មា ឃានវិញ្ញេយ្យា យេ វា បន តេ ធម្មា ឃានវិញ្ញេយ្យា ន តេ ធម្មា កាយវិញ្ញេយ្យា យេ តេ ធម្មា កាយវិញ្ញេយ្យា ន តេ ធម្មា ជិវ្ហាវិញ្ញេយ្យា យេ វា បន តេ ធម្មា ជិវ្ហាវិញ្ញេយ្យា ន តេ ធម្មា កាយវិញ្ញេយ្យា ឥមេ ធម្មា កេនចិ វិញ្ញេយ្យា កេនចិ ន វិញ្ញេយ្យា ។

(២០៨) កតមេ ធម្មា អាសវា ។ ចត្តារោ អាសវា កាមាសវោ ភវាសវោ ទិដ្ឋាសវោ អវិជ្ជាសវោ ។

ពួកធម៌នោះ មិនមែនបុគ្គលដឹងដោយឃានវិញ្ញាណទេ មួយទៀត ពួកធម៌ណា ដែលគប្បីដឹងដោយឃានវិញ្ញាណ ពួកធម៌នោះ មិនមែនបុគ្គលដឹងដោយជិវ្ហាវិញ្ញាណទេ ពួកធម៌ណា ដែលគប្បីដឹងដោយកាយវិញ្ញាណ ពួកធម៌នោះ មិនមែនបុគ្គលដឹងដោយចក្ខុវិញ្ញាណទេ មួយទៀត ពួកធម៌ណា ដែលគប្បីដឹងដោយចក្ខុវិញ្ញាណ ពួកធម៌នោះ មិនមែនបុគ្គលដឹងដោយកាយវិញ្ញាណទេ ពួកធម៌ណា ដែលគប្បីដឹងដោយកាយវិញ្ញាណ ពួកធម៌នោះ មិនមែនបុគ្គលដឹង ដោយសោតវិញ្ញាណទេ មួយទៀត ពួកធម៌ណា ដែលគប្បីដឹងដោយសោតវិញ្ញាណ ពួកធម៌នោះ មិនមែនបុគ្គលដឹងដោយកាយវិញ្ញាណទេ ពួកធម៌ណា ដែលគប្បីដឹងដោយកាយ-វិញ្ញាណ ពួកធម៌នោះ មិនមែនបុគ្គលដឹងដោយឃានវិញ្ញាណទេ មួយទៀត ពួកធម៌ណា ដែលគប្បីដឹង ដោយឃានវិញ្ញាណ ពួកធម៌នោះ មិនមែនបុគ្គលដឹង ដោយកាយវិញ្ញាណទេ ពួកធម៌ណា ដែលគប្បីដឹងដោយកាយវិញ្ញាណ ពួកធម៌នោះ មិនមែនបុគ្គលដឹងដោយជិវ្ហាវិញ្ញាណទេ មួយទៀត ពួកធម៌ណា ដែលគប្បីដឹងដោយជិវ្ហាវិញ្ញាណ ពួកធម៌នោះ មិនមែនបុគ្គលដឹងដោយកាយវិញ្ញាណទេ នេះពួកធម៌ដែលគួរដឹងច្បាស់ដោយវិញ្ញាណនីមួយ មិនគួរដឹងច្បាស់ដោយវិញ្ញាណនីមួយ ។

( ៦០៨ ) ពួកធម៌ជាអាសវៈ តើដូចម្តេច ។ អាសវៈ ៤ យ៉ាង គឺ កាមាសវៈ ភវាសវៈ ទិដ្ឋាសវៈ អវិជ្ជាសវៈ ។

ចូឡន្តរទុកេ និក្ខេបោ

(២០៩) តត្ថ កតមោ កាមាសវោ ។ យោ កាមេសុ កាមច្ឆន្ទោ កាមរាគោ កាមនន្ទី កាមតណ្ហា កាមសិនេហោ(១) កាមបរិឡាហោ កាមមុច្ឆា កាមជ្ឈោសានំ អយំ វុច្ចតិ កាមាសវោ ។

(២១០) តត្ថ កតមោ ភវាសវោ ។ យោ ភវេសុ ភវច្ឆន្ទោ ភវរាគោ ភវនន្ទី ភវតណ្ហា ភវសិនេហោ ភវបរិឡាហោ ភវមុច្ឆា ភវជ្ឈោសានំ អយំ វុច្ចតិ ភវាសវោ ។

(២១១) តត្ថ កតមោ ទិដ្ឋាសវោ ។ សស្សតោ លោកោតិ វា អសស្សតោ លោកោតិ វា អន្តវា លោកោតិ វា អនន្តវា លោកោតិ វា តំ ជីវំ តំ សរីរន្តិ វា អញ្ញំ ជីវំ អញ្ញំ សរីរន្តិ វា ហោតិ តថាគតោ បរម្មរណាតិ វា ន ហោតិ តថាគតោ បរម្មរណាតិ វា ហោតិ ច ន ច ហោតិ តថាគតោ បរម្មរណាតិ វា នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណាតិ វា យា ឯវរូបា ទិដ្ឋិ ទិដ្ឋិគតំ ទិដ្ឋិគហនំ ទិដ្ឋិកន្តារោ ទិដ្ឋិវិសូកាយិកំ

---

១ ឱ. ឯត្ថន្តរេ កាមបិបាសោតិ ទិស្សតិ ។

(២០៩) បណ្ដាអាសវៈទាំងនោះ កាមាសវៈ តើដូចម្ដេច ។ សេចក្ដីប្រាថ្នាក្នុងកាម តម្រេកក្នុងកាម ការរីករាយក្នុងកាម ការអន្ទះសាក្នុងកាម សេចក្ដីស្រឡាញ់ក្នុងកាម ការរោលរាលក្នុងកាម ការជ្រប់នៅក្នុងកាម ការងប់ចិត្តក្នុងកាម ណា បំពោះកាមទាំងឡាយ នេះហៅថា កាមាសវៈ ។

(២១០) បណ្ដាអាសវៈទាំងនោះ ភវាសវៈ តើដូចម្ដេច ។ សេចក្ដីប្រាថ្នាក្នុងភព តម្រេកក្នុងភព ការរីករាយក្នុងភព ការអន្ទះសាក្នុងភព សេចក្ដីស្រឡាញ់ក្នុងភព ការរោលរាលក្នុងភព ការជ្រប់នៅក្នុងភព ការងប់ចិត្តក្នុងភព ណា បំពោះភពទាំងឡាយ នេះហៅថា ភវាសវៈ ។

(២១១) បណ្ដាអាសវៈទាំងនោះ ទិដ្ឋាសវៈ តើដូចម្ដេច ។ ការយល់ឃើញ ថាលោកទៀងខ្លះ ថាលោកមិនទៀងខ្លះ ថាលោកមានទីបំផុតខ្លះ ថាលោកមិនមានទីបំផុតខ្លះ ថាជីវិតនោះ គឺសរីរៈនោះខ្លះ ថាជីវិតដទៃ សរីរៈដទៃខ្លះ ថាសត្វស្លាប់ទៅកើតទៀតខ្លះ ថាសត្វស្លាប់ទៅមិនកើតទៀតខ្លះ ថាសត្វស្លាប់ទៅកើតទៀតក៏មាន មិនកើតទៀតក៏មានខ្លះ ថាសត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនខ្លះ និងទិដ្ឋិ ដំណើរគឺទិដ្ឋិ ព្រៃញាតស្បាតគឺទិដ្ឋិ ផ្លូវឆ្ងាយគឺទិដ្ឋិ ចម្រុងគឺទិដ្ឋិ

ទិដ្ឋិវិប្ផន្ទិតំ ទិដ្ឋិសញ្ញោជនំ គាហោ បដិគ្គាហោ អភិនិវេសោ បរាមាសោ កុម្មគ្គោ មិច្ឆាបថោ មិច្ឆត្តំ តិត្ថាយតនំ វិបរិយេសគ្គាហោ អយំ វុច្ចតិ ទិដ្ឋាសវោ ។ សព្វាបិ មិច្ឆាទិដ្ឋិ ទិដ្ឋាសវោ ។

(២១២) តត្ថ កតមោ អវិជ្ជាសវោ ។ ទុក្ខេ អញ្ញាណំ ទុក្ខសមុទយេ អញ្ញាណំ ទុក្ខនិរោធេ អញ្ញាណំ ទុក្ខនិរោធគាមិនិយា បដិបទាយ អញ្ញាណំ បុព្វន្តេ អញ្ញាណំ អបរន្តេ អញ្ញាណំ បុព្វន្តាបរន្តេ អញ្ញាណំ ឥទប្បច្ចយតាបដិច្ចសមុប្បន្នេសុ ធម្មេសុ អញ្ញាណំ យំ ឯវរូបំ អញ្ញាណំ អទស្សនំ អនភិសមយោ អននុពោធោ អសម្ពោធោ អប្បដិវេធោ អសង្គាហនា អបរិយោគាហនា អសមបេក្ខនា អប្បច្ចវេក្ខណា អប្បច្ចក្ខកម្មំ ទុម្មេជ្ឈំ ពាល្យំ អសម្បជញ្ញំ មោហោ បមោហោ សម្មោហោ អវិជ្ជា អវិជ្ជោឃោ អវិជ្ជាយោគោ អវិជ្ជានុសយោ អវិជ្ជាបរិយុដ្ឋានំ អវិជ្ជាលង្គី មោហោ អកុសលមូលំ អយំ វុច្ចតិ អវិជ្ជាសវោ ។

ឥមេ ធម្មា អាសវា ។

ការយល់ឃើញគឺទិដ្ឋិ ការទាក់ទិនគឺទិដ្ឋិ ការកាន់ ការប្រកាន់ ការប្រកាន់ខ្ជាប់ ការស្ទាបអង្អែល ផ្លូវអាក្រក់ ផ្លូវខុស ធម្មជាតដែលខុស លទ្ធិដូចជាកំពង់ សេចក្ដីប្រកាន់ក្នុងការស្វែងរកខុស ណា ដែលមានសភាពបែបនេះ នេះហៅថា ទិដ្ឋាសវៈ ។ មួយទៀត មិច្ឆាទិដ្ឋិទាំងអស់ ក៏ហៅថា ទិដ្ឋាសវៈដែរ ។

[ ៦១៦ ] បណ្ដាអាសវៈទាំងនោះ អវិជ្ជាសវៈ តើដូចម្ដេច ។ ការមិនដឹងក្នុងទុក្ខ មិនដឹងក្នុងហេតុនៃទុក្ខ មិនដឹងក្នុងការរលត់ទុក្ខ មិនដឹងក្នុងបដិបទា ជាដំណើរទៅកាន់ទីរលត់ទុក្ខ មិនដឹងក្នុងខន្ធជាចំណែកខាងដើម មិនដឹងក្នុងខន្ធជាចំណែកខាងចុង មិនដឹងក្នុងខន្ធជាចំណែកខាងដើមនិងខាងចុង មិនដឹងក្នុងពួកធម៌ដែលកើតឡើង ព្រោះអាស្រ័យបច្ច័យនោះៗ និងការមិនដឹង ការមិនឃើញ ការមិនត្រាស់ដឹង ការមិនយល់ ការមិនត្រាស់ដឹងព្រម ការមិនចាក់ធ្លុះ ការមិនបានដោតក្រងទុក មិនចុះចិត្តស៊ប់ មិនរំពឹងមើល មិនពិចារណា អំពើមិនជាក់ច្បាស់ ការយល់បានដោយក្រ ភាពនៃចិត្តល្ងង់ ការមិនដឹងខ្លួន ការវង្វេង វង្វេងជ្រប់ ការភ្លេចភ្លាំង អវិជ្ជា (ការមិនដឹងច្បាស់) ជំនន់គឺអវិជ្ជា ការប្រកបគឺអវិជ្ជា អនុស័យគឺអវិជ្ជា ការស្ទាក់ដំណើរគឺអវិជ្ជា គន្លឹះគឺអវិជ្ជា ការវង្វេង ជាអកុសលមូល ណា ដែលមានសភាពបែបនេះ នេះហៅថាអវិជ្ជាសវៈ ។

នេះពួកធម៌ជាអាសវៈ ។

(២១៣) កតមេ ធម្មា នោ អាសវា ។ តេ ធម្មេ ឋបេត្វា អវសេសា កុសលាកុសលាព្យាកតា ធម្មា កាមាវចរា រូបាវចរា អរូបាវចរា អបរិយាបន្នា វេទនាក្ខន្ធោ ។ បេ ។ វិញ្ញាណក្ខន្ធោ សព្វញ្ច រូបំ អសង្ខតា ច ធាតុ ឥមេ ធម្មា នោ អាសវា ។

(២១៤) កតមេ ធម្មា សាសវា ។ សាសវា កុសលាកុសលាព្យាកតា ធម្មា កាមាវចរា រូបាវចរា អរូបាវចរា រូបក្ខន្ធោ ។ បេ ។ វិញ្ញាណក្ខន្ធោ ឥមេ ធម្មា សាសវា ។ កតមេ ធម្មា អនាសវា ។ អបរិយាបន្នា មគ្គា ច មគ្គផលានិ ច អសង្ខតា ច ធាតុ ឥមេ ធម្មា អនាសវា ។

(២១៥) កតមេ ធម្មា អាសវសម្បយុត្តា ។ តេហិ ធម្មេហិ យេ ធម្មា សម្បយុត្តា វេទនាក្ខន្ធោ ។ បេ ។ វិញ្ញាណក្ខន្ធោ ឥមេ ធម្មា អាសវសម្បយុត្តា ។ កតមេ ធម្មា អាសវវិប្បយុត្តា ។ តេហិ ធម្មេហិ យេ ធម្មា វិប្បយុត្តា វេទនាក្ខន្ធោ ។ បេ ។ វិញ្ញាណក្ខន្ធោ សព្វញ្ច រូបំ អសង្ខតា ច ធាតុ ឥមេ ធម្មា អាសវវិប្បយុត្តា ។

[ ២១៣ ] ពួកធម៌មិនមែនជាអាសវៈ តើដូចម្តេច ។ វៀរតែធម៌ទាំងនោះចេញ ពួកធម៌ដ៏សេសសល់ ជាកុសល អកុសល និងអព្យាក្រឹត ជាកាមាវចរ រូបាវចរ អរូបាវចរ អបរិយាបន្នៈ វេទនាខន្ធ ។ បេ ។ វិញ្ញាណក្ខន្ធ រូបទាំងអស់ និងអសង្ខតធាតុ នេះពួកធម៌មិនមែនជាអាសវៈ ។

[ ២១៤ ] ពួកធម៌ប្រព្រឹត្តទៅជាមួយនឹងអាសវៈ តើដូចម្តេច ។ ពួកធម៌ប្រព្រឹត្តទៅជាមួយនឹងអាសវៈ ជាកុសល អកុសល និងអព្យាក្រឹត ជាកាមាវចរ រូបាវចរ អរូបាវចរ និងរូបក្ខន្ធ ។ បេ ។ វិញ្ញាណក្ខន្ធ នេះពួកធម៌ ប្រព្រឹត្តទៅជាមួយនឹងអាសវៈ ។ ពួកធម៌មិនប្រព្រឹត្តទៅជាមួយនឹងអាសវៈ តើដូចម្តេច ។ មគ្គជាអបរិយាបន្នៈផង ផលនៃមគ្គផង អសង្ខតធាតុផង នេះពួកធម៌ មិនប្រព្រឹត្តទៅជាមួយនឹងអាសវៈ ។

[ ២១៥ ] ពួកធម៌ប្រកបដោយអាសវៈ តើដូចម្តេច ។ ពួកធម៌ណា ប្រកបដោយធម៌ទាំងនោះ និងវេទនាខន្ធ ។ បេ ។ វិញ្ញាណក្ខន្ធ នេះពួកធម៌ប្រកបដោយអាសវៈ ។ ពួកធម៌ប្រាសចាកអាសវៈ តើដូចម្តេច ។ ពួកធម៌ណា ប្រាសចាកធម៌ទាំងនោះ វេទនាខន្ធ ។ បេ ។ វិញ្ញាណក្ខន្ធ រូបទាំងអស់ និងអសង្ខតធាតុ នេះពួកធម៌ប្រាសចាកអាសវៈ ។

[២១៦] កតមេ ធម្មា អាសវា ចេវ សាសវា ច ។ តេយេវ(១) អាសវា អាសវា ចេវ សាសវា ច ។ កតមេ ធម្មា សាសវា ចេវ នោ ច អាសវា ។ តេហិ ធម្មេហិ យេ ធម្មា សាសវា តេ ធម្មេ ឋបេត្វា អវសេសា សាសវា កុសលាកុសលាព្យាកតា ធម្មា កាមាវចរា រូបាវចរា អរូបាវចរា រូបក្ខន្ធោ ។ បេ ។ វិញ្ញាណក្ខន្ធោ ឥមេ ធម្មា សាសវា ចេវ នោ ច អាសវា ។

[២១៧] កតមេ ធម្មា អាសវា ចេវ អាសវសម្បយុត្តា ច ។ កាមាសវោ អវិជ្ជាសវេន អាសវោ ចេវ អាសវសម្បយុត្តោ ច អវិជ្ជាសវោ កាមាសវេន អាសវោ ចេវ អាសវសម្បយុត្តោ ច ភវាសវោ អវិជ្ជាសវេន អាសវោ ចេវ អាសវសម្បយុត្តោ ច អវិជ្ជាសវោ ភវាសវេន អាសវោ ចេវ អាសវសម្បយុត្តោ ច ទិដ្ឋាសវោ អវិជ្ជាសវេន អាសវោ ចេវ អាសវសម្បយុត្តោ ច អវិជ្ជាសវោ ទិដ្ឋាសវេន អាសវោ ចេវ អាសវសម្បយុត្តោ ច ឥមេ

១ ឱ. តេ ប ។

[ ៦១៦ ] ពួកធម៌ជាអាសវៈផង ប្រព្រឹត្តទៅជាមួយនឹងអាសវៈផង តើដូចម្តេច ។ អាសវៈទាំងនោះឯង ជាអាសវៈផង ប្រព្រឹត្តទៅជាមួយនឹងអាសវៈផង ។ ពួកធម៌គ្រាន់តែប្រព្រឹត្តទៅជាមួយនឹងអាសវៈ តែមិនមែនអាសវៈ តើដូចម្តេច ។ ពួកធម៌ណា ប្រព្រឹត្តទៅជាមួយនឹងអាសវៈ ដោយធម៌ទាំងនោះ វៀរតែធម៌ទាំងនោះចេញ ពួកធម៌ដ៏សេសសល់ ដែលប្រព្រឹត្តទៅជាមួយនឹងអាសវៈ ជាកុសល អកុសល និងអព្យាក្រឹត ជាកាមាវចរ រូបាវចរ អរូបាវចរ និងរូបក្ខន្ធ ។បេ។ វិញ្ញាណក្ខន្ធ នេះពួកធម៌ គ្រាន់តែប្រព្រឹត្តទៅជាមួយនឹងអាសវៈ តែមិនមែនអាសវៈ ។

[ ៦១៧ ] ពួកធម៌ជាអាសវៈផង ប្រកបដោយអាសវៈផង តើដូចម្តេច ។ កាមាសវៈ ជាអាសវៈផង ប្រកបដោយអាសវៈផង ដោយអវិជ្ជាសវៈ អវិជ្ជាសវៈ ជាអាសវៈផង ប្រកបដោយអាសវៈផង ដោយកាមាសវៈ ភវាសវៈ ជាអាសវៈផង ប្រកបដោយអាសវៈផង ដោយអវិជ្ជាសវៈ អវិជ្ជាសវៈ ជាអាសវៈផង ប្រកបដោយអាសវៈផង ដោយភវាសវៈ ទិដ្ឋាសវៈ ជាអាសវៈផង ប្រកបដោយអាសវៈផង ដោយអវិជ្ជាសវៈ អវិជ្ជាសវៈ ជាអាសវៈផង ប្រកបដោយអាសវៈផង ដោយទិដ្ឋាសវៈ

ធម្មា អាសវា ចេវ អាសវសម្បយុត្តា ច ។ កតមេ ធម្មា អាសវសម្បយុត្តា ចេវ នោ ច អាសវា ។ តេហិ ធម្មេហិ យេ ធម្មា សម្បយុត្តា តេ ធម្មេ ឋបេត្វា វេទនាក្ខន្ធោ ។ បេ ។ វិញ្ញាណក្ខន្ធោ ឥមេ ធម្មា អាសវសម្បយុត្តា ចេវ នោ ច អាសវា ។

(២១៨) កតមេ ធម្មា អាសវវិប្បយុត្តា សាសវា ។ តេហិ ធម្មេហិ យេ ធម្មា វិប្បយុត្តា សាសវា កុសលាកុសលាព្យាកតា ធម្មា កាមាវចរា រូបាវចរា អរូបាវចរា រូបក្ខន្ធោ ។ បេ ។ វិញ្ញាណក្ខន្ធោ ឥមេ ធម្មា អាសវវិប្បយុត្តា សាសវា ។ កតមេ ធម្មា អាសវវិប្បយុត្តា អនាសវា ។ អបរិយាបន្នា មគ្គា ច មគ្គផលានិ ច អសង្ខតា ច ធាតុ ឥមេ ធម្មា អាសវវិប្បយុត្តា អនាសវា ។

(២១៩) កតមេ ធម្មា សញ្ញោជនា ។ ទស សញ្ញោជនានិ កាមរាគសញ្ញោជនំ បដិឃសញ្ញោជនំ មានសញ្ញោជនំ ទិដ្ឋិសញ្ញោជនំ វិចិកិច្ឆាសញ្ញោជនំ សីលព្វតបរាមាសសញ្ញោជនំ ភវរាគសញ្ញោជនំ ឥស្សាសញ្ញោជនំ មច្ឆរិយសញ្ញោជនំ អវិជ្ជាសញ្ញោជនំ ។

នេះពួកធម៌ ជាអាសវៈផង ប្រកបដោយអាសវៈផង ។ ពួកធម៌គ្រាន់តែប្រកបដោយអាសវៈ តែមិនមែនអាសវៈ តើដូចម្តេច ។ ពួកធម៌ណា ប្រកបដោយធម៌ទាំងនោះ វៀរតែធម៌ទាំងនោះចេញ វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ នេះពួកធម៌ គ្រាន់តែប្រកបដោយអាសវៈ តែមិនមែនអាសវៈ ។

(៦១៨) ពួកធម៌ប្រាសចាកអាសវៈ តែប្រព្រឹត្តទៅជាមួយនឹងអាសវៈ តើដូចម្តេច ។ ពួកធម៌ណា ប្រាសចាកធម៌ទាំងនោះ ពួកធម៌ប្រព្រឹត្តទៅជាមួយនឹងអាសវៈ ជាកុសល អកុសល និងអព្យាក្រឹត ជាកាមាវចរ រូបាវចរ អរូបាវចរ និងរូបក្ខន្ធ ។បេ។ វិញ្ញាណក្ខន្ធ នេះពួកធម៌ប្រាសចាកអាសវៈ តែប្រព្រឹត្តទៅជាមួយនឹងអាសវៈ ។ ពួកធម៌ប្រាសចាកអាសវៈផង មិនប្រព្រឹត្តទៅជាមួយនឹងអាសវៈផង តើដូចម្តេច ។ មគ្គជាអបរិយាបន្នៈផង ផលនៃមគ្គផង អសង្ខតធាតុផង នេះពួកធម៌ប្រាសចាកអាសវៈផង មិនប្រព្រឹត្តទៅជាមួយនឹងអាសវៈផង ។

(៦១៩) ពួកធម៌ជាសញ្ញោជនៈ (ធម៌ចងសត្វទុកក្នុងវដ្តៈ) តើដូចម្តេច ។ សញ្ញោជនៈ ១០ ប្រការ គឺ កាមរាគសញ្ញោជនៈ បដិឃសញ្ញោជនៈ មានសញ្ញោជនៈ ទិដ្ឋិសញ្ញោជនៈ វិចិកិច្ឆាសញ្ញោជនៈ សីលព្វតបរាមាសសញ្ញោជនៈ ភវរាគសញ្ញោជនៈ ឥស្សាសញ្ញោជនៈ មច្ឆរិយសញ្ញោជនៈ អវិជ្ជាសញ្ញោជនៈ ១ ។

[២២០] តត្ថ កតមំ កាមរាគសញ្ញោជនំ ។ យោ កាមេសុ កាមច្ឆន្ទោ កាមរាគោ កាមនន្ទី កាមតណ្ហា កាមសិនេហោ កាមបរិឡាហោ កាមមុច្ឆា កាមជ្ឈោសានំ ឥទំ វុច្ចតិ កាមរាគសញ្ញោជនំ ។

(២៧៦) កតមេ ធម្មា ចិត្តសំសដ្ឋសមុដ្ឋានានុបរិវត្តិនោ ។ វេទនាក្ខន្ធោ សញ្ញាក្ខន្ធោ សង្ខារក្ខន្ធោ ឥមេ ធម្មា ចិត្តសំសដ្ឋសមុដ្ឋានានុបរិវត្តិនោ ។ កតមេ ធម្មា នោ ចិត្តសំសដ្ឋសមុដ្ឋានានុបរិវត្តិនោ ។ ចិត្តញ្ច សព្ពញ្ច រូបំ អសង្ខតា ច ធាតុ ឥមេ ធម្មា នោ ចិត្តសំសដ្ឋសមុដ្ឋានានុបរិវត្តិនោ ។

(២៧៧) កតមេ ធម្មា អជ្ឈត្តិកា ។ ចក្ខាយតនំ ។ បេ ។ មនាយតនំ ឥមេ ធម្មា អជ្ឈត្តិកា ។ កតមេ ធម្មា ពាហិរា ។ រូបាយតនំ ។ បេ ។ ធម្មាយតនំ ឥមេ ធម្មា ពាហិរា ។

ប្រឡូកប្រឡំទាំងតាំងឡើងដោយចិត្ត ។ ពួកធម៌មិនប្រឡូកប្រឡំមិនតាំងឡើងដោយចិត្ត តើដូចម្តេច ។ ចិត្តផង រូបទាំងអស់ផង អសង្ខតធាតុផង នេះពួកធម៌មិនប្រឡូកប្រឡំមិនតាំងឡើងដោយចិត្ត ។

(២៧៥) ពួកធម៌ប្រឡូកប្រឡំទាំងតាំងឡើងទាំងកើតជាមួយនឹងចិត្ត តើដូចម្តេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ នេះពួកធម៌ប្រឡូកប្រឡំទាំងតាំងឡើងទាំងកើតជាមួយនឹងចិត្ត ។ ពួកធម៌មិនប្រឡូកប្រឡំមិនតាំងឡើងមិនកើតជាមួយនឹងចិត្ត តើដូចម្តេច ។ ចិត្តផង រូបទាំងអស់ផង អសង្ខតធាតុផង នេះពួកធម៌មិនប្រឡូកប្រឡំមិនតាំងឡើងមិនកើតជាមួយនឹងចិត្ត ។

(២៧៦) ពួកធម៌ប្រឡូកប្រឡំទាំងតាំងឡើងទាំងប្រព្រឹត្តទៅតាមចិត្ត តើដូចម្តេច ។ វេទនាខន្ធ វិញ្ញាខន្ធ សង្ខារក្ខន្ធ នេះពួកធម៌ប្រឡូកប្រឡំទាំងតាំងឡើងទាំងប្រព្រឹត្តទៅតាមចិត្ត ។ ពួកធម៌មិនប្រឡូកប្រឡំមិនតាំងឡើងមិនប្រព្រឹត្តទៅតាមចិត្ត តើដូចម្តេច ។ ចិត្តផង រូបទាំងអស់ផង អសង្ខតធាតុផង នេះពួកធម៌មិនប្រឡូកប្រឡំមិនតាំងឡើងមិនប្រព្រឹត្តទៅតាមចិត្ត ។

(២៧៧) ពួកធម៌ជាខាងក្នុង តើដូចម្តេច ។ ចក្ខាយតនៈ ។ បេ ។ មនាយតនៈ នេះពួកធម៌ជាខាងក្នុង ។ ពួកធម៌ជាខាងក្រៅ តើដូចម្តេច ។ រូបាយតនៈ ។ បេ ។ ធម្មាយតនៈ នេះពួកធម៌ជាខាងក្រៅ ។

(២៧៨) កតមេ ធម្មា ឧបាទា ។ ចក្ខាយតនំ ។ បេ ។ កពឡីការោ អាហារោ ឥមេ ធម្មា ឧបាទា ។ កតមេ ធម្មា នោ ឧបាទា ។ វេទនាក្ខន្ធោ សញ្ញាក្ខន្ធោ សង្ខារក្ខន្ធោ វិញ្ញាណក្ខន្ធោ ចត្តារោ ច(១) មហាភូតា អសង្ខតា ច ធាតុ ឥមេ ធម្មា នោ ឧបាទា ។

(២៧៩) កតមេ ធម្មា ឧបាទិន្នា ។ សាសវា កុសលាកុសលានំ ធម្មានំ វិបាកា កាមាវចរា រូបាវចរា អរូបាវចរា វេទនាក្ខន្ធោ ។ បេ ។ វិញ្ញាណក្ខន្ធោ យញ្ច រូបំ កម្មស្ស កតត្តា ឥមេ ធម្មា ឧបាទិន្នា ។ កតមេ ធម្មា អនុបាទិន្នា ។ សាសវា កុសលាកុសលា ធម្មា កាមាវចរា រូបាវចរា អរូបាវចរា វេទនាក្ខន្ធោ ។ បេ ។ វិញ្ញាណក្ខន្ធោ យេ ច ធម្មា កិរិយា នេវ កុសលា នាកុសលា ន ច កម្មវិបាកា យញ្ច រូបំ ន កម្មស្ស កតត្តា អបរិយាបន្នា មគ្គា ច មគ្គផលានិ ច អសង្ខតា ច ធាតុ ឥមេ ធម្មា អនុបាទិន្នា ។

១ ឱ. បសត្ថោ នត្ថិ ។

[២៧៨] ពួកធម៌ជាឧបាទា (ឧបាទារូប) តើដូចម្តេច ។ ចក្ខាយតនៈ ។ បេ ។ កពឡិង្ការាហារ នេះពួកធម៌ជាឧបាទា ។ ពួកធម៌មិនមែនជាឧបាទា តើដូចម្តេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ មហាភូតរូបទាំង ៤ និងអសង្ខតធាតុ នេះធម៌មិនមែនជាឧបាទា ។

[២៧៩] ពួកធម៌ជាឧបាទិន្នៈ (ធម៌មានកម្មប្រកបដោយកិលេសមានតណ្ហាជាដើមកាន់យកហើយ) តើដូចម្តេច ។ វិបាក ប្រកបដោយអាសវៈ របស់ពួកធម៌ជាកុសល និងអកុសល ជាកាមាវចរ រូបាវចរ អរូបាវចរ វេទនាខន្ធ ។ បេ ។ វិញ្ញាណក្ខន្ធ និងរូបដែលជាកម្មស្សកតត្តា នេះពួកធម៌ជាឧបាទិន្នៈ ។ ពួកធម៌ជាអនុបាទិន្នៈ (ធម៌មិនមានកម្មប្រកបដោយកិលេសមានតណ្ហាជាដើមកាន់យកហើយ) តើដូចម្តេច ។ ពួកធម៌ប្រកបដោយអាសវៈ ជាកុសល និងអកុសល ជាកាមាវចរ រូបាវចរ អរូបាវចរ វេទនាខន្ធ ។ បេ ។ វិញ្ញាណក្ខន្ធ ឬពួកធម៌ជាកិរិយា ដែលមិនមែនជាកុសល មិនមែនជាអកុសល មិនមែនជាកម្មវិបាក រូបដែលមិនមែនជាកម្មស្សកតត្តា មគ្គ ជាអបរិយាបន្នៈ ផលនៃមគ្គ និងអសង្ខតធាតុ នេះពួកធម៌ ជាអនុបាទិន្នៈ ។

(២៨០) កតមេ ធម្មា ឧបាទានា ។ ចត្តារិ ឧបាទានានិ កាមុបាទានំ ទិដ្ឋុបាទានំ សីលព្វតុបាទានំ អត្តវាទុបាទានំ ។

(២៨១) តត្ថ កតមំ កាមុបាទានំ ។ យោ កាមេសុ កាមច្ឆន្ទោ កាមរាគោ កាមនន្ទី កាមតណ្ហា កាមសិនេហោ កាមបរិឡាហោ កាមមុច្ឆា កាមជ្ឈោសានំ ឥទំ វុច្ចតិ កាមុបាទានំ ។

(២៨២) តត្ថ កតមំ ទិដ្ឋុបាទានំ ។ នត្ថិ ទិន្នំ នត្ថិ យិដ្ឋំ នត្ថិ ហុតំ នត្ថិ សុកតទុក្កដានំ កម្មានំ ផលំ វិបាកោ នត្ថិ អយំ លោកោ នត្ថិ បរោ លោកោ នត្ថិ មាតា នត្ថិ បិតា នត្ថិ សត្តា ឱបបាតិកា នត្ថិ លោកេ សមណព្រាហ្មណា សម្មគ្គតា សម្មាបដិបន្នា យេ ឥមញ្ច លោកំ បរញ្ច លោកំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេន្តិ យា ឯវរូបា ទិដ្ឋិ ទិដ្ឋិគតំ ទិដ្ឋិគហនំ ទិដ្ឋិកន្តារោ ទិដ្ឋិវិសូកាយិកំ ទិដ្ឋិវិប្ផន្ទិតំ ទិដ្ឋិសញ្ញោជនំ គាហោ បដិគ្គាហោ អភិនិវេសោ បរាមាសោ កុម្មគ្គោ មិច្ឆាបថោ

(២៨០) ពួកធម៌ ជាឧបាទាន (សេចក្ដីប្រកាន់មាំ) តើដូចម្ដេច ។ ឧបាទាន ៤ គឺ កាមុបាទាន ទិដ្ឋុបាទាន សីលព្វតុបាទាន អត្តវាទុបាទាន ។

(២៨១) បណ្ដាឧបាទានទាំងនោះ កាមុបាទាន តើដូចម្ដេច ។ សេចក្ដីប្រាថ្នាចំពោះកាម ការត្រេកអរចំពោះកាម ការរីករាយចំពោះកាម ការអន្ទះសាចំពោះកាម សេចក្ដីស្រឡាញ់ចំពោះកាម ការពេលពលចំពោះកាម ការជ្រុលជ្រប់ចំពោះកាម ការងុលងប់ចំពោះកាម ណាក្នុងកាមទាំងឡាយ នេះហៅថា កាមុបាទាន ។

(២៨២) បណ្ដាឧបាទានទាំងនោះ ទិដ្ឋុបាទាន តើដូចម្ដេច ។ ការយល់ថា ទានដែលបានឲ្យហើយមិនមានផល បូជាធំមិនមានផល បូជាតូចមិនមានផល ផលវិបាកនៃកម្មដែលបុគ្គលធ្វើល្អ ឬធ្វើអាក្រក់មិនមាន លោកនេះមិនមាន លោកខាងមុខមិនមាន មាតាមិនមានគុណ បិតាមិនមានគុណ ពួកសត្វជាឧបបាតិកៈមិនមាន ពួកសមណព្រាហ្មណ៍ ក្នុងលោក ជាអ្នកប្រព្រឹត្តល្អ ប្រតិបត្តិល្អ ធ្វើឲ្យជាក់ច្បាស់នូវលោកនេះនិងលោកខាងមុខ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ហើយសំដែងប្រាប់បាន ក៏មិនមាន និងទិដ្ឋិ ដំណើរគឺទិដ្ឋិ ព្រៃញាតស្បាតគឺទិដ្ឋិ ផ្លូវឆ្ងាយគឺទិដ្ឋិ បម្រួងគឺទិដ្ឋិ ការយល់ខ្វេងគឺទិដ្ឋិ ការជាប់ចំពាក់គឺទិដ្ឋិ ការកួចកាន់ ការប្រកាន់ ការប្រកាន់ខ្ជាប់ ការស្ទាបអង្អែល ផ្លូវអាក្រក់ ផ្លូវខុស

មិច្ឆត្តំ តិត្ថាយតនំ វិបរិយេសគ្គាហោ អយំ វុច្ចតិ ទិដ្ឋុបាទានំ ។ ឋបេត្វា សីលព្វតុបាទានញ្ច អត្តវាទុបាទានញ្ច សព្វាបិ មិច្ឆាទិដ្ឋិ ទិដ្ឋុបាទានំ ។

(២៨៣) តត្ថ កតមំ សីលព្វតុបាទានំ ។ ឥតោ ពហិទ្ធា សមណព្រាហ្មណានំ សីលេន សុទ្ធិ វតេន សុទ្ធិ សីលព្វតេន សុទ្ធីតិ យា ឯវរូបា ទិដ្ឋិ ទិដ្ឋិគតំ ទិដ្ឋិគហនំ ទិដ្ឋិកន្តារោ ទិដ្ឋិវិសូកាយិកំ ទិដ្ឋិវិប្ផន្ទិតំ ទិដ្ឋិសញ្ញោជនំ គាហោ បដិគ្គាហោ អភិនិវេសោ បរាមាសោ កុម្មគ្គោ មិច្ឆាបថោ មិច្ឆត្តំ តិត្ថាយតនំ វិបរិយេសគ្គាហោ អយំ វុច្ចតិ សីលព្វតុបាទានំ ។

(២៨៤) តត្ថ កតមំ អត្តវាទុបាទានំ ។ ឥធ អស្សុតវា បុថុជ្ជនោ អរិយានំ អទស្សាវី អរិយធម្មស្ស អកោវិទោ អរិយធម្មេ អវិនីតោ សប្បុរិសានំ អទស្សាវី សប្បុរិសធម្មស្ស អកោវិទោ សប្បុរិសធម្មេ អវិនីតោ រូបំ អត្តតោ សមនុបស្សតិ រូបវន្តំ វា អត្តានំ អត្តនិ វា រូបំ រូបស្មិំ វា អត្តានំ

ភាពនៃចិត្តខុស លទ្ធិដូចជាកំពង់ សេចក្តីប្រកាន់ក្នុងការស្វែងរកខុស ណា ដែលមានសភាពបែបនេះ នេះហៅថា ទិដ្ឋុបាទាន ។ លើកលែងតែសីលព្វតុបាទាន និងអត្តវាទុបាទានចេញ សូម្បីមិច្ឆាទិដ្ឋិទាំងអស់ ក៏ហៅថា ទិដ្ឋុបាទានដែរ ។

(២៨៣) បណ្តាឧបាទានទាំងនោះ សីលព្វតុបាទាន តើដូចម្តេច ។ ពួកសមណព្រាហ្មណ៍ខាងក្រៅ អំពីសាសនានេះ (ប្រកាន់ថា) សេចក្តីបរិសុទ្ធិដោយសីល បរិសុទ្ធិដោយវត្ត បរិសុទ្ធិដោយសីលនិងវត្ត និងទិដ្ឋិដំណើរគឺទិដ្ឋិ ព្រៃញាតស្បាតគឺទិដ្ឋិ ផ្លូវឆ្ងាយគឺទិដ្ឋិ បម្រះគឺទិដ្ឋិ ការយល់ច្រឡំគឺទិដ្ឋិ ការជាប់ចំពាក់គឺទិដ្ឋិ ការក្តួចកាន់ ការប្រកាន់ ការប្រកាន់ខ្ជាប់ ការស្ទាបអង្អែល ផ្លូវអាក្រក់ ផ្លូវខុស ភាពនៃចិត្តខុស លទ្ធិដូចជាកំពង់ សេចក្តីប្រកាន់ក្នុងការស្វែងរកខុស ណា ដែលមានសភាពបែបនេះ នេះហៅថា សីលព្វតុបាទាន ។

(២៨៤) បណ្តាឧបាទានទាំងនោះ អត្តវាទុបាទាន តើដូចម្តេច ។ បុថុជ្ជន ជាអ្នកមិនចេះដឹង ក្នុងលោកនេះ មិនធ្លាប់ឃើញពួកព្រះអរិយៈ មិនឈ្លាសវៃ ក្នុងអរិយធម៌ មិនទូន្មានខ្លួន ក្នុងអរិយធម៌ មិនធ្លាប់ឃើញពួកសប្បុរស មិនឈ្លាសវៃ ក្នុងសប្បុរិសធម៌ មិនទូន្មានខ្លួន ក្នុងសប្បុរិសធម៌ រមែងយល់ឃើញរូបថាជាខ្លួន ឃើញខ្លួនថាមានរូបខ្លះ ឃើញរូបថាមានក្នុងខ្លួនខ្លះ ឃើញខ្លួនថាមានក្នុងរូបខ្លះ

វេទនំ អត្តតោ សមនុបស្សតិ វេទនាវន្តំ វា អត្តានំ អត្តនិ វា វេទនំ វេទនាយ វា អត្តានំ សញ្ញំ អត្តតោ សមនុបស្សតិ សញ្ញាវន្តំ វា អត្តានំ អត្តនិ វា សញ្ញំ សញ្ញាយ វា អត្តានំ សង្ខារេ អត្តតោ សមនុបស្សតិ សង្ខារវន្តំ វា អត្តានំ អត្តនិ វា សង្ខារេ សង្ខារេសុ វា អត្តានំ វិញ្ញាណំ អត្តតោ សមនុបស្សតិ វិញ្ញាណវន្តំ វា អត្តានំ អត្តនិ វា វិញ្ញាណំ វិញ្ញាណស្មឹ វា អត្តានំ យា ឯវរូបា ទិដ្ឋិ ទិដ្ឋិគតំ ទិដ្ឋិគហនំ ទិដ្ឋិកន្តារោ ទិដ្ឋិវិសូកាយិកំ ទិដ្ឋិវិប្ផន្ទិតំ ទិដ្ឋិសញ្ញោជនំ គាហោ បដិគ្គាហោ អភិនិវេសោ បរាមាសោ កុម្មគ្គោ មិច្ឆាបថោ មិច្ឆត្តំ តិត្ថាយតនំ វិបរិយេសគ្គាហោ ឥទំ វុច្ចតិ អត្តវាទុបាទានំ ។

ឥមេ ធម្មា ឧបាទានា ។

(៦៨៥) កតមេ ធម្មា នោ ឧបាទានា ។ តេ ធម្មេ ឋបេត្វា អវសេសា កុសលាកុសលាព្យាកតា ធម្មា កាមាវចរា រូបាវចរា អរូបាវចរា អបរិយាបន្នា វេទនាក្ខន្ធោ ។ បេ ។ វិញ្ញាណក្ខន្ធោ សព្វញ្ច រូបំ អសង្ខតា ច ធាតុ ឥមេ ធម្មា នោ ឧបាទានា ។

ឃើញវេទនាថាជាខ្លួន ឃើញខ្លួនថាមានវេទនាខ្លះ ឃើញវេទនាថាមានក្នុងខ្លួនខ្លះ ឃើញខ្លួនថាមានក្នុងវេទនាខ្លះ ឃើញសញ្ញាថាជាខ្លួន ឃើញខ្លួនថាមានសញ្ញាខ្លះ ឃើញសញ្ញាថាមានក្នុងខ្លួនខ្លះ ឃើញខ្លួនថាមានក្នុងសញ្ញាខ្លះ ឃើញសង្ខារថាជាខ្លួន ឃើញខ្លួនថាមានសង្ខារខ្លះ ឃើញសង្ខារថាមានក្នុងខ្លួនខ្លះ ឃើញខ្លួនថាមានក្នុងសង្ខារខ្លះ ឃើញវិញ្ញាណថាជាខ្លួន ឃើញខ្លួនថាមានវិញ្ញាណខ្លះ ឃើញវិញ្ញាណថាមានក្នុងខ្លួនខ្លះ ឃើញខ្លួនថាមានក្នុងវិញ្ញាណខ្លះ និងទិដ្ឋិ ដំណើរគឺទិដ្ឋិ ព្រៃញាតស្បាតគឺទិដ្ឋិ ផ្លូវឆ្ងាយគឺទិដ្ឋិ បម្រ្បងគឺទិដ្ឋិ ការយល់ខ្វេងគឺទិដ្ឋិ ការជាប់ចំពាក់គឺទិដ្ឋិ ការកួបកាន់ ការប្រកាន់ ការប្រកាន់ខ្ជាប់ ការស្ទាបអង្អែល ផ្លូវអាក្រក់ ផ្លូវខុស ភាពនៃចិត្តខុស លទ្ធិដូចជាកំពង់ សេចក្ដីប្រកាន់ក្នុងការស្វែងរកខុស ណា ដែលមានសភាពបែបនេះ នេះហៅថា អត្តវាទុបាទាន ។

នេះពួកធម៌ ជាឧបាទាន ។

( ២៨៥ ) ពួកធម៌មិនមែនជាឧបាទាន តើដូចម្ដេច ។ វៀរតែធម៌ទាំងនោះចេញ ពួកធម៌ដ៏សេសសល់ ជាកុសល អកុសល និងអព្យាក្រឹត ជាកាមាវចរ រូបាវចរ អរូបាវចរ អបរិយាបន្នៈ វេទនាខន្ធ ។ បេ ។ វិញ្ញាណក្ខន្ធ រូបទាំងអស់ និងអសង្ខតធាតុ នេះពួកធម៌មិនមែនជាឧបាទាន ។

(២៨៦) កតមេ ធម្មា ឧបាទានិយា ។ សាសវា កុសលាកុសលាព្យាកតា ធម្មា កាមាវចរា រូបាវចរា អរូបាវចរា រូបក្ខន្ធោ ។ បេ ។ វិញ្ញាណក្ខន្ធោ ឥមេ ធម្មា ឧបាទានិយា ។ កតមេ ធម្មា អនុបាទានិយា ។ អបរិយាបន្នា មគ្គា ច មគ្គផលានិ ច អសង្ខតា ច ធាតុ ឥមេ ធម្មា អនុបាទានិយា ។

(២៨៧) កតមេ ធម្មា ឧបាទានសម្បយុត្តា ។ តេហិ ធម្មេហិ យេ ធម្មា សម្បយុត្តា វេទនាក្ខន្ធោ ។ បេ ។ វិញ្ញាណក្ខន្ធោ ឥមេ ធម្មា ឧបាទានសម្បយុត្តា ។ កតមេ ធម្មា ឧបាទានវិប្បយុត្តា ។ តេហិ ធម្មេហិ យេ ធម្មា វិប្បយុត្តា វេទនាក្ខន្ធោ ។ បេ ។ វិញ្ញាណក្ខន្ធោ សព្វញ្ច រូបំ អសង្ខតា ច ធាតុ ឥមេ ធម្មា ឧបាទានវិប្បយុត្តា ។

(២៨៨) កតមេ ធម្មា ឧបាទានា ចេវ ឧបាទានិយា ច ។ តានេវ ឧបាទានានិ ឧបាទានា ចេវ ឧបាទានិយា ច ។ កតមេ ធម្មា ឧបាទានិយា ចេវ នោ ច ឧបាទានា ។ តេហិ ធម្មេហិ យេ ធម្មា ឧបាទានិយា តេ ធម្មេ ឋបេត្វា អវសេសា សាសវា

ឧបាទានគោច្ឆកនិក្ខេប

( ២៨៦ ) ពួកធម៌ជាប្រយោជន៍ដល់ឧបាទាន តើដូចម្តេច ។ ពួកធម៌ប្រកបដោយអាសវៈ ជាកុសល អកុសល និងអព្យាក្រឹត ជាកាមាវចរ រូបាវចរ អរូបាវចរ និងរូបក្ខន្ធ ។ បេ ។ វិញ្ញាណក្ខន្ធ នេះពួកធម៌ជាប្រយោជន៍ដល់ឧបាទាន ។ ពួកធម៌មិនជាប្រយោជន៍ដល់ឧបាទាន តើដូចម្តេច ។ មគ្គ ជាអបរិយាបន្នៈផង ផលនៃមគ្គផង អសង្ខតធាតុផង នេះពួកធម៌ មិនជាប្រយោជន៍ដល់ឧបាទាន ។

( ២៨៧ ) ពួកធម៌ប្រកបដោយឧបាទាន តើដូចម្តេច ។ ពួកធម៌ណា ប្រកបដោយធម៌ទាំងនោះ វេទនាក្ខន្ធ ។ បេ ។ វិញ្ញាណក្ខន្ធ នេះពួកធម៌ប្រកបដោយឧបាទាន ។ ពួកធម៌ប្រាសចាកឧបាទាន តើដូចម្តេច ។ ពួកធម៌ណា ប្រាសចាកធម៌ទាំងនោះ វេទនាក្ខន្ធ ។ បេ ។ វិញ្ញាណក្ខន្ធ រូបទាំងអស់ និងអសង្ខតធាតុ នេះពួកធម៌ ប្រាសចាកឧបាទាន ។

( ២៨៨ ) ពួកធម៌ជាឧបាទានផង ជាប្រយោជន៍ដល់ឧបាទានផង តើដូចម្តេច ។ ឧបាទានទាំងនោះឯង ជាឧបាទានផង ជាប្រយោជន៍ដល់ឧបាទានផង ។ ពួកធម៌ គ្រាន់តែជាប្រយោជន៍ដល់ឧបាទាន តែមិនមែនជាឧបាទាន តើដូចម្តេច ។ ពួកធម៌ណា ជាប្រយោជន៍ដល់ឧបាទាន ដោយធម៌ទាំងនោះ វៀរតែធម៌ទាំងនោះចេញ ពួកធម៌ដ៏សេសសល់ ប្រកបដោយអាសវៈ

កុសលាកុសលាព្យាកតា ធម្មា កាមាវចរា រូបាវចរា អរូបាវចរា រូបក្ខន្ធោ ។ បេ ។ វិញ្ញាណក្ខន្ធោ ឥមេ ធម្មា ឧបាទានិយា ចេវ នោ ច ឧបាទានា ។

(២៨៩) កតមេ ធម្មា ឧបាទានា ចេវ ឧបាទានសម្បយុត្តា ច ។ ទិដ្ឋុបាទានំ កាមុបាទានេន ឧបាទានញ្ចេវ ឧបាទានសម្បយុត្តញ្ច កាមុបាទានំ ទិដ្ឋុបាទានេន ឧបាទានញ្ចេវ ឧបាទានសម្បយុត្តញ្ច សីលព្វតុបាទានំ កាមុបាទានេន ឧបាទានញ្ចេវ ឧបាទានសម្បយុត្តញ្ច កាមុបាទានំ សីលព្វតុបាទានេន ឧបាទានញ្ចេវ ឧបាទានសម្បយុត្តញ្ច អត្តវាទុបាទានំ កាមុបាទានេន ឧបាទានញ្ចេវ ឧបាទានសម្បយុត្តញ្ច កាមុបាទានំ អត្តវាទុបាទានេន ឧបាទានញ្ចេវ ឧបាទានសម្បយុត្តញ្ច ឥមេ ធម្មា ឧបាទានា ចេវ ឧបាទានសម្បយុត្តា ច ។ កតមេ ធម្មា ឧបាទានសម្បយុត្តា ចេវ នោ ច ឧបាទានា ។ តេហិ ធម្មេហិ យេ ធម្មា សម្បយុត្តា តេ ធម្មេ ឋបេត្វា វេទនាក្ខន្ធោ ។ បេ ។ វិញ្ញាណក្ខន្ធោ ឥមេ ធម្មា ឧបាទានសម្បយុត្តា ចេវ នោ ច ឧបាទានា ។

ជាកុសល អកុសល និងអព្យាក្រឹត ជាកាមាវចរ រូបាវចរ អរូបាវចរ រូបក្ខន្ធ ។ បេ ។ វិញ្ញាណក្ខន្ធ នេះពួកធម៌គ្រាន់តែជាប្រយោជន៍ដល់ឧបាទាន តែមិនមែនជាឧបាទាន ។

[ ២៨៩ ] ពួកធម៌ជាឧបាទានផង ប្រកបដោយឧបាទានផង តើដូចម្តេច ។ ទិដ្ឋុបាទាន ជាឧបាទានផង ប្រកបដោយឧបាទានផង ដោយកាមុបាទាន កាមុបាទាន ជាឧបាទានផង ប្រកបដោយឧបាទានផង ដោយទិដ្ឋុបាទាន សីលព្វតុបាទាន ជាឧបាទានផង ប្រកបដោយឧបាទានផង ដោយកាមុបាទាន កាមុបាទាន ជាឧបាទានផង ប្រកបដោយឧបាទានផង ដោយសីលព្វតុបាទាន អត្តវាទុបាទាន ជាឧបាទានផង ប្រកបដោយឧបាទានផង ដោយកាមុបាទាន កាមុបាទាន ជាឧបាទានផង ប្រកបដោយឧបាទានផង ដោយអត្តវាទុបាទាន នេះពួកធម៌ជាឧបាទានផង ប្រកបដោយឧបាទានផង ។ ពួកធម៌គ្រាន់តែប្រកបដោយឧបាទាន តែមិនមែនជាឧបាទាន តើដូចម្តេច ។ ពួកធម៌ណាប្រកបដោយធម៌ទាំងនោះ វៀរតែធម៌ទាំងនោះចេញ និងវេទនាខន្ធ ។ បេ ។ វិញ្ញាណក្ខន្ធ នេះពួកធម៌គ្រាន់តែប្រកបដោយឧបាទាន តែមិនមែនជាឧបាទាន ។

## ឧបាទានគោច្ឆកេ និក្ខេបោ

(២៩០) កតមេ ធម្មា ឧបាទានវិប្បយុត្តា ឧបាទានិយា ។ តេហិ ធម្មេហិ យេ ធម្មា វិប្បយុត្តា សាសវា កុសលាកុសលាព្យាកតា ធម្មា កាមាវចរា រូបាវចរា អរូបាវចរា រូបក្ខន្ធោ ។ បេ ។ វិញ្ញាណក្ខន្ធោ ឥមេ ធម្មា ឧបាទានវិប្បយុត្តា ឧបាទានិយា ។ កតមេ ធម្មា ឧបាទានវិប្បយុត្តា អនុបាទានិយា ។ អបរិយាបន្នា មគ្គា ច មគ្គផលានិ ច អសង្ខតា ច ធាតុ ឥមេ ធម្មា ឧបាទានវិប្បយុត្តា អនុបាទានិយា ។

(២៩១) កតមេ ធម្មា កិលេសា ។ ទស កិលេសវត្ថូនិ លោភោ ទោសោ មោហោ មានោ ទិដ្ឋិ វិចិកិច្ឆា ថីនំ ឧទ្ធច្ចំ អហិរិកំ អនោត្តប្បំ ។

(២៩២) តត្ថ កតមោ លោភោ ។ យោ រាគោ សារាគោ អនុនយោ អនុរោធោ នន្ទី នន្ទិរាគោ ចិត្តស្ស សារាគោ ឥច្ឆា មុច្ឆា អជ្ឈោសានំ គេធោ បលិគេធោ សង្គោ បង្កោ ឯជា មាយា ជនិកា សញ្ជននី សិព្វិនី ជាលិនី សរិតា វិសត្តិកា សុត្តំ

ឧបាទានគោច្ឆកនិក្ខេប

[៤៩០] ពួកធម៌ប្រាសចាកឧបាទាន តែជាប្រយោជន៍ដល់ឧបាទាន តើដូចម្តេច ។ ពួកធម៌ណា ប្រាសចាកធម៌ទាំងនោះ ពួកធម៌ប្រកបដោយអាសវៈ ជាកុសល អកុសល និងអព្យាក្រឹត ជាកាមាវចរ រូបាវចរ អរូបាវចរ និងរូបក្ខន្ធ ។ បេ ។ វិញ្ញាណក្ខន្ធ នេះពួកធម៌ប្រាសចាកឧបាទាន តែជាប្រយោជន៍ដល់ឧបាទាន ។ ពួកធម៌ប្រាសចាកឧបាទានផង មិនជាប្រយោជន៍ដល់ឧបាទានផង តើដូចម្តេច ។ មគ្គ ជាអបរិយាបន្នៈផង ផលនៃមគ្គផង អសង្ខតធាតុផង នេះពួកធម៌ប្រាសចាកឧបាទានផង មិនជាប្រយោជន៍ដល់ឧបាទានផង ។

[៤៩១] ពួកធម៌ជាកិលេស (គ្រឿងសៅហ្មង) តើដូចម្តេច ។ កិលេសវត្ថុ ១០ គឺ លោភៈ ទោសៈ មោហៈ មានៈ ទិដ្ឋិ វិចិកិច្ឆា ថីនៈ ឧទ្ធច្ចៈ អហិរិកៈ អនោត្តប្បៈ ។

[៤៩២] បណ្តាកិលេសវត្ថុទាំងនោះ លោភៈ តើដូចម្តេច ។ តម្រេក ការត្រេកអរខ្លាំង ការជាប់ចំពាក់ក្នុងអារម្មណ៍ ការស្រើបស្រាល ការរីករាយ ការរីករាយខ្លាំង តម្រេកខ្លាំងនៃចិត្ត សេចក្តីប្រាថ្នា ការជ្រួលជ្រប់ ការវង្វេងចិត្ត ការពាក់ព័ន្ធ ការរួបរឹត ការជាប់ចំពាក់ ការលិចចុះ ធម្មជាតិនាំសត្វឲ្យកើតក្នុងភព មាយា ធម្មជាតិបង្កើតសត្វ ការញុំាងសត្វឲ្យប្រកបដោយទុក្ខ ធម្មជាតិចាក់ស្រែះសត្វទុក បណ្តាញ ការបង្ហូរទៅ ការផ្សាយទៅកាន់អារម្មណ៍ផ្សេង ៗ ចំណងចងសត្វទុក

វិសដា អាយូហនី ទុតិយា បណិធិ ភវនេត្តិ វនំ
វនថោ សន្ថវោ សិនេហោ អបេក្ខា បដិពន្ធុ អាសា
អាសីសនា អាសីសិតត្តំ រូបាសា សទ្ទាសា គន្ធាសា
រសាសា ផោដ្ឋព្វាសា លាភាសា ធនាសា បុត្តាសា
ជីវិតាសា ជប្បា បជប្បា អភិជប្បា ជប្បា ជប្បនា
ជប្បិតត្តំ លោលុប្បំ លោលុប្បាយនា លោលុប្បា-
យិតត្តំ បុច្ឆញ្ជិកតា សាធុកម្យតា អធម្មរាគោ វិស-
មលោភោ និកន្តិ និកាមនា បត្ថនា បិហនា
សម្បត្ថនា កាមតណ្ហា ភវតណ្ហា វិភវតណ្ហា រូប-
តណ្ហា អរូបតណ្ហា និរោធតណ្ហា រូបតណ្ហា សទ្ទ-
តណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្ម-
តណ្ហា ឱឃោ យោគោ គន្ថោ ឧបាទានំ អាវរណំ
នីវរណំ ឆាទនំ ពន្ធនំ ឧបក្កិលេសោ អនុសយោ
បរិយុដ្ឋានំ លតា វេវិច្ឆំ ទុក្ខមូលំ ទុក្ខនិទានំ

ការផ្សាយទៅកាន់អារម្មណ៍ ធម្មជាតិញុំាងសត្វឲ្យចំរើន ធម្មជាតិជាគម្រប់ពីរ ការតាំងចិត្តទុក ធម្មជាតិនាំសត្វទៅកាន់ភព ធម្មជាតិដុះជាព្រៃ ដូចព្រៃញាតស្បាត ការមូលមិត្ត សេចក្តីស្រឡាញ់ ការអាលោះអាល័យផៅពង្សតទៅ សេចក្តីប៉ុនប៉ង អាការប៉ុនប៉ង ភាពនៃចិត្តប៉ុនប៉ង ការប៉ុនប៉ងរូប ប៉ុនប៉ងសំឡេង ប៉ុនប៉ងក្លិន ប៉ុនប៉ងរស ប៉ុនប៉ងផ្សព្វ ប៉ុនប៉ងលាភ ប៉ុនប៉ងទ្រព្យ ប៉ុនប៉ងបុត្រ ប៉ុនប៉ងជីវិត ធម្មជាតិឆ្ងេឆ្ងា ឆ្ងេឆ្ងាជ្រុល ឆ្ងេឆ្ងាខ្លាំង សេចក្តីឆ្ងេឆ្ងា អាការឆ្ងេឆ្ងា ភាពនៃចិត្តឆ្ងេឆ្ងា ការរុលត្បុល អាការប្រព្រឹត្តរុលត្បុល ភាពនៃចិត្តរុលត្បុល ការញាប់ញ័រការចង់បានឲ្យសម្រេចប្រយោជន៍ ការត្រេកអរខុសគន្លងធម៌ ការលោភហួសកំណត់ ការត្រេកត្រអាល ការចង់បានមិនឈប់ សេចក្តីប្រាថ្នាសេចក្តីស្រឡាញ់ សេចក្តីប្រាថ្នាព្រម សេចក្តីប្រាថ្នាក្នុងកាម ប្រាថ្នាភព ប្រាថ្នាប្រាសចាកភព ប្រាថ្នាក្នុងរូបភព ប្រាថ្នាក្នុងអរូបភពប្រាថ្នាក្នុងនិរោធ ប្រាថ្នារូប ប្រាថ្នាសំឡេង ប្រាថ្នាក្លិន ប្រាថ្នារសប្រាថ្នាផ្សព្វ ប្រាថ្នាធម៌ កិលេសដូចជាជំនន់ គ្រឿងប្រកប គ្រឿងចងក្រង គ្រឿងប្រកាន់មាំ គ្រឿងរាំងទួទៅ គ្រឿងរាំងមិនសល់គ្រឿងបិទបាំង គ្រឿងចង គ្រឿងចូលទៅជិតសៅហ្មង គ្រឿងស្ទាក់ដំណើរ តណ្ហាដូចជាវល្លិ ប្រាថ្នាផ្សេងៗ ឫសគល់នៃទុក្ខ ហេតុនៃទុក្ខ

ទុក្ខប្បភវោ មារបាសោ មារពលិសំ មារវិសយោ តណ្ហានទី តណ្ហាជាលំ តណ្ហាគទ្ទុលំ តណ្ហាសមុទ្ទោ អភិជ្ឈា លោភោ អកុសលមូលំ អយំ វុច្ចតិ លោភោ ។

(២៩៣) តត្ថ កតមោ ទោសោ ។ អនត្ថំ មេ អចរីតិ អាឃាតោ ជាយតិ អនត្ថំ មេ ចរតីតិ អាឃាតោ ជាយតិ អនត្ថំ មេ ចរិស្សតីតិ អាឃាតោ ជាយតិ បិយស្ស មេ មនាបស្ស អនត្ថំ អចរិ ។ បេ ។ អនត្ថំ ចរតិ ។ បេ ។ អនត្ថំ ចរិស្សតីតិ អាឃាតោ ជាយតិ អប្បិយស្ស មេ អមនាបស្ស អត្ថំ អចរិ ។ បេ ។ អត្ថំ ចរតិ ។ បេ ។ អត្ថំ ចរិស្សតីតិ អាឃាតោ ជាយតិ អដ្ឋានេ វា បន អាឃាតោ ជាយតិ យោ ឯវរូបោ ចិត្តស្ស អាឃាតោ បដិឃាតោ បដិឃំ បដិវិរោធោ កោបោ បកោបោ សម្បកោបោ ទោសោ បទោសោ សម្បទោសោ ចិត្តស្ស ព្យាបត្តិ មនោបទោសោ កោធោ កុជ្ឈនា កុជ្ឈិតត្តំ ទោសោ

ហេតុជាដែនកើតនៃទុក្ខ អន្ទាក់នៃមារ ទុយនៃមារ អារម្មណ៍នៃមារ ស្ទឹងគឺតណ្ហា បណ្ដាញគឺតណ្ហា ខ្នោះគឺតណ្ហា សមុទ្រគឺតណ្ហា ការសំឡឹងរំពៃ សេចក្ដីជាប់ចំពាក់ ជាអកុសលមូល ណា នេះហៅថា លោភៈ ។

(៤៩៣) បណ្ដាកិលេសវត្ថុទាំងនោះ ទោសៈ តើដូចម្ដេច ។ គំនុំកើតឡើងថា ជនឯណោះ បានប្រព្រឹត្តនូវកម្មមិនជាប្រយោជន៍ដល់អញ គំនុំកើតឡើងថា ជនឯណោះ កំពុងប្រព្រឹត្តនូវកម្មមិនជាប្រយោជន៍ដល់អញ គំនុំកើតឡើងថា ជនឯណោះ នឹងប្រព្រឹត្តនូវកម្មមិនជាប្រយោជន៍ដល់អញ គំនុំកើតឡើងថា ជនឯណោះ បានប្រព្រឹត្តនូវកម្មមិនជាប្រយោជន៍ ដល់បុគ្គលជាទីស្រឡាញ់ ជាទីពេញចិត្តនៃអញ ។ បេ ។ កំពុងប្រព្រឹត្តនូវកម្មមិនជាប្រយោជន៍ ។ បេ ។ នឹងប្រព្រឹត្តនូវកម្មមិនជាប្រយោជន៍ គំនុំកើតឡើងថា ជនឯណោះ បានប្រព្រឹត្តនូវកម្មជាប្រយោជន៍ ដល់បុគ្គលមិនជាទីស្រឡាញ់ មិនជាទីពេញចិត្តនៃអញ ។ បេ ។ កំពុងប្រព្រឹត្តនូវកម្មជាប្រយោជន៍ ។ បេ ។ នឹងប្រព្រឹត្តនូវកម្មជាប្រយោជន៍ ឬគំនុំកើតឡើង ក្នុងហេតុមិនគួរ និងការគុំគួននៃចិត្ត ការគុំគួនតប សេចក្ដីថ្នាំងថ្នាក់ ការខឹងតប ការខឹងញ័រ ការក្រោធខ្លាំង ការក្រោធញ័រ ការប្រទូស្ត ការប្រទូស្តតប ការប្រទូស្តគ្រប់យ៉ាង ការខូចនៃចិត្ត ការប្រទូស្តនៃចិត្ត ការក្រោធ ការខឹង ភាពនៃចិត្តខឹង សេចក្ដីប្រទូស្ត

ទុស្សនា ទុស្សិតត្តំ ព្យាបត្តិ ព្យាបជ្ជនា ព្យាបជ្ជិតត្តំ វិរោធោ បដិវិរោធោ ចណ្ឌិក្កំ អសុរោបោ អនត្តមនតា ចិត្តស្ស អយំ វុច្ចតិ ទោសោ ។

(២៩៦) តត្ថ កតមោ មោហោ ។ ទុក្ខេ អញ្ញាណំ ទុក្ខសមុទយេ អញ្ញាណំ ទុក្ខនិរោធេ អញ្ញាណំ ទុក្ខនិរោធគាមិនិយា បដិបទាយ អញ្ញាណំ បុព្វន្តេ អញ្ញាណំ អបរន្តេ អញ្ញាណំ បុព្វន្តាបរន្តេ អញ្ញាណំ ឥទប្បច្ចយតាបដិច្ចសមុប្បន្នេសុ ធម្មេសុ អញ្ញាណំ យំ ឯវរូបំ អញ្ញាណំ អទស្សនំ អនភិសមយោ អននុពោធោ អសម្ពោធោ អប្បដិវេធោ អសង្គាហនា អបរិយោគាហនា អសមបេក្ខនា អប្បច្ចវេក្ខណា អប្បច្ចក្ខកម្មំ ទុម្មេជ្ឈំ ពាល្យំ អសម្បជញ្ញំ មោហោ បមោហោ សម្មោហោ អវិជ្ជា អវិជ្ជោឃោ អវិជ្ជាយោគោ អវិជ្ជានុសយោ អវិជ្ជាបរិយុដ្ឋានំ អវិជ្ជាលង្គី មោហោ អកុសលមូលំ អយំ វុច្ចតិ មោហោ ។

(២៩៧) តត្ថ កតមោ មានោ ។ សេយ្យោហមស្មីតិ មានោ សទិសោហមស្មីតិ មានោ ហីនោហមស្មីតិ មានោ

អាការប្រទូស្ត ភាពនៃចិត្តប្រទូស្ត សេចក្ដីវិនាស អាការវិនាស ភាពនៃចិត្តវិនាស ការខឹង ការខឹងតប ភាពនៃចិត្តកាច ការខឹង ការតូចចិត្តណា ដែលមានសភាពបែបនេះ នេះហៅថា ទោសៈ ។

(៨៩៨) បណ្ដាកិលេសវត្ថុទាំងនោះ មោហៈ តើដូចម្ដេច ។ ការមិនដឹងច្បាស់ក្នុងទុក្ខ មិនដឹងច្បាស់ក្នុងទុក្ខសមុទយ មិនដឹងច្បាស់ក្នុងទុក្ខនិរោធ មិនដឹងច្បាស់ក្នុងទុក្ខនិរោធគាមិនីបដិបទា មិនដឹងច្បាស់ក្នុងខន្ធជាចំណែកខាងដើម មិនដឹងច្បាស់ក្នុងខន្ធជាចំណែកខាងចុង មិនដឹងច្បាស់ក្នុងខន្ធទាំងជាចំណែកខាងដើមនិងខាងចុង មិនដឹងច្បាស់ក្នុងពួកធម៌ ដែលកើតឡើង ព្រោះអាស្រ័យបច្ច័យនោះៗ និងការមិនដឹងច្បាស់ ការមិនឃើញ ការមិនត្រាស់ដឹង ការមិនភ្ញាក់រលឹក ការមិនត្រាស់ដឹងព្រម ការមិនចាក់ធ្លុះ ការមិនបានដោតក្រងទុក ការមិនចុះចិត្តស៊ប់ ការមិនរំពឹងមើល ការមិនបាទពិចារណា អំពើមិនជាក់ច្បាស់ ការយល់បានដោយក្រ ភាពនៃសេចក្ដីល្ងង់ ការមិនដឹងខ្លួន ការវង្វេង ការវង្វេងជ្រប់ ការភ្លេចភាំង អវិជ្ជា ជំនន់គឺអវិជ្ជា ការប្រកបគឺអវិជ្ជា អនុស័យគឺអវិជ្ជា ការស្ទាក់ដំណើរគឺអវិជ្ជា គន្លឹះគឺអវិជ្ជា ការវង្វេង ជាអកុសលមូល ណា ដែលមានសភាពបែបនេះ នេះហៅថា មោហៈ ។

(៨៩៩) បណ្ដាកិលេសវត្ថុទាំងនោះ មានះ តើដូចម្ដេច ។ សេចក្ដីប្រកាន់ថា អញប្រសើរ (ជាងគេ) ប្រកាន់ថា អញស្មើ (នឹងគេ) ប្រកាន់ថា អញថោកទាប (ជាងគេ)

យោ ឯវរូបោ មានោ មញ្ញនា មញ្ញិតត្តំ ឧណ្ណតិ ឧណ្ណាមោ ធជោ សម្បគ្គាហោ កេតុកម្យតា ចិត្តស្ស អយំ វុច្ចតិ មានោ ។

(២៩៦) តត្ថ កតមា ទិដ្ឋិ ។ សស្សតោ លោកោតិ វា អសស្សតោ លោកោតិ វា អន្តវា លោកោតិ វា អនន្តវា លោកោតិ វា តំ ជីវំ តំ សរីរន្តិ វា អញ្ញំ ជីវំ អញ្ញំ សរីរន្តិ វា ហោតិ តថាគតោ បរម្មរណាតិ វា ន ហោតិ តថាគតោ បរម្មរណាតិ វា ហោតិ ច ន ច ហោតិ តថាគតោ បរម្មរណាតិ វា នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណាតិ វា យា ឯវរូបា ទិដ្ឋិ ទិដ្ឋិគតំ ទិដ្ឋិគហនំ ទិដ្ឋិកន្តារោ ទិដ្ឋិវិសូកាយិកំ ទិដ្ឋិវិប្ផន្ទិតំ ទិដ្ឋិសញ្ញោជនំ គាហោ បដិគ្គាហោ អភិនិវេសោ បរាមាសោ កុម្មគ្គោ មិច្ឆាបថោ មិច្ឆត្តំ តិត្ថាយតនំ វិបរិយេសគ្គាហោ អយំ វុច្ចតិ ទិដ្ឋិ ។ សព្វាបិ មិច្ឆាទិដ្ឋិ ទិដ្ឋិ ។

(២៩៧) តត្ថ កតមា វិចិកិច្ឆា ។ សត្ថរិ កង្ខតិ វិចិកិច្ឆតិ ធម្មេ កង្ខតិ វិចិកិច្ឆតិ សង្ឃេ កង្ខតិ វិចិកិច្ឆតិ សិក្ខាយ កង្ខតិ វិចិកិច្ឆតិ បុព្វន្តេ កង្ខតិ វិចិកិច្ឆតិ

សេចក្ដីប្រកាន់ អាការប្រកាន់ ភាពនៃចិត្តប្រកាន់ ការលើកខ្លួន ការប៉ោងឡើង អាការដូចទង់ជ័យ ការតំកើង ភាពនៃចិត្តប្រាថ្នាដូចជាទង់ ណា ដែលមានសភាពបែបនេះ នេះហៅថា មានៈ ។

[ ២៩៦ ] បណ្ដាកិលេសវត្ថុទាំងនោះ ទិដ្ឋិ តើដូចម្ដេច ។ ( ការយល់ ) ថា លោកទៀងក្ដី ថា លោកមិនទៀងក្ដី ថា លោកមានទីបំផុតក្ដី ថា លោកមិនមានទីបំផុតក្ដី ថា ជីវិតនោះគឺសរីរៈនោះក្ដី ថា ជីវិតដទៃសរីរៈដទៃក្ដី ថា សត្វស្លាប់ទៅកើតទៀតក្ដី ថា សត្វស្លាប់ទៅមិនកើតទៀតក្ដី ថា សត្វស្លាប់ទៅកើតទៀតក៏មាន មិនកើតទៀតក៏មានក្ដី ថា សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនក្ដី ទិដ្ឋិ ដំណើរគឺទិដ្ឋិ ព្រៃស្បាតគឺទិដ្ឋិ ផ្លូវឆ្ងាយគឺទិដ្ឋិ ចម្រូងគឺទិដ្ឋិ ការយល់ឆ្វេងគឺទិដ្ឋិ ការជាប់ចំពាក់គឺទិដ្ឋិ ការក្ដួចកាន់ ការប្រកាន់ ការប្រកាន់ខ្ជាប់ ការស្ទាបអង្អែល ផ្លូវអាក្រក់ ផ្លូវខុស ភាពនៃចិត្តខុស លទ្ធិដូចជាកំពង់ សេចក្ដីប្រកាន់ក្នុងការស្វែងរកខុស ណា ដែលមានសភាពបែបនេះ នេះហៅថា ទិដ្ឋិ ។ សូម្បីមិច្ឆាទិដ្ឋិទាំងអស់ ក៏ហៅថា ទិដ្ឋិដែរ ។

[ ២៩៧ ] បណ្ដាកិលេសវត្ថុទាំងនោះ វិចិកិច្ឆា តើដូចម្ដេច ។ បុគ្គលងឿងឆ្ងល់ សង្ស័យ ចំពោះព្រះសាស្ដា ងឿងឆ្ងល់សង្ស័យ ចំពោះព្រះធម៌ ងឿងឆ្ងល់ សង្ស័យ ចំពោះព្រះសង្ឃ ងឿងឆ្ងល់សង្ស័យចំពោះសិក្ខា ងឿងឆ្ងល់សង្ស័យ ចំពោះខន្ធជាចំណែកខាងដើម

អបរន្តេ កង្ខតិ វិចិកិច្ឆតិ បុព្វន្តាបរន្តេ កង្ខតិ វិចិកិច្ឆតិ ឥទប្បច្ចយតាបដិច្ចសមុប្បន្នេសុ ធម្មេសុ កង្ខតិ វិចិកិច្ឆតិ យា ឯវរូបា កង្ខា កង្ខាយនា កង្ខាយិតត្តំ វិមតិ វិចិកិច្ឆា ទ្វេឡ្ហកំ ទ្វេធាបថោ សំសយោ អនេកំសគ្គាហោ អាសប្បនា បរិសប្បនា អបរិយោគាហនា ថម្ភិតត្តំ ចិត្តស្ស មនោវិលេខោ អយំ វុច្ចតិ វិចិកិច្ឆា ។

(២៩៨) តត្ថ កតមំ ថីនំ ។ យា ចិត្តស្ស អកល្យតា អកម្មញ្ញតា ឱលីយនា សល្លីយនា លីនំ លីយនា លីយិតត្តំ ថីនំ ថីយនា ថីយិតត្តំ ចិត្តស្ស ឥទំ វុច្ចតិ ថីនំ ។

(២៩៩) តត្ថ កតមំ ឧទ្ធច្ចំ ។ យំ ចិត្តស្ស ឧទ្ធច្ចំ អវូបសមោ ចេតសោ វិក្ខេបោ ភន្តត្តំ ចិត្តស្ស ឥទំ វុច្ចតិ ឧទ្ធច្ចំ ។

(៣០០) តត្ថ កតមំ អហិរិកំ ។ យំ ន ហិរិយតិ ហិរិយិតព្វេន ន ហិរិយតិ បាបកានំ អកុសលានំ ធម្មានំ សមាបត្តិយា ឥទំ វុច្ចតិ អហិរិកំ ។

ងឿងឆ្ងល់ សង្ស័យ ចំពោះខន្ធ ជាចំណែកខាងចុង ងឿងឆ្ងល់សង្ស័យ ចំពោះខន្ធ ទាំងជាចំណែកខាងដើមនិងខាងចុង ងឿងឆ្ងល់ សង្ស័យ ចំពោះធម៌ដែលកើតឡើង ព្រោះអាស្រ័យបច្ច័យនោះៗ និងសេចក្តីងឿងឆ្ងល់ អាការងឿងឆ្ងល់ ភាពនៃសេចក្តីងឿងឆ្ងល់ ការយល់ស្ទាក់ស្ទើរ ការសង្ស័យ ការបែកចិត្តជាចំពាមពីរ ការបែកជាផ្លូវពីរ ការកន្ទុះរា ការប្រកាន់យកចំណែកដ៏ច្រើន ការសាញប្រដាញ ការសាន់រាន់ចិត្ត ការប្រកាន់មិនដាច់ស្រេច ភាពនៃចិត្តរឹងរូស ការរសេមរសាមនៃចិត្ត ណាដែលមានសភាពបែបនេះ នេះហៅថា វិចិកិច្ឆា ៗ

[ ២៩៨ ] បណ្តាកិលេសវត្ថុទាំងនោះ ថីនៈ តើដូចម្តេច ៗ ភាពនៃចិត្តមិនស្រួល មិនគួរដល់ការងារ ការជ្រប់នៅ ការសម្ងំនៅ សេចក្តីរួញរា អាការរួញរា ភាពនៃចិត្តរួញរា សេចក្តីធុញទ្រាន់ អាការធុញទ្រាន់ ភាពនៃចិត្តធុញទ្រាន់ ណា នេះហៅថា ថីនៈ ៗ

[ ២៩៩ ] បណ្តាកិលេសវត្ថុទាំងនោះ កុក្កុច្ចៈ តើដូចម្តេច ៗ ភាពនៃចិត្តរវើរវាយ ការមិនស្ងប់រម្ងាប់ ការរាយមាយនៃចិត្ត ការភ័ន្តភាំងនៃចិត្ត ណា នេះហៅថា កុក្កុច្ចៈ ៗ

[ ៣០០ ] បណ្តាកិលេសវត្ថុទាំងនោះ អហិរិកៈ តើដូចម្តេច ៗ ត្រង់ដែលបុគ្គល មិនខ្មាសដោយអំពើដែលគួរខ្មាស មិនខ្មាសដោយការកប់ប្រសប់នូវអកុសលធម៌ដ៏លាមក នេះហៅថា អហិរិកៈ ៗ

## កិលេសគោច្ឆកេ និក្ខេបោ

(៣០១) តត្ថ កតមំ អនោត្តប្បំ ។ យំ ន ឱត្តប្បតិ ឱត្តប្បិតព្វេន ន ឱត្តប្បតិ បាបកានំ អកុសលានំ ធម្មានំ សមាបត្តិយា ឥទំ វុច្ចតិ អនោត្តប្បំ ។

ឥមេ ធម្មា កិលេសា ។

(៣០២) កតមេ ធម្មា នោ កិលេសា ។ តេ ធម្មេ ឋបេត្វា អវសេសា កុសលាកុសលាព្យាកតា ធម្មា កាមាវចរា រូបាវចរា អរូបាវចរា អបរិយាបន្នា វេទនាក្ខន្ធោ ។ បេ ។ វិញ្ញាណក្ខន្ធោ សព្វញ្ច រូបំ អសង្ខតា ច ធាតុ ឥមេ ធម្មា នោ កិលេសា ។

(៣០៣) កតមេ ធម្មា សង្កិលេសិកា ។ សាសវា កុសលាកុសលាព្យាកតា ធម្មា កាមាវចរា រូបាវចរា អរូបាវចរា រូបក្ខន្ធោ ។ បេ ។ វិញ្ញាណក្ខន្ធោ ឥមេ ធម្មា សង្កិលេសិកា ។ កតមេ ធម្មា អសង្កិលេសិកា ។ អបរិយាបន្នា មគ្គា ច មគ្គផលានិ ច អសង្ខតា ច ធាតុ ឥមេ ធម្មា អសង្កិលេសិកា ។

(៣០៤) កតមេ ធម្មា សង្កិលិដ្ឋា ។ តីណិ អកុសលមូលានិ លោភោ ទោសោ មោហោ តទេកដ្ឋា ច កិលេសា តំសម្បយុត្តោ វេទនាក្ខន្ធោ ។ បេ ។

## កិលេសគោច្ឆកនិក្ខេប

[៣០១] បណ្ដាកិលេសទាំងនោះ អនោត្តប្បៈ តើដូចម្ដេច ។ ត្រង់ដែលបុគ្គលមិនតក់ស្លុត ដោយអំពើដែលគួរតក់ស្លុត មិនតក់ស្លុត ដោយការគប់ប្រសព្វនូវអកុសលធម៌ដ៏លាមក នេះហៅថា អនោត្តប្បៈ ។ នេះពួកធម៌ជាកិលេស ។

[៣០២] ពួកធម៌មិនមែនកិលេស តើដូចម្ដេច ។ វៀរតែធម៌ទាំងនោះចេញ ពួកធម៌ដ៏សេសសល់ ជាកុសល អកុសល និងអព្យាក្រឹត ជាកាមាវចរ រូបាវចរ អរូបាវចរ អបរិយាបន្នៈ វេទនាខន្ធ ។ បេ ។ វិញ្ញាណក្ខន្ធ រូបទាំងអស់ និងអសង្ខតធាតុ នេះពួកធម៌មិនមែនកិលេស ។

[៣០៣] ពួកធម៌គួរដល់សេចក្ដីសៅហ្មង តើដូចម្ដេច ។ ពួកធម៌ប្រកបដោយអាសវៈ ជាកុសល អកុសល និងអព្យាក្រឹត ជាកាមាវចរ រូបាវចរ អរូបាវចរ និងរូបក្ខន្ធ ។ បេ ។ វិញ្ញាណក្ខន្ធ នេះពួកធម៌គួរដល់សេចក្ដីសៅហ្មង ។ ពួកធម៌មិនគួរដល់សេចក្ដីសៅហ្មង តើដូចម្ដេច ។ មគ្គជាអបរិយាបន្នៈផង ផលនៃមគ្គផង អសង្ខតធាតុផង នេះពួកធម៌មិនគួរដល់សេចក្ដីសៅហ្មង ។

[៣០៤] ពួកធម៌ដែលសៅហ្មង តើដូចម្ដេច ។ អកុសលមូល ៣ យ៉ាង គឺ លោភៈ ទោសៈ មោហៈ ទាំងពួកកិលេសដែលតាំងនៅជាមួយនឹងអកុសលមូល មានលោភៈជាដើមនោះ វេទនាខន្ធ ។ បេ ។

វិញ្ញាណក្ខន្ធោ តំសមុដ្ឋានំ កាយកម្មំ វចីកម្មំ មនោកម្មំ ឥមេ ធម្មា សង្កិលិដ្ឋា ។ កតមេ ធម្មា អសង្កិលិដ្ឋា ។ កុសលាព្យាកតា ធម្មា កាមាវចរា រូបាវចរា អរូបាវចរា អបរិយាបន្នា វេទនាក្ខន្ធោ ។ បេ ។ វិញ្ញាណក្ខន្ធោ សព្វញ្ច រូបំ អសង្ខតា ច ធាតុ ឥមេ ធម្មា អសង្កិលិដ្ឋា ។

(៣០៥) កតមេ ធម្មា កិលេសសម្បយុត្តា ។ តេហិ ធម្មេហិ យេ ធម្មា សម្បយុត្តា វេទនាក្ខន្ធោ ។ បេ ។ វិញ្ញាណក្ខន្ធោ ឥមេ ធម្មា កិលេស-សម្បយុត្តា ។ កតមេ ធម្មា កិលេសវិប្បយុត្តា ។ តេហិ ធម្មេហិ យេ ធម្មា វិប្បយុត្តា វេទនាក្ខន្ធោ ។ បេ ។ វិញ្ញាណក្ខន្ធោ សព្វញ្ច រូបំ អសង្ខតា ច ធាតុ ឥមេ ធម្មា កិលេសវិប្បយុត្តា ។

(៣០៦) កតមេ ធម្មា កិលេសា ចេវ សង្កិ-លេសិកា ច ។ តេវ កិលេសា កិលេសា ចេវ សង្កិលេសិកា ច ។ កតមេ ធម្មា សង្កិលេសិកា ចេវ នោ ច កិលេសា ។ តេហិ ធម្មេហិ យេ ធម្មា សង្កិលេសិកា តេ ធម្មេ ឋបេត្វា អវសេសា សាសវា

វិញ្ញាណក្ខន្ធ ដែលប្រកបដោយអកុសលមូលមានលោភៈជាដើមនោះ និង កាយកម្ម វចីកម្ម មនោកម្ម ដែលតាំងឡើងអំពីអកុសលមូលមានលោភៈ ជាដើមនោះ នេះពួកធម៌ដែលសៅហ្មង ។ ពួកធម៌ដែលមិនសៅហ្មង តើដូចម្តេច ។ ពួកធម៌ជាកុសល និងអព្យាក្រឹត ជាកាមាវចរ រូបាវចរ អរូបាវចរ អបរិយាបន្នៈ វេទនាខន្ធ ។ បេ ។ វិញ្ញាណក្ខន្ធ រូបទាំងអស់ និងអសង្ខតធាតុ នេះពួកធម៌ដែលមិនសៅហ្មង ។

( ៣០៥ ) ពួកធម៌ប្រកបដោយកិលេស តើដូចម្តេច ។ ពួកធម៌ណា ប្រកបដោយធម៌ទាំងនោះ និងវេទនាខន្ធ ។ បេ ។ វិញ្ញាណក្ខន្ធ នេះពួកធម៌ប្រកបដោយកិលេស ។ ពួកធម៌ប្រាសចាកកិលេស តើដូចម្តេច ។ ពួកធម៌ណា ប្រាសចាកធម៌ទាំងនោះ វេទនាខន្ធ ។ បេ ។ វិញ្ញាណក្ខន្ធ រូបទាំងអស់ និងអសង្ខតធាតុ នេះពួកធម៌ ប្រាសចាកកិលេស ។

( ៣០៦ ) ពួកធម៌ជាកិលេសផង គួរដល់សេចក្តីសៅហ្មងផង តើដូចម្តេច ។ កិលេសទាំងនោះឯង ជាកិលេសផង គួរដល់សេចក្តីសៅហ្មងផង ។ ពួកធម៌គ្រាន់តែគួរដល់សេចក្តីសៅហ្មង តែមិនមែនកិលេស តើដូចម្តេច ។ ពួកធម៌ណា គួរដល់សេចក្តីសៅហ្មងដោយធម៌ទាំងនោះ វៀរតែធម៌ទាំងនោះចេញ ពួកធម៌ដ៏សេសសល់ ប្រកបដោយអាសវៈ

កុសលាកុសលាព្យាកតា ធម្មា កាមាវចរា រូបា-វចរា អរូបាវចរា រូបក្ខន្ធោ ។ បេ ។ វិញ្ញាណ-ក្ខន្ធោ ឥមេ ធម្មា សង្កិលេសិកា ចេវ នោ ច កិលេសា ។

(៣០៧) កតមេ ធម្មា កិលេសា ចេវ សង្កិ-លិដ្ឋា ច ។ តេវ កិលេសា កិលេសា ចេវ សង្កិលិដ្ឋា ច ។ កតមេ ធម្មា សង្កិលិដ្ឋា ចេវ នោ ច កិលេសា ។ តេហិ ធម្មេហិ យេ ធម្មា សង្កិលិដ្ឋា តេ ធម្មេ ឋបេត្វា វេទនាក្ខន្ធោ ។ បេ ។ វិញ្ញាណក្ខន្ធោ ឥមេ ធម្មា សង្កិលិដ្ឋា ចេវ នោ ច កិលេសា ។

(៣០៨) កតមេ ធម្មា កិលេសា ចេវ កិលេ-សសម្បយុត្តា ច ។ លោភោ មោហេន កិលេសោ ចេវ កិលេសសម្បយុត្តោ ច មោហោ លោភេន កិលេសោ ចេវ កិលេសសម្បយុត្តោ ច ទោសោ មោហេន កិលេសោ ចេវ កិលេសសម្បយុត្តោ ច មោហោ ទោសេន កិលេសោ ចេវ កិលេស-សម្បយុត្តោ ច មានោ មោហេន កិលេសោ

ជាកុសល អកុសល និងអព្យាក្រឹត ជាកាមាវចរ រូបាវចរ អរូបាវចរ និងរូបក្ខន្ធ ។ បេ ។ វិញ្ញាណក្ខន្ធ នេះពួកធម៌គ្រាន់តែគួរដល់សេចក្តីសៅហ្មង តែមិនមែនកិលេស ។

(៣០៧) ពួកធម៌ជាកិលេសផង សៅហ្មងផង តើដូចម្តេច ។ កិលេសទាំងនោះឯង ជាកិលេសផង សៅហ្មងផង ។ ពួកធម៌គ្រាន់តែសៅហ្មង តែមិនមែនកិលេស តើដូចម្តេច ។ ពួកធម៌ណា សៅហ្មងដោយធម៌ទាំងនោះ វៀរតែធម៌ទាំងនោះចេញ និងវេទនាខន្ធ ។ បេ ។ វិញ្ញាណក្ខន្ធ នេះពួកធម៌ គ្រាន់តែសៅហ្មង តែមិនមែនកិលេស ។

(៣០៨) ពួកធម៌ជាកិលេសផង ប្រកបដោយកិលេសផង តើដូចម្តេច ។ លោភៈ ជាកិលេសផង ប្រកបដោយកិលេសផង ដោយមោហៈ មោហៈ ជាកិលេសផង ប្រកបដោយកិលេសផង ដោយលោភៈ ទោសៈ ជាកិលេសផង ប្រកបដោយកិលេសផង ដោយមោហៈ មោហៈ ជាកិលេសផង ប្រកបដោយកិលេសផង ដោយទោសៈ មានៈ ជាកិលេសផង

ចេវ កិលេសសម្បយុត្តោ ច មោហោ មានេន កិ-
លេសោ ចេវ កិលេសសម្បយុត្តោ ច ទិដ្ឋិ មោហេ-
ន កិលេសោ ចេវ កិលេសសម្បយុត្តា ច មោហោ
ទិដ្ឋិយា កិលេសោ ចេវ កិលេសសម្បយុត្តោ ច
វិចិកិច្ឆា មោហេន កិលេសោ ចេវ កិលេសស-
ម្បយុត្តា ច មោហោ វិចិកិច្ឆាយ កិលេសោ ចេវ
កិលេសសម្បយុត្តោ ច ថីនំ មោហេន កិលេសោ
ចេវ កិលេសសម្បយុត្តញ្ច មោហោ ថីនេន កិលេ-
សោ ចេវ កិលេសសម្បយុត្តោ ច ឧទ្ធច្ចំ មោហេ-
ន កិលេសោ ចេវ កិលេសសម្បយុត្តញ្ច មោហោ
ឧទ្ធច្ចេន កិលេសោ ចេវ កិលេសសម្បយុត្តោ ច
អហិរិកំ មោហេន កិលេសោ ចេវ កិលេសសម្ប-
យុត្តញ្ច មោហោ អហិរិកេន កិលេសោ ចេវ កិ-
លេសសម្បយុត្តោ ច អនោត្តប្បំ មោហេន កិលេ-
សោ ចេវ កិលេសសម្បយុត្តញ្ច មោហោ អនោត្ត-
ប្បេន កិលេសោ ចេវ កិលេសសម្បយុត្តោ ច
លោភោ ឧទ្ធច្ចេន កិលេសោ ចេវ កិលេសសម្ប-
យុត្តោ ច ឧទ្ធច្ចំ លោភេន កិលេសោ ចេវ

ប្រកបដោយកិលេសផង ដោយមោហៈ មោហៈ ជាកិលេសផង ប្រកបដោយកិលេសផង ដោយមានះ ទិដ្ឋិ ជាកិលេសផង ប្រកបដោយកិលេសផង ដោយមោហៈ មោហៈ ជាកិលេសផង ប្រកបដោយកិលេសផង ដោយទិដ្ឋិ វិចិកិច្ឆា ជាកិលេសផង ប្រកបដោយកិលេសផង ដោយមោហៈ មោហៈ ជាកិលេសផង ប្រកបដោយកិលេសផង ដោយវិចិកិច្ឆា ថីនៈ ជាកិលេសផង ប្រកបដោយកិលេសផង ដោយមោហៈ មោហៈ ជាកិលេសផង ប្រកបដោយកិលេសផង ដោយថីនៈ ឧទ្ធច្ចៈ ជាកិលេសផង ប្រកបដោយកិលេសផង ដោយមោហៈ មោហៈ ជាកិលេសផង ប្រកបដោយកិលេសផង ដោយឧទ្ធច្ចៈ អហិរិកៈ ជាកិលេសផង ប្រកបដោយកិលេសផង ដោយមោហៈ មោហៈ ជាកិលេសផង ប្រកបដោយកិលេសផង ដោយអហិរិកៈ អនោត្តប្បៈ ជាកិលេសផង ប្រកបដោយកិលេសផង ដោយមោហៈ មោហៈ ជាកិលេសផង ប្រកបដោយកិលេសផង ដោយអនោត្តប្បៈ លោភៈ ជាកិលេសផង ប្រកបដោយកិលេសផង ដោយឧទ្ធច្ចៈ ឧទ្ធច្ចៈ ជាកិលេសផង ប្រកបដោយកិលេសផង ដោយលោភៈ

## កិលេសគោច្ឆកេ និក្ខេបោ

កិលេសសម្បយុត្តញ្ច លោភោ ឧទ្ធច្ចេន កិលេសោ ចេវ កិលេសសម្បយុត្តោ ច ឧទ្ធច្ចំ លោភេន កិលេសោ ចេវ កិលេសសម្បយុត្តញ្ច ទោសោ ឧទ្ធច្ចេន កិលេសោ ចេវ កិលេសសម្បយុត្តោ ច ឧទ្ធច្ចំ ទោសេន កិលេសោ ចេវ កិលេសសម្បយុត្តញ្ច មោហោ ឧទ្ធច្ចេន កិលេសោ ចេវ កិលេសសម្បយុត្តោ ច ឧទ្ធច្ចំ មោហេន កិលេសោ ចេវ កិលេសសម្បយុត្តញ្ច ទិដ្ឋិ ឧទ្ធច្ចេន កិលេសោ ចេវ កិលេសសម្បយុត្តោ ច ឧទ្ធច្ចំ ទិដ្ឋិយា កិលេសោ ចេវ កិលេសសម្បយុត្តញ្ច វិចិកិច្ឆា ឧទ្ធច្ចេន កិលេសោ ចេវ កិលេសសម្បយុត្តោ ច ឧទ្ធច្ចំ វិចិកិច្ឆាយ កិលេសោ ចេវ កិលេសសម្បយុត្តញ្ច ថីនំ ឧទ្ធច្ចេន កិលេសោ ចេវ កិលេសសម្បយុត្តញ្ច ឧទ្ធច្ចំ ថីនេន កិលេសោ ចេវ កិលេសសម្បយុត្តញ្ច អហិរិកំ ឧទ្ធច្ចេន កិលេសោ ចេវ កិលេសសម្បយុត្តញ្ច ឧទ្ធច្ចំ អហិរិកេន កិលេសោ ចេវ កិលេសសម្បយុត្តញ្ច អនោត្តប្បំ ឧទ្ធច្ចេន កិលេសោ ចេវ កិលេសសម្បយុត្តញ្ច ឧទ្ធច្ចំ អនោត្តប្បេន កិលេសោ ចេវ

ទោសៈ ជាកិលេសផង ប្រកបដោយកិលេសផង ដោយឧទ្ធច្ចៈ ឧទ្ធច្ចៈ ជាកិលេសផង ប្រកបដោយកិលេសផង ដោយទោសៈ មោហៈ ជាកិលេសផង ប្រកបដោយកិលេសផង ដោយឧទ្ធច្ចៈ ឧទ្ធច្ចៈ ជាកិលេសផង ប្រកបដោយកិលេសផង ដោយមោហៈ មានៈ ជាកិលេសផង ប្រកបដោយកិលេសផង ដោយឧទ្ធច្ចៈ ឧទ្ធច្ចៈ ជាកិលេសផង ប្រកបដោយកិលេសផង ដោយមានៈ ទិដ្ឋិ ជាកិលេសផង ប្រកបដោយកិ-លេសផង ដោយឧទ្ធច្ចៈ ឧទ្ធច្ចៈ ជាកិលេសផង ប្រកបដោយកិលេសផង ដោយទិដ្ឋិ វិចិកិច្ឆា ជាកិលេសផង ប្រកបដោយកិលេសផង ដោយឧទ្ធច្ចៈ ឧទ្ធច្ចៈ ជាកិលេសផង ប្រកបដោយកិលេសផង ដោយវិចិកិច្ឆា ថីនៈ ជាកិលេសផង ប្រកបដោយកិលេសផង ដោយឧទ្ធច្ចៈ ឧទ្ធច្ចៈ ជាកិលេសផង ប្រកបដោយកិលេសផង ដោយថីនៈ អហិរិកៈ ជាកិលេសផង ប្រកបដោយកិលេសផង ដោយឧទ្ធច្ចៈ ឧទ្ធច្ចៈ ជាកិ-លេសផង ប្រកបដោយកិលេសផង ដោយអហិរិកៈ អនោត្តប្បៈ ជាកិ-លេសផង ប្រកបដោយកិលេសផង ដោយឧទ្ធច្ចៈ ឧទ្ធច្ចៈ ជាកិលេសផង

កិលេសសម្បយុត្តញ្ច លោភោ អហិរិកេន កិ-
លេសោ ចេវ កិលេសសម្បយុត្តោ ច អហិរិកំ
លោភេន កិលេសោ ចេវ កិលេសសម្បយុត្តញ្ច
ទោសោ អហិរិកេន កិលេសោ ចេវ កិលេសស-
ម្បយុត្តោ ច អហិរិកំ ទោសេន កិលេសោ ចេវ
កិលេសសម្បយុត្តញ្ច មោហោ អហិរិកេន កិលេ-
សោ ចេវ កិលេសសម្បយុត្តោ ច អហិរិកំ មោ-
ហេន កិលេសោ ចេវ កិលេសសម្បយុត្តញ្ច មានោ
អហិរិកេន កិលេសោ ចេវ កិលេសសម្បយុត្តោ ច
អហិរិកំ មានេន កិលេសោ ចេវ កិលេសសម្ប-
យុត្តញ្ច ទិដ្ឋិ អហិរិកេន កិលេសោ ចេវ កិលេស-
សម្បយុត្តា ច អហិរិកំ ទិដ្ឋិយា កិលេសោ ចេវ កិ-
លេសសម្បយុត្តញ្ច វិចិកិច្ឆា អហិរិកេន កិលេសោ
ចេវ កិលេសសម្បយុត្តា ច អហិរិកំ វិចិកិច្ឆាយ កិ-
លេសោ ចេវ កិលេសសម្បយុត្តញ្ច ថីនំ អហិរិកេន
កិលេសោ ចេវ កិលេសសម្បយុត្តញ្ច អហិរិកំ ថី-
នេន កិលេសោ ចេវ កិលេសសម្បយុត្តញ្ច ឧទ្ធច្ចំ
អហិរិកេន កិលេសោ ចេវ កិលេសសម្បយុត្តញ្ច

ប្រកបដោយកិលេសផង ដោយអនោត្តប្បៈ លោភៈ ជាកិលេសផង ប្រកបដោយកិលេសផង ដោយអហិរិកៈ អហិរិកៈ ជាកិលេសផង ប្រកបដោយកិលេសផង ដោយលោភៈ ទោសៈ ជាកិលេសផង ប្រកបដោយកិលេសផង ដោយអហិរិកៈ អហិរិកៈ ជាកិលេសផង ប្រកបដោយកិលេសផង ដោយទោសៈ មោហៈ ជាកិលេសផង ប្រកបដោយកិលេសផង ដោយអហិរិកៈ អហិរិកៈ ជាកិលេសផង ប្រកបដោយកិលេសផង ដោយមោហៈ មានៈ ជាកិលេសផង ប្រកបដោយកិលេសផង ដោយអហិរិកៈ អហិរិកៈ ជាកិលេសផង ប្រកបដោយកិលេសផង ដោយមានៈ ទិដ្ឋិ ជាកិលេសផង ប្រកបដោយកិលេសផង ដោយអហិរិកៈ អហិរិកៈ ជាកិលេសផង ប្រកបដោយកិលេសផង ដោយទិដ្ឋិ វិចិកិច្ឆា ជាកិលេសផង ប្រកបដោយកិលេសផង ដោយអហិរិកៈ អហិរិកៈ ជាកិលេសផង ប្រកបដោយកិលេសផង ដោយវិចិកិច្ឆា ថីនៈ ជាកិលេសផង ប្រកបដោយកិលេសផង ដោយអហិរិកៈ អហិរិកៈ ជាកិលេសផង ប្រកបដោយកិលេសផង ដោយថីនៈ ឧទ្ធច្ចៈ ជាកិលេសផង ប្រកបដោយកិលេសផង ដោយអហិរិកៈ

កិលេសគោច្ឆកេ និក្ខេបោ

អហិរិកំ ឧទ្ធច្ចេន កិលេសោ ចេវ កិលេសសម្បយុត្តញ្ច អនោត្តប្បំ អហិរិកេន កិលេសោ ចេវ កិលេសសម្បយុត្តញ្ច អហិរិកំ អនោត្តប្បេន កិលេសោ ចេវ កិលេសសម្បយុត្តញ្ច លោភោ អនោត្តប្បេន កិលេសោ ចេវ កិលេសសម្បយុត្តោ ច អនោត្តប្បំ លោភេន កិលេសោ ចេវ កិលេសសម្បយុត្តញ្ច ទោសោ អនោត្តប្បេន កិលេសោ ចេវ កិលេសសម្បយុត្តោ ច អនោត្តប្បំ ទោសេន កិលេសោ ចេវ កិលេសសម្បយុត្តញ្ច មោហោ អនោត្តប្បេន កិលេសោ ចេវ កិលេសសម្បយុត្តោ ច អនោត្តប្បំ មោហេន កិលេសោ ចេវ កិលេសសម្បយុត្តញ្ច មានោ អនោត្តប្បេន កិលេសោ ចេវ កិលេសសម្បយុត្តោ ច អនោត្តប្បំ មានេន កិលេសោ ចេវ កិលេសសម្បយុត្តញ្ច ទិដ្ឋិ អនោត្តប្បេន កិលេសោ ចេវ កិលេសសម្បយុត្តា ច អនោត្តប្បំ ទិដ្ឋិយា កិលេសោ ចេវ កិលេសសម្បយុត្តញ្ច វិចិកិច្ឆា អនោត្តប្បេន កិលេសោ ចេវ កិលេសសម្បយុត្តា ច អនោត្តប្បំ

## កិលេសគោច្ឆកនិក្ខេប

អហិរិកៈ ជាកិលេសផង ប្រកបដោយកិលេសផង ដោយឧទ្ធច្ចៈ អនោត្តប្បៈ ជាកិលេសផង ប្រកបដោយកិលេសផង ដោយអហិរិកៈ អហិរិកៈ ជាកិលេសផង ប្រកបដោយកិលេសផង ដោយអនោត្តប្បៈ លោភៈ ជាកិលេសផង ប្រកបដោយកិលេសផង ដោយអនោត្តប្បៈ អនោត្តប្បៈ ជាកិលេសផង ប្រកបដោយកិលេសផង ដោយលោភៈ ទោសៈ ជាកិលេសផង ប្រកបដោយកិលេសផង ដោយអនោត្តប្បៈ អនោត្តប្បៈ ជាកិលេសផង ប្រកបដោយកិលេសផង ដោយទោសៈ មោហៈ ជាកិលេសផង ប្រកបដោយកិលេសផង ដោយអនោត្តប្បៈ អនោត្តប្បៈ ជាកិលេសផង ប្រកបដោយកិលេសផង ដោយមោហៈ មានៈ ជាកិលេសផង ប្រកបដោយកិលេសផង ដោយអនោត្តប្បៈ អនោត្តប្បៈ ជាកិលេសផង ប្រកបដោយកិលេសផង ដោយមានៈ ទិដ្ឋិ ជាកិលេសផង ប្រកបដោយកិលេសផង ដោយអនោត្តប្បៈ អនោត្តប្បៈ ជាកិលេសផង ប្រកបដោយកិលេសផង ដោយទិដ្ឋិ វិចិកិច្ឆា ជាកិលេសផង ប្រកបដោយកិលេសផង ដោយអនោត្តប្បៈ អនោត្តប្បៈ

វិចិកិច្ឆាយ កិលេសោ ចេវ កិលេសសម្បយុត្តញ្ច ឯកំ អនោត្តប្បេន កិលេសោ ចេវ កិលេសសម្បយុត្តញ្ច អនោត្តប្បំ ឯកេន កិលេសោ ចេវ កិលេសសម្បយុត្តញ្ច ឧទ្ធច្ចំ អនោត្តប្បេន កិលេសោ ចេវ កិលេសសម្បយុត្តញ្ច អនោត្តប្បំ ឧទ្ធច្ចេន កិលេសោ ចេវ កិលេសសម្បយុត្តញ្ច អហិរិកំ អនោត្តប្បេន កិលេសោ ចេវ កិលេសសម្បយុត្តញ្ច អនោត្តប្បំ អហិរិកេន កិលេសោ ចេវ កិលេសសម្បយុត្តញ្ច ។ ឥមេ ធម្មា កិលេសា ចេវ កិលេសសម្បយុត្តា ច ។ កតមេ ធម្មា កិលេសសម្បយុត្តា ចេវ នោ ច កិលេសា ។ តេហិ ធម្មេហិ យេ ធម្មា សម្បយុត្តា តេ ធម្មេ ឋបេត្វា វេទនាខន្ធោ ។ បេ ។ វិញ្ញាណក្ខន្ធោ ឥមេ ធម្មា កិលេសសម្បយុត្តា ចេវ នោ ច កិលេសា ។

(៣០៩) កតមេ ធម្មា កិលេសវិប្បយុត្តា សង្កិលេសិកា ។ តេហិ ធម្មេហិ យេ ធម្មា វិប្បយុត្តា សាសវា កុសលាព្យាកតា ធម្មា កាមាវចរា រូបាវចរា អរូបាវចរា រូបក្ខន្ធោ ។ បេ ។ វិញ្ញាណក្ខន្ធោ

ជាកិលេសផង ប្រកបដោយកិលេសផង ដោយវិចិកិច្ឆា ថីនៈ ជាកិលេសផង ប្រកបដោយកិលេសផង ដោយអនោត្តប្បៈ អនោត្តប្បៈ ជាកិលេសផង ប្រកបដោយកិលេសផង ដោយថីនៈ ឧទ្ធច្ចៈ ជាកិលេសផង ប្រកបដោយកិលេសផង ដោយអនោត្តប្បៈ អនោត្តប្បៈ ជាកិលេសផង ប្រកបដោយកិលេសផង ដោយឧទ្ធច្ចៈ អហិរិកៈ ជាកិលេសផង ប្រកបដោយកិលេសផង ដោយអនោត្តប្បៈ អនោត្តប្បៈ ជាកិលេសផង ប្រកបដោយកិលេសផង ដោយអហិរិកៈ នេះពួកធម៌ជាកិលេសផង ប្រកបដោយកិលេសផង ។ ពួកធម៌គ្រាន់តែប្រកបដោយកិលេស តែមិនមែនជាកិលេស តើដូចម្តេច ។ ពួកធម៌ណា ប្រកបដោយធម៌ទាំងនោះ វៀរតែធម៌ទាំងនោះចេញ វេទនាខន្ធ ។ បេ ។ វិញ្ញាណក្ខន្ធ នេះពួកធម៌គ្រាន់តែប្រកបដោយកិលេស តែមិនមែនជាកិលេស ។

(៣០៩) ពួកធម៌ ប្រាសចាកកិលេស តែគួរដល់សេចក្តីសៅហ្មង តើដូចម្តេច ។ ពួកធម៌ណា ប្រាសចាកធម៌ទាំងនោះ ពួកធម៌ប្រកបដោយអាសវៈ ជាកុសល និងអព្យាក្រឹត ជាកាមាវចរ រូបាវចរ អរូបាវចរ និងរូបក្ខន្ធ ។ បេ ។ វិញ្ញាណក្ខន្ធ

ឥមេ ធម្មា កិលេសវិប្បយុត្តា សង្កិលេសិកា ។ ក-
តមេ ធម្មា កិលេសវិប្បយុត្តា អសង្កិលេសិកា ៖
អបរិយាបន្នា មគ្គា ច មគ្គផលានិ ច អសង្ខតា ច ធាតុ
ឥមេ ធម្មា កិលេសវិប្បយុត្តា អសង្កិលេសិកា ។

(៣១០) កតមេ ធម្មា ទស្សនេន បហាតព្វា ។
តីណិ សញ្ញោជនានិ សក្កាយទិដ្ឋិ វិចិកិច្ឆា សីល-
ព្វតបរាមាសោ ។

(៣១១) តត្ថ កតមា សក្កាយទិដ្ឋិ ។ ឥធ
អស្សុតវា បុថុជ្ជនោ អរិយានំ អទស្សាវី អរិយធម្ម-
ស្ស អកោវិទោ អរិយធម្មេ អវិនីតោ សប្បុរិសានំ
អទស្សាវី សប្បុរិសធម្មស្ស អកោវិទោ សប្បុរិស-
ធម្មេ អវិនីតោ រូបំ អត្តតោ សមនុបស្សតិ រូបវន្តំ
វា អត្តានំ អត្តនិ វា រូបំ រូបស្មឹ វា អត្តានំ វេទនំ
។ បេ ។ សញ្ញំ ។ បេ ។ សង្ខារេ ។ បេ ។
វិញ្ញាណំ អត្តតោ សមនុបស្សតិ វិញ្ញាណវន្តំ វា
អត្តានំ អត្តនិ វា វិញ្ញាណំ វិញ្ញាណស្មឹ វា អត្តានំ
យា ឯវរូបា ទិដ្ឋិ ទិដ្ឋិគតំ ។ បេ ។ វិបរិយេសគ្គា-
ហោ អយំ វុច្ចតិ សក្កាយទិដ្ឋិ ។

បិដ្ឋិទុកនិក្ខេប

នេះពួកធម៌ប្រាសចាកកិលេស តែគួរដល់សេចក្ដីសៅហ្មង ៗ ពួកធម៌ប្រាសចាកកិលេសផង មិនគួរដល់សេចក្ដីសៅហ្មងផង តើដូចម្ដេច ៗ មគ្គជាអបរិយាបន្នៈផង ផលនៃមគ្គផង អសង្ខតធាតុផង នេះពួកធម៌ប្រាសចាកកិលេសផង មិនគួរដល់សេចក្ដីសៅហ្មងផង ៗ

[ ៣១០ ] ពួកធម៌គួរលះ ដោយទស្សនៈ ( សោតាបត្តិមគ្គ ) តើដូចម្ដេច ៗ សញ្ញោជនៈ ៣ គឺ សក្កាយទិដ្ឋិ វិចិកិច្ឆា និងសីលព្វតបរាមាសៈ ៗ

[ ៣១១ ] បណ្ដាសញ្ញោជនៈទាំងនោះ សក្កាយទិដ្ឋិ តើដូចម្ដេច ៗ បុថុជ្ជនក្នុងលោកនេះ ជាអ្នកមិនចេះដឹង មិនឃើញពួកព្រះអរិយៈ មិនឈ្លាសវៃក្នុងអរិយធម៌ មិនបានទូន្មានខ្លួនក្នុងអរិយធម៌ មិនបានឃើញពួកសប្បុរស មិនឈ្លាសវៃក្នុងសប្បុរិសធម៌ មិនបានទូន្មានខ្លួនក្នុងសប្បុរិសធម៌ រមែងយល់ឃើញរូបថាជាខ្លួន ឃើញខ្លួនថាមានរូបខ្លះ ឃើញរូបថាមានក្នុងខ្លួនខ្លះ ឃើញខ្លួនថាមានក្នុងរូបខ្លះ ឃើញវេទនា ៗ បេ ៗ សញ្ញា ៗ បេ ៗ សង្ខារ ៗ បេ ៗ ឃើញវិញ្ញាណថាជាខ្លួន ឃើញខ្លួនថាមានវិញ្ញាណខ្លះ ឃើញវិញ្ញាណថាមានក្នុងខ្លួនខ្លះ ឃើញខ្លួនថាមានក្នុងវិញ្ញាណខ្លះ ទិដ្ឋិ ដំណើរគឺទិដ្ឋិ ៗ បេ ៗ សេចក្ដីប្រកាន់ក្នុងការស្វែងរកខុស ណា ដែលមានសភាពបែបនេះ នេះហៅថា សក្កាយទិដ្ឋិ ៗ

(៣១២) តត្ថ កតមា វិចិកិច្ឆា ។ សត្ថរិ កង្ខតិ វិចិកិច្ឆតិ ។ បេ ។ ឆម្ភិតត្តំ ចិត្តស្ស មនោវិលេខោ អយំ វុច្ចតិ វិចិកិច្ឆា ។

(៣១៣) តត្ថ កតមោ សីលព្វតបរាមាសោ ។ ឥតោ ពហិទ្ធា សមណព្រាហ្មណានំ សីលេន សុទ្ធិ វតេន សុទ្ធិ សីលព្វតេន សុទ្ធីតិ យា ឯវរូបា ទិដ្ឋិ ទិដ្ឋិគតំ ។ បេ ។ វិបរិយេសគ្គាហោ អយំ វុច្ចតិ សីលព្វតបរាមាសោ ។

(៣១៤) ឥមានិ តីណិ សញ្ញោជនានិ តទេកដ្ឋា ច កិលេសា តំសម្បយុត្តោ វេទនាក្ខន្ធោ ។ បេ ។ វិញ្ញាណក្ខន្ធោ តំសមុដ្ឋានំ កាយកម្មំ វចីកម្មំ មនោកម្មំ ឥមេ ធម្មា ទស្សនេន បហាតព្វា ។ កតមេ ធម្មា ន ទស្សនេន បហាតព្វា ។ តេ ធម្មេ ឋបេត្វា អវសេសា កុសលាកុសលាព្យាកតា ធម្មា កាមាវចរា រូបាវចរា អរូបាវចរា អបរិយាបន្នា វេទនាក្ខន្ធោ ។ បេ ។ វិញ្ញាណក្ខន្ធោ សព្វញ្ច រូបំ អសង្ខតា ច ធាតុ ឥមេ ធម្មា ន ទស្សនេន បហាតព្វា ។

( ៣១២ ) បណ្ដាសញ្ញោជនៈទាំងនោះ វិចិកិច្ឆា តើដូចម្ដេច ។ បុគ្គលងឿងឆ្ងល់ សង្ស័យ ចំពោះព្រះសាស្ដា ។ បេ ។ ភាពនៃចិត្តរឹងរូស ការរសេមរសាមនៃចិត្ត នេះហៅថា វិចិកិច្ឆា ។

(៣១៣) បណ្ដាសញ្ញោជនៈទាំងនោះ សីលព្វតបរាមាសៈ តើដូចម្ដេច ។ ពួកសមណព្រាហ្មណ៍ ខាងក្រៅអំពីសាសនានេះ (យល់ឃើញ) ថា សេចក្ដីបរិសុទ្ធិដោយសីល បរិសុទ្ធិដោយវ័ត បរិសុទ្ធិដោយសីលនិងវ័ត ទិដ្ឋិ ដំណើរគឺទិដ្ឋិ ។ បេ ។ សេចក្ដីប្រកាន់ក្នុងការស្ទួងរកខុសណា ដែលមានសភាពបែបនេះ នេះហៅថា សីលព្វតបរាមាសៈ ។

( ៣១៤ ) សញ្ញោជនៈ ៣ នេះ ទាំងពួកកិលេសដែលតាំងនៅជាមួយនឹងសញ្ញោជនៈនោះ វេទនាខន្ធ ។ បេ ។ វិញ្ញាណក្ខន្ធ ដែលប្រកបដោយសញ្ញោជនៈនោះ កាយកម្ម វចីកម្ម មនោកម្ម ដែលតាំងឡើង អំពីសញ្ញោជនៈនោះ នេះពួកធម៌ គួរលះដោយទស្សនៈ ។ ពួកធម៌មិនគួរលះ ដោយទស្សនៈ តើដូចម្ដេច ។ វៀរតែធម៌ទាំងនោះចេញ ពួកធម៌ដ៏សេសសល់ ជាកុសល អកុសល និងអព្យាក្រឹត ជាកាមាវចរ រូបាវចរ អរូបាវចរ អបរិយាបន្នៈ វេទនាខន្ធ ។ បេ ។ វិញ្ញាណក្ខន្ធ រូបទាំងអស់ និងអសង្ខតធាតុ នេះពួកធម៌ មិនគួរលះដោយទស្សនៈ ។

(៣១៥) កតមេ ធម្មា ភាវនាយ បហាតព្វា ។ អវសេសោ លោភោ ទោសោ មោហោ តទេកដ្ឋា ច កិលេសា តំសម្បយុត្តោ វេទនាក្ខន្ធោ ។ បេ ។ វិញ្ញាណក្ខន្ធោ តំសមុដ្ឋានំ កាយកម្មំ វចីកម្មំ មនោកម្មំ ឥមេ ធម្មា ភាវនាយ បហាតព្វា ។ កតមេ ធម្មា ន ភាវនាយ បហាតព្វា ។ តេ ធម្មេ ឋបេត្វា អវសេសា កុសលាកុសលាព្យាកតា ធម្មា កាមាវចរា រូបាវចរា អរូបាវចរា អបរិយាបន្នា វេទនាក្ខន្ធោ ។ បេ ។ វិញ្ញាណក្ខន្ធោ សព្វញ្ច រូបំ អសង្ខតា ច ធាតុ ឥមេ ធម្មា ន ភាវនាយ បហាតព្វា ។

(៣១៦) កតមេ ធម្មា ទស្សនេន បហាតព្វហេតុកា ។ តីណិ សញ្ញោជនានិ សក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសោ ។

(៣១៧) តត្ថ កតមា សក្កាយទិដ្ឋិ ។ ឥធ អស្សុតវា បុថុជ្ជនោ អរិយានំ អទស្សាវី អរិយធម្មស្ស អកោវិទោ អរិយធម្មេ អវិនីតោ សប្បុរិសានំ អទស្សាវី សប្បុរិសធម្មស្ស អកោវិទោ សប្បុរិសធម្មេ អវិនីតោ រូបំ អត្តតោ សមនុបស្សតិ រូបវន្តំ

## បិដ្ឋិទុកនិក្ខេប

(៣១៥) ពួកធម៌គួរលះដោយភាវនា តើដូចម្តេច ។ លោភៈ ទោសៈ មោហៈ ដ៏សេសសល់ ទាំងពួកកិលេស ដែលតាំងនៅជាមួយនឹងកិលេស មានលោភៈជាដើមនោះ វេទនាខន្ធ ។ បេ ។ វិញ្ញាណក្ខន្ធ ដែលប្រកបដោយកិលេស មានលោភៈជាដើមនោះ កាយកម្ម វចីកម្ម មនោកម្ម ដែលតាំងឡើងអំពីកិលេស មានលោភៈជាដើមនោះ នេះពួកធម៌ គួរលះដោយភាវនា ។ ពួកធម៌ មិនគួរលះដោយភាវនា តើដូចម្តេច ។ វៀរតែធម៌ទាំងនោះចេញ ពួកធម៌ដ៏សេសសល់ ជាកុសល អកុសល និងអព្យាក្រឹត ជាកាមាវចរ រូបាវចរ អរូបាវចរ អបរិយាបន្នៈ វេទនាខន្ធ ។ បេ ។ វិញ្ញាណក្ខន្ធ រូបទាំងអស់ និងអសង្ខតធាតុ នេះពួកធម៌មិនគួរលះដោយភាវនា ។

(៣១៦) ពួកធម៌មានហេតុគួរលះដោយទស្សនៈ តើដូចម្តេច ។ សញ្ញោជនៈ ៣ គឺ សក្កាយទិដ្ឋិ វិចិកិច្ឆា និងសីលព្វតបរាមាសៈ ។

(៣១៧) បណ្តាសញ្ញោជនៈទាំងនោះ សក្កាយទិដ្ឋិ តើដូចម្តេច ។ បុថុជ្ជនក្នុងលោកនេះ ជាអ្នកមិនចេះដឹង មិនបានឃើញពួកព្រះអរិយៈ មិនឈ្លាសវៃក្នុងអរិយធម៌ មិនបានទូន្មានខ្លួន ក្នុងអរិយធម៌ មិនបានឃើញពួកសប្បុរស មិនឈ្លាសវៃ ក្នុងសប្បុរិសធម៌ មិនបានទូន្មានខ្លួន ក្នុងសប្បុរិសធម៌ រមែងយល់ឃើញរូបថាជាខ្លួន ឃើញខ្លួនថាមានរូបខ្លះ

វា អត្តានំ អត្តនិ វា រូបំ រូបស្មឹ វា អត្តានំ វេទនំ ។ បេ ។ សញ្ញំ ។ បេ ។ សង្ខារេ ។ បេ ។ វិញ្ញាណំ អត្តតោ សមនុបស្សតិ វិញ្ញាណវន្តំ វា អត្តានំ អត្តនិ វា វិញ្ញាណំ វិញ្ញាណស្មឹ វា អត្តានំ យា ឯវរូបា ទិដ្ឋិ ទិដ្ឋិគតំ ។ បេ ។ វិបរិយេសគ្គាហោ អយំ វុច្ចតិ សក្កាយទិដ្ឋិ ។

(៣១៨) តត្ថ កតមា វិចិកិច្ឆា ។ សត្ថរិ កង្ខតិ វិចិកិច្ឆតិ ។ បេ ។ ឆម្ភិតត្តំ ចិត្តស្ស មនោវិលេខោ អយំ វុច្ចតិ វិចិកិច្ឆា ។

(៣១៩) តត្ថ កតមោ សីលព្វតបរាមាសោ ។ ឥតោ ពហិទ្ធា សមណព្រាហ្មណានំ សីលេន សុទ្ធិ វតេន សុទ្ធិ សីលព្វតេន សុទ្ធីតិ យា ឯវរូបា ទិដ្ឋិ ទិដ្ឋិគតំ ។ បេ ។ វិបរិយេសគ្គាហោ អយំ វុច្ចតិ សីលព្វតបរាមាសោ ។

(៣២០) ឥមានិ តីណិ សញ្ញោជនានិ តទេកដ្ឋា ច កិលេសា តំសម្បយុត្តោ វេទនាក្ខន្ធោ ។ បេ ។ វិញ្ញាណក្ខន្ធោ តំសមុដ្ឋានំ កាយកម្មំ វចីកម្មំ មនោកម្មំ ឥមេ ធម្មា ទស្សនេន បហាតព្វហេតុកា ។

ឃើញរូបថាមានក្នុងខន្ធខ្លះ ឃើញខន្ធថាមានក្នុងរូបខ្លះ (ឃើញ) វេទនា ។ បេ ។ សញ្ញា ។ បេ ។ សង្ខារ ។ បេ ។ ឃើញវិញ្ញាណថាជាខន្ធ ឃើញខន្ធថាមានវិញ្ញាណខ្លះ ឃើញវិញ្ញាណថាមានក្នុងខន្ធខ្លះ ឃើញខន្ធថាមានក្នុងវិញ្ញាណខ្លះ ទិដ្ឋិ ដំណើរគឺទិដ្ឋិ ។ បេ ។ ការប្រកាន់ក្នុងការស្ទង់រកខុស ណា ដែលមានសភាពបែបនេះ នេះហៅថា សក្កាយ-ទិដ្ឋិ ។

(៣១៨) បណ្ដាសញ្ញោជនៈទាំងនោះ វិចិកិច្ឆា តើដូចម្ដេច ។ បុគ្គលនឿងឆ្ងល់ សង្ស័យ ចំពោះព្រះសាស្ដា ។ បេ ។ ភាពនៃសេចក្ដីរឹងរូស ការរេសមរសាមនៃចិត្ត នេះហៅថា វិចិកិច្ឆា ។

(៣១៩) បណ្ដាសញ្ញោជនៈទាំងនោះ សីលព្វតបរាមាសៈ តើដូចម្ដេច ។ ពួកសមណព្រាហ្មណ៍ ខាងក្រៅអំពីសាសនានេះ (យល់ឃើញ) ថា សេចក្ដីបរិសុទ្ធិដោយសីល បរិសុទ្ធិដោយវ័ត បរិសុទ្ធិដោយសីលនិងវ័ត និងទិដ្ឋិ ដំណើរគឺទិដ្ឋិ ។ បេ ។ ការប្រកាន់ក្នុងការស្ទង់រកខុស ណា ដែលមានសភាពបែបនេះ នេះហៅថា សីលព្វតបរាមាសៈ ។

(៣២០) សញ្ញោជនៈ៣នេះ និងពួកកិលេសដែលតាំងនៅជាមួយនឹងសញ្ញោជនៈនោះ វេទនាខន្ធ ។ បេ ។ វិញ្ញាណក្ខន្ធ ដែលប្រកបដោយសញ្ញោជនៈនោះ កាយកម្ម វចីកម្ម មនោកម្ម ដែលតាំងឡើងអំពីសញ្ញោជនៈនោះ នេះពួកធម៌ មានហេតុគួរលះដោយទស្សនៈ ។

តីណិ សញ្ញោជនានិ សក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសោ ឥមេ ធម្មា ទស្សនេន បហាតព្វា(១) ៖ តទេកដ្ឋោ(២) លោភោ ទោសោ មោហោ ឥមេ ធម្មា ទស្សនេន បហាតព្វហេតូ(៣) ។ តទេកដ្ឋា ច កិលេសា តំសម្បយុត្តោ វេទនាខន្ធោ ។ បេ ។ វិញ្ញាណក្ខន្ធោ តំសមុដ្ឋានំ កាយកម្មំ វចីកម្មំ មនោកម្មំ ឥមេ ធម្មា ទស្សនេន បហាតព្វហេតុកា ។ កតមេ ធម្មា ន ទស្សនេន បហាតព្វហេតុកា ។ តេ ធម្មេ ឋបេត្វា អវសេសា កុសលាកុសលាព្យាកតា ធម្មា កាមាវចរា រូបាវចរា អរូបាវចរា អបរិយាបន្នា វេទនាខន្ធោ ។ បេ ។ វិញ្ញាណក្ខន្ធោ សព្វញ្ច រូបំ អសង្ខតា ច ធាតុ ឥមេ ធម្មា ន ទស្សនេន បហាតព្វហេតុកា ។

(៣២១) កតមេ ធម្មា ភាវនាយ បហាតព្វហេតុកា ។ អវសេសោ លោភោ ទោសោ មោហោ ឥមេ ធម្មា ភាវនាយ បហាតព្វហេតូ ។ តទេកដ្ឋា ច កិលេសា តំសម្បយុត្តោ វេទនាខន្ធោ ។ បេ ។ វិញ្ញាណក្ខន្ធោ តំសមុដ្ឋានំ កាយកម្មំ វចីកម្មំ

១. ឱ. បហាតព្វហេតុកា ។ ២ ឱ. ឯត្ថន្តរេ បសទ្ធោ អត្ថិ ។ ៣ ឱ. បហាតព្វហេតុកា ។

សញ្ញោជនៈ ៣ គឺ សក្កាយទិដ្ឋិ វិចិកិច្ឆា និងសីលព្វតបរាមាសៈ នេះពួកធម៌គួរលះដោយទស្សនៈ ។ លោភៈ ទោសៈ មោហៈ ដែលតាំងនៅជាមួយនឹងសញ្ញោជនៈនោះ នេះពួកធម៌ មានហេតុគួរលះដោយទស្សនៈ ។ ទាំងពួកកិលេសដែលតាំងនៅ ជាមួយនឹងកិលេសមានលោភៈជាដើមនោះ វេទនាខន្ធ ។ បេ ។ វិញ្ញាណក្ខន្ធ ដែលប្រកបដោយកិលេសមានលោភៈជាដើមនោះ កាយកម្ម វចីកម្ម មនោកម្ម ដែលតាំងឡើងអំពីកិលេសមានលោភៈជាដើមនោះ នេះពួកធម៌មានហេតុគួរលះដោយទស្សនៈ ។ ពួកធម៌មានហេតុមិនគួរលះដោយទស្សនៈ តើដូចម្តេច ។ វៀរតែធម៌ទាំងនោះចេញ ពួកធម៌ដ៏សេសសល់ ជាកុសល អកុសល និងអព្យាក្រឹត ជាកាមាវចរ រូបាវចរ អរូបាវចរ អបរិយាបន្នៈ វេទនាខន្ធ ។ បេ ។ វិញ្ញាណក្ខន្ធ រូបទាំងអស់ និងអសង្ខតធាតុ នេះពួកធម៌មានហេតុមិនគួរលះដោយទស្សនៈ ។

(៣៦១) ពួកធម៌មានហេតុគួរលះដោយភាវនា តើដូចម្តេច ។ លោភៈ ទោសៈ មោហៈ ដ៏សេសសល់ នេះពួកធម៌ មានហេតុគួរលះ ដោយភាវនា ។ ទាំងពួកកិលេស ដែលតាំងនៅជាមួយ នឹងកិលេសមានលោភៈជាដើមនោះ វេទនាខន្ធ ។ បេ ។ វិញ្ញាណក្ខន្ធ ដែលប្រកបដោយកិលេស មានលោភៈជាដើមនោះ កាយកម្ម វចីកម្ម

មនោកម្មំ ឥមេ ធម្មា ភាវនាយ បហាតព្វហេតុកា ។ កតមេ ធម្មា ន ភាវនាយ បហាតព្វហេតុកា ។ តេ ធម្មេ ឋបេត្វា អវសេសា កុសលាកុសលាព្យាកតា ធម្មា កាមាវចរា រូបាវចរា អរូបាវចរា អបរិយាបន្នា វេទនាក្ខន្ធោ ។ បេ ។ វិញ្ញាណក្ខន្ធោ សព្វញ្ច រូបំ អសង្ខតា ច ធាតុ ឥមេ ធម្មា ន ភាវនាយ បហាតព្វហេតុកា ។

(៣២២) កតមេ ធម្មា សវិតក្កា ។ សវិតក្កភូមិយំ កាមាវចរេ រូបាវចរេ អបរិយាបន្នេ វិតក្កំ ឋបេត្វា តំសម្បយុត្តោ វេទនាក្ខន្ធោ ។ បេ ។ វិញ្ញាណក្ខន្ធោ ឥមេ ធម្មា សវិតក្កា ។ កតមេ ធម្មា អវិតក្កា ។ អវិតក្កភូមិយំ កាមាវចរេ រូបាវចរេ អរូបាវចរេ អបរិយាបន្នេ វេទនាក្ខន្ធោ ។ បេ ។ វិញ្ញាណក្ខន្ធោ វិតក្កោ ច សព្វញ្ច រូបំ អសង្ខតា ច ធាតុ ឥមេ ធម្មា អវិតក្កា ។

(៣២៣) កតមេ ធម្មា សវិចារា ។ សវិចារភូមិយំ កាមាវចរេ រូបាវចរេ អបរិយាបន្នេ វិចារំ ឋបេត្វា តំសម្បយុត្តោ វេទនាក្ខន្ធោ ។ បេ ។ វិញ្ញាណក្ខន្ធោ

មនោកម្ម ដែលតាំងឡើងអំពីកិលេសមានលោភៈជាដើមនោះ នេះពួកធម៌ មានហេតុគួរលះដោយភាវនា ។ ពួកធម៌មានហេតុមិនគួរលះដោយភាវនា តើដូចម្ដេច ។ វៀរតែធម៌ទាំងនោះចេញ ពួកធម៌ដ៏សេសសល់ ជាកុសល អកុសល និងអព្យាក្រឹត ជាកាមាវចរ រូបាវចរ អរូបាវចរ អបរិយាបន្នៈ វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ រូបទាំងអស់ និងអសង្ខតធាតុ នេះពួកធម៌ មានហេតុមិនគួរលះដោយភាវនា ។

(៣២២) ពួកធម៌ប្រកបដោយវិតក្កៈ តើដូចម្ដេច ។ វៀរតែវិតក្កៈក្នុងសវិតក្កភូមិ ជាកាមាវចរ រូបាវចរ អបរិយាបន្នៈចេញ វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ ដែលប្រកបដោយវិតក្កៈនោះ នេះពួកធម៌ប្រកបដោយវិតក្កៈ ។ ពួកធម៌មិនមានវិតក្កៈ តើដូចម្ដេច ។ វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ ក្នុងអវិតក្កភូមិ ជាកាមាវចរ រូបាវចរ អរូបាវចរ អបរិយាបន្នៈ និងវិតក្កៈផង រូបទាំងអស់ផង អសង្ខតធាតុផង នេះពួកធម៌មិនមានវិតក្កៈ ។

(៣២៣) ពួកធម៌ ប្រកបដោយវិចារៈ (ការពិចារណា) តើដូចម្ដេច ។ វៀរតែវិចារៈ ក្នុងសវិចារភូមិ ជាកាមាវចរ រូបាវចរ អបរិយាបន្នៈចេញ វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ

## បិដ្ឋិទុកេ និក្ខេបោ

ឥមេ ធម្មា សវិចារា ។ កតមេ ធម្មា អវិចារា ។ អវិចារភូមិយំ កាមាវចរេ រូបាវចរេ អរូបាវចរេ អបរិយាបន្នេ វេទនាក្ខន្ធោ ។ បេ ។ វិញ្ញាណក្ខន្ធោ វិចារោ ច សព្ពញ្ច រូបំ អសង្ខតា ច ធាតុ ឥមេ ធម្មា អវិចារា ។

(៣៦៨) កតមេ ធម្មា សប្បីតិកា ។ សប្បីតិកភូមិយំ កាមាវចរេ រូបាវចរេ អបរិយាបន្នេ បីតិំ ឋបេត្វា តំសម្បយុត្តោ វេទនាក្ខន្ធោ ។ បេ ។ វិញ្ញាណក្ខន្ធោ ឥមេ ធម្មា សប្បីតិកា ។ កតមេ ធម្មា អប្បីតិកា ។ អប្បីតិកភូមិយំ កាមាវចរេ រូបាវចរេ អរូបាវចរេ អបរិយាបន្នេ វេទនាក្ខន្ធោ ។ បេ ។ វិញ្ញាណក្ខន្ធោ បីតិ ច សព្ពញ្ច រូបំ អសង្ខតា ច ធាតុ ឥមេ ធម្មា អប្បីតិកា ។

(៣៦៩) កតមេ ធម្មា បីតិសហគតា ។ បីតិភូមិយំ កាមាវចរេ រូបាវចរេ អបរិយាបន្នេ បីតិំ ឋបេត្វា តំសម្បយុត្តោ វេទនាក្ខន្ធោ ។ បេ ។ វិញ្ញាណក្ខន្ធោ ឥមេ ធម្មា បីតិសហគតា ។ កតមេ ធម្មា ន បីតិសហគតា ។ ន បីតិភូមិយំ កាមាវចរេ រូបាវចរេ អរូបាវចរេ អបរិយាបន្នេ វេទនាក្ខន្ធោ ។ បេ ។

ដែលប្រកបដោយវិចារៈនោះ នេះពួកធម៌ប្រកបដោយវិចារៈ ។ ពួកធម៌មិនមានវិចារៈ តើដូចម្តេច ។ វេទនាខន្ធ ។ បេ ។ វិញ្ញាណក្ខន្ធ កង់អវិចារភូមិ ជាកាមាវចរ រូបាវចរ អរូបាវចរ អបរិយាបន្នៈ និងវិចារៈផង រូបទាំងអស់ផង អសង្ខតធាតុផង នេះពួកធម៌មិនមានវិចារៈ ។

(៣២៤) ពួកធម៌ប្រព្រឹត្តទៅជាមួយនឹងបីតិ តើដូចម្តេច ។ វៀរតែបីតិ កង់សប្បីតិកភូមិ ជាកាមាវចរ រូបាវចរ អបរិយាបន្នៈចេញ វេទនាខន្ធ ។ បេ ។ វិញ្ញាណក្ខន្ធ ដែលប្រកបដោយបីតិនោះ នេះពួកធម៌ប្រព្រឹត្តទៅជាមួយនឹងបីតិ ។ ពួកធម៌មិនប្រព្រឹត្តទៅជាមួយនឹងបីតិ តើដូចម្តេច ។ វេទនាខន្ធ ។ បេ ។ វិញ្ញាណក្ខន្ធ កង់អប្បីតិកភូមិ ជាកាមាវចរ រូបាវចរ អរូបាវចរ អបរិយាបន្នៈ និងបីតិផង រូបទាំងអស់ផង អសង្ខតធាតុផង នេះពួកធម៌មិនប្រព្រឹត្តទៅជាមួយនឹងបីតិ ។

(៣២៥) ពួកធម៌ប្រកបដោយបីតិ តើដូចម្តេច ។ វៀរតែបីតិ កង់បីតិភូមិ ជាកាមាវចរ រូបាវចរ អរូបាវចរ អបរិយាបន្នៈចេញ វេទនាខន្ធ ។ បេ ។ វិញ្ញាណក្ខន្ធ ដែលប្រកបដោយបីតិនោះ នេះពួកធម៌ប្រកបដោយបីតិ ។ ពួកធម៌មិនប្រកបដោយបីតិ តើដូចម្តេច ។ វេទនាខន្ធ

វិញ្ញាណក្ខន្ធោ បីតិ ច សព្ទញ្ច រូបំ អសង្ខតា ច ធាតុ ឥមេ ធម្មា ន បីតិសហគតា ។

(៣២៦) កតមេ ធម្មា សុខសហគតា ។ សុខភូមិយំ កាមាវចរេ រូបាវចរេ អបរិយាបន្នេ សុខំ ឋបេត្វា តំសម្បយុត្តោ សញ្ញាខន្ធោ សង្ខារក្ខន្ធោ វិញ្ញាណក្ខន្ធោ ឥមេ ធម្មា សុខសហគតា ។ កតមេ ធម្មា ន សុខសហគតា ។ ន សុខភូមិយំ កាមាវចរេ រូបាវចរេ អរូបាវចរេ អបរិយាបន្នេ វេទនាខន្ធោ ។ បេ ។ វិញ្ញាណក្ខន្ធោ សុខញ្ច សព្ទញ្ច រូបំ អសង្ខតា ច ធាតុ ឥមេ ធម្មា ន សុខសហគតា ។

(៣២៧) កតមេ ធម្មា ឧបេក្ខាសហគតា ។ ឧបេក្ខាភូមិយំ កាមាវចរេ រូបាវចរេ អរូបាវចរេ អបរិយាបន្នេ ឧបេក្ខំ ឋបេត្វា តំសម្បយុត្តោ សញ្ញាខន្ធោ សង្ខារក្ខន្ធោ វិញ្ញាណក្ខន្ធោ ឥមេ ធម្មា ឧបេក្ខាសហគតា ។ កតមេ ធម្មា ន ឧបេក្ខាសហគតា ។ ន ឧបេក្ខាភូមិយំ កាមាវចរេ រូបាវចរេ អរូបាវចរេ អបរិយាបន្នេ វេទនាខន្ធោ ។ បេ ។ វិញ្ញាណក្ខន្ធោ ឧបេក្ខា ច សព្ទញ្ច រូបំ អសង្ខតា ច ធាតុ ឥមេ ធម្មា ន ឧបេក្ខាសហគតា ។

។ បេ ។ វិញ្ញាណក្ខន្ធ ក្ដីទីមិនមែនជាបីតិភូមិ ជាកាមាវចរ រូបាវចរ អរូបាវចរ អបរិយាបន្នៈ និងបីតិផង រូបទាំងអស់ផង អសង្ខតធាតុផង នេះពួកធម៌ មិនប្រកបដោយបីតិ ។

(៣២៦) ពួកធម៌ប្រកបដោយសុខៈ តើដូចម្ដេច ។ វៀរតែសុខៈ ក្ដីសុខភូមិ ជាកាមាវចរ រូបាវចរ អបរិយាបន្នៈចេញ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ ប្រកបដោយសុខៈនោះ នេះពួកធម៌ប្រកបដោយសុខៈ ។ ពួកធម៌មិនប្រកបដោយសុខៈ តើដូចម្ដេច ។ វេទនាខន្ធ ។ បេ ។ វិញ្ញាណក្ខន្ធ ក្ដីទីមិនមែនជាសុខភូមិ ជាកាមាវចរ រូបាវចរ អរូបាវចរ អបរិយាបន្នៈ និងសុខៈផង រូបទាំងអស់ផង អសង្ខតធាតុផង នេះពួកធម៌ មិនប្រកបដោយសុខៈ ។

(៣២៧) ពួកធម៌ប្រកបដោយឧបេក្ខា តើដូចម្ដេច ។ វៀរតែឧបេក្ខាក្ដីឧបេក្ខាភូមិ ជាកាមាវចរ រូបាវចរ អរូបាវចរ អបរិយាបន្នៈចេញ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ ដែលប្រកបដោយឧបេក្ខានោះ នេះពួកធម៌ប្រកបដោយឧបេក្ខា ។ ពួកធម៌មិនប្រកបដោយឧបេក្ខា តើដូចម្ដេច ។ វេទនាខន្ធ ។ បេ ។ វិញ្ញាណក្ខន្ធ ក្ដីទីមិនមែនជាឧបេក្ខាភូមិ ជាកាមាវចរ រូបាវចរ អរូបាវចរ អបរិយាបន្នៈ និងឧបេក្ខាផង រូបទាំងអស់ផង អសង្ខតធាតុផង នេះពួកធម៌មិនប្រកបដោយឧបេក្ខា ។

## បិដ្ឋិទុកេ និក្ខេបោ

(៣២៨) កតមេ ធម្មា កាមាវចរា ។ ហេដ្ឋតោ អវីចិនិរយំ បរិយន្តំ ករិត្វា ឧបរិតោ បរនិម្មិតវសវត្តី ទេវេ អន្តោ ករិត្វា យំ ឯតស្មឹ អន្តរេ ឯត្ថាវចរា ឯត្ថ បរិយាបន្នា ខន្ធធាតុអាយតនា រូបា វេទនា សញ្ញា សង្ខារា វិញ្ញាណំ ឥមេ ធម្មា កាមាវចរា ។ កតមេ ធម្មា ន កាមាវចរា ។ រូបាវចរា អរូបាវចរា អបរិយាបន្នា ឥមេ ធម្មា ន កាមាវចរា ។

(៣២៩) កតមេ ធម្មា រូបាវចរា ។ ហេដ្ឋតោ ព្រហ្មលោកំ បរិយន្តំ ករិត្វា ឧបរិតោ អកនិដ្ឋេ ទេវេ អន្តោ ករិត្វា យំ ឯតស្មឹ អន្តរេ ឯត្ថាវចរា ឯត្ថ បរិយាបន្នា សមាបន្នស្ស វា ឧបបន្នស្ស វា ទិដ្ឋធម្មសុខវិហារិស្ស វា ចិត្តចេតសិកា ធម្មា ឥមេ ធម្មា រូបាវចរា ។ កតមេ ធម្មា ន រូបាវចរា ។ កាមាវចរា អរូបាវចរា អបរិយាបន្នា ឥមេ ធម្មា ន រូបាវចរា ។

(៣៣០) កតមេ ធម្មា អរូបាវចរា ។ ហេដ្ឋតោ អាកាសានញ្ចាយតនូបគេ ទេវេ បរិយន្តំ ករិត្វា ឧបរិតោ នេវសញ្ញានាសញ្ញាយតនូបគេ ទេវេ អន្តោ

បដ្ឋិទុកនិក្ខេប

(៣២៨) ពួកធម៌ជាកាមាវចរ តើដូចម្តេច ។ ខាងក្រោម កំណត់យកអវិចិនរកជាទីបំផុត ខាងលើ កំណត់យកបរនិម្មិតវសវត្តីទេវលោកជាទីបំផុត ទីណា ដែលមានកន្លងចនោះនេះ ខន្ធ ធាតុ អាយតនៈ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ដែលត្រាច់ចុះក្នុងទីនុ៎ះ រាប់បញ្ចូលក្នុងទីនុ៎ះ នេះពួកធម៌ជាកាមាវចរ ។ ពួកធម៌មិនមែនជាកាមាវចរ តើដូចម្តេច ។ រូបាវចរ អរូបាវចរ អបរិយាបន្នៈ នេះពួកធម៌មិនមែនជាកាមាវចរ ។

(៣២៩) ពួកធម៌ជារូបាវចរ តើដូចម្តេច ។ ខាងក្រោម កំណត់យកព្រហ្មលោកជាទីបំផុត ខាងលើ កំណត់យកអកនិដ្ឋទេវលោកជាទីបំផុត ទីណាដែលមានកន្លងចនោះនេះ ធម៌គឺចិត្តនិងចេតសិក ដែលត្រាច់ចុះក្នុងទីនុ៎ះ រាប់បញ្ចូលក្នុងទីនុ៎ះ នៃបុគ្គលអ្នកចូល (កាន់សមាបត្តិ) ឬបុគ្គលដែលកើតហើយ ឬក៏បុគ្គលអ្នកនៅជាសុខក្នុងបច្ចុប្បន្ន នេះពួកធម៌ជារូបាវចរ ។ ពួកធម៌មិនមែនជារូបាវចរ តើដូចម្តេច ។ កាមាវចរ អរូបាវចរ អបរិយាបន្នៈ នេះពួកធម៌មិនមែនជារូបាវចរ ។

(៣៣០) ពួកធម៌ ជាអរូបាវចរ តើដូចម្តេច ។ ខាងក្រោម កំណត់យកពួកទេវតា ដែលកើតក្នុងអាកាសានញ្ចាយតនភព ជាទីបំផុត ខាងលើ កំណត់យកទេវតា ដែលកើតក្នុងនេវសញ្ញានាសញ្ញាយតនភព

ករិត្វា យំ ឯតស្មឹ អន្តរេ ឯត្ថាវចរា ឯត្ថ បរិយាបន្នា សមាបន្នស្ស វា ឧបបន្នស្ស វា ទិដ្ឋធម្មសុខវិហារិស្ស វា ចិត្តចេតសិកា ធម្មា ឥមេ ធម្មា អរូបាវចរា ។ កតមេ ធម្មា ន អរូបាវចរា ។ កាមាវចរា រូបាវចរា អបរិយាបន្នា ឥមេ ធម្មា ន អរូបាវចរា ។

(៣៣១) កតមេ ធម្មា បរិយាបន្នា ។ សាសវា កុសលាកុសលាព្យាកតា ធម្មា កាមាវចរា រូបាវចរា អរូបាវចរា រូបក្ខន្ធោ ។ បេ ។ វិញ្ញាណក្ខន្ធោ ឥមេ ធម្មា បរិយាបន្នា ។ កតមេ ធម្មា អបរិយាបន្នា ។ មគ្គា ច មគ្គផលានិ ច អសង្ខតា ច ធាតុ ឥមេ ធម្មា អបរិយាបន្នា ។

(៣៣២) កតមេ ធម្មា និយ្យានិកា ។ ចត្តារោ មគ្គា អបរិយាបន្នា ឥមេ ធម្មា និយ្យានិកា ។ កតមេ ធម្មា អនិយ្យានិកា ។ តេ ធម្មេ ឋបេត្វា អវសេសា កុសលាកុសលាព្យាកតា ធម្មា កាមាវចរា រូបាវចរា អរូបាវចរា អបរិយាបន្នា វេទនាក្ខន្ធោ ។ បេ ។ វិញ្ញាណក្ខន្ធោ សព្វញ្ច រូបំ អសង្ខតា ច ធាតុ ឥមេ ធម្មា អនិយ្យានិកា ។

ជាទីបំផុត ទីណា ដែលមានក្នុងចន្លោះនេះ ធម៌គឺចិត្តនិងចេតសិក ត្រាប់ចុះក្នុងទីនុ៎ះ រាប់បញ្ចូលក្នុងទីនុ៎ះ នៃបុគ្គលអ្នកចូល (កាន់សមាបត្តិ) ឬបុគ្គលដែលទៅកើតហើយ ឬក៏បុគ្គលអ្នកនៅជាសុខ ក្នុងបច្ចុប្បន្ន នេះពួកធម៌ជាអរូបាវចរ ។ ពួកធម៌មិនមែនជាអរូបាវចរ តើដូចម្តេច ។ កាមាវចរ រូបាវចរ អបរិយាបន្នៈ នេះពួកធម៌មិនមែនជាអរូបាវចរ ។

(៣៣១) ពួកធម៌ជាបរិយាបន្នៈ តើដូចម្តេច ។ ពួកធម៌ប្រកបដោយអាសវៈ ជាកុសល អកុសល និងអព្យាក្រឹត ជាកាមាវចរ រូបាវចរ អរូបាវចរ និងរូបក្ខន្ធ ។ បេ ។ វិញ្ញាណក្ខន្ធ នេះពួកធម៌ជាអបរិយាបន្នៈ ។ ពួកធម៌ជាអបរិយាបន្នៈ តើដូចម្តេច ។ មគ្គផង ផលនៃមគ្គផង អសង្ខតធាតុផង នេះពួកធម៌ជាអបរិយាបន្នៈ ។

(៣៣២) ពួកធម៌ជានិយ្យានិកៈ (ធម៌នាំសត្វឲ្យរួចចាកវដ្តៈ) តើដូចម្តេច ។ មគ្គ ៤ ជាអបរិយាបន្នៈ នេះពួកធម៌ជានិយ្យានិកៈ ។ ពួកធម៌ជាអនិយ្យានិកៈ តើដូចម្តេច ។ វៀរតែធម៌ទាំងនោះចេញ ពួកធម៌ដ៏សេសសល់ ជាកុសល អកុសល និងអព្យាក្រឹត ជាកាមាវចរ រូបាវចរ អរូបាវចរ អបរិយាបន្នៈ វេទនាខន្ធ ។ បេ ។ វិញ្ញាណក្ខន្ធ រូបទាំងអស់ និងអសង្ខតធាតុ នេះពួកធម៌ជាអនិយ្យានិកៈ ។

(៣៣៣) កតមេ ធម្មា និយតា ។ បញ្ច កម្មានិ អានន្តរិកានិ យា ច មិច្ឆាទិដ្ឋិ និយតា ចត្តារោ មគ្គា អបរិយាបន្នា ឥមេ ធម្មា និយតា ។ កតមេ ធម្មា អនិយតា ។ តេ ធម្មេ ឋបេត្វា អវសេសា កុសលាកុសលាព្យាកតា ធម្មា កាមាវចរា រូបាវចរា អរូបាវចរា អបរិយាបន្នា វេទនាក្ខន្ធោ ។ បេ ។ វិញ្ញាណក្ខន្ធោ សព្វញ្ច រូបំ អសង្ខតា ច ធាតុ ឥមេ ធម្មា អនិយតា ។

(៣៣៤) កតមេ ធម្មា សឧត្តរា ។ សាសវា កុសលាកុសលាព្យាកតា ធម្មា កាមាវចរា រូបាវចរា អរូបាវចរា រូបក្ខន្ធោ ។ បេ ។ វិញ្ញាណក្ខន្ធោ ឥមេ ធម្មា សឧត្តរា ។ កតមេ ធម្មា អនុត្តរា ។ អបរិយាបន្នា មគ្គា ច មគ្គផលានិ ច អសង្ខតា ច ធាតុ ឥមេ ធម្មា អនុត្តរា ។

(៣៣៥) កតមេ ធម្មា សរណា ។ តីណិ អកុសលមូលានិ លោភោ ទោសោ មោហោ តទេកដ្ឋា ច កិលេសា តំសម្បយុត្តោ វេទនាក្ខន្ធោ ។ បេ ។ វិញ្ញាណក្ខន្ធោ តំសមុដ្ឋានំ កាយកម្មំ

(៣៣៣) ពួកធម៌ជានិយតៈ (ទៀង) តើដូចម្ដេច ។ អានន្តរិកកម្ម ៥ និយតមិច្ឆាទិដ្ឋិ និងមគ្គ ៤ ជាអបរិយាបន្នៈ នេះពួកធម៌ជានិយតៈ ។ ពួកធម៌ជាអនិយតៈ តើដូចម្ដេច ។ វៀរលែងធម៌ទាំងនោះចេញ ពួកធម៌ដ៏សេសសល់ ជាកុសល អកុសល និងអព្យាក្រឹត ជាកាមាវចរ រូបាវចរ អរូបាវចរ អបរិយាបន្នៈ វេទនាខន្ធ ។ បេ ។ វិញ្ញាណក្ខន្ធ រូបទាំងអស់ និងអសង្ខតធាតុ នេះពួកធម៌ជាអនិយតៈ ។

(៣៣៤) ពួកធម៌ប្រកបដោយឧត្តរ (ការលើឡើងនូវខ្លួន) តើដូចម្ដេច ។ ពួកធម៌ប្រកបដោយអាសវៈ ជាកុសល អកុសល និងអព្យាក្រឹត ជាកាមាវចរ រូបាវចរ អរូបាវចរ និងរូបក្ខន្ធ ។ បេ ។ វិញ្ញាណក្ខន្ធ នេះពួកធម៌ប្រកបដោយឧត្តរៈ ។ ពួកធម៌មិនមែនជាឧត្តរៈ តើដូចម្ដេច ។ មគ្គជាអបរិយាបន្នៈផង ផលនៃមគ្គផង អសង្ខតធាតុផង នេះពួកធម៌មិនមែនជាឧត្តរៈ ។

(៣៣៥) ពួកធម៌ប្រកបដោយរណៈ (សឹកសត្រូវ) តើដូចម្ដេច ។ អកុសលមូល ៣ គឺ លោភៈ ទោសៈ និងមោហៈ ទាំងពួកកិលេស ដែលតាំងនៅជាមួយនឹងអកុសលមូលនោះ វេទនាខន្ធ ។ បេ ។ វិញ្ញាណក្ខន្ធ ប្រកបដោយអកុសលមូលនោះ កាយកម្ម

វចីកម្មំ មនោកម្មំ ឥមេ ធម្មា សរណា ។ កតមេ ធម្មា អរណា ។ កុសលាព្យាកតា ធម្មា កាមាវចរា រូបាវចរា អរូបាវចរា អបរិយាបន្នា វេទនាក្ខន្ធោ ។ បេ ។ វិញ្ញាណក្ខន្ធោ សព្វញ្ច រូបំ អសង្ខតា ច ធាតុ ឥមេ ធម្មា អរណា ។

(៣៣៦) កតមេ ធម្មា វិជ្ជាភាគិនោ ។ វិជ្ជាយ សម្បយុត្តកា ធម្មា ឥមេ ធម្មា វិជ្ជាភាគិនោ ។ កតមេ ធម្មា អវិជ្ជាភាគិនោ ។ អវិជ្ជាយ សម្បយុត្តកា ធម្មា ឥមេ ធម្មា អវិជ្ជាភាគិនោ ។

(៣៣៧) កតមេ ធម្មា វិជ្ជូបមា ។ ហេដ្ឋិមេសុ តីសុ អរិយមគ្គេសុ បញ្ញា ឥមេ ធម្មា វិជ្ជូបមា ។ កតមេ ធម្មា វជិរូបមា ។ ឧបរិដ្ឋិមេ អរហត្តមគ្គេ បញ្ញា ឥមេ ធម្មា វជិរូបមា ។

(៣៣៨) កតមេ ធម្មា ពាលា ។ អហិរិកញ្ច អនោត្តប្បញ្ច ឥមេ ធម្មា ពាលា សព្វេបិ អកុសលា ធម្មា ពាលា ។ កតមេ ធម្មា បណ្ឌិតា ។ ហិរី ច ឱត្តប្បញ្ច ឥមេ ធម្មា បណ្ឌិតា សព្វេបិ កុសលា ធម្មា បណ្ឌិតា ។

វចីកម្ម មនោកម្ម ដែលតាំងឡើងអំពីអកុសលមូលនោះ នេះពួកធម៌ប្រកបដោយរណៈ ។ ពួកធម៌មិនមែនជារណៈ (មិនជាសឹកសត្រូវ) តើដូចម្ដេច ។ ពួកធម៌ជាកុសល និងអព្យាក្រឹត ជាកាមាវចរ រូបាវចរ អរូបាវចរ អបរិយាបន្នៈ វេទនាខន្ធ ។ បេ ។ វិញ្ញាណក្ខន្ធ រូបទាំងអស់ និងអសង្ខតធាតុ នេះពួកធម៌មិនមែនជារណៈ ។

(៣៣៦) ពួកធម៌ប្រព្រឹត្តទៅក្នុងចំណែកនៃវិជ្ជា តើដូចម្ដេច ។ ពួកធម៌ប្រកបដោយវិជ្ជា នេះពួកធម៌ប្រព្រឹត្តទៅ ក្នុងចំណែកនៃវិជ្ជា ។ ពួកធម៌ប្រព្រឹត្តទៅ ក្នុងចំណែកនៃអវិជ្ជា តើដូចម្ដេច ។ ពួកធម៌ប្រកបដោយអវិជ្ជា នេះពួកធម៌ប្រព្រឹត្តទៅ ក្នុងចំណែកនៃអវិជ្ជា ។

(៣៣៧) ពួកធម៌ប្រៀបដូចផ្លេកបន្ទោរ តើដូចម្ដេច ។ បញ្ញាក្នុងអរិយមគ្គ ៣ ខាងក្រោម នេះពួកធម៌ប្រៀបប្រដូចផ្លេកបន្ទោរ ។ ពួកធម៌ប្រៀបដូចពេជ្រ តើដូចម្ដេច ។ បញ្ញាក្នុងអរហត្តមគ្គខាងលើ នេះពួកធម៌ប្រៀបដូចពេជ្រ ។

(៣៣៨) ពួកធម៌ពាល តើដូចម្ដេច ។ អហិរិកៈនិងអនោត្តប្បៈ នេះពួកធម៌ពាល សូម្បីអកុសលធម៌ទាំងអស់ ក៏ជាពួកធម៌ពាលដែរ ។ ពួកធម៌បណ្ឌិត តើដូចម្ដេច ។ ហិរិនិងឱត្តប្បៈ នេះពួកធម៌បណ្ឌិត សូម្បីកុសលធម៌ទាំងអស់ ក៏ជាពួកធម៌បណ្ឌិតដែរ ។

(៣៣៩) កតមេ ធម្មា កណ្ហា ។ អហិរិកញ្ច អនោត្តប្បញ្ច ឥមេ ធម្មា កណ្ហា សព្វេបិ អកុសលា ធម្មា កណ្ហា ។ កតមេ ធម្មា សុក្កា ។ ហិរិ ច ឱត្តប្បញ្ច ឥមេ ធម្មា សុក្កា សព្វេបិ កុសលា ធម្មា សុក្កា ។

(៣៤០) កតមេ ធម្មា តបនិយា ។ កាយទុច្ចរិតំ វចីទុច្ចរិតំ មនោទុច្ចរិតំ ឥមេ ធម្មា តបនិយា សព្វេបិ អកុសលា ធម្មា តបនិយា ។ កតមេ ធម្មា អតបនិយា ។ កាយសុចរិតំ វចីសុចរិតំ មនោសុចរិតំ ឥមេ ធម្មា អតបនិយា សព្វេបិ កុសលា ធម្មា អតបនិយា ។

(៣៤១) កតមេ ធម្មា អធិវចនា ។ យា តេសំ តេសំ ធម្មានំ សង្ខា សមញ្ញា បញ្ញត្តិ វោហារោ នាមំ នាមកម្មំ នាមធេយ្យំ និរុត្តិ ព្យញ្ជនំ អភិលាបោ ឥមេ ធម្មា អធិវចនា ។ សព្វេវ ធម្មា អធិវចនបថា ។

(៣៤២) កតមេ ធម្មា និរុត្តិ ។ យា តេសំ តេសំ ធម្មានំ សង្ខា សមញ្ញា បញ្ញត្តិ វោហារោ នាមំ នាមកម្មំ នាមធេយ្យំ និរុត្តិ ព្យញ្ជនំ អភិលាបោ ឥមេ ធម្មា និរុត្តិ ។ សព្វេវ ធម្មា និរុត្តិបថា ។

បិដ្ឋិទុកនិប្ទេប

( ៣៣៩ ) ពួកធម៌ខ្មៅ តើដូចម្ដេច ។ អហិរិកៈ និងអនោត្តប្បៈ នេះពួកធម៌ខ្មៅ សូម្បីអកុសលធម៌ទាំងអស់ ក៏ជាពួកធម៌ខ្មៅដែរ ។ ពួកធម៌ស តើដូចម្ដេច ។ ហិរិ និង ឱត្តប្បៈ នេះពួកធម៌ស សូម្បីកុសលធម៌ទាំងអស់ ក៏ជាពួកធម៌សដែរ ។

( ៣៤០ ) ពួកធម៌ដុតកំដៅ តើដូចម្ដេច ។ កាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត នេះពួកធម៌ដុតកំដៅ សូម្បីអកុសលធម៌ទាំងអស់ ក៏ជាពួកធម៌ដុតកំដៅដែរ ។ ពួកធម៌មិនដុតកំដៅ តើដូចម្ដេច ។ កាយសុចរិត វចីសុចរិត មនោសុចរិត នេះពួកធម៌មិនដុតកំដៅ សូម្បីកុសលធម៌ទាំងអស់ ក៏ជាពួកធម៌មិនដុតកំដៅដែរ ។

( ៣៤១ ) ពួកធម៌ជាអធិវចនៈ (ឈ្មោះ) តើដូចម្ដេច ។ ការរាប់ ការដឹងដោយប្រពៃ ការតាំងទុក ការនិយាយ ឈ្មោះ ការធ្វើនូវឈ្មោះ ការតែកល់ទុកនូវឈ្មោះ លំនាំពាក្យពោល ព្យញ្ជនៈ ការនិយាយចំឈ្មោះ ណា នៃពួកធម៌នោះ ៗ នេះពួកធម៌ជាអធិវចនៈ ។ ឯពួកធម៌ទាំងអស់ ក៏ជាគន្លងនៃអធិវចនៈដែរ ។

(៣៤២) ពួកធម៌ជានិរុត្តិ (ពាក្យពោល) តើដូចម្ដេច ។ ការរាប់ ការដឹងដោយប្រពៃ ការតាំងទុក ការនិយាយ ឈ្មោះ ការធ្វើនូវឈ្មោះ ការតែកល់ទុកនូវឈ្មោះ លំនាំពាក្យពោល ព្យញ្ជនៈ ការនិយាយចំឈ្មោះ ណា នៃពួកធម៌នោះ ៗ នេះពួកធម៌ជានិរុត្តិ ។ ឯពួកធម៌ទាំងអស់ ក៏ជាគន្លងនៃនិរុត្តិដែរ ។

(៣៤៣) កតមេ ធម្មា បញ្ញត្តិ ។ យា តេសំ តេសំ ធម្មានំ សង្ខា សមញ្ញា បញ្ញត្តិ វោហារោ នាមំ នាមកម្មំ នាមធេយ្យំ និរុត្តិ ព្យញ្ជនំ អភិលាបោ ឥមេ ធម្មា បញ្ញត្តិ ។ សព្វេវ ធម្មា បញ្ញត្តិបថា ។

(៣៤៤) តត្ថ កតមំ នាមំ ។ វេទនាខន្ធោ សញ្ញាខន្ធោ សង្ខារក្ខន្ធោ វិញ្ញាណក្ខន្ធោ អសង្ខតា ច ធាតុ ឥទំ វុច្ចតិ នាមំ ។ តត្ថ កតមំ រូបំ ។ ចត្តារោ ច មហាភូតា ចតុន្នញ្ច មហាភូតានំ ឧបាទាយ រូបំ ឥទំ វុច្ចតិ រូបំ ។

(៣៤៥) តត្ថ កតមា អវិជ្ជា ។ យំ អញ្ញាណំ អទស្សនំ ។ បេ ។ អវិជ្ជាលង្គី មោហោ អកុសលមូលំ អយំ វុច្ចតិ អវិជ្ជា ។ តត្ថ កតមា ភវតណ្ហា ។ យោ ភវេសុ ភវច្ឆន្ទោ ។ បេ ។ ភវជ្ឈោសានំ អយំ វុច្ចតិ ភវតណ្ហា ។

(៣៤៦) តត្ថ កតមា ភវទិដ្ឋិ ។ ភវិស្សតិ អត្តា ច លោកោ ចាតិ យា ឯវរូបា ទិដ្ឋិ ទិដ្ឋិគតំ ។ បេ ។ វិបរិយេសគ្គាហោ អយំ វុច្ចតិ ភវទិដ្ឋិ ។

(៣៤៣) ពួកធម៌ជាបញ្ញត្តិ តើដូចម្តេច ។ ការរាប់ ការដឹងដោយប្រពៃ ការតាំងទុក ការនិយាយ ឈ្មោះ ការធ្វើនូវឈ្មោះ ការតំកល់ទុកនូវឈ្មោះ សំនាំពាក្យពោល ព្យញ្ជនៈ ការនិយាយចំឈ្មោះ ណា នៃពួកធម៌នោះ ៗ នេះពួកធម៌ជាបញ្ញត្តិ ។ ពួកធម៌ទាំងអស់ ក៏ជាគន្លងនៃបញ្ញត្តិដែរ ។

(៣៤៤) បណ្តាធម៌ទាំងនោះ នាម តើដូចម្តេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ និងអសង្ខតធាតុ នេះហៅថា នាម ។ បណ្តាធម៌ទាំងនោះ រូប តើដូចម្តេច ។ មហាភូតរូប ៤ និងរូបដែលអាស្រ័យមហាភូតរូបទាំង ៤ នេះហៅថា រូប ។

(៣៤៥) បណ្តាធម៌ទាំងនោះ អវិជ្ជា តើដូចម្តេច ។ ការមិនដឹង ការមិនឃើញ ។ បេ ។ គន្លឹះគឺអវិជ្ជា សេចក្តីវង្វេង ជាអកុសលមូល ណា នេះហៅថា អវិជ្ជា ។ បណ្តាធម៌ទាំងនោះ ភវតណ្ហា តើដូចម្តេច ។ ការប្រាថ្នាក្នុងភព ។ បេ ។ ការចុះចិត្តស៊ប់ក្នុងភព ចំពោះភពទាំងឡាយ ណា នេះហៅថា ភវតណ្ហា ។

(៣៤៦) បណ្តាធម៌ទាំងនោះ ភវទិដ្ឋិ (ការយល់ឃើញថាសត្វកើតទៀត) តើដូចម្តេច ។ (សេចក្តីយល់) ថា ខ្លួនក្តី លោកក្តីនឹងកើតមាន និងទិដ្ឋិ ដំណើរគឺទិដ្ឋិ ។ បេ ។ សេចក្តីប្រកាន់ ក្នុងការស្វែងរកខុស ណា ដែលមានសភាពបែបនេះ នេះហៅថា ភវទិដ្ឋិ ។

តត្ថ កតមា វិភវទិដ្ឋិ ។ ន ភវិស្សតិ អត្តា ច លោកោ ចាតិ យា ឯវរូបា ទិដ្ឋិ ទិដ្ឋិគតំ ។បេ។ វិបរិយេសគ្គាហោ អយំ វុច្ចតិ វិភវទិដ្ឋិ ។

(៣៤៧) តត្ថ កតមា សស្សតទិដ្ឋិ ។ សស្សតោ អត្តា ច លោកោ ចាតិ យា ឯវរូបា ទិដ្ឋិ ទិដ្ឋិគតំ ។បេ។ វិបរិយេសគ្គាហោ អយំ វុច្ចតិ សស្សតទិដ្ឋិ ។ តត្ថ កតមា ឧច្ឆេទទិដ្ឋិ ។ ឧច្ឆិជ្ជិស្សតិ អត្តា ច លោកោ ចាតិ យា ឯវរូបា ទិដ្ឋិ ទិដ្ឋិគតំ ។បេ។ វិបរិយេសគ្គាហោ អយំ វុច្ចតិ ឧច្ឆេទទិដ្ឋិ ។

(៣៤៨) តត្ថ កតមា អន្តវាទិដ្ឋិ ។ អន្តវា អត្តា ច លោកោ ចាតិ យា ឯវរូបា ទិដ្ឋិ ទិដ្ឋិគតំ ។បេ។ វិបរិយេសគ្គាហោ អយំ វុច្ចតិ អន្តវាទិដ្ឋិ ។ តត្ថ កតមា អនន្តវាទិដ្ឋិ ។

បណ្ដាធម៌ទាំងនោះ វិភវទិដ្ឋិ (សេចក្ដីយល់ឃើញថាសត្វមិនកើតទៀត) តើដូចម្ដេច ។ (សេចក្ដីយល់) ថា ខ្លួនក្ដី លោកក្ដី នឹងមិនកើតមាន និងទិដ្ឋិ ដំណើរគឺទិដ្ឋិ ។ បេ ។ សេចក្ដីប្រកាន់ ត្រូវការស្វែងរកខុស ណា ដែលមានសភាពបែបនេះ នេះហៅថា វិភវទិដ្ឋិ ។

(៣៤៧) បណ្ដាធម៌ទាំងនោះ សស្សតទិដ្ឋិ (សេចក្ដីយល់ថា ខ្លួននិងលោកទៀង) តើដូចម្ដេច ។ (សេចក្ដីយល់) ថា ខ្លួនក្ដី លោកក្ដី ទៀងទាត់ និងទិដ្ឋិ ដំណើរគឺទិដ្ឋិ ។ បេ ។ សេចក្ដីប្រកាន់ ត្រូវការស្វែងរកខុស ណា ដែលមានសភាពបែបនេះ នេះហៅថា សស្សតទិដ្ឋិ ។ បណ្ដាធម៌ទាំងនោះ ឧច្ឆេទទិដ្ឋិ (សេចក្ដីយល់ថាសត្វ សូន្យ មិនកើតទៀត) តើដូចម្ដេច ។ (សេចក្ដីយល់) ថា ខ្លួនក្ដី លោកក្ដី ដាច់សូន្យ និងទិដ្ឋិ ដំណើរគឺទិដ្ឋិ ។ បេ ។ សេចក្ដីប្រកាន់ត្រូវការស្វែងរកខុស ណា ដែលមានសភាពបែបនេះ នេះហៅថា ឧច្ឆេទទិដ្ឋិ ។

(៣៤៨) បណ្ដាធម៌ទាំងនោះ អន្តវាទិដ្ឋិ (សេចក្ដីយល់ថា លោកមានទីបំផុត) តើដូចម្ដេច ។ (សេចក្ដីយល់) ថា ខ្លួនក្ដី លោកក្ដី មានទីបំផុត និងទិដ្ឋិ ដំណើរគឺទិដ្ឋិ ។ បេ ។ សេចក្ដីប្រកាន់ ត្រូវការស្វែងរកខុស ណា ដែលមានសភាពបែបនេះ នេះហៅថា អន្តវាទិដ្ឋិ ។ បណ្ដាធម៌ទាំងនោះ អនន្តវាទិដ្ឋិ តើដូចម្ដេច ។

អនន្តវា អត្តា ច លោកោ ចាតិ យា ឯវរូបា ទិដ្ឋិ ទិដ្ឋិគតំ ។ បេ ។ វិបរិយេសគ្គាហោ អយំ វុច្ចតិ អន្តគ្គាហិកាទិដ្ឋិ ។

(៣៨៩) តត្ថ កតមា បុព្វន្តានុទិដ្ឋិ ។ បុព្វន្តំ អារព្ភ យា ឧប្បជ្ជតិ ទិដ្ឋិ ទិដ្ឋិគតំ ។ បេ ។ វិបរិយេសគ្គាហោ អយំ វុច្ចតិ បុព្វន្តានុទិដ្ឋិ ។ តត្ថ កតមា អបរន្តានុទិដ្ឋិ ។ អបរន្តំ អារព្ភ យា ឧប្បជ្ជតិ ទិដ្ឋិ ទិដ្ឋិគតំ ។ បេ ។ វិបរិយេសគ្គាហោ អយំ វុច្ចតិ អបរន្តានុទិដ្ឋិ ។

(៣៩០) តត្ថ កតមំ អហិរិកំ ។ យំ ន ហិរីយតិ ហិរិយិតព្វេន ន ហិរីយតិ បាបកានំ អកុសលានំ ធម្មានំ សមាបត្តិយា ឥទំ វុច្ចតិ អហិរិកំ ។ តត្ថ កតមំ អនោត្តប្បំ ។ យំ ន ឱត្តប្បតិ ឱត្តប្បិតព្វេន ន ឱត្តប្បតិ បាបកានំ អកុសលានំ ធម្មានំ សមាបត្តិយា ឥទំ វុច្ចតិ អនោត្តប្បំ ។

(៣៩១) តត្ថ កតមា ហិរិ ។ យំ ហិរីយតិ ហិរិយិតព្វេន ហិរីយតិ បាបកានំ អកុសលានំ ធម្មានំ

(សេចក្ដីយល់)ថា ខន្ធក្ដី លោកក្ដី មិនមានទីបំផុត និងទិដ្ឋិ ដំណើរគឺទិដ្ឋិ ។ បេ ។ សេចក្ដីប្រកាន់កន្ត្រាស់ការស្វែងរកខុស ណា ដែលមានសភាពបែបនេះ នេះហៅថា អនន្តវាទិដ្ឋិ ។

(៣៨៩) បណ្ដាធម៌ទាំងនោះ បុព្វន្តានុទិដ្ឋិ (សេចក្ដីយល់តាមចំណែកនៃខន្ធខាងដើម) តើដូចម្ដេច ។ ទិដ្ឋិ ដំណើរគឺទិដ្ឋិ ។ បេ ។ សេចក្ដីប្រកាន់កន្ត្រាស់ការស្វែងរកខុស ណា កើតឡើង ព្រោះប្រារព្ធនូវខន្ធជាចំណែកខាងដើម នេះហៅថា បុព្វន្តានុទិដ្ឋិ ។ បណ្ដាធម៌ទាំងនោះ អបរន្តានុទិដ្ឋិ តើដូចម្ដេច ។ ទិដ្ឋិ ដំណើរគឺទិដ្ឋិ ។ បេ ។ សេចក្ដីប្រកាន់កន្ត្រាស់ការស្វែងរកខុស ណា កើតឡើង ព្រោះប្រារព្ធនូវខន្ធជាចំណែកខាងចុង នេះហៅថា អបរន្តានុទិដ្ឋិ ។

(៣៩០) បណ្ដាធម៌ទាំងនោះ អហិរិកៈ តើដូចម្ដេច ។ ត្រង់ដែលបុគ្គល មិនខ្មាសដោយអំពើដែលគួរខ្មាស មិនខ្មាសដោយការជួបប្រទះនូវធម៌ជាអកុសលដ៏លាមក នេះហៅថា អហិរិកៈ ។ បណ្ដាធម៌ទាំងនោះ អនោត្តប្បៈ តើដូចម្ដេច ។ ត្រង់ដែលបុគ្គល មិនក្ដៅក្រហាយដោយអំពើដែលគួរក្ដៅក្រហាយ មិនក្ដៅក្រហាយដោយការជួបប្រទះនូវធម៌ជាអកុសលដ៏លាមក នេះហៅថា អនោត្តប្បៈ ។

(៣៩១) បណ្ដាធម៌ទាំងនោះ ហិរិ តើដូចម្ដេច ។ ត្រង់ដែលបុគ្គលខ្មាស ដោយអំពើដែលគួរខ្មាស ខ្មាសដោយការជួបប្រទះនូវធម៌

សមាបត្តិយា អយំ វុច្ចតិ ហិរិ ។ តត្ថ កតមំ ឱត្តប្បំ ។ យំ ឱត្តប្បតិ ឱត្តប្បិតព្វេន ឱត្តប្បតិ បាបកានំ អកុសលានំ ធម្មានំ សមាបត្តិយា ឥទំ វុច្ចតិ ឱត្តប្បំ ។

(៣៩២) តត្ថ កតមា ទោវចស្សតា ។ សហធម្មិកេ វុច្ចមានេ ទោវចស្សាយំ(១) ទោវចស្សិយំ ទោវចស្សតា វិប្បដិកូលគ្គាហិតា វិបច្ចនីកសាតតា អនាទរិយំ អនាទរតា អគារវតា អប្បដិស្សវតា អយំ វុច្ចតិ ទោវចស្សតា ។ តត្ថ កតមា បាបមិត្តតា ។ យេ តេ បុគ្គលា អស្សទ្ធា ទុស្សីលា អប្បស្សុតា មច្ឆរិនោ ទុប្បញ្ញា យា តេសំ សេវនា និសេវនា សំសេវនា ភជនា សម្ភជនា ភត្តិ សម្ភត្តិ តំសម្បវង្កតា អយំ វុច្ចតិ បាបមិត្តតា ។

(៣៩៣) តត្ថ កតមា សោវចស្សតា ។ សហធម្មិកេ វុច្ចមានេ សោវចស្សាយំ សោវចស្សិយំ

---

១ ឱ. ទោវចស្សតាយំ ។

ជាអកុសលដ៏លាមក នេះហៅថា ហិរិ ។ បណ្ដាធម៌ទាំងនោះ ឱត្តប្បៈ តើដូចម្ដេច ។ ត្រង់ដែលបុគ្គល ក្ដៅក្រហាយដោយអំពើដែលគួរក្ដៅក្រហាយ ក្ដៅក្រហាយដោយការដួបប្រទះ នូវធម៌ជាអកុសលដ៏លាមក នេះហៅថា ឱត្តប្បៈ ។

(៣៩២) បណ្ដាធម៌ទាំងនោះ ភាពនៃបុគ្គលដែលគេប្រដៅក្រ តើដូចម្ដេច ។ សេចក្ដីប្រដៅក្រ ការស្ដីថាក្រ ភាពនៃបុគ្គលដែលគេប្រដៅក្រ ភាពនៃបុគ្គលប្រកាន់យកខាងខុស ភាពនៃបុគ្គលត្រេកអរក្នុងធម៌ជាសត្រូវ ការមិនអើពើ ភាពនៃបុគ្គលមិនយកចិត្តទុកដាក់ ភាពនៃបុគ្គលមិនគោរព ភាពនៃបុគ្គលមិនទទួលស្ដាប់បង្គាប់ ចំពោះសហធម្មិកជន ដែលស្ដីប្រដៅ នេះហៅថា ភាពនៃបុគ្គលដែលគេប្រដៅក្រ ។ បណ្ដាធម៌ទាំងនោះ ភាពនៃបុគ្គលមានមិត្រអាក្រក់ តើដូចម្ដេច ។ ពួកបុគ្គលណា ជាអ្នកមិនមានសទ្ធា ទ្រុស្ដសីល បេះដូងតិច ជាមនុស្សកំណាញ់ គ្មានប្រាជ្ញា ការសេព ការជិតដិតនឹងគ្នា ការត្រាំគំនិតគ្នា ការគប់រកគ្នា ការស្រេបគំនិតគ្នា សេចក្ដីស្រឡាញ់គ្នា ការជិតស្និទ្ធនឹងគ្នា ភាពនៃបុគ្គលមូលមិត្រនឹងគ្នា ណា នៃបុគ្គលទាំងនោះ នេះហៅថា ភាពនៃបុគ្គលមានមិត្រអាក្រក់ ។

(៣៩៣) បណ្ដាធម៌ទាំងនោះ ភាពនៃបុគ្គលដែលគេប្រដៅងាយ តើដូចម្ដេច ។ ការប្រដៅងាយ ការស្ដីថាងាយ ភាពនៃបុគ្គលដែល

សោវចស្សតា អប្បដិកុលគ្គាហិតា អវិបច្ចនីកសា-
តតា សាទរិយំ សាទរតា សគារវតា សប្បដិស្សវតា
អយំ វុច្ចតិ សោវចស្សតា ។ តត្ថ កតមា កល្យា-
ណមិត្តតា ។ យេ តេ បុគ្គលា សទ្ធា សីលវន្តោ
ពហុស្សុតា ចាគវន្តោ បញ្ញវន្តោ យា តេសំ សេវនា
និសេវនា សំសេវនា ភជនា សម្ភជនា ភត្តិ សម្ភត្តិ
តំសម្បវង្កតា អយំ វុច្ចតិ កល្យាណមិត្តតា ។

(៣៤៦) តត្ថ កតមា អាបត្តិកុសលតា ។
បញ្ចបិ អាបត្តិក្ខន្ធា អាបត្តិយោ សត្តបិ អាបត្តិ-
ក្ខន្ធា អាបត្តិយោ យា តាសំ អាបត្តីនំ អាបត្តិកុ-
សលតា បញ្ញា បជាននា ។បេ។ អមោហោ ធម្ម-
វិចយោ សម្មាទិដ្ឋិ អយំ វុច្ចតិ អាបត្តិកុសលតា ។
តត្ថ កតមា អាបត្តិវុដ្ឋានកុសលតា ។ យា តាហិ
អាបត្តីហិ វុដ្ឋានកុសលតា បញ្ញា បជាននា ។បេ។

គេប្រដៅងាយ ភាពនៃបុគ្គលមិនកាន់យកខាងខុស ភាពនៃបុគ្គលមិនត្រេកអរ ចំពោះធម៌ជាសត្រូវ សេចក្ដីអើពើ ភាពនៃបុគ្គលយកចិត្តទុកដាក់ ភាពនៃបុគ្គលប្រកបដោយសេចក្ដីគោរព ភាពនៃបុគ្គលប្រកបដោយការទទួលស្ដាប់បង្គាប់ ចំពោះសហធម្មិកជនដែលស្ដីប្រដៅ នេះហៅថា ភាពនៃបុគ្គលប្រដៅងាយ ។ បណ្ដាធម៌ទាំងនោះ ភាពនៃបុគ្គលមានមិត្រល្អ តើដូចម្ដេច ។ បុគ្គលណា ជាអ្នកមានសទ្ធា មានសីល ចេះដឹងច្រើន មានចាគៈ មានប្រាជ្ញា ការសេព ការជិតដិតនឹងគ្នា ការត្រូវគំនិតគ្នា ការគប់គេគ្នា ការស្របគំនិតគ្នា សេចក្ដីស្រឡាញ់គ្នា ការជិតស្និទ្ធនឹងគ្នា ភាពនៃបុគ្គលមូលមិត្រនឹងគ្នា ណា នៃបុគ្គលទាំងនោះ នេះហៅថា ភាពនៃបុគ្គលមានមិត្រល្អ ។

(៣៥៤) បណ្ដាធម៌ទាំងនោះ សេចក្ដីឈ្លាសក្នុងអាបត្តិ តើដូចម្ដេច ។ ពួកអាបត្តិមានកងនៃអាបត្តិ ៥ ក្ដី ពួកអាបត្តិមានកងនៃអាបត្តិ ៧ ក្ដី សេចក្ដីឈ្លាសក្នុងអាបត្តិ ការដឹងច្បាស់ ការយល់ច្បាស់ ។ បេ ។ ការមិនវង្វេង ការពិចារណាធម៌ ការយល់ត្រូវ ណា ចំពោះអាបត្តិទាំងនោះ នេះហៅថា សេចក្ដីឈ្លាសក្នុងអាបត្តិ ។ បណ្ដាធម៌ទាំងនោះ ភាពនៃបុគ្គលអ្នកឈ្លាសក្នុងការចេញចាកអាបត្តិ តើដូចម្ដេច ។ សេចក្ដីឈ្លាសក្នុងការចេញចាកអាបត្តិទាំងនោះ ការដឹងច្បាស់ ការយល់ច្បាស់ ។ បេ ។

អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ អយំ វុច្ចតិ អាបត្តិវុដ្ឋានកុសលតា ។

(៣៥៥) តត្ថ កតមា សមាបត្តិកុសលតា ។ អត្ថិ សវិតក្កសវិចារា សមាបត្តិ អត្ថិ អវិតក្កវិចារមត្តា សមាបត្តិ អត្ថិ អវិតក្កអវិចារា សមាបត្តិ យា តាសំ សមាបត្តីនំ សមាបត្តិកុសលតា បញ្ញា បជានា ។បេ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ អយំ វុច្ចតិ សមាបត្តិកុសលតា ។ តត្ថ កតមា សមាបត្តិវុដ្ឋានកុសលតា ។ យា តាហិ សមាបត្តីហិ វុដ្ឋានកុសលតា បញ្ញា បជានា ។បេ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ អយំ វុច្ចតិ សមាបត្តិវុដ្ឋានកុសលតា ។

(៣៥៦) តត្ថ កតមា ធាតុកុសលតា ។ អដ្ឋារសធាតុយោ ចក្ខុធាតុ រូបធាតុ ចក្ខុវិញ្ញាណធាតុ សោតធាតុ សទ្ទធាតុ សោតវិញ្ញាណធាតុ ឃានធាតុ គន្ធធាតុ ឃានវិញ្ញាណធាតុ ជិវ្ហាធាតុ រសធាតុ ជិវ្ហាវិញ្ញាណធាតុ កាយធាតុ ផោដ្ឋព្វធាតុ

ការមិនវង្វេង ការពិចារណាធម៌ ការយល់ត្រូវ ណា នេះហៅថា សេចក្ដីឈ្លាសក្នុងការចេញចាកអាបត្តិ ។

[៣៥៥] បណ្ដាធម៌ទាំងនោះ សេចក្ដីឈ្លាសក្នុងសមាបត្តិ តើដូចម្ដេច ។ សមាបត្តិ ប្រកបដោយវិតក្កៈនិងវិចារៈក៏មាន សមាបត្តិ មិនមានវិតក្កៈ មានត្រឹមតែវិចារៈក៏មាន សមាបត្តិ មិនមានវិតក្ក ទាំងមិនមានវិចារៈក៏មាន សេចក្ដីឈ្លាសក្នុងសមាបត្តិ ការដឹងច្បាស់ ការយល់ច្បាស់ ។ បេ ។ ការមិនវង្វេង ការពិចារណាធម៌ ការយល់ត្រូវ ណា ចំពោះសមាបត្តិទាំងនោះ នេះហៅថា សេចក្ដីឈ្លាសក្នុងសមាបត្តិ ។ បណ្ដាធម៌ទាំងនោះ សេចក្ដីឈ្លាសក្នុងការចេញចាកសមាបត្តិ តើដូចម្ដេច ។ សេចក្ដីឈ្លាស ក្នុងការចេញចាកសមាបត្តិទាំងនោះ ការដឹងច្បាស់ ការយល់ច្បាស់ ។ បេ ។ ការមិនវង្វេង ការពិចារណាធម៌ ការយល់ត្រូវ ណា នេះហៅថា សេចក្ដីឈ្លាសក្នុងការចេញចាកសមាបត្តិ ។

[៣៥៦] បណ្ដាធម៌ទាំងនោះ សេចក្ដីឈ្លាសក្នុងធាតុ តើដូចម្ដេច ។ ធាតុ ១៨ គឺ ចក្ខុធាតុ រូបធាតុ ចក្ខុវិញ្ញាណធាតុ សោតធាតុ សទ្ទធាតុ សោតវិញ្ញាណធាតុ ឃានធាតុ គន្ធធាតុ ឃានវិញ្ញាណធាតុ ជិវ្ហាធាតុ រសធាតុ ជិវ្ហាវិញ្ញាណធាតុ កាយធាតុ ផោដ្ឋព្វធាតុ

កាយវិញ្ញាណធាតុ មនោធាតុ ធម្មធាតុ មនោវិញ្ញា-ណធាតុ យា តាសំ ធាតូនំ ធាតុកុសលតា បញ្ញា បជានា ។បេ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ អយំ វុច្ចតិ ធាតុកុសលតា ។ តត្ថ កតមា មនសិ-ការកុសលតា ។ យា តាសំ ធាតូនំ មនសិការ-កុសលតា បញ្ញា បជានា ។បេ។ អមោហោ ធម្ម-វិចយោ សម្មាទិដ្ឋិ អយំ វុច្ចតិ មនសិការកុសលតា ។

(៣៨៧) តត្ថ កតមា អាយតនកុសលតា ។ ទ្វាទសាយតនានិ ចក្ខាយតនំ រូបាយតនំ សោតាយ-តនំ សទ្ទាយតនំ ឃានាយតនំ គន្ធាយតនំ ជិវ្ហាយ-តនំ រសាយតនំ កាយាយតនំ ផោដ្ឋព្វាយតនំ មនា-យតនំ ធម្មាយតនំ យា តេសំ អាយតនានំ អាយ-តនកុសលតា បញ្ញា បជានា ។បេ។ អមោ-ហោ ធម្មវិចយោ សម្មាទិដ្ឋិ អយំ វុច្ចតិ អាយតន-កុសលតា ។ តត្ថ កតមា បដិច្ចសមុប្បាទកុ-សលតា ។ អវិជ្ជាបច្ចយា សង្ខារា សង្ខារបច្ចយា វិញ្ញាណំ វិញ្ញាណបច្ចយា នាមរូបំ នាមរូបបច្ចយា

កាយវិញ្ញាណធាតុ មនោធាតុ ធម្មធាតុ មនោវិញ្ញាណធាតុ សេចក្តីឈ្លាសក្នុងធាតុ ការដឹងច្បាស់ ការយល់ច្បាស់ ។ បេ ។ ការមិនវង្វេង ការពិចារណាធម៌ ការយល់ត្រូវ ណា ចំពោះធាតុទាំងនោះ នេះហៅថា សេចក្តីឈ្លាសក្នុងធាតុ ។ បណ្តាធម៌ទាំងនោះ សេចក្តីឈ្លាស ក្នុងការធ្វើទុកក្នុងចិត្ត តើដូចម្តេច ។ សេចក្តីឈ្លាស ក្នុងការធ្វើទុកក្នុងចិត្ត ការដឹងច្បាស់ ការយល់ច្បាស់ ។ បេ ។ ការមិនវង្វេង ការពិចារណាធម៌ ការយល់ត្រូវ ណា ចំពោះធាតុទាំងនោះ នេះហៅថា សេចក្តីឈ្លាសក្នុងការធ្វើទុកក្នុងចិត្ត ។

(៣៩៧) បណ្តាធម៌ទាំងនោះ សេចក្តីឈ្លាស ក្នុងអាយតនៈ តើដូចម្តេច ។ អាយតនៈ ១២ គឺ ចក្ខាយតនៈ រូបាយតនៈ សោតាយតនៈ សទ្ទាយតនៈ ឃានាយតនៈ គន្ធាយតនៈ ជិវ្ហាយតនៈ រសាយតនៈ កាយាយតនៈ ផោដ្ឋព្វាយតនៈ មនាយតនៈ ធម្មាយតនៈ សេចក្តីឈ្លាស ក្នុងអាយតនៈ ការដឹងច្បាស់ ការយល់ច្បាស់ ។ បេ ។ ការមិនវង្វេង ការពិចារណាធម៌ ការយល់ត្រូវ ណា ចំពោះអាយតនៈទាំងនោះ នេះហៅថា សេចក្តីឈ្លាសក្នុងអាយតនៈ ។ បណ្តាធម៌ទាំងនោះ សេចក្តីឈ្លាស ក្នុងបដិច្ចសមុប្បាទ តើដូចម្តេច ។ សង្ខារកើតឡើង ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណកើតឡើង ព្រោះសង្ខារជាបច្ច័យ នាមរូបកើតឡើង

សឡាយតនំ សឡាយតនបច្ចយា ផស្សោ ផស្ស-
បច្ចយា វេទនា វេទនាបច្ចយា តណ្ហា តណ្ហាបច្-
ចយា ឧបាទានំ ឧបាទានបច្ចយា ភវោ ភវបច្ចយា
ជាតិ ជាតិបច្ចយា ជរាមរណំ សោកបរិទេវទុក្ខ-
ទោមនស្សុបាយាសា សម្ភវន្តិ ឯវមេតស្ស កេវលស្ស
ទុក្ខក្ខន្ធស្ស សមុទយោ ហោតីតិ យា តត្ថ បញ្ញា
បជាននា ។ បេ ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ
អយំ វុច្ចតិ បដិច្ចសមុប្បាទកុសលតា ។

(៣៥៨) តត្ថ កតមា ឋានកុសលតា ។ យេ
យេ ធម្មា យេសំ យេសំ ធម្មានំ ហេតូ បច្ចយា ឧ-
ប្បាទាយ តំ តំ ឋានំ យា តត្ថ បញ្ញា បជាននា
។ បេ ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ អយំ
វុច្ចតិ ឋានកុសលតា ។ តត្ថ កតមា អដ្ឋានកុស-
លតា ។ យេ យេ ធម្មា យេសំ យេសំ ធម្មានំ ន
ហេតូ ន បច្ចយា ឧប្បាទាយ តំ តំ អដ្ឋានំ យា

ព្រោះវិញ្ញាណជាបច្ច័យ សឡាយតនៈកើតឡើង ព្រោះនាមរូបជាបច្ច័យ ផស្សៈកើតឡើង ព្រោះសឡាយតនៈជាបច្ច័យ វេទនាកើតឡើង ព្រោះផស្សៈជាបច្ច័យ តណ្ហាកើតឡើង ព្រោះវេទនាជាបច្ច័យ ឧបាទានកើតឡើង ព្រោះតណ្ហាជាបច្ច័យ ភពកើតឡើង ព្រោះឧបាទានជាបច្ច័យ ជាតិកើតឡើង ព្រោះភពជាបច្ច័យ ជរាមរណៈកើតឡើង ព្រោះជាតិជាបច្ច័យ សេចក្ដីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស និងសេចក្ដីចង្អៀតចង្អល់ចិត្ត ក៏កើតឡើងព្រម ការកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ការដឹងច្បាស់ ការយល់ច្បាស់ ។ បេ ។ ការមិនវង្វេង ការពិចារណាធម៌ ការយល់ត្រូវ ណា ចំពោះបដិច្ចសមុប្បាទធម៌នោះ នេះហៅថា សេចក្ដីឈ្លាសក្នុងបដិច្ចសមុប្បាទ ។

[៣៤៨] បណ្ដាធម៌ទាំងនោះ សេចក្ដីឈ្លាសក្នុងឋានៈ (ហេតុ) តើដូចម្ដេច ។ ពួកធម៌ណា ៗ ជាហេតុ ជាបច្ច័យ នៃពួកធម៌ណា ៗ ពួកធម៌នោះ ៗ ឈ្មោះ ឋានៈ ព្រោះអាស្រ័យនូវហេតុប្បច្ច័យនោះ ៗ ការដឹងច្បាស់ ការយល់ច្បាស់ ។ បេ ។. ការមិនវង្វេង ការពិចារណាធម៌ ការយល់ត្រូវ ណា ចំពោះធម៌ទាំងនោះ នេះហៅថា សេចក្ដីឈ្លាសក្នុងឋានៈ ។ បណ្ដាធម៌ទាំងនោះ សេចក្ដីឈ្លាសក្នុងអដ្ឋានៈ (មិនមែនជាហេតុ) តើដូចម្ដេច ។ ពួកធម៌ណា ៗ មិនមែនជាហេតុ មិនមែនជាបច្ច័យនៃពួកធម៌ណា ៗ ពួកធម៌នោះ ៗ ឈ្មោះថា អដ្ឋានៈ

តត្ថ បញ្ញា បជានណា ។បេ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ អយំ វុច្ចតិ អដ្ឋានកុសលតា ។

(៣៥៩) តត្ថ កតមោ អាជ្ជវោ ។ យា អាជ្ជវតា អជិម្ហតា អវង្កតា អកុដិលតា អយំ វុច្ចតិ អាជ្ជវោ ។ តត្ថ កតមោ មទ្ទវោ ។ យា មុទុតា មទ្ទវតា អកក្ខឡតា អកឋិនតា នីចចិត្តតា អយំ វុច្ចតិ មទ្ទវោ ។

(៣៦០) តត្ថ កតមា ខន្តិ ។ យា ខន្តិ ខមនតា អធិវាសនតា អចណ្ឌិក្កំ អនសុរោបោ អត្តមនតា ចិត្តស្ស អយំ វុច្ចតិ ខន្តិ ។ តត្ថ កតមំ សោរច្ចំ ។ យោ កាយិកោ អវីតិក្កមោ វាចសិកោ អវីតិក្កមោ កាយិកវាចសិកោ អវីតិក្កមោ ឥទំ វុច្ចតិ សោរច្ចំ ។ សព្វោបិ សីលសំវរោ សោរច្ចំ ។

(៣៦១) តត្ថ កតមំ សាខល្យំ ។ យា សា វាចា អណ្ឌកា(១) កក្កសា បរកដុកា បរាភិសជ្ជនី

---

១ ឱ. ឯត្តន្តរេ អសាតាតិ ទិស្សតិ ។

ព្រោះអាស្រ័យនូវហេតុប្បច្ច័យនោះ ៗ ការដឹងច្បាស់ ការយល់ច្បាស់ ។ បេ ។ ការមិនវង្វេង ការពិចារណាធម៌ ការយល់ត្រូវ ណា ចំពោះធម៌ទាំងនោះ នេះហៅថា សេចក្តីឈ្លាសក្នុងអដ្ឋានៈ ។

(៣៥៩) បណ្តាធម៌ទាំងនោះ ភាពត្រង់ តើដូចម្តេច ។ ភាពនៃអាការត្រង់ ការមិនឆ្វើងឆ្វៃ ការមិនវៀចវេរ ការមិនកោងកាច ណា នេះហៅថា ភាពត្រង់ ។ បណ្តាធម៌ទាំងនោះ ភាពទន់ភ្លន់ តើដូចម្តេច ។ ភាពនៃអាការទន់ភ្លន់ ដំណើរទន់ភ្លន់ ការមិនរឹងរូស ការមិនក្រអឺតក្រអោង ការមានចិត្តរាបទាប ណា នេះហៅថា ភាពទន់ភ្លន់ ។

(៣៦០) បណ្តាធម៌ទាំងនោះ សេចក្តីអត់សង្កត់ តើដូចម្តេច ។ សេចក្តីអត់ធន់ ភាពអត់ធ្មត់ ការអត់សង្កត់ ភាពមិនកាច មិនព្រហើន ភាពនៃចិត្តរីករាយ ណា នេះហៅថា សេចក្តីអត់សង្កត់ ។ បណ្តាធម៌ទាំងនោះ សេចក្តីស្ងួត តើដូចម្តេច ។ ការមិនប្រព្រឹត្តិល្មើសកាយ ការមិនប្រព្រឹត្តិល្មើសវាចា ការមិនប្រព្រឹត្តិល្មើសកាយនិងវាចា ណា នេះហៅថា សេចក្តីស្ងួត ។ សូម្បីការសង្រួម ក្នុងសីលទាំងអស់ ក៏ហៅថា សេចក្តីស្ងួតដែរ ។

(៣៦១) បណ្តាធម៌ទាំងនោះ សេចក្តីរាក់ទាក់ តើដូចម្តេច ។ វាចា ណា ជាវាចារាកកន្ទួល ពុកស្អុយ វាចាមិនជាទីពេញចិត្តអ្នកដទៃ

កោធសាមន្តា អសមាធិសំវត្តនិកា តថារូបឹ វាចំ បហាយ យា សា វាចា នេឡា កណ្ណសុខា បេមនីយា ហទយង្គមា បោរី ពហុជនកន្តា ពហុជនមនាបា តថារូបឹ វាចំ ភាសិតា ហោតិ យា តត្ថ សណ្ហវាចតា សខិលវាចតា អផរុសវាចតា ឥទំ វុច្ចតិ សាខល្យំ ។ តត្ថ កតមោ បដិសន្ថារោ ។ ទ្វេ បដិសន្ថារា អាមិសបដិសន្ថារោ ច ធម្មបដិសន្ថារោ ច ឥធេកច្ចោ បដិសន្ថារកោ ហោតិ អាមិសបដិសន្ថារេន វា ធម្មបដិសន្ថារេន វា អយំ វុច្ចតិ បដិសន្ថារោ ។

(៣៦២) តត្ថ កតមា ឥន្ទ្រិយេសុ អគុត្តទ្វារតា ។ ឥធេកច្ចោ ចក្ខុនា រូបំ ទិស្វា និមិត្តគ្គាហី ហោតិ អនុព្យញ្ជនគ្គាហី យត្វាធិករណមេនំ ចក្ខុន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ ន បដិបជ្ជតិ ន រក្ខតិ ចក្ខុន្ទ្រិយំ ចក្ខុន្ទ្រិយេ ន សំវរំ អាបជ្ជតិ សោតេន សទ្ទំ សុត្វា ។បេ។ ឃានេន គន្ធំ ឃាយិត្វា ។បេ។

ជាកថាដាលកាលដល់អ្នកដទៃ ជាសំដីជិតការក្រោធ មិនប្រព្រឹត្តទៅដើម្បីសមាធិ បុគ្គលក៏លះបង់នូវកថាបែបនោះចេញ កថាណា មិនជាទោស ជាកថាសុខដល់ត្រចៀក ជាទីស្រឡាញ់ ជាទីពេញចិត្ត ជាកថានៃអ្នកក្រុង ជាទីត្រេកអរនៃជនច្រើន ជាទីពេញចិត្តនៃជនច្រើន បុគ្គលក៏ជាអ្នកនិយាយចំពោះកថាបែបនោះ បានដល់ការពោលពាក្យពីរោះ ការពោលពាក្យផូរផង់ ការពោលពាក្យមិនទ្រគោះ នេះហៅថាសេចក្ដីរាក់ទាក់ ៗ បណ្ដាធម៌ទាំងនោះ ការទទួលរាក់ទាក់ តើដូចម្ដេច ៗ ការទទួលរាក់ទាក់មាន ២ យ៉ាង គឺ ការទទួលរាក់ទាក់ដោយអាមិសៈ ១ ការទទួលរាក់ទាក់ដោយធម៌ ១ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកទទួលរាក់ទាក់ ដោយការទទួលរាក់ទាក់ដោយអាមិសៈ ឬដោយការទទួលរាក់ទាក់ដោយធម៌ នេះហៅថា ការទទួលរាក់ទាក់ ៗ

(៣៦២) បណ្ដាធម៌ទាំងនោះ ការមិនរក្សាទ្វារក្នុងឥន្ទ្រិយ តើដូចម្ដេច ៗ បុគ្គលខ្លះ ក្នុងលោកនេះ ឃើញរូបដោយចក្ខុហើយ ជាអ្នកកាន់យកនូវនិមិត្ត កាន់យកនូវអនុព្យញ្ជនៈ អភិជ្ឈានិងទោមនស្ស ជាអកុសលធម៌ដ៏លាមក គប្បីគ្របសង្កត់ នូវបុគ្គលដែលមិនសង្រួមចក្ខុន្ទ្រិយ
+
នុះ ព្រោះហេតុមិនសង្រួម នូវចក្ខុន្ទ្រិយណា ក៏មិនប្រតិបត្តិដើម្បីសង្រួម នូវចក្ខុន្ទ្រិយនោះ មិនរក្សានូវចក្ខុន្ទ្រិយ មិនដល់នូវការសង្រួម ក្នុងចក្ខុន្ទ្រិយ ឮសំឡេងដោយត្រចៀក ៗ បេ ៗ ធុំក្លិនដោយច្រមុះ ៗ បេ ៗ

ជិវ្ហាយ រសំ សាយិត្វា ។ បេ ។ កាយេន ផោដ្ឋព្វំ
ផុសិត្វា ។ បេ ។ មនសា ធម្មំ វិញ្ញាយ និមិត្តគ្គាហី
ហោតិ អនុព្យញ្ជនគ្គាហី យត្វាធិករណមេនំ មនិន្ទ្រិ-
យំ អសំវុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា
អកុសលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ ន
បដិបជ្ជតិ ន រក្ខតិ មនិន្ទ្រិយំ មនិន្ទ្រិយេ ន សំវរំ
អាបជ្ជតិ យា ឥមេសំ ឆន្នំ ឥន្ទ្រិយានំ អគុត្តិ អ-
គោបនា អនារក្ខោ អសំវរោ អយំ វុច្ចតិ ឥន្ទ្រិ-
យេសុ អគុត្តទ្វារតា ។ តត្ថ កតមា ភោជនេ អ-
មត្តញ្ញុតា ។ ឥធេកច្ចោ អប្បដិសង្ខា អយោនិសោ
អាហារំ អាហារេតិ ទវាយ មទាយ មណ្ឌនាយ វិភូ-
សនាយ យា តត្ថ អសន្តុដ្ឋិតា អមត្តញ្ញុតា អប្បដិ-
សង្ខា ភោជនេ អយំ វុច្ចតិ ភោជនេ អមត្តញ្ញុតា ។

(៣៦៣) តត្ថ កតមា ឥន្ទ្រិយេសុ គុត្តទ្វារតា ។
ឥធេកច្ចោ ចក្ខុនា រូបំ ទិស្វា ន និមិត្តគ្គាហី ហោតិ
នានុព្យញ្ជនគ្គាហី យត្វាធិករណមេនំ ចក្ខុន្ទ្រិយំ អសំ-
វុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុសលា

លិទ្ធភក្សដោយអណ្ដាត ។ បេ ។ ពាល់ត្រូវផោដ្ឋព្វៈដោយកាយ ។ បេ ។ ដឹងច្បាស់នូវធម្មារម្មណ៍ដោយចិត្តហើយ ជាអ្នកកាន់យកនូវនិមិត្ត កាន់យកនូវអនុព្យញ្ជនៈ អភិជ្ឈានិងទោមនស្ស ជាអកុសលធម៌ ដ៏លាមកគប្បីគ្របសង្កត់នូវបុគ្គល ដែលមិនសង្រួមមនិន្ទ្រិយនុ៎ះ ព្រោះហេតុមិនសង្រួម នូវមនិន្ទ្រិយណា ក៏មិនប្រតិបត្តិដើម្បីសង្រួម នូវមនិន្ទ្រិយនោះ មិនរក្សានូវមនិន្ទ្រិយ មិនដល់នូវការសង្រួមក្នុងមនិន្ទ្រិយ និងសេចក្ដីមិនគ្រប់គ្រង អាការមិនគ្រប់គ្រង ការមិនរក្សា ការមិនសង្រួម នូវឥន្ទ្រិយទាំង ៦ នេះ ណា នេះហៅថា ការមិនរក្សាទ្វារ ក្នុងឥន្ទ្រិយ ។ បណ្ដាធម៌ទាំងនោះ ការមិនដឹងប្រមាណក្នុងភោជន តើដូចម្ដេច ។ បុគ្គលខ្លះ ក្នុងលោកនេះ មិនបានពិចារណា ដោយឧបាយប្រាជ្ញា ហើយបរិភោគអាហារ ដើម្បីលេង ដើម្បីស្រវឹង ដើម្បីប្រដាប់ ដើម្បីស្អិតស្អាង សេចក្ដីមិនសន្ដោស ការមិនដឹងប្រមាណ ការមិនពិចារណាក្នុងភោជននោះ ណា នេះហៅថា ការមិនដឹងប្រមាណក្នុងភោជន ។

( ៣៦៣ ) បណ្ដាធម៌ទាំងនោះ ការរក្សាទ្វារក្នុងឥន្ទ្រិយ តើដូចម្ដេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ឃើញរូបដោយចក្ខុហើយ ជាអ្នកមិនកាន់យកនូវនិមិត្ត មិនកាន់យក នូវអនុព្យញ្ជនៈ អភិជ្ឈានិងទោមនស្ស ជាអកុសលធម៌ដ៏លាមក គប្បីគ្របសង្កត់នូវបុគ្គល ដែលមិនសង្រួមចក្ខុន្ទ្រិយនុ៎ះ ព្រោះហេតុមិនសង្រួម នូវចក្ខុន្ទ្រិយណា

ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ បដិបជ្ជតិ រក្ខតិ ចក្ខុន្ទ្រិយំ ចក្ខុន្ទ្រិយេ សំវរំ អាបជ្ជតិ សោតេន សទ្ទំ សុត្វា ។បេ។ ឃានេន គន្ធំ ឃាយិត្វា ។បេ។ ជិវ្ហាយ រសំ សាយិត្វា ។បេ។ កាយេន ផោដ្ឋព្វំ ផុសិត្វា ។បេ។ មនសា ធម្មំ វិញ្ញាយ ន និមិត្តគ្គាហី ហោតិ នានុព្យញ្ជនគ្គាហី យត្វាធិករណមេនំ មនិន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ បដិបជ្ជតិ រក្ខតិ មនិន្ទ្រិយំ មនិន្ទ្រិយេ សំវរំ អាបជ្ជតិ យា ឥមេសំ ឆន្នំ ឥន្ទ្រិយានំ គុត្តិ គោបនា អារក្ខា សំវរោ អយំ វុច្ចតិ ឥន្ទ្រិយេសុ គុត្តទ្វារតា ។ តត្ថ កតមា ភោជនេ មត្តញ្ញុតា ។ ឥធេកច្ចោ បដិសង្ខា យោនិសោ អាហារំ អាហារេតិ នេវ ទវាយ ន មទាយ ន មណ្ឌនាយ ន វិភូសនាយ យាវទេវ ឥមស្ស កាយស្ស ឋិតិយា យាបនាយ វិហឹសុបរតិយា ព្រហ្មចរិយានុគ្គហាយ ឥតិ បុរាណញ្ច វេទនំ បដិហង្ខាមិ នវញ្ច វេទនំ ន ឧប្បាទេស្សាមិ យាត្រា ច មេ ភវិស្សតិ អនវជ្ជតា ច ផាសុវិហារោ ចាតិ

ក៏ប្រតិបត្តិដើម្បីសង្រួម នូវចក្ខុន្ទ្រិយនោះ រក្សានូវចក្ខុន្ទ្រិយ ដល់នូវការសង្រួមក្នុងចក្ខុន្ទ្រិយ ឮសំឡេងដោយត្រចៀក ។ បេ ។ ធុំក្លិនដោយច្រមុះ ។ បេ ។ លិទ្ធភ្លក្សរសដោយអណ្តាត ។ បេ ។ ពាល់ត្រូវផោដ្ឋព្វៈដោយកាយ ។ បេ ។ ដឹងធម្មារម្មណ៍ដោយចិត្តហើយ ជាអ្នកមិនកាន់យកនូវនិមិត្ត មិនកាន់យកនូវអនុព្យញ្ជនៈ អភិជ្ឈានិងទោមនស្ស ជាអកុសលធម៌ដ៏លាមក គប្បីគ្របសង្កត់នូវបុគ្គល ដែលមិនសង្រួមមនិន្ទ្រិយនុ៎ះ ព្រោះហេតុមិនសង្រួមនូវមនិន្ទ្រិយណា ក៏ប្រតិបត្តិដើម្បីសង្រួម នូវមនិន្ទ្រិយនោះ រក្សានូវមនិន្ទ្រិយ ដល់នូវការសង្រួមក្នុងមនិន្ទ្រិយ និងសេចក្តីគ្រប់គ្រង អា-ការគ្រប់គ្រង ការរក្សា ការសង្រួមនូវឥន្ទ្រិយទាំង ៦ នេះ ណា នេះហៅថា ការរក្សាទ្វារ ក្នុងឥន្ទ្រិយ ។ បណ្តាធម៌ទាំងនោះ ការដឹងប្រមាណក្នុងភោជន តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ពិចារណាដោយឧបាយប្រាជ្ញា ហើយទើបបរិភោគនូវអាហារ មិនមែនដើម្បីលេង មិនមែនដើម្បីស្រវឹង មិនមែនដើម្បីប្រដាប់ មិនមែនដើម្បីស្អិតស្អាង គឺបរិភោគដើម្បីតាំងនៅនៃកាយនេះ ដើម្បីញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ដើម្បីកំចាត់បង់នូវសេចក្តីលំបាក ដើម្បីអនុគ្រោះនូវព្រហ្មចរិយធម៌ តែប៉ុណ្ណោះ អាត្មាអញនឹងកំចាត់បង់នូវវេទនាចាស់ផង នឹងមិនឲ្យវេទនាថ្មីកើតឡើងបានផង ការប្រព្រឹត្តិទៅនៃឥរិយាបថក្តី ការមិនមានទោសក្តី ការនៅជាសុខសប្បាយក្តី នឹងមានដល់អញ សេចក្តីសន្តោស

យា តត្ថ សន្តុដ្ឋិតា មត្តញ្ញុតា បដិសង្ខា ភោជនេ អយំ វុច្ចតិ ភោជនេ មត្តញ្ញុតា ។

(៣៦៤) តត្ថ កតមំ មុដ្ឋសច្ចំ ។ យា អសតិ អននុស្សតិ អប្បដិស្សតិ អសតិ អសរណតា អធារណតា បិលាបនតា សម្មុសនតា ឥទំ វុច្ចតិ មុដ្ឋសច្ចំ ។ តត្ថ កតមំ អសម្បជញ្ញំ ។ យំ អញ្ញាណំ អទស្សនំ ។បេ។ អវិជ្ជាលង្គី មោហោ អកុសលមូលំ ឥទំ វុច្ចតិ អសម្បជញ្ញំ ។

(៣៦៥) តត្ថ កតមា សតិ ។ យា សតិ អនុស្សតិ បដិស្សតិ សតិ សរណតា ធារណតា អបិលាបនតា អសម្មុសនតា សតិ សតិន្ទ្រិយំ សតិពលំ សម្មាសតិ អយំ វុច្ចតិ សតិ ។ តត្ថ កតមំ សម្បជញ្ញំ ។ យា បញ្ញា បជាននា ។បេ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ ឥទំ វុច្ចតិ សម្បជញ្ញំ ។

(៣៦៦) តត្ថ កតមំ បដិសង្ខានពលំ ។ យា បញ្ញា បជាននា ។បេ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ ឥទំ វុច្ចតិ បដិសង្ខានពលំ ។

ការដឹងប្រមាណ ការពិចារណាដូចេះ ក្នុងភោជននោះ ណា នេះហៅថា ការដឹងប្រមាណក្នុងភោជន ។

(៣៦៤) បណ្ដាធម៌ទាំងនោះ ការភ្លេចស្មារតី តើដូចម្ដេច ។ ការគ្មានស្មារតី ការនឹកមិនឃើញ ការភ្លេចស្មារតី ការមិនមានស្មារតី ការមិនរលឹក ការមិនបានចាំទុក ការភ្លេចភ្លាំង និងការវង្វេង ណា នេះហៅថា ការភ្លេចស្មារតី ។ បណ្ដាធម៌ទាំងនោះ សេចក្ដីមិនដឹងខ្លួន តើដូចម្ដេច ។ ការមិនដឹង ការមិនឃើញ ។ បេ ។ គន្លះគឺអវិជ្ជា សេចក្ដីវង្វេង ជាអកុសលមូល ណា នេះហៅថា សេចក្ដីមិនដឹងខ្លួន ។

(៣៦៥) បណ្ដាធម៌ទាំងនោះ ស្មារតី តើដូចម្ដេច ។ ការមានស្មារតី ការនឹកឃើញ ការនឹករលឹក ស្មារតី សេចក្ដីរលឹក ការចាំទុក ការមិនភ្លេចភ្លាំង ការមិនវង្វេង សតិ (ការរលឹក) ឥន្ទ្រិយគឺសតិ ពលៈគឺសតិ ការនឹកត្រូវ ណា នេះហៅថា ស្មារតី ។ បណ្ដាធម៌ទាំងនោះ សេចក្ដីដឹងខ្លួន តើដូចម្ដេច ។ ប្រាជ្ញា ការដឹងច្បាស់ ។ បេ ។ ការមិនវង្វេង ការពិចារណាធម៌ ការយល់ត្រូវ ណា នេះហៅថា សេចក្ដីដឹងខ្លួន ។

(៣៦៦) បណ្ដាធម៌ទាំងនោះ កំឡាំងគឺការពិចារណា តើដូចម្ដេច ។ ប្រាជ្ញា ការដឹងច្បាស់ ។ បេ ។ ការមិនវង្វេង ការពិចារណាធម៌ ការយល់ត្រូវ ណា នេះហៅថា កំឡាំងគឺការពិចារណា ។

តត្ថ កតមំ ភាវនាពលំ ។ យា កុសលានំ ធម្មានំ អាសេវនា ភាវនា ពហុលីកម្មំ ឥទំ វុច្ចតិ ភាវនាពលំ សត្តបិ ពោជ្ឈង្គា ភាវនាពលំ ។

(៣៦៧) តត្ថ កតមោ សមថោ ។ យា ចិត្តស្ស ឋិតិ ។ បេ ។ សម្មាសមាធិ អយំ វុច្ចតិ សមថោ ។ តត្ថ កតមា វិបស្សនា ។ យា បញ្ញា បជានានា ។ បេ ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ អយំ វុច្ចតិ វិបស្សនា ។

(៣៦៨) តត្ថ កតមំ សមថនិមិត្តំ ។ យា ចិត្តស្ស ឋិតិ ។ បេ ។ សម្មាសមាធិ ឥទំ វុច្ចតិ សមថនិមិត្តំ ។ តត្ថ កតមំ បគ្គាហនិមិត្តំ ។ យោ ចេតសិកោ វីរិយារម្ភោ ។ បេ ។ សម្មាវាយាមោ ឥទំ វុច្ចតិ បគ្គាហនិមិត្តំ ។

(៣៦៩) តត្ថ កតមោ បគ្គាហោ ។ យោ ចេតសិកោ វីរិយារម្ភោ ។ បេ ។ សម្មាវាយាមោ អយំ វុច្ចតិ បគ្គាហោ ។ តត្ថ កតមោ អវិក្ខេបោ ។ យា ចិត្តស្ស ឋិតិ ។ បេ ។ សម្មាសមាធិ អយំ វុច្ចតិ អវិក្ខេបោ ។

បណ្ដាធម៌ទាំងនោះ កំឡាំងគឺការនា តើដូចម្ដេច ។ ការគប់រក ការអប់រំ ការធ្វើឲ្យច្រើននូវពួកកុសលធម៌ ណា នេះហៅថា កំឡាំងគឺការនា សម្បជ្ឈង្គទាំង ៧ ក៏ហៅថា កំឡាំងគឺការនាដែរ ។

(៣៦៧) បណ្ដាធម៌ទាំងនោះ សមថៈ (សភាពរម្ងាប់ធម៌ជាសត្រូវ) តើដូចម្ដេច ។ ការឋិតនៅនៃចិត្ត ។ បេ ។ ការតំកល់ចិត្តត្រូវ ណា នេះហៅថា សមថៈ ។ បណ្ដាធម៌ទាំងនោះ វិបស្សនា (ធម្មជាតិឃើញដោយអាការផ្សេង ៗ) តើដូចម្ដេច ។ ប្រាជ្ញា ការដឹងច្បាស់ ។ បេ ។ ការមិនវង្វេង ការពិចារណា សេចក្ដីយល់ត្រូវ ណា នេះហៅថា វិបស្សនា ។

(៣៦៨) បណ្ដាធម៌ទាំងនោះ និមិត្តគឺសមថៈ តើដូចម្ដេច ។ ការឋិតនៅនៃចិត្ត ។ បេ ។ ការតំកល់ចិត្តត្រូវ ណា នេះហៅថា និមិត្តគឺសមថៈ ។ បណ្ដាធម៌ទាំងនោះ និមិត្តគឺការផ្គងឡើង តើដូចម្ដេច ។ ការប្រារព្ធព្យាយាម ប្រកបដោយចិត្ត ។ បេ ។ ព្យាយាមត្រូវ ណា នេះហៅថា និមិត្តគឺការផ្គងឡើង ។

(៣៦៩) បណ្ដាធម៌ទាំងនោះ ការផ្គងឡើង តើដូចម្ដេច ។ ការប្រារព្ធព្យាយាម ប្រកបដោយចិត្ត ។ បេ ។ ព្យាយាមត្រូវ ណា នេះហៅថា ការផ្គងឡើង ។ បណ្ដាធម៌ទាំងនោះ ការមិនរាយមាយ តើដូចម្ដេច ។ ការឋិតនៅនៃចិត្ត ។ បេ ។ ការតំកល់ចិត្តត្រូវ ណា នេះហៅថា ការមិនរាយមាយ ។

(៣៧០) តត្ថ កតមា សីលវិបត្តិ ។ យោ កាយិកោ វីតិក្កមោ វាចសិកោ វីតិក្កមោ កាយិកវាចសិកោ វីតិក្កមោ អយំ វុច្ចតិ សីលវិបត្តិ សព្វម្បិ ទុស្សីល្យំ សីលវិបត្តិ ។ តត្ថ កតមា ទិដ្ឋិវិបត្តិ ។ នត្ថិ ទិន្នំ នត្ថិ យិដ្ឋំ នត្ថិ ហុតំ នត្ថិ សុកដទុក្កដានំ កម្មានំ ផលវិបាកោ នត្ថិ អយំ លោកោ នត្ថិ បរោ លោកោ នត្ថិ មាតា នត្ថិ បិតា នត្ថិ សត្តា ឱបបាតិកា នត្ថិ លោកេ សមណព្រាហ្មណា សម្មគ្គតា សម្មាបដិបន្នា យេ ឥមញ្ច លោកំ បរញ្ច លោកំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេន្តីតិ យា ឯវរូបា ទិដ្ឋិ ទិដ្ឋិគតំ ។ បេ ។ វិបរិយេសគ្គាហោ អយំ វុច្ចតិ ទិដ្ឋិវិបត្តិ សព្វាបិ មិច្ឆាទិដ្ឋិ ទិដ្ឋិវិបត្តិ ។

(៣៧១) តត្ថ កតមា សីលសម្បទា ។ កាយិកោ អវីតិក្កមោ វាចសិកោ អវីតិក្កមោ កាយិកវាចសិកោ អវីតិក្កមោ អយំ វុច្ចតិ សីលសម្បទា សព្វោបិ

(៣៧០) បណ្ដាធម៌ទាំងនោះ វិបត្តិនៃសីល តើដូចម្ដេច ។ ការប្រព្រឹត្តិល្មើសប្រកបដោយកាយ ការប្រព្រឹត្តិល្មើសប្រកបដោយវាចា ការប្រព្រឹត្តិល្មើសប្រកបដោយកាយនិងវាចា ណា នេះហៅថា វិបត្តិនៃសីល សូម្បីទ្រុស្តសីលទាំងអស់ ក៏ហៅថា វិបត្តិនៃសីលដែរ ។ បណ្ដាធម៌ទាំងនោះ វិបត្តិនៃទិដ្ឋិ តើដូចម្ដេច ។ (សេចក្ដីយល់ឃើញ) ថាទានដែលគេឲ្យហើយ មិនមានផល បូជាធំមិនមានផល បូជាតូចមិនមានផល ផលវិបាកនៃកម្មដែលគេធ្វើល្អ ធ្វើអាក្រក់មិនមាន លោកនេះមិនមាន លោកខាងមុខមិនមាន មាតាមិនមានគុណ បិតាមិនមានគុណ ពួកសត្វជាឱបបាតិកៈកំណើតមិនមាន ពួកសមណព្រាហ្មណ៍ក្នុងលោក អ្នកប្រព្រឹត្តល្អ ប្រតិបត្តិត្រឹមត្រូវ ដែលធ្វើឲ្យជាក់ច្បាស់នូវលោកនេះ និងលោកខាងមុខ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ហើយសំដែងបាន ក៏មិនមាន និងទិដ្ឋិ ដំណើរគឺទិដ្ឋិ ។ បេ ។ សេចក្ដីប្រកាន់ក្នុងការស្វែងរកខុស ណា ដែលមានសភាពបែបនេះ នេះហៅថា វិបត្តិនៃទិដ្ឋិ សូម្បីមិច្ឆាទិដ្ឋិទាំងអស់ ក៏ហៅថា វិបត្តិនៃទិដ្ឋិដែរ ។

(៣៧១) បណ្ដាធម៌ទាំងអស់ ការបរិបូណ៌ដោយសីល តើដូចម្ដេច ។ ការមិនប្រព្រឹត្តិល្មើសប្រកបដោយកាយ ការមិនប្រព្រឹត្តិល្មើសប្រកបដោយវាចា ការមិនប្រព្រឹត្តិល្មើសប្រកបដោយកាយនិងវាចា នេះហៅថា ការបរិបូណ៌ដោយសីល សូម្បីការសង្រួមក្នុងសីលទាំងអស់

សីលសំវរោ សីលសម្បទា ។ តត្ថ កតមា ទិដ្ឋិ-
សម្បទា ។ អត្ថិ ទិន្នំ អត្ថិ យិដ្ឋំ អត្ថិ ហុតំ អត្ថិ
សុកដទុក្កដានំ កម្មានំ ផលវិបាកោ អត្ថិ អយំ
លោកោ អត្ថិ បរោ លោកោ អត្ថិ មាតា អត្ថិ បិតា
អត្ថិ សត្តា ឱបបាតិកា អត្ថិ លោកេ សមណព្រាហ្ម-
ណា សម្មគ្គតា សម្មាបដិបន្នា យេ ឥមញ្ច លោកំ
បរញ្ច លោកំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេន្តីតិ
យា ឯវរូបា បញ្ញា បជានានា ។បេ។ អមោហោ
ធម្មវិចយោ សម្មាទិដ្ឋិ អយំ វុច្ចតិ ទិដ្ឋិសម្បទា ស-
ព្វាបិ សម្មាទិដ្ឋិ ទិដ្ឋិសម្បទា ។

(៣៧២) តត្ថ កតមា សីលវិសុទ្ធិ ។ កាយិ-
កោ អវីតិក្កមោ វាចសិកោ អវីតិក្កមោ កាយិកវា-
ចសិកោ អវីតិក្កមោ អយំ វុច្ចតិ សីលវិសុទ្ធិ ស-
ព្វោបិ សីលសំវរោ សីលវិសុទ្ធិ ។ តត្ថ កតមា ទិដ្ឋិ-
វិសុទ្ធិ ។ កម្មស្សកតញ្ញាណំ សច្ចានុលោមិកញ្ញាណំ

ក៏ហៅថា ការបរិបូណ៌ដោយសីលដែរ ។ បណ្តាធម៌ទាំងនោះ ការបរិបូណ៌ដោយទិដ្ឋិ តើដូចម្តេច ។ (សេចក្តីយល់ឃើញ) ថា ទានដែលគេឲ្យហើយមានផល បូជាធំមានផល បូជាតូចមានផល ផលនៃវិបាកនៃកម្មដែលគេធ្វើល្អនិងធ្វើអាក្រក់មាន លោកនេះមាន លោកខាងមុខមាន មាតាមានគុណ បិតាមានគុណ ពួកសត្វជាឧបបាតិកៈកំណើតមាន ពួកសមណព្រាហ្មណ៍ក្នុងលោក ជាអ្នកប្រព្រឹត្តល្អ ប្រតិបត្តិត្រឹមត្រូវ ដែលធ្វើឲ្យជាក់ច្បាស់នូវលោកនេះ និងលោកខាងមុខ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ហើយសំដែងបានមាន និងប្រាជ្ញា ការដឹងច្បាស់ ។ បេ ។ សេចក្តីមិនវង្វេង ការពិចារណាធម៌ សេចក្តីយល់ត្រូវ ណា ដែលមានសភាពបែបនេះ នេះហៅថា ការបរិបូណ៌ដោយទិដ្ឋិ សូម្បីសម្មាទិដ្ឋិទាំងអស់ ក៏ហៅថា ការបរិបូណ៌ដោយទិដ្ឋិដែរ ។

(៣៧៦) បណ្តាធម៌ទាំងនោះ ការបរិសុទ្ធិនៃសីល តើដូចម្តេច ។ ការមិនប្រព្រឹត្តិល្មើសប្រកបដោយកាយ ការមិនប្រព្រឹត្តិល្មើសប្រកបដោយវាចា ការមិនប្រព្រឹត្តិល្មើសប្រកបដោយកាយនិងវាចា នេះហៅថា ការបរិសុទ្ធិនៃសីល សូម្បីការសង្រួមក្នុងសីលទាំងអស់ ក៏ហៅថា ការបរិសុទ្ធិនៃសីលដែរ ។ បណ្តាធម៌ទាំងនោះ ការបរិសុទ្ធិនៃទិដ្ឋិ តើដូចម្តេច ។ កម្មស្សកតញ្ញាណ (ការដឹងច្បាស់កម្មជារបស់ខ្លួន) សច្ចានុលោមិកញ្ញាណ (ការដឹងច្បាស់ អនុលោមតាមសច្ចៈ ៤ )

មគ្គសមង្គិស្ស ញាណំ ផលសមង្គិស្ស ញាណំ ។

(៣៧៣) ទិដ្ឋិវិសុទ្ធិ ខោ បនាតិ យា បញ្ញា ប-
ជាននា ។ បេ ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ ។
យថាទិដ្ឋិស្ស ច បធានន្តិ យោ ចេតសិកោ វីរិ-
យារម្ភោ ។ បេ ។ សម្មាវាយាមោ ។

(៣៧៤) សំវេគោតិ ជាតិភយំ ជរាភយំ ព្យាធិ-
ភយំ មរណភយំ ។ សំវេជនិយំ ឋានន្តិ ជាតិ ជរា
ព្យាធិ មរណំ ។ សំវិគ្គស្ស ច យោនិសោ បធានន្តិ
ឥធ ភិក្ខុ អនុប្បន្នានំ បាបកានំ អកុសលានំ ធម្មា-
នំ អនុប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ
ចិត្តំ បគ្គណ្ហាតិ បទហតិ ឧប្បន្នានំ បាបកានំ អកុ-
សលានំ ធម្មានំ បហានាយ ឆន្ទំ ជនេតិ វាយមតិ
វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ អនុប្ប-
ន្នានំ កុសលានំ ធម្មានំ ឧប្បាទាយ ឆន្ទំ ជនេតិ
វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ

ការដឹងច្បាស់ របស់បុគ្គលអ្នកព្រមព្រៀងដោយមគ្គ ការដឹងច្បាស់របស់បុគ្គលអ្នកព្រមព្រៀងដោយផល (នេះហៅថា ការបរិសុទ្ធិនៃទិដ្ឋិ) ។

(៣៧៣) ពាក្យថា ការបរិសុទ្ធិនៃទិដ្ឋិ បានដល់ប្រាជ្ញា ការដឹងច្បាស់ ។ បេ ។ សេចក្តីមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវ ។ ពាក្យថា សេចក្តីព្យាយាមនៃបុគ្គល ដែលមានទិដ្ឋិសមគួរ បានដល់សេចក្តីប្រារព្ធព្យាយាមប្រកបដោយចិត្ត ។ បេ ។ ការព្យាយាមត្រូវ ។

(៣៧៤) ពាក្យថា សង្វេគ បានដល់ជាតិភ័យ ជរាភ័យ ព្យាធិភ័យ មរណភ័យ ។ ពាក្យថា ទីដែលគួរសង្វេគ បានដល់ ជាតិ ជរា ព្យាធិ មរណៈ ។ ពាក្យថា សេចក្តីព្យាយាម ដោយឧបាយប្រាជ្ញា នៃបុគ្គលដែលមានសង្វេគ សេចក្តីថា ភិក្ខុក្នុងសាសនានេះ ញុំាងសេចក្តីប៉ុនប៉ងឲ្យកើត ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្តទុកតាំងព្យាយាម ដើម្បីញុំាងអកុសលធម៌ដ៏លាមកដែលមិនទាន់កើត មិនឲ្យកើត ញុំាងសេចក្តីប៉ុនប៉ងឲ្យកើត ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្តទុក តាំងព្យាយាម ដើម្បីលះបង់អកុសលធម៌ដ៏លាមកដែលកើតហើយ ញុំាងសេចក្តីប៉ុនប៉ងឲ្យកើត ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្តទុកតាំងព្យាយាម ដើម្បីញុំាងកុសលធម៌ដែលមិនទាន់កើត ឲ្យកើតឡើង

ឧប្បន្នានំ កុសលានំ ធម្មានំ ឋិតិយា អសម្មោសាយ ភិយ្យោភាវាយ វេបុល្លាយ ភាវនាយ បារិបូរិយា ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។

(៣៧៥) អសន្តុដ្ឋិតា ច កុសលេសុ ធម្មេសូតិ យា កុសលានំ ធម្មានំ ភាវនាយ អសន្តុដ្ឋស្ស ភិយ្យោកម្យតា ។ អប្បដិវានិតា ច បធានស្មិន្តិ យា កុសលានំ ធម្មានំ ភាវនាយ សក្កច្ចកិរិយតា សាតច្ចកិរិយតា អដ្ឋិតកិរិយតា អនោលីនវុត្តិតា អនិក្ខិត្តច្ឆន្ទតា អនិក្ខិត្តធុរតា អាសេវនា ភាវនា ពហុលីកម្មំ ។

(៣៧៦) វិជ្ជាតិ តិស្សោ វិជ្ជា បុព្វេនិវាសានុស្សតិញ្ញាណំ វិជ្ជា សត្តានំ ចុតូបបាតេ ញាណំ វិជ្ជា អាសវានំ ខយេ ញាណំ វិជ្ជា ។ វិមុត្តីតិ ទ្វេ វិមុត្តិយោ ចិត្តស្ស ច អធិមុត្តិ និព្វានញ្ច ។

(៣៧៧) ខយេ ញាណន្តិ មគ្គសមង្គិស្ស ញាណំ ។ អនុប្បាទេ ញាណន្តិ ផលសមង្គិស្ស ញាណំ ។

និក្ខេបកណ្ឌំ និដ្ឋិតំ ។

ញ៉ាំងសេចក្ដីប៉ុនប៉ងឲ្យកើត ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្តទុកតាំងព្យាយាម ដើម្បីឋិតនៅ ដើម្បីមិនវិនាស ដើម្បីចម្រើនក្រៃលែង ដើម្បីធំទូលាយ ដើម្បីចម្រើន ដើម្បីបរិបូណ៌ឡើង នៃកុសលធម៌ដែលកើតហើយ ។

(៣៧៥) ពាក្យថា សេចក្ដីមិនសន្ដោសក្នុងកុសលធម៌ បានដល់សេចក្ដីប្រាថ្នាក្រៃលែង នៃបុគ្គលអ្នកមិនត្រេកអរក្នុងការចំរើន នូវកុសលធម៌ ។ ពាក្យថា សេចក្ដីមិនបន្ថយបន្ថយក្នុងព្យាយាម បានដល់ការធ្វើដោយគោរព ការធ្វើរឿយ ៗ ការធ្វើមិនឈប់ ការប្រព្រឹត្តមិនរួញរា ការមិនដាក់ចោលនូវសេចក្ដីប៉ុនប៉ង ការមិនដាក់ចោលនូវធុរៈ ការសេព ការអប់រំ ការធ្វើឲ្យរឿយ ៗ ក្នុងការចំរើន នូវកុសលធម៌ ។

(៣៧៦) ពាក្យថា វិជ្ជា បានដល់វិជ្ជា ៣ គឺ បុព្វេនិវាសានុស្សតិញាណវិជ្ជា ១ សត្តានំចុតូបបាតញាណវិជ្ជា ១ អាសវក្ខយញាណវិជ្ជា ១ ។ ពាក្យថា វិមុត្តិ បានដល់វិមុត្តិ ២ គឺ ការរួចស្រឡះនៃចិត្ត ១ ព្រះនិព្វាន ១ ។

(៣៧៧) ពាក្យថា សេចក្ដីដឹងក្នុងធម៌ជាគ្រឿងអស់ទៅនៃកិលេស បានដល់សេចក្ដីដឹងនៃបុគ្គល ដែលព្រមព្រៀងដោយមគ្គ ។ ពាក្យថា សេចក្ដីដឹងក្នុងធម៌ ដែលធ្វើកិលេសមិនឲ្យកើតឡើងទៀត បានដល់សេចក្ដីដឹងនៃបុគ្គល ដែលព្រមព្រៀងដោយផល ។

ចប់ និក្ខេបកណ្ឌ ។

# អត្ថុទ្ធារកណ្ឌំ

(៣៧៨) កតមេ ធម្មា កុសលា ។ ចតូសុ ភូមីសុ កុសលំ ឥមេ ធម្មា កុសលា ។ កតមេ ធម្មា អកុសលា ។ ទ្វាទស អកុសលចិត្តុប្បាទា ឥមេ ធម្មា អកុសលា ។ កតមេ ធម្មា អព្យាកតា ។ ចតូសុ ភូមីសុ វិបាកោ តីសុ ភូមីសុ កិរិយាព្យាកតំ រូបញ្ច និព្វានញ្ច ឥមេ ធម្មា អព្យាកតា ។

(៣៧៩) កតមេ ធម្មា សុខាយ វេទនាយ សម្បយុត្តា ។ កាមាវចរកុសលតោ ចត្តារោ សោមនស្សសហគតា ចិត្តុប្បាទា អកុសលតោ ចត្តារោ កាមាវចរកុសលស្ស វិបាកតោ ច កិរិយតោ ច បញ្ច រូបាវចរតិកចតុក្កជ្ឈានា កុសលតោ ច វិបាកតោ ច កិរិយតោ ច លោកុត្តរតិកចតុក្កជ្ឈានា កុសលតោ ច វិបាកតោ ច ឯត្ថុប្បន្នំ សុខំ វេទនំ ឋបេត្វា ឥមេ ធម្មា សុខាយ វេទនាយ សម្បយុត្តា ។ កតមេ ធម្មា ទុក្ខាយ វេទនាយ សម្បយុត្តា ។ ទ្វេ ទោមនស្សសហគតា ចិត្តុប្បាទា ទុក្ខសហគតំ កាយវិញ្ញាណំ ឯត្ថុប្បន្នំ ទុក្ខំ វេទនំ ឋបេត្វា

# អត្ថុទ្ធារកណ្ឌ

(៣៧៨) ពួកធម៌ជាកុសល តើដូចម្ដេច ។ កុសលកុសលមូល ៤ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាអកុសល តើដូចម្ដេច ។ អកុសលចិត្តុប្បាទ (ការកើតនៃចិត្តជាអកុសល) ១២ នេះពួកធម៌ជាអកុសល ។ ពួកធម៌ជាអព្យាក្រឹត តើដូចម្ដេច ។ វិបាកកុសលមូល ៤ កិរិយានិងអព្យាក្រឹត កុសលមូល ៣ រូប និងនិព្វាន នេះពួកធម៌ជាអព្យាក្រឹត ។

(៣៧៩) ពួកធម៌ដែលប្រកបដោយសុខវេទនា តើដូចម្ដេច ។ ចិត្តុប្បាទ ប្រកបដោយសោមនស្ស ៤ ខាងកាមាវចរកុសល ចិត្តុប្បាទ ៤ ខាងអកុសល ចិត្តុប្បាទ ៥ ខាងវិបាកផង ខាងកិរិយាផង នៃកាមាវចរកុសល រូបាវចរតិកចតុក្កជ្ឈាន ខាងកុសលផង ខាងវិបាកផង ខាងកិរិយាផង លោកុត្តរតិកចតុក្កជ្ឈាន ខាងកុសលផង ខាងវិបាកផង វៀរតែសុខវេទនា ដែលកើតឡើងក្នុងទីនោះចេញ នេះពួកធម៌ដែលប្រកបដោយសុខវេទនា ។ ពួកធម៌ដែលប្រកបដោយទុក្ខវេទនា តើដូចម្ដេច ។ ចិត្តុប្បាទ ប្រកបដោយទោមនស្ស ២ និងកាយវិញ្ញាណ ប្រកបដោយទុក្ខ វៀរតែទុក្ខវេទនា ដែលកើតឡើងក្នុងទីនុ៎ះចេញ

## តិកេ អត្ថុទ្ធារោ

ឥមេ ធម្មា ទុក្ខាយ វេទនាយ សម្បយុត្តា ។ កតមេ ធម្មា អទុក្ខមសុខាយ វេទនាយ សម្បយុត្តា ។ កាមាវចរកុសលតោ ចត្តារោ ឧបេក្ខាសហគតា ចិត្តុប្បាទា អកុសលតោ ច កាមាវចរកុសលស្ស វិបាកតោ ទស អកុសលស្ស វិបាកតោ ច កិរិយតោ ច រូបាវចរំ ចតុត្ថំ ឈានំ កុសលតោ ច វិបាកតោ ច កិរិយតោ ច ចត្តារោ អារុប្បា កុសលតោ ច វិបាកតោ ច កិរិយតោ ច លោកុត្តរំ ចតុត្ថំ ឈានំ កុសលតោ ច វិបាកតោ ច ឯត្ថុប្បន្នំ អទុក្ខមសុខំ វេទនំ ឋបេត្វា ឥមេ ធម្មា អទុក្ខមសុខាយ វេទនាយ សម្បយុត្តា ។ តិស្សោ ច វេទនា រូបញ្ច និព្វានញ្ច ឥមេ ធម្មា ន វត្តព្វា សុខាយ វេទនាយ សម្បយុត្តាតិបិ ទុក្ខាយ វេទនាយ សម្បយុត្តាតិបិ អទុក្ខមសុខាយ វេទនាយ សម្បយុត្តាតិបិ ។

(៣៨០) កតមេ ធម្មា វិបាកា ។ ចតូសុ ភូមីសុ វិបាកោ ឥមេ ធម្មា វិបាកា ។ កតមេ ធម្មា វិបាកធម្មធម្មា ។ ចតូសុ ភូមីសុ កុសលំ អកុសលំ

នេះពួកធម៌ដែលប្រកបដោយទុក្ខវេទនា ។ ពួកធម៌ប្រកបដោយវេទនាមិនជាទុក្ខមិនជាសុខ តើដូចម្តេច ។ ចិត្តុប្បាទ ប្រកបដោយឧបេក្ខា ៤ ខាងកាមាវចរកុសល ចិត្តុប្បាទ ៦ ខាងអកុសល ចិត្តុប្បាទ ១០ ខាងវិបាកនៃកាមាវចរកុសល ចិត្តុប្បាទ ៦ ខាងវិបាកនៃអកុសល ចិត្តុប្បាទ ៦ ខាងកិរិយា ចតុត្ថជ្ឈាន ជារូបាវចរ ខាងកុសលផង ខាងវិបាកផង ខាងកិរិយាផង អរូបជ្ឈាន ៤ ខាងកុសលផង ខាងវិបាកផង ខាងកិរិយាផង ចតុត្ថជ្ឈាន ជាលោកុត្តរៈ ខាងកុសលផង ខាងវិបាកផង វៀរតែវេទនាមិនជាទុក្ខមិនជាសុខ ដែលកើតឡើងក្នុងទីនុ៎ះចេញ នេះពួកធម៌ដែលប្រកបដោយវេទនា មិនជាទុក្ខមិនជាសុខ ។ វេទនា ៣ ផង រូបផង និព្វានផង នេះពួកធម៌ដែលមិនគប្បីពោលថា ប្រកបដោយសុខវេទនាផង ថាប្រកបដោយទុក្ខវេទនាផង ថាប្រកបដោយវេទនាមិនជាទុក្ខ មិនជាសុខផងទេ ។

(៣៨០) ពួកធម៌ជាវិបាក តើដូចម្តេច ។ វិបាក ក្នុងភូមិ ៤ នេះពួកធម៌ ជាវិបាក ។ ពួកធម៌ មានវិបាកធម៌ជាប្រក្រតី តើដូចម្តេច ។ កុសល និងអកុសល ក្នុងភូមិ ៤

ឥមេ ធម្មា វិបាកធម្មធម្មា ។ កតមេ ធម្មា នេវ វិបាកនវិបាកធម្មធម្មា ។ តីសុ ភូមីសុ កិរិយាព្យាកតំ រូបញ្ច និព្វានញ្ច ឥមេ ធម្មា នេវ វិបាកនវិបាកធម្មធម្មា ។

(៣៨១) កតមេ ធម្មា ឧបាទិន្នុបាទានិយា ។ តីសុ ភូមីសុ វិបាកោ យញ្ច រូបំ កម្មស្ស កតត្តា ឥមេ ធម្មា ឧបាទិន្នុបាទានិយា ។ កតមេ ធម្មា អនុបាទិន្នុបាទានិយា ។ តីសុ ភូមីសុ កុសលំ អកុសលំ តីសុ ភូមីសុ កិរិយាព្យាកតំ យញ្ច រូបំ ន កម្មស្ស កតត្តា ឥមេ ធម្មា អនុបាទិន្នុបាទានិយា ។ កតមេ ធម្មា អនុបាទិន្នុបាទានិយា ។ ចត្តារោ មគ្គា អបរិយាបន្នា ចត្តារិ ច សាមញ្ញផលានិ និព្វានញ្ច ឥមេ ធម្មា អនុបាទិន្នានុបាទានិយា ។

នេះពួកធម៌មានវិបាកធម៌ជាប្រក្រតី ។ ពួកធម៌មិនមែនវិបាក ទាំងមិនមែនជាធម៌មានវិបាកជាប្រក្រតី តើដូចម្តេច ។ កិរិយាទិនអព្យាក្រឹត ក្នុងភូមិ ៣ រូបនិងនិព្វាន នេះពួកធម៌មិនមែនជាវិបាក ទាំងមិនមែនជាធម៌មានវិបាកជាប្រក្រតី ។

[៣៨១] ពួកធម៌មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទាន តើដូចម្តេច ។ វិបាកក្នុងភូមិ ៣ និងរូបដែលជាកម្មសមុដ្ឋាន នេះពួកធម៌ មានកម្មប្រកបដោយកិលេសមានតណ្ហាជាដើមកាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទាន ។ ពួកធម៌មិនមានកម្មប្រកបដោយកិលេសមានតណ្ហាជាដើមកាន់យកហើយ តែជាប្រយោជន៍ដល់ឧបាទាន តើដូចម្តេច ។ កុសលនិងអកុសលក្នុងភូមិ ៣ កិរិយានិងអព្យាក្រឹតក្នុងភូមិ ៣ និងរូបដែលមិនមែនជាកម្មសមុដ្ឋាន នេះពួកធម៌ មិនមានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយ តែជាប្រយោជន៍ដល់ឧបាទាន ។ ពួកធម៌មិនមានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយ ទាំងមិនជាប្រយោជន៍ដល់ឧបាទាន តើដូចម្តេច ។ មគ្គ ៤ ជាអបរិយាបន្នៈផង សាមញ្ញផល ៤ ផង និព្វានផង នេះពួកធម៌ មិនមានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយ ទាំងមិនជាប្រយោជន៍ដល់ឧបាទាន ។

## តិកេ អត្ថុទ្ធារោ

(៣៨២) កតមេ ធម្មា សង្កិលិដ្ឋសង្កិលេសិកា ។ ទ្វាទស អកុសលចិត្តុប្បាទា ឥមេ ធម្មា សង្កិលិដ្ឋសង្កិលេសិកា ។ កតមេ ធម្មា អសង្កិលិដ្ឋសង្កិលេសិកា ។ តីសុ ភូមីសុ កុសលំ តីសុ ភូមីសុ វិបាកោ តីសុ ភូមីសុ កិរិយាព្យាកតំ សព្វញ្ច រូបំ ឥមេ ធម្មា អសង្កិលិដ្ឋសង្កិលេសិកា ។ កតមេ ធម្មា អសង្កិលិដ្ឋាសង្កិលេសិកា ។ ចត្តារោ មគ្គា អបរិយាបន្នា ចត្តារិ ច សាមញ្ញផលានិ និព្វានញ្ច ឥមេ ធម្មា អសង្កិលិដ្ឋាសង្កិលេសិកា ។

(៣៨៣) កតមេ ធម្មា សវិតក្កសវិចារា ។ កាមាវចរកុសលំ អកុសលំ កាមាវចរកុសលស្ស វិបាកតោ ឯកាទស ចិត្តុប្បាទា អកុសលស្ស វិបាកតោ ទ្វេ កិរិយតោ ឯកាទស រូបាវចរំ បឋមំ ឈានំ កុសលតោ ច វិបាកតោ ច កិរិយតោ ច លោកុត្តរំ បឋមំ ឈានំ កុសលតោ ច វិបាកតោ ច ឯត្ថុប្បន្នេ វិតក្កវិចារេ ឋបេត្វា ឥមេ ធម្មា សវិតក្កសវិចារា ។ កតមេ ធម្មា អវិតក្កវិចារមត្តា ។ រូបាវចរបញ្ចកនយេ ទុតិយំ ឈានំ កុសលតោ ច វិបាកតោ

## តិកអត្ថុទ្ធារៈ

(៣៨២) ពួកធម៌ដែលសៅហ្មង ទាំងគួរដល់សេចក្ដីសៅហ្មង តើដូចម្ដេច ។ អកុសលចិត្តុប្បាទ ១២ នេះពួកធម៌ដែលសៅហ្មង ទាំងគួរដល់សេចក្ដីសៅហ្មង ។ ពួកធម៌ដែលមិនសៅហ្មង តែគួរដល់សេចក្ដីសៅហ្មង តើដូចម្ដេច ។ កុសល ក្នុងភូមិ ៣ វិបាក ក្នុងភូមិ ៣ កិរិយានិងអព្យាក្រឹត ក្នុងភូមិ ៣ និងរូបទាំងអស់ នេះពួកធម៌ដែលមិនសៅហ្មង តែគួរដល់សេចក្ដីសៅហ្មង ។ ពួកធម៌ដែលមិនសៅហ្មង ទាំងមិនគួរដល់សេចក្ដីសៅហ្មង តើដូចម្ដេច ។ មគ្គ ៤ ជាអបរិយាបន្នៈផង សាមញ្ញផល ៤ ផង និព្វានផង នេះពួកធម៌ដែលមិនសៅហ្មង ទាំងមិនគួរដល់សេចក្ដីសៅហ្មង ។

(៣៨៣) ពួកធម៌ប្រកបដោយវិតក្កៈ ទាំងប្រកបដោយវិចារៈ តើដូចម្ដេច ។ កាមាវចរកុសលនិងអកុសល ចិត្តុប្បាទ ១១ ខាងវិបាកនៃកាមាវចរកុសល ចិត្តុប្បាទ ២ ខាងវិបាកនៃអកុសល ចិត្តុប្បាទ ១១ ខាងកិរិយា បឋមជ្ឈានជារូបាវចរ ខាងកុសលផង ខាងវិបាកផង ខាងកិរិយាផង បឋមជ្ឈានជាលោកុត្តរៈ ខាងកុសលផង ខាងវិបាកផង វៀរតែវិតក្កៈ វិចារៈ ដែលកើតឡើង ក្នុងទីនុះចេញ នេះពួកធម៌ប្រកបដោយវិតក្កៈ ទាំងប្រកបដោយវិចារៈ ។ ពួកធម៌មិនមានវិតក្កៈ មានត្រឹមតែវិចារៈ តើដូចម្ដេច ។ ទុតិយជ្ឈាន ក្នុងរូបាវចរបញ្ចកន័យ ខាងកុសលផង ខាងវិបាកផង

ច កិរិយតោ ច លោកុត្តរបញ្ចកនយេ ទុតិយំ ឈានំ កុសលតោ ច វិបាកតោ ច ឯត្ថុប្បន្នំ វិចារំ ឋបេត្វា ឥមេ ធម្មា អវិតក្កវិចារមត្តា ។ កតមេ ធម្មា អវិតក្កាវិចារា ។ ទ្វេ បញ្ចវិញ្ញាណានិ រូបាវចរ-តិកតិកជ្ឈានា កុសលតោ ច វិបាកតោ ច កិរិយ-តោ ច ចត្តារោ អារុប្បា កុសលតោ ច វិបាកតោ ច កិរិយតោ ច លោកុត្តរតិកតិកជ្ឈានា កុសលតោ ច វិបាកតោ ច បញ្ចកនយេ ទុតិយេ ឈានេ ឧប្បន្នោ ច វិចារោ រូបញ្ច និព្វានញ្ច ឥមេ ធម្មា អវិតក្កាវិចា-រា ។ វិតក្កសហជាតោ វិបាកោ ន វត្តព្វោ សវិតក្កស-វិចារោតិបិ អវិតក្កវិចារមត្តោតិបិ អវិតក្កាវិចារោតិបិ ។

(៣៨៤) កតមេ ធម្មា បីតិសហគតា ។ កាមាវចរ-កុសលតោ ចត្តារោ សោមនស្សសហគតា ចិត្តុប្បាទា អកុសលតោ ចត្តារោ កាមាវចរកុសលស្ស វិបា-កតោ បញ្ច កិរិយតោ បញ្ច រូបាវចរទុកតិកជ្ឈានា កុសលតោ ច វិបាកតោ ច កិរិយតោ ច លោកុ-ត្តរទុកតិកជ្ឈានា កុសលតោ ច វិបាកតោ ច ឯ-ត្ថុប្បន្នំ បីតឹ ឋបេត្វា ឥមេ ធម្មា បីតិសហគតា ។

ខាងកិរិយាផង ទុតិយជ្ឈាន ក្នុងលោកុត្តរបញ្ចកន័យ ខាងកុសលផង ខាងវិបាកផង វៀរតែវិចារៈដែលកើតឡើងក្នុងទីនុ៎ះចេញ នេះពួកធម៌មិនមានវិតក្កៈមានត្រឹមតែវិចារៈ ។ ពួកធម៌មិនមានវិតក្កៈទាំងមិនមានវិចារៈ តើដូចម្តេច ។ បញ្ចវិញ្ញាណ ២ រូបាវចរតិកតិកជ្ឈាន ខាងកុសលផង ខាងវិបាកផង ខាងកិរិយាផង អរូបជ្ឈាន ៤ ខាងកុសលផង ខាងវិបាកផង ខាងកិរិយាផង លោកុត្តរតិកតិកជ្ឈាន ខាងកុសលផង ខាងវិបាកផង វិចារៈដែលកើតក្នុងទុតិយជ្ឈាន ជាបញ្ចកន័យផង រូបផង និព្វានផង នេះពួកធម៌មិនមានវិតក្កៈ ទាំងមិនមានវិចារៈ ។ វិចារៈដែលកើតជាមួយនឹងវិតក្កៈ មិនគួរពោលថា ប្រកបដោយវិតក្កៈទាំងប្រកបដោយវិចារៈផង ថាមិនមានវិតក្កៈមានត្រឹមតែវិចារៈផង ថាមិនមានវិតក្កៈទាំងមិនមានវិចារៈផងទេ ។

( ៣៨៤ ) ពួកធម៌ប្រកបដោយបីតិ តើដូចម្តេច ។ ចិត្តុប្បាទ ប្រកបដោយសោមនស្ស ៤ ខាងកាមាវចរកុសល ចិត្តុប្បាទ ៤ ខាងអកុសល ចិត្តុប្បាទ ៥ ខាងវិបាកនៃកាមាវចរកុសល ចិត្តុប្បាទ ៥ ខាងកិរិយា រូបាវចរទុកតិកជ្ឈាន ខាងកុសលផង ខាងវិបាកផង ខាងកិរិយាផង លោកុត្តរទុកជ្ឈាន ខាងកុសលផង ខាងវិបាកផង វៀរតែបីតិដែលកើតឡើងក្នុងទីនុ៎ះចេញ នេះពួកធម៌ប្រកបដោយបីតិ ។

## តិកេ អត្ថុទ្ធារោ

កតមេ ធម្មា សុខសហគតា ។ កាមាវចរកុសលតោ ចត្តារោ សោមនស្សសហគតា ចិត្តុប្បាទា អកុសលតោ ចត្តារោ កាមាវចរកុសលស្ស វិបាកតោ ច កិរិយតោ បញ្ច រូបាវចរតិកចតុក្កជ្ឈានា កុសលតោ ច វិបាកតោ ច កិរិយតោ ច លោកុត្តរតិកចតុក្កជ្ឈានា កុសលតោ ច វិបាកតោ ច ឯត្ថុប្បន្នំ សុខំ ឋបេត្វា ឥមេ ធម្មា សុខសហគតា ។ កតមេ ធម្មា ឧបេក្ខាសហគតា ។ កាមាវចរកុសលតោ ចត្តារោ ឧបេក្ខាសហគតា ចិត្តុប្បាទា អកុសលតោ ច កាមាវចរកុសលស្ស វិបាកតោ ទស អកុសលស្ស វិបាកតោ ច កិរិយតោ ច រូបាវចរំ ចតុត្ថំ ឈានំ កុសលតោ ច វិបាកតោ ច កិរិយតោ ច ចត្តារោ អារុប្បា កុសលតោ ច វិបាកតោ ច កិរិយតោ ច លោកុត្តរំ ចតុត្ថំ ឈានំ កុសលតោ ច វិបាកតោ ច ឯត្ថុប្បន្នំ ឧបេក្ខំ ឋបេត្វា ឥមេ ធម្មា ឧបេក្ខាសហគតា ។ បីតិ ន បីតិសហគតា សុខសហគតា ន ឧបេក្ខាសហគតា សុខំ ន សុខសហគតំ សិយា បីតិសហគតំ

ពួកធម៌ប្រកបដោយសុខ: តើដូចម្តេច ។ ចិត្តុប្បាទ ប្រកបដោយសោម-នស្ស ៤ ខាងកាមាវចរកុសល ចិត្តុប្បាទ ៤ ខាងអកុសល ចិត្តុប្បាទ ៦ ខាងវិបាកនៃកាមាវចរកុសល ចិត្តុប្បាទ ៥ ខាងកិរិយា រូបាវចរតិក-ចតុក្កជ្ឈាន ខាងកុសលផង ខាងវិបាកផង ខាងកិរិយាផង លោកុត្តរ-តិកចតុក្កជ្ឈាន ខាងកុសលផង ខាងវិបាកផង វៀរតែសុខ:ដែលកើតឡើងក្នុងទីនុ៎ះចេញ នេះពួកធម៌ប្រកបដោយសុខ: ។ ពួកធម៌ប្រកបដោយឧបេក្ខា តើដូចម្តេច ។ ចិត្តុប្បាទ ប្រកបដោយឧបេក្ខា ៤ ខាងកាមាវចរកុសល ចិត្តុប្បាទ ៦ ខាងអកុសល ចិត្តុប្បាទ ១០ ខាងវិបាកនៃកាមាវចរកុសល ចិត្តុប្បាទ ៦ ខាងវិបាកនៃអកុសល ចិត្តុប្បាទ ៦ ខាងកិរិយា ចតុត្ថជ្ឈាន ជារូបាវចរ ខាងកុសលផង ខាងវិបាកផង ខាងកិរិយាផង អរូបជ្ឈាន ៤ ខាងកុសលផង ខាងវិបាកផង ខាងកិរិយាផង ចតុត្ថជ្ឈាន ជាលោកុត្តរ: ខាងកុសលផង ខាងវិបាកផង វៀរតែឧបេក្ខា ដែលកើតឡើង ក្នុងទីនុ៎ះចេញ នេះពួកធម៌ ប្រកបដោយឧបេក្ខា ។ បីតិ មិនប្រកបដោយបីតិ ប្រកបតែដោយសុខ: មិនប្រកបដោយឧបេក្ខាទេ សុខ: មិនប្រកបដោយសុខ: ប្រកបតែដោយបីតិ

ន ឧបេក្ខាសហគតំ សិយា ន វត្តព្វំ បីតិសហគ-
តន្តិ ។ ទ្វេ ទោមនស្សសហគតា ចិត្តុប្បាទា ទុក្ខស-
ហគតំ កាយវិញ្ញាណំ យា ច វេទនា ឧបេក្ខា រូបញ្ច
និព្វានញ្ច ឥមេ ធម្មា ន វត្តព្វា បីតិសហគតាតិបិ
សុខសហគតាតិបិ ឧបេក្ខាសហគតាតិបិ ។

(៣៨៥) កតមេ ធម្មា ទស្សនេន បហាតព្វា ។
ចត្តារោ ទិដ្ឋិគតសម្បយុត្តា ចិត្តុប្បាទា វិចិកិច្ឆាសហ-
គតោ ចិត្តុប្បាទោ ឥមេ ធម្មា ទស្សនេន បហា-
តព្វា ។ កតមេ ធម្មា ភាវនាយ បហាតព្វា ។ ឧទ្ធ-
ច្ចសហគតោ ចិត្តុប្បាទោ ឥមេ ធម្មា ភាវនាយ ប-
ហាតព្វា ។ ចត្តារោ ទិដ្ឋិគតវិប្បយុត្តលោភសហគតា
ចិត្តុប្បាទា ទ្វេ ទោមនស្សសហគតា ចិត្តុប្បាទា ឥមេ
ធម្មា សិយា ទស្សនេន បហាតព្វា សិយា ភាវនាយ
បហាតព្វា ។ កតមេ ធម្មា នេវ ទស្សនេន ន
ភាវនាយ បហាតព្វា ។ ចតូសុ ភូមីសុ កុសលំ
ចតូសុ ភូមីសុ វិបាកោ តីសុ ភូមីសុ កិរិយាព្យា-
កតំ រូបញ្ច និព្វានញ្ច ឥមេ ធម្មា នេវ ទស្សនេន
ន ភាវនាយ បហាតព្វា ។

មិនប្រកបដោយទុក្ខ ក៏មាន មិនគប្បីពោលថា ប្រកបដោយបីតិ ក៏មាន ។ ចិត្តុប្បាទ ២ ប្រកបដោយទោមនស្ស កាយវិញ្ញាណប្រកបដោយទុក្ខ និងទុក្ខវេទនាផង រូបផង និព្វានផង នេះពួកធម៌មិនត្រូវពោលថា ប្រកបដោយបីតិផង ថាប្រកបដោយសុខៈផង ថាប្រកបដោយទុក្ខផងឡើយ ។

[៣៨៥] ពួកធម៌ត្រូវលះដោយទស្សនៈ (សោតាបត្តិមគ្គ) តើដូចម្តេច ។ ចិត្តុប្បាទ ៤ ប្រកបដោយទិដ្ឋិ និងចិត្តុប្បាទប្រកបដោយវិចិកិច្ឆា នេះពួកធម៌ដែលត្រូវលះដោយទស្សនៈ ។ ពួកធម៌ត្រូវលះដោយភាវនា តើដូចម្តេច ។ ចិត្តុប្បាទប្រកបដោយឧទ្ធច្ចៈ នេះពួកធម៌ត្រូវលះដោយភាវនា ។ ចិត្តុប្បាទ ៤ ប្រាសចាកទិដ្ឋិតែប្រកបដោយលោភៈ និងចិត្តុប្បាទ ២ ប្រកបដោយទោមនស្ស នេះពួកធម៌ត្រូវលះដោយទស្សនៈក៏មាន ត្រូវលះដោយភាវនាក៏មាន ។ ពួកធម៌ដែលមិនត្រូវលះដោយទស្សនៈ ទាំងមិនត្រូវលះដោយភាវនា តើដូចម្តេច ។ កុសលក្នុងភូមិ ៤ វិបាកក្នុងភូមិ ៤ កិរិយានិងអព្យាក្រឹត ក្នុងភូមិ ៣ រូបនិងនិព្វាន នេះពួកធម៌មិនត្រូវលះដោយទស្សនៈ ទាំងមិនត្រូវលះដោយភាវនា ។

## តិកេ អត្ថុទ្ធារោ

[៣៨៦] កតមេ ធម្មា ទស្សនេន បហាតព្វហេតុកា ។ ចត្តារោ ទិដ្ឋិគតសម្បយុត្តា ចិត្តុប្បាទា វិចិកិច្ឆាសហគតោ ចិត្តុប្បាទោ ឯត្ថុប្បន្នំ មោហំ ឋបេត្វា ឥមេ ធម្មា ទស្សនេន បហាតព្វហេតុកា ។ កតមេ ធម្មា ភាវនាយ បហាតព្វហេតុកា ។ ឧទ្ធច្ចសហគតោ ចិត្តុប្បាទោ ឯត្ថុប្បន្នំ មោហំ ឋបេត្វា ឥមេ ធម្មា ភាវនាយ បហាតព្វហេតុកា ។ ចត្តារោ ទិដ្ឋិគតវិប្បយុត្តលោភសហគតា ចិត្តុប្បាទា ទ្វេ ទោមនស្សសហគតា ចិត្តុប្បាទា ឥមេ ធម្មា សិយា ទស្សនេន បហាតព្វហេតុកា សិយា ភាវនាយ បហាតព្វហេតុកា ។ កតមេ ធម្មា នេវ ទស្សនេន ន ភាវនាយ បហាតព្វហេតុកា ។ វិចិកិច្ឆាសហគតោ មោហោ ឧទ្ធច្ចសហគតោ មោហោ ចតូសុ ភូមីសុ កុសលំ ចតូសុ ភូមីសុ វិបាកោ តីសុ ភូមីសុ កិរិយាព្យាកតំ រូបញ្ច និព្វានញ្ច ឥមេ ធម្មា នេវ ទស្សនេន ន ភាវនាយ បហាតព្វហេតុកា ។

តិកអត្ថុទ្ធារៈ

[៣៨៦] ពួកធម៌មានហេតុត្រូវលះដោយទស្សនៈ តើដូចម្តេច ។ ចិត្តុប្បាទ ៤ ប្រកបដោយទិដ្ឋិ និងចិត្តុប្បាទប្រកបដោយវិចិកិច្ឆា វៀរតែមោហៈដែលកើតឡើងក្នុងទី្ទនុះចេញ នេះពួកធម៌មានហេតុត្រូវលះដោយទស្សនៈ ។ ពួកធម៌មានហេតុត្រូវលះដោយភាវនា តើដូចម្តេច ។ ចិត្តុប្បាទប្រកបដោយឧទ្ធច្ចៈ វៀរតែមោហៈ ដែលកើតឡើងក្នុងទី្ទនុះចេញ នេះពួកធម៌ មានហេតុត្រូវលះដោយភាវនា ។ ចិត្តុប្បាទ ៤ ប្រាសចាកទិដ្ឋិតែប្រកបដោយលោភៈ និងចិត្តុប្បាទ ២ ប្រកបដោយទោមនស្ស នេះពួកធម៌ មានហេតុត្រូវលះដោយទស្សនៈក៏មាន មានហេតុត្រូវលះដោយភាវនាក៏មាន ។ ពួកធម៌មានហេតុមិនត្រូវលះដោយទស្សនៈ ទាំងមិនត្រូវលះដោយភាវនា តើដូចម្តេច ។ មោហៈប្រកបដោយវិចិកិច្ឆា មោហៈប្រកបដោយឧទ្ធច្ចៈ កុសលក្នុងភូមិ ៤ វិបាកក្នុងភូមិ ៤ កិរិយានិងអព្យាក្រឹត ក្នុងភូមិ ៣ រូបនិងនិព្វាន នេះពួកធម៌ មានហេតុមិនត្រូវលះដោយទស្សនៈ ទាំងមិនត្រូវលះដោយភាវនា ។

(៣៨៧) កតមេ ធម្មា អាចយគាមិនោ ។ តីសុ ភូមីសុ កុសលំ អកុសលំ ឥមេ ធម្មា អាចយគាមិនោ ។ កតមេ ធម្មា អបចយគាមិនោ ។ ចត្តារោ មគ្គា អបរិយាបន្នា ឥមេ ធម្មា អបចយគាមិនោ ។ កតមេ ធម្មា នេវាចយគាមិនោ នាបចយគាមិនោ ។ ចតូសុ ភូមីសុ វិបាកោ តីសុ ភូមីសុ កិរិយាព្យាកតំ រូបញ្ច និព្វានញ្ច ឥមេ ធម្មា នេវាចយគាមិនោ នាបចយគាមិនោ ។

(៣៨៨) កតមេ ធម្មា សេក្ខា ។ ចត្តារោ មគ្គា អបរិយាបន្នា ហេដ្ឋិមានិ ច តីណិ សាមញ្ញផលានិ ឥមេ ធម្មា សេក្ខា ។ កតមេ ធម្មា អសេក្ខា ។ ឧបរិមំ អរហត្តផលំ ឥមេ ធម្មា អសេក្ខា ។ កតមេ ធម្មា នេវសេក្ខា នាសេក្ខា ។ តីសុ ភូមីសុ កុសលំ អកុសលំ តីសុ ភូមីសុ វិបាកោ តីសុ ភូមីសុ កិរិយាព្យាកតំ រូបញ្ច និព្វានញ្ច ឥមេ ធម្មា នេវសេក្ខា នាសេក្ខា ។

(៣៨៩) កតមេ ធម្មា បរិត្តា ។ កាមាវចរកុសលំ អកុសលំ សព្វោ កាមាវចរស្ស វិបាកោ

(៣៨៧) ពួកធម៌ដល់នូវការសន្សំកពូនឡើង តើដូចម្ដេច ។ កុសលនិងអកុសលក្នុងភូមិ ៣ នេះពួកធម៌ដល់នូវការសន្សំកពូនឡើង ។ ពួកធម៌មិនដល់នូវការសន្សំកពូនឡើង តើដូចម្ដេច ។ មគ្គ ៤ ជាអបរិយាបន្នៈ នេះពួកធម៌មិនដល់នូវការសន្សំកពូនឡើង ។ ពួកធម៌មិនមែនដល់នូវការសន្សំកពូនឡើង ទាំងមិនមែនមិនដល់នូវការសន្សំកពូនឡើង តើដូចម្ដេច ។ វិបាក ក្នុងភូមិ ៤ កិរិយានិងអព្យាក្រឹត ក្នុងភូមិ ៣ រូបនិងនិព្វាន នេះពួកធម៌ មិនមែនដល់នូវការសន្សំកពូនឡើង ទាំងមិនមែនមិនដល់នូវការសន្សំកពូនឡើង ។

